ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- ការយល់ដឹងអំពីរបបប្រល័យពូជសាសន៍
- តើកម្ពុជាបានផ្សះផ្សាហើយឬនៅ?

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ៧៧ ខែឧសភា ឆ្នាំ២០០៦

ស្វែងរកការពិត
លេខ៧៧ ខែឧសភា ឆ្នាំ២០០៦

# ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆ សំបុត្រ ៖ ការយល់ដឹងអំពីរបបប្រល័យពូជសាសន៍ ...... ១

**ផ្នែកឯកសារ**

◆ ចម្លើយសារភាពរបស់ អ៊ាង សីហា ...... ៤
◆ បញ្ជីឈ្មោះជនរងគ្រោះដែលកម្មេចនៅមន្ទីរ ស-២១ ...... ៩
◆ ផែនការណែនាំស្តីពីការចាត់តាំងទិវាចងកំហឹង ...... ១១

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ រឿងរ៉ាវដែលមិនចេះសាបសូន្យ ...... ១៥
◆ ដំណើរទស្សនកិច្ចលើកទី៤ ទៅកាន់អង្គជំនុំជម្រះវិសាមញ្ញ ...... ២៣
◆ បំណាងខក្រិដ្ឋកម្មមន្ទីរសន្តិសុខភូមិភាគនិរតី ...... ២៥
◆ អ្នកបកប្រែភាសាខ្មែរនៅវិទ្យុជាតិឡាវ ...... ៤០

**ផ្នែកច្បាប់**

◆ ព្រះរាជក្រឹត្យតែងតាំងចៅក្រមសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ ...... ៤៦

**វេទិកាពិភាក្សាសាធារណៈ**

◆ ខ្សែភាពយន្តរឿង"ល្បែងខ្មោច" ...... ៤៨
◆ តើកម្ពុជាបានផ្សះផ្សាហើយឬនៅ? ...... ៤៨
◆ លិខិតពីមិត្តអ្នកអាន ...... ៥០
◆ យុត្តិធម៌សម្រាប់វាលពិឃាត ...... ៥២

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ស្ត្រីមេម៉ាយនៅក្រោមរបបតាលីបង់ ...... ៥៣
◆ ស្វែងរកប្តីនិងកូនប្រុសដែលបាត់ខ្លួន ...... ៥៤
◆ ចង់ដឹងចង់ឃើញការកាត់ទោសខ្មែរក្រហម ...... ៥៧





**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ ៖** ប៊ុនង ពីរីន, ស៊ិរិ សារីណា, ភូ គឹមមឿ, ញាណ សុជាតិ, ទន់ អ៊ុត, សូ ហ្វារីណា, ព្រំ សាម៉ុន, អៀ ម៉េងទ្រី, ដេហ្វ ស្ត្រាកា **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** លី សុផល, ណយ សុផារី, ឌី ខាំបូលី **អ្នកបកប្រែ ៖** បាន់ ចំរើន, ប៉ាន់ ស៊ីម៉ាឡា **និពន្ធនាយករង ៖** សាន់ កល្យាណ **និពន្ធនាយកទូទៅ ៖** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រ ៖** គឹម សុវណ្ណដានី **គ្រប់គ្រងការចែកផ្សាយ ៖** រ័ត្ន គារាពិដោរ Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ :*

# ការយល់ដឹងអំពីរបបប្រល័យពូជសាសន៍

ប្រសិនបើអ្នករួចជីវិតពីការប្រល័យពូជសាសន៍ អ្នកប្រៀបដូចជាត្រូវបានព្រះតាមការពារ ។ អ្នកអាចចាប់ផ្តើមកសាងជីវិតជាថ្មីម្តងទៀត ។ អ្នកអាចស្វែងរកទីកន្លែងរស់នៅ មានការងារធ្វើ បង្កើតភាពស្និទ្ធិស្នាលជាមួយអ្នកដទៃ និងចាប់ផ្តើមរៀបចំគ្រួសារសាជាថ្មី ។ ការរួចជីវិតផ្នែករូបរាងកាយពុំសូវជួបការលំបាកទេ ក៏ប៉ុន្តែ អ្នកក៏ជួបនូវសំណាងអាក្រក់ជាច្រើនដែរ ព្រោះក្នុងចិត្តរបស់អ្នកខ្ទេចខ្ទាំនិងឈឺចាប់ដោយសារតែការបាត់បង់មនុស្សដែលអ្នកស្រលាញ់ ។ ការចងចាំរបស់អ្នកតាមលងបន្ទាចអ្នកជានិច្ច ។ អ្នកមានអារម្មណ៍មិនសប្បាយនឹងការរស់រានមានជីវិតខណៈដែលមនុស្សជាច្រើនបានបាត់បង់ជីវិត ។ អ្វីដែលអាក្រក់បំផុតគឺអ្នកបាត់បង់ក្តីសង្ឃឹមក្នុងជីវិត ។

ខ្ញុំក៏ជាមនុស្សម្នាក់ដែលរួចជីវិតពីរបបប្រល័យពូជសាសន៍នៅកម្ពុជា ។ សព្វថ្ងៃ ខ្ញុំចង់និយាយប្រាប់អ្នកឲ្យដឹងថាតើការវិលត្រឡប់មកប្រទេសកម្ពុជាវិញបានជួយអ្វីខ្លះដល់រូបខ្ញុំក្នុងការស្វែងយល់អំពីអ្វីដែលបានកើតឡើងនៅកម្ពុជាជិតបីទសវត្សរ៍កន្លងមក ហើយការវិលត្រឡប់នេះផ្តល់ក្តីសង្ឃឹមអ្វីខ្លះដល់ខ្ញុំក្នុងការបន្តជីវិតរស់នៅតទៅទៀត ។

មានមនុស្សជាច្រើនសួរខ្ញុំថា ហេតុអ្វីបានជាខ្ញុំវិលត្រឡប់មកប្រទេសកម្ពុជាវិញ? ក្រោយពីបានរស់នៅក្នុងជំរំជនភៀសខ្លួនអស់រយៈពេលជាច្រើនឆ្នាំ ខ្ញុំពិតជាមានសំណាងណាស់ដែលមានឱកាសបានទៅរស់នៅសហរដ្ឋអាមេរិក ។ នៅសហរដ្ឋអាមេរិក ខ្ញុំបានបញ្ចប់ការសិក្សានៅមហាវិទ្យាល័យ និងមានជីវភាពរស់នៅសមរម្យនិងប្រកបដោយផ្លែផ្កា ។ តើហេតុអ្វីបានជាខ្ញុំចង់វិលត្រឡប់មកប្រទេសក្រីក្រមួយក្នុងចំណោមប្រទេសក្រីក្របំផុតនៅពិភពលោកដូច្នេះទៅវិញ? តើហេតុអ្វីបានជាខ្ញុំចាកចេញពីរដ្ឋដែលមានសុវត្ថិភាព គឺរដ្ឋតិចសាស មកកាន់ប្រទេសមួយដែលពោរពេញទៅដោយភាពគ្រោះថ្នាក់និងអស្ថិរភាពបែបនេះទៅវិញ? ហើយតើហេតុអ្វីបានជាខ្ញុំចង់មករស់នៅទីក្រុងភ្នំពេញខណៈដែលសមាជិកក្រុមគ្រួសាររបស់ខ្ញុំជាច្រើននាក់ត្រូវសម្លាប់និងចាកចេញពីប្រទេសកម្ពុជាដូច្នេះ?

ក្នុងឆ្នាំ១៩៩៣ រយៈពេល១៥ឆ្នាំបន្ទាប់ពីខ្ញុំបានរត់ភៀសខ្លួនកាត់ព្រៃទៅប្រទេសថៃ ខ្ញុំបានវិលត្រឡប់មកប្រទេសកម្ពុជាវិញដើម្បីស្វែងរកចម្លើយនៃសំណួរជាច្រើនដែលចេះតែតាមសួរខ្ញុំ ។ ខ្ញុំចង់ដឹងថាតើហេតុអ្វីប្រជាជនកម្ពុជា២៥ភាគរយស្លាប់នៅក្រោមស្នាដៃប្រជាជនកម្ពុជាខ្លួនឯងដូច្នេះ ។ ចាប់តាំងពីពេលនោះនិងអស់រយៈពេលជាច្រើនឆ្នាំមកហើយ ខ្ញុំក៏ដូចជាប្រជាជនកម្ពុជាដទៃទៀតដែរ មានចម្ងល់ថាតើមេដឹកនាំខ្មែរក្រហមនឹងត្រូវប្រឈមមុខនឹងការកាត់ទោសដែរឬទេ ដោយហេតុថាមេដឹកនាំខ្មែរក្រហមទាំងនេះកំពុងរស់នៅក្នុងជីវិតយ៉ាងសប្បាយ ម្យ៉ាងទៀត រាជរដ្ឋាភិបាលបានផ្តល់ការលើកលែងទោសដល់មេដឹកនាំទាំងនេះថែមទៀត ។ ខ្ញុំក៏យល់ឃើញថា ប្រជាជនកម្ពុជាភាគច្រើននៅតែរងគ្រោះយ៉ាងធ្ងន់ធ្ងរដោយសារអ្វីដែលគាត់បានជួបប្រទះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ អ្វីដែលបង្កជាបញ្ហាធ្ងន់ធ្ងរបំផុតនោះគឺអ្នកស្រុកអ្នកភូមិកំពុងរស់នៅក្នុងសហគមន៍តែមួយជាមួយនឹងកម្មាភិបាលខ្មែរក្រហមដែលធ្លាប់ធ្វើបាបគាត់ ។ តើយើងអាចយល់អំពីអ្វីដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានដែរឬទេ?

ការស្វែងរកចម្លើយនៃសំណួរខាងលើនេះទំនងជាហេតុផលមួយដែលជំរុញឲ្យខ្ញុំសម្រេចចិត្តវិលត្រឡប់មកប្រទេសកម្ពុជាវិញក៏មិនដឹង ។ តាមពិត ខ្ញុំគ្មានបំណងនឹងវិលត្រឡប់មកកម្ពុជាវិញទេ ។ ខ្ញុំធ្វើបែបនេះដោយសារតែខ្ញុំចង់សងសឹកចំពោះអ្នកដែលសម្លាប់សមាជិកគ្រួសាររបស់ខ្ញុំ ។

ក្រោយពីរស់នៅកម្ពុជាអស់រយៈពេលពីរបីឆ្នាំ ខ្ញុំបានទៅជួបប្រធានភូមិម្នាក់ដែលបានរួមចំណែកធ្វើឲ្យបងស្រីរបស់ខ្ញុំស្លាប់ ។ គាត់ចំណាំខ្ញុំមិនបានទេ ដោយហេតុថាកាលណោះខ្ញុំគ្រាន់តែជាក្មេងប្រុសតូចម្នាក់តែប៉ុណ្ណោះ ។ ក៏ប៉ុន្តែខ្ញុំចំណាំគាត់យ៉ាងច្បាស់ ។ បើទោះបីជាគាត់មានវ័យចំណាស់ជាងមុនក៏ដោយ ក៏ខ្ញុំកត់សម្គាល់ឃើញថាជីវិតរបស់គាត់នៅតែដូចមុន ។ គាត់រស់នៅក្នុងផ្ទះខ្ពស់

មួយនៅក្នុងភូមិដដែល និងមានគោស្គមៗពីរក្បាល ។ ស្ថានភាពរបស់គាត់ឥឡូវនេះ គ្មានអ្វីប្រសើរជាងកាលពីពេលដែលខ្មែរក្រហមធ្វើបដិវត្តន៍ដើម្បី "រំដោះ" កសិករឡើយ ។

បន្ទាប់ពីបានជួបគាត់ប៉ុន្មានលើក ខ្ញុំភ្ញាក់ផ្អើលដោយសារខ្ញុំឃើញថាគាត់មិនមែនជាមនុស្សអាក្រក់ទេ ។ តាមពិត គាត់ប្រព្រឹត្តអំពើអាក្រក់ពីព្រោះគាត់គិតថាការធ្វើបដិវត្តន៍នឹងផ្តល់ឲ្យគាត់នូវជីវិតនិងសង្គមមួយដែលល្អប្រសើរជាងមុន ក៏ប៉ុន្តែ បដិវត្តន៍មិនផ្តល់គាត់ដូចដែលបដិវត្តន៍បានសន្យានោះទេ ។ ការដែលដឹងថាជនដៃដល់នៃរបបប្រល័យពូជសាសន៍ក៏ជាជនរងគ្រោះដែរនោះ បានធ្វើខ្ញុំយល់កាន់តែច្បាស់អំពីរបបប្រល័យពូជសាសន៍ ។

យើងចាំបាច់ត្រូវតែស្វែងយល់ពីវប្បធម៌របស់ប្រជាជនកម្ពុជា ដើម្បីឲ្យដឹងពីមូលហេតុដែលអាចធ្វើឲ្យមនុស្សប្រព្រឹត្តអំពើឃោរឃៅដូចនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ប្រជាជនកម្ពុជាមិនធ្វើអ្វីមួយដើម្បីបុព្វហេតុផ្ទាល់ខ្លួនទេ ព្រោះការធ្វើដូច្នេះគឺជាកាយវិការក្រអឺតក្រទម ។ ប្រជាជនកម្ពុជាភាគច្រើនធ្វើអ្វីៗគឺដើម្បីបុព្វហេតុ ជាតិ សាសនា និងព្រះមហាក្សត្រ ។ ជាលទ្ធផលគឺថា បុគ្គលម្នាក់ៗមិនយល់ពីសារសំខាន់និងតម្លៃនៃជីវិតរបស់ខ្លួនឡើយ ឬសូម្បីតែផលប៉ះពាល់នៃអំពើរបស់ខ្លួនទៅលើអ្នកដទៃឬខ្លួនឯងក៏ដោយ ។ ប្រជាជនកម្ពុជាបែរជាគិតថា ប្រសិនបើរដ្ឋអំណាចរំលោភសិទ្ធិប្រជាជន ប្រជាជនអាចទទួលយកបាន ព្រោះសកម្មភាពនេះគឺដើម្បីផលប្រយោជន៍ជាតិ ។ ហេតុដូចនេះហើយ ទើបខ្ញុំយល់ថាការសងសឹកនឹងបុគ្គលម្នាក់មិនមែនជាចម្លើយដែលយើងចង់បាននោះទេ ពីព្រោះការសងសឹកនឹងមិននាំត្រឡប់មកវិញនូវអ្វីដែលខ្ញុំឬអ្នកណាម្នាក់ផ្សេងទៀតបានបាត់បង់នោះឡើយ ។

កិច្ចការងាររបស់ខ្ញុំបានបង្ហាញឲ្យខ្ញុំយល់ដឹងកាន់តែច្បាស់ពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា និងជាបុព្វហេតុដែលនាំឲ្យខ្ញុំមានក្តីសង្ឃឹមម្តងទៀត ប៉ុន្តែមិនមែនដើម្បីខ្លួនខ្ញុំផ្ទាល់ទេ គឺដើម្បីមនុស្សជាតិ សង្គម និងប្រទេសជាតិរបស់ខ្ញុំ ។ ក្រោយមកខ្ញុំចាប់ផ្តើមយល់ដឹងពីភាពជាម្ចាស់ការនិងភាពចាំបាច់ប្រឈមមុខនឹងរឿងរ៉ាវអតីតកាលដែលជាកាតព្វកិច្ចរបស់ជនរងគ្រោះនៃរបបប្រល័យពូជសាសន៍ ។

ក្នុងឆ្នាំ១៩៩៥ បន្ទាប់ពីខ្ញុំបានបំពេញការងារអស់រយៈពេលពីរឆ្នាំនៅក្នុងដំណើរការបោះឆ្នោតបែបប្រជាធិបតេយ្យលើកដំបូងសម្រាប់កម្ពុជា ក្នុងតួនាទីជាអ្នកអប់រំពលរដ្ឋកម្ពុជា ខ្ញុំត្រូវបានស្នើឲ្យចូលក្នុងគម្រោងកម្មវិធីស្តីពីអំពើប្រល័យពូជសាសន៍នៅកម្ពុជានៃសកលវិទ្យាល័យយែល ដែលក្រោយមកគម្រោងនេះបានបង្កើតជាមជ្ឈមណ្ឌលឯកសារកម្ពុជា ។ មជ្ឈមណ្ឌលនេះជាអង្គការក្រៅរដ្ឋាភិបាលមួយដែលឯករាជ្យនិងមានគោលបំណងសំខាន់ពីរ ។ គោលបំណងសំខាន់ទីមួយគឺកត់ត្រា និងថែរក្សាប្រវត្តិសាស្ត្រខ្មែរក្រហមទុកសម្រាប់មនុស្សជំនាន់ក្រោយយល់ដឹងអំពីអ្វីដែលបានកើតឡើងនៅក្នុងរបបនេះ ។ គោលបំណងសំខាន់ទីពីរគឺចងក្រងនិងរៀបចំឯកសារដែលអាចប្រើប្រាស់ជាភស្តុតាងដ៏មានសារសំខាន់ក្នុងផ្នែកច្បាប់ដែលទាក់ទងនឹងឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម ។ គោលបំណងទាំងពីរនេះបង្ហាញពីការជំរុញឲ្យមានការចងចាំនិងយុត្តិធម៌របស់យើង ព្រោះគោលបំណងនេះជាមូលដ្ឋានគ្រឹះយ៉ាងសំខាន់សម្រាប់ការបង្កើតនីតិរដ្ឋនិងការផ្សះផ្សាជាតិយ៉ាងពិតប្រាកដនៅក្នុងប្រទេសកម្ពុជា ។

ការប្រមូលយកសក្ខីកម្មរបស់អ្នកដែលរួចជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យគឺជាកិច្ចការមួយក្នុងចំណោមកិច្ចការសំខាន់ៗបំផុតនៃការសិក្សាស្រាវជ្រាវរបស់ខ្ញុំ ។ កិច្ចការនេះបម្រើឲ្យគោលបំណងសំខាន់បីគឺ ទីមួយ ជំរុញឲ្យមានការយល់យោគនិងធូរស្បើយនៅក្នុងចិត្តបុគ្គលគ្រប់រូប ទីពីរ រួមចំណែកស្វែងរកយុត្តិធម៌សម្រាប់ប្រជាជនកម្ពុជា និងទីបី ថែរក្សាប្រវត្តិសាស្ត្រកម្ពុជា ។

ពេលវេលាអាចធ្វើឲ្យការចងចាំរបស់បុគ្គលម្នាក់ផ្លាស់ប្តូរ ។ ខ្ញុំមិនចាំរឿងរ៉ាវគ្រប់យ៉ាងដែលបានកើតឡើងកាលពី៣០ឆ្នាំមុនទេ ។ រឿងរ៉ាវមួយចំនួនប្រៀបដូចជានៅក្នុងស្រមោល ។ ប្រជាជនកម្ពុជាភាគច្រើនមិនចង់ចងចាំរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ ។ ដូច្នេះទន្ទឹមនឹងពេលដែលការចងចាំអាចផ្តល់អត្ថប្រយោជន៍ វាក៏អាចបង្កជាគ្រោះថ្នាក់ដែរ ។ នៅពេលដែលប្រជាជនអាចរំឭកការចងចាំរបស់ខ្លួនឡើងវិញបានច្បាស់ គាត់អាចយកវាធ្វើជាមូលដ្ឋានសម្រាប់ការពិចារណា ។

ការជួយឲ្យប្រជាជនចងចាំបានច្បាស់ជាងមុនអាចជួយឲ្យគាត់ដោះស្រាយបញ្ហាទុក្ខព្រួយនិងការប៉ះទង្គិចផ្លូវចិត្តបាន ព្រម

ទាំងជួយឲ្យប្រជាជនទាំងអស់ទទួលស្គាល់ថាអ្វីដែលគាត់បានជួបប្រទះ អ្នកដទៃទៀតក៏ជួបប្រទះដូចគ្នាដែរ ។ តាមរយៈនេះ ប្រជាជនប្រហែលជាអាចចាប់ផ្តើមយល់ថា អ្វីដែលគាត់ជួបប្រទះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺជាអ្វីដែលកំណត់ថាគាត់ជាបុគ្គលដែលជាមែកធាងផ្សេងៗរបស់សង្គម ។

ខ្ញុំបានជួបសម្ភាសជាមួយអ្នករស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ ទាំងជនរងគ្រោះនិងជនដៃដល់ដែលសុទ្ធតែធ្លាប់បានឆ្លងកាត់ព្រឹត្តិការណ៍ដ៏សែនរន្ធត់នោះ ។ ខ្ញុំគិតថាគ្មាននរណាម្នាក់អាចយល់បានពេញលេញនូវអារម្មណ៍ដែលរស់នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យទេ ។ យើងមិនអាចរៀបរាប់អំពើប្រល័យពូជសាសន៍តាមរយៈពាក្យសម្តីបានឡើយ ហេតុនេះហើយបានជាជនរងគ្រោះភាគច្រើនមានអារម្មណ៍ខឹងសម្បារនៅពេលដែលគាត់ព្យាយាមរៀបរាប់អំពីសោកនាដកម្មនោះ ។ អ្នកស្រាវជ្រាវជាន់ខ្ពស់បរទេសមួយចំនួនមើលឃើញសក្ខីកម្មរបស់ជនរងគ្រោះថាជាការបំផ្លើស នៅពេលដែលជនរងគ្រោះរៀបរាប់អំពីរបៀបដែលខ្មែរក្រហមបំបែកមនុស្សជាបំណែកៗ ដុតកុមារតូចៗ នៅចំពោះមុខមនុស្សរាប់ពាន់រាប់លាននាក់ ។ ខ្ញុំគិតថាពេលខ្លះ សក្ខីកម្មទាំងនេះស្ទើរតែក្លាយទៅជារឿងមិនពិតទាំងស្រុង ហើយការណ៍នេះមិនត្រឹមតែមិនអាចជួយឲ្យមានការចងចាំច្បាស់ឡើងវិញទេ ថែមទាំងធ្វើឲ្យមានការសង្ស័យលើសមាសភាពរបស់អ្នកផ្តល់សក្ខីកម្មនោះទៀតផង ។

ប្រសិនបើខ្ញុំមានការចងចាំតិចតួច ខ្ញុំមិនអាចប្រាប់អំពីបទពិសោធន៍នោះទៅកូនចៅឬក្មេងជំនាន់ក្រោយបានឡើយ ហើយប្រសិនបើខ្ញុំមិនបន្តប្រាប់រឿងរ៉ាវនេះទេ តើអ្នកទាំងនោះធ្វើម្តេចនឹងជឿថាមានហេតុការណ៍បែបនេះកើតឡើងពិតមែន? ជាញឹកញាប់ ខ្ញុំគិតថាតើហេតុអ្វីបានជាយើងការសិក្សាអំពីបទពិសោធន៍របស់អ្នកដទៃបានតិចតួចដូច្នេះ ។ ជាឧទាហរណ៍ ប្រជាជនកម្ពុជាភាគច្រើនដឹងរឿងរ៉ាវតិចតួចខ្លាំងណាស់ ឬក៏មិនបានដឹងទាល់តែសោះពីអំពើប្រល័យពូជសាសន៍ ។ ក្មេងជំនាន់ក្រោយជាច្រើននាក់មិនបានជឿថាមានការប្រល័យពូជសាសន៍បានកើតឡើងនៅក្នុងប្រទេសរបស់ខ្លួនឡើយ ។

ដូច្នេះវាមានសារសំខាន់ក្នុងការថែរក្សារឿងរ៉ាវរបស់អ្នករួចរស់ជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យសម្រាប់ឲ្យអ្នកជំនាន់ក្រោយបានដឹង ។ និយាយឲ្យងាយស្តាប់ ការដឹងថាប្រទេសរបស់ខ្លួនគឺជាប្រទេសតែមួយគត់ដែលបានប្រព្រឹត្តអំពើឃោរឃៅសាហាវព្រៃផ្សៃ អាចស្តែងចេញតាមរបៀបចំអកទៅវិញ ។ ដោយសារតែមូលហេតុនេះហើយទើបយើងស្នើសុំឲ្យមានការស្រាវជ្រាវដើម្បីផ្លាស់ប្តូរបទពិសោធន៍គ្នា ។ ការស្រាវជ្រាវបទពិសោធន៍នេះត្រូវចាប់ផ្តើមផ្សារភ្ជាប់គ្នាជាមួយនឹងការពិតអំពីថាតើហេតុអ្វីបានជារបបប្រល័យពូជសាសន៍កើតឡើង និងសិក្សាអំពីរបបប្រល័យពូជសាសន៍ ។ ដូចនេះរបបប្រល័យពូជសាសន៍នឹងមិនអាចកើតឡើងជាថ្មីម្តងទៀតឡើយ ។

មានការលំបាកក្នុងការគិតទុកជាមុនថាតើយើងអាចសម្រេចបាននូវយុត្តិធម៌ដែរឬយ៉ាងណានោះ ។ អស់រយៈពេល២៨ឆ្នាំហើយបន្ទាប់ពីការដួលរំលំនៃរបបកម្ពុជាប្រជាធិបតេយ្យ អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាគ្រោងកំណត់ពេលវេលាសម្រាប់អង្គជំនុំជម្រះកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ឥឡូវនេះ ភាគច្រើននៃមេដឹកនាំខ្មែរក្រហមទាំងនោះកំពុងតែស្ថិតនៅក្នុងវ័យ៧០ឆ្នាំ និងមានសុខភាពកាន់តែទន់ខ្សោយថែមទៀត ។ សកម្មភាពរៀបចំសវនាការនេះ នឹងជួយឲ្យប្រជាជនកម្ពុជាមានទស្សនវិស័យផ្សេងៗគ្នាលើអ្វីដែលបានកើតឡើងនិងធ្វើឲ្យពិភពលោកបានដឹងអំពីការឈឺចាប់របស់ប្រជាជនកម្ពុជា ។ សំខាន់ជាងនេះទៅទៀត ប្រសិនបើសវនាការជំនុំជម្រះក្តីប្រព្រឹត្តទៅដោយយុត្តិធម៌និងមានតម្លាភាព ប្រជាជនកម្ពុជាអាចចាប់ផ្តើមមានក្តីសង្ឃឹមបន្តិចខ្លះមកវិញលើប្រព័ន្ធយុត្តិធម៌របស់ប្រទេសខ្លួននិងក្តីសង្ឃឹមសម្រាប់ថ្ងៃអនាគត ។

សព្វថ្ងៃ ខ្ញុំរីករាយក្នុងចិត្តជាខ្លាំងដែលបានដឹងថាយុត្តិធម៌និងការផ្សះផ្សាបានក្លាយជាប្រធានបទសំខាន់សម្រាប់មនុស្សជាច្រើន ។ ដោយសារតែយើងធ្វើដំណើរកាន់តែជិតដល់ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាទៅហើយនោះ កម្ពុជា គួរតែផ្តល់មេរៀនមានតម្លៃខ្លះដល់ប្រជាជាតិដទៃទៀតក៏ដូចជាសម្រាប់សហគមន៍អន្តរជាតិទាំងមូល ។ ដូចដែលយើងឃើញនៅក្នុងប្រវត្តិសាស្ត្រ អំពើប្រល័យពូជសាសន៍ដូចជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាដើម អាចកើតឡើងនៅគ្រប់

ទឹកន្លែងទាំងអស់ ។ បើយើងក្រឡេកមើលទៅប្រទេសរ៉្វាន់ដា ទីម័រខាងកើត បូស្នៀ ស៊ូដង់ និងប្រទេសផ្សេងៗទៀត យើងនឹងឃើញថាអំពើឃោរឃៅនេះនៅតែកើតឡើងជានិច្ច ។ ប្រសិនបើគ្មានកិច្ចខិតខំប្រឹងប្រែងនិងការគាំទ្រពីសហគមន៍អន្តរជាតិទេនោះ យើងក៏មិនអាចទប់ស្កាត់អំពើប្រល័យពូជសាសន៍បានដែរ ។ ប្រសិនបើគ្មានទស្សនវិស័យសកលទេ ការយល់ឃើញរបស់យើងអាចនៅចង្អៀតចង្អល់ ដែលអាចធ្វើឲ្យយើងមានទស្សនៈជ្រុលនិយម ហើយភាពជ្រុលនិយមនេះអាចនាំទៅដល់ការប្រព្រឹត្តអំពើហិង្សាម្តងទៀត ។

អ្នកដែលធ្លាប់ឆ្លងកាត់អំពើប្រល័យពូជសាសន៍ដឹងថាគ្មានអ្នកណាម្នាក់ឬអ្វីមួយអាចប៉ះប៉ូវសងចំពោះអ្វីដែលបានកើតឡើងបានឡើយ ហើយយើងដឹងថា អំពើប្រល័យពូជសាសន៍បានបំផ្លាញប្រទេសមួយតាមមធ្យោបាយជាច្រើន ។ ដូចដែលអ្នកបានដឹងវិធីឆ្ពោះទៅរកការធូរស្បើយគឺជាផ្លូវមួយដ៏វែងឆ្ងាយសម្រាប់កម្ពុជា ។ ២៥ឆ្នាំបន្ទាប់ពីអំពើសោកនាដកម្ម កម្ពុជានៅតែជាប្រទេសក្រីក្រមួយក្នុងចំណោមប្រទេសក្រីក្របំផុតនៅក្នុងពិភពលោក ហើយសុខុមាលភាពប្រជាជនរបស់ប្រទេសនេះកំពុងតែដើរថយក្រោយទៀតផង ។ យើងចាំបាច់ត្រូវស្វែងយល់ពីប្រវត្តិសាស្ត្ររបស់យើងជាមុនសិនទើបយើងអាចបន្តដំណើរឆ្ពោះទៅមុខទៀត ហើយការចងក្រងឯកសារនិងការយល់ដឹងអំពីបទពិសោធន៍ដូចៗគ្នានេះគឺជាជំហានតូចមួយឆ្ពោះទៅរកទិសដៅនេះ ។

**ឆាំង យុ**

# អ៊ាង សីហា វិស្វករសំណង់ស្ពានថ្នល់

អ៊ាង សីហា គឺជាវិស្វករស្ពានថ្នល់មកពីប្រទេសសូវៀត ។ សីហា បានត្រឡប់មកប្រទេសកម្ពុជាវិញនៅខែសីហា ឆ្នាំ១៩៦៨ ។ មុនឆ្នាំ១៩៧៥ សីហា ធ្វើការនៅស្ថានីយ៍រថភ្លើងកម្ពុជាផងនិងនៅអាកាសចរណ៍កម្ពុជាផង ។ បន្ទាប់ពីឆ្នាំ១៩៧៥មក សីហា ធ្វើជាអ្នកបច្ចេកទេសនៅអគ្គភាពរថភ្លើងភ្នំពេញ ហើយត្រូវអង្គការចាប់ខ្លួននិងបញ្ជូនចូលគុកទួលស្លែងនៅចុងឆ្នាំ១៩៧៦ ។

អ៊ាង សីហា មានស្រុកកំណើតនៅនៅភូមិក្រាំង ស្រុកព្រៃកប្បាស ខេត្តតាកែវ ។ សីហា រៀននៅវិទ្យាល័យខទ័យខេត្តតាកែវ ។ នៅឆ្នាំ១៩៥៥ ក្រោយពីប្រលងធ្លាក់ថ្នាក់ទី៦ សីហា ត្រូវម្តាយមីងយកមកភ្នំពេញនិងជួយទំនុកបម្រុងឲ្យរៀនថ្នាក់ទី៦ នៅវិទ្យាល័យឯកជនមួយឈ្មោះកម្ពុជបុត្រ ។ គ្រូបង្រៀនរបស់សីហា មាន ៖ មុី ម៉ាន បង្រៀនមុខវិជ្ជាគណិតវិទ្យា, ហ៊ូ យន់ បង្រៀនមុខវិជ្ជាសីលធម៌ និង អៀង សារី បង្រៀនមុខវិជ្ជាភូមិសាស្ត្រនិងពង្សាវតា ។ល ។ អៀង សារី បានហៅ អ៊ាង សីហា, ឡោ ជីនហុង និង វ៉ោយ ហូ ទៅលេងផ្ទះរបស់គាត់ ដែលស្ថិតនៅខាងលិចវត្តប្រយូរវង្ស ។ អៀង សារី បាននិយាយប្រាប់សិស្សអំពីការមើលងាយមើលថោកពីសំណាក់ប៉ូលិសនិងគិញ និងការជិះជាន់របស់អ្នកមានអំណាចមកលើប្រជាជនស្លូតត្រង់ ។ សីហា និងមិត្តភក្តិឧស្សាហ៍ទៅលេងផ្ទះ អៀង សារី ណាស់ ប៉ុន្តែក្រោយមកក៏លែងហ៊ានទៅលេងទៀត ដោយ វ៉ោយ ហូ ប្រាប់ថាមានគិញកំពុងតាមដាន ។

សីហា ប្រលងជាប់ឡើងថ្នាក់ជាបន្តបន្ទាប់ ។ នៅឆ្នាំ១៩៥៨ សីហា បានប្រលងជាប់ថ្នាក់ទី៣ នៅវិទ្យាល័យស៊ីសុវត្ថិ ។ នៅក្នុងថ្នាក់រៀន សីហា អង្គុយតុរួមគ្នាជាមួយ ពិន យ៉ាថៃ (អ្នកនិពន្ធសៀវភៅ “ជីវិតកូនថ្ងៃកូនត្រូវតែរស់”) ។ ក្រៅពីរៀននៅសាលារដ្ឋ សីហា ឆ្លៀតរៀនភាសាអង់គ្លេសដែលស្ថានទូតអាមេរិកាំងបើកបង្រៀនជាទូទៅ ។ មួយឆ្នាំក្រោយមក សីហា បានប្រលងជាប់ឌីប្លូម ហើយប្តេជ្ញាចិត្តថានឹងខិតខំប្រឹងប្រែងរៀនបន្តទៅទៀត ។ នៅខែកញ្ញា សីហា បានចូលរៀនថ្នាក់ទី២ នៅវិទ្យាល័យស៊ីសុវត្ថិ ហើយអង្គុយតុជាមួយ ពិន យ៉ាថៃ ដដែល ។ ដោយឃើញ ពិន យ៉ាថៃ ខិតខំរៀនសូត្រដើម្បីប្រឡងផ្លោះ សីហា បានសុំម្តាយមីងរៀនបន្ថែមដើម្បីប្រលងផ្លោះដែរ ។

ឆ្នាំ១៩៦០ សីហា បានសម្រេចបំណងប្រាថ្នារបស់ខ្លួន ដោយប្រលងផ្លោះជាប់ចូលរៀនថ្នាក់ទី១ នៅវិទ្យាល័យស៊ីសុវត្ថិ ហើយមានទំនាក់ទំនងរៀនសូត្រជាមួយ វ៉ាន់ ពីនី, មាន ប៊ុនឈួយ, ជ័យ វ៉េត, យុង សុខន, ខៀវ វ៉ាណូ និង ប៉េច

ប៊ុនឈួយ ។ ក្រោយពីប្រលងជាប់ថ្នាក់បាក់ឌុបនៅឆ្នាំ១៩៦១ មក សីហា មានបំណងបន្តការសិក្សានៅប្រទេសបារាំង ប៉ុន្តែគ្មានអាហារូបករណ៍ ។ ក្រោយមក កាសែត“សារពត៌មានខ្មែរ”បានចុះផ្សាយសេចក្តីជូនដំណឹងថា ប្រទេសសូវៀតផ្តល់អាហារូបករណ៍ដល់សិស្សសញ្ជាតិខ្មែរចំនួនប្រាំពីរនាក់ ។ សីហា បានដាក់សុំទៅក្រសួងសិក្សាធិការជាតិហើយបានជាប់អាហារូបករណ៍ទៅរៀននៅសូវៀត ហើយចេញដំណើរនៅខែកញ្ញា ឆ្នាំ១៩៦១ ។ នៅសូវៀត សីហា បានទទួលការស្វាគមន៍ពីសំណាក់ ម៉ែន សុំផាវ ដែលជាលេខាទី១នៃទូតខ្មែរប្រចាំសហភាពសូវៀត និងបានជួបជាមួយនិស្សិតខ្មែរជាច្រើនដែលកំពុងរៀននៅទីនោះ ។

## សកម្មភាពនយោបាយនៅសូវៀត

នៅខែតុលា សីហា បានចូលរួមប្រជុំជាមួយនិស្សិតខ្មែរទាំងអស់នៅសូវៀតដើម្បីបង្កើតសមាគមន៍និស្សិតខ្មែរមួយ ប៉ុន្តែការប្រជុំនេះមិនបានសម្រេចលទ្ធផលជាផ្លែផ្កាទេ ដោយសារមានយោបល់ជំទាស់គ្នាច្រើននិងអវត្តមានរបស់និស្សិតដែលនៅតាមបណ្តាខេត្តក្រៅមួយចំនួន ។ មួយខែក្រោយមក ការជួបប្រជុំគ្នាត្រូវបានធ្វើឡើងម្តងទៀតដោយមានការចូលរួមពីនិស្សិតខ្មែរទាំងអស់ចំនួន៤១នាក់ ។ អង្គប្រជុំបានសម្រេចជ្រើសតាំង ប៉ែន ថៅងអាន ជាប្រធានអង្គប្រជុំ ។ គោលបំណងនៃការប្រជុំនេះ គឺបង្កើតសមាគមនិស្សិតខ្មែរមួយដើម្បីជួយសម្រួលដល់ការរស់នៅនិងលើកទឹកចិត្តឲ្យនិស្សិតខ្មែរទាំងអស់ខិតខំរៀនសូត្រឲ្យបានចប់និងយកចំណេះវិជ្ជាទៅបម្រើប្រទេសជាតិវិញ ។ ចុងបញ្ចប់អង្គប្រជុំបានសម្រេចបង្កើតសមាគមនិស្សិតខ្មែរមួយ ដោយមានសំឡេងគាំទ្រចំនួន២៤សំឡេង ប្រឆាំង១២សំឡេង និងអនុប្បវាទ៥សំឡេង ។ អង្គប្រជុំបានសម្រេចដាក់ឈ្មោះសមាគមនេះថា “សហភាពខេមរនិស្សិត” ដែល ភាសាបារាំងហៅថា អ៊ុយ-អឺ-សេ (UEC) ។ និមិត្តសញ្ញារបស់សមាគមគឺដៃកាន់ភ្លើងគុបនៅពីមុខប្រាសាទអង្គរវត្ត ។ សមាសភាពគណៈកម្មាធិការកណ្តាលរបស់សមាគមមាន ៖ ប៉ែន ថៅងអាន ប្រធាន, កាំ ដានយ៉ា អនុប្រធាន, ថាច់ សួង លេខា, តែ ហ៊ាន និង អ៊ាង សីហា ហិរញ្ញិក ។ រៀងរាល់ខែសមាជិកម្នាក់ៗត្រូវឧបត្ថម្ភថវិកា១រូពីទៅឲ្យ សមាគម ។

ខែមិថុនា ឆ្នាំ១៩៦២ សីហា បានរៀនចប់ភាសារុស្ស៊ី ។ ហើយនៅខែកញ្ញា បានចូលរៀនឆ្នាំទី១នៅសាលាសំណង់ស្ពាននិងផ្លូវថ្នល់ ។ ថ្ងៃមួយ ហាក់ សៀងឡាយនី បានបបួល សីហា ទៅលេងផ្ទះរបស់ខ្លួនដើម្បីសួរនាំអំពីការរៀនសូត្រនិងការរស់នៅ និងប្រាប់ពីព្រឹត្តិការណ៍នៅស្រុកខ្មែរថា មានអំពើពុករលួយ ការសូកប៉ាន់ និងផ្ទះស្រីខូចរាំរែក ហើយថា កម្ពុជានឹងបាត់រូបពីផែនទីសកលលោកក្នុងពេលអនាគតជាមិនខាន ។ ឡាយនី បានស្នើសុំឲ្យ សីហា ទាក់ទងជាមួយនិស្សិតខ្មែរដទៃទៀតដើម្បីជួបប្រជុំគ្នាពីរឿងប្រទេសជាតិ ។ សីហា ទាក់ទងបានមនុស្សពីនាក់ឈ្មោះ ឡៅ ជិនហុង និង ជីងកុកហួរ ។ ការប្រជុំជាសម្ងាត់មួយត្រូវបានធ្វើឡើងនៅសាលាថាមពល សមាសភាពចូលរួមមាន ឡាយនី, ប៉ែន ថៅងអាន, ម៉ែន ម៉ូនីង៉ាម, ថាច់ សួង, ឡៅ ជិនហុង, ជីង កុកហួរ, អ៊ាង សីហា, ហាក់ ផាដេត, និង អ៊ុំង វ៉ាត់ឈីវ ។ ឡាយនី និយាយថា សហរដ្ឋអាមេរិកចង់ធ្វើមហាអំណាចនៅអាស៊ីអាគ្នេយ៍ ដោយយកស្រុកខ្មែរធ្វើជាឈ្នាន់ ចំណែកចិនចង់យកខ្មែរធ្វើជារនាំងទប់ទល់នឹងការឈ្លានពានរបស់ចក្រពត្តិអាមេរិក ។ ឡាយនី បន្តទៀតថា មានតែសូវៀតទេដែលជួយកម្ពុជាដោយឥតលក្ខខណ្ឌ ។ ឡាយនី បានបំផុសឲ្យនិស្សិតទៅបញ្ចុះបញ្ចូលប្រជាជនដើម្បីចូលរួមវាយដណ្តើមអំណាចគ្រប់គ្រងប្រទេសទៅថ្ងៃក្រោយ ហើយថែមទាំងបានណែនាំនិស្សិតឲ្យរៀនសូត្រទ្រឹស្តីម៉ាក្ស-ឡេនីន និងចូលជាសមាជិកអង្គការ កា.ហ្សេ.បេ របស់សូវៀត ។ នៅក្នុងការប្រជុំនេះ ប៉ែន ថៅងអាន បានឲ្យយោបល់ថា បក្សពួករបស់គាត់គួរតែរក្សាកៅអីគណៈកម្មាធិការកណ្តាលរបស់សហភាពខេមរនិស្សិតឲ្យបានជាប់ដើម្បីឲ្យសមាគមន៍នេះបម្រើសកម្មភាពរបស់ក្រុមខ្លួន ។ និស្សិតខ្មែរទាំងនោះមានជំនឿយ៉ាងមុតមាំថា មានតែសូវៀតទេដែលអាចដោះស្រាយបញ្ហាពិភពលោកបាន ។

និស្សិតមួយចំនួនដែលរួមមានទាំង សីហា ផងបានចូលជាសមាជិកកា.ហ្សេ.បេ ហើយតែងតែជួបប្រជុំគ្នាជាញឹកញាប់ពិភាក្សាពីបញ្ហានៅកម្ពុជានិងបញ្ហាអន្តរជាតិ ។ ដើម្បីស្វែងយល់អំពីសភាពការណ៍នៅកម្ពុជាឲ្យកាន់តែច្បាស់ទៀត សីហា ត្រូវអានកាសែតភាសាខ្មែរនិងភាសាបារាំងដែលយកពីស្ថានទូតខ្មែរប្រចាំនៅសូវៀត ។

ឆ្នាំ១៩៦៣ សីហា បានចូលរៀនថ្នាក់ឆ្នាំទី២នៃសាលា

សំណង់ផ្លូវថ្នល់និងរថយន្ត ។ នៅក្នុងឆ្នាំនេះមាននិស្សិតខ្មែរប្រាំមួយនាក់ឈ្មោះ តឹក នៃ, អៀម ជូ, តាន់ នៃហេង, ហៃ គិមសាង, គ្រិន លាន, ទី យ៉ាវ, និង ចាន់ បានមកដល់សូវៀត ។ សីហា មានភារកិច្ចទៅទទួលនិស្សិតទាំងនេះនិងជួយរកបន្ទប់ឲ្យស្នាក់នៅ ។ ឆ្លៀតឱកាសនេះ សីហា ស៊ាបសួរមើលអំពីជំហរនយោបាយរបស់អ្នកទាំងនេះ ដើម្បីងាយស្រួលអូសទាញទៅក្នុងក្រុមរបស់ខ្លួន ។ មួយរយៈក្រោយមក និស្សិតទាំង៦នាក់បានយល់ព្រមចូលជាសមាជិកសហភាពខេមរនិស្សិត ។

ខែវិច្ឆិកា ១៩៦៣ វិទ្យុទីក្រុងម៉ូស្គូបានមកទាក់ទងសហភាពខេមរនិស្សិតខ្មែរដើម្បីរកអ្នកដែលអាចអានព័ត៌មានតាមវិទ្យុបាន ។ វិទ្យុនេះនឹងផ្សព្វផ្សាយព័ត៌មានជាភាសាខ្មែរពីរថ្ងៃម្តង ។ បន្ទាប់ពីជួបពិភាក្សាគ្នាក្នុងក្រុម ឡាយនី បានឲ្យយោបល់ថា សមាគមគួរតែយល់ព្រមធ្វើកិច្ចការនេះ ព្រោះសមាគមកំពុងត្រូវការថវិកាដើម្បីយកមកបោះពុម្ពទស្សនាវដ្តីភាសាខ្មែរនិងផ្គត់ផ្គង់និស្សិតដែលមានការខ្វះខាត ។ សីហា និងមិត្តភក្តិមួយចំនួនទៀត បានយល់ព្រមទទួលកិច្ចការនេះ ។ ក្រៅពីរៀនសូត្រនិងការងារវិទ្យុ សីហា ជាសមាជិកនៃគណៈកម្មាធិការទស្សនាវដ្តី "កម្រងវិជ្ជា" និងជាអ្នកប្រមូលនិងបោះពុម្ពផ្សាយ ដែលមាន ឡាយនី ជាប្រធាន ។

ខែសីហា ឆ្នាំ១៩៦៥ សីហា បានទៅលេងឪពុកមាឈ្មោះ សារិន ឆាក ដែលជាអគ្គរដ្ឋទូតខ្មែរប្រចាំនៅប្រទេសបារាំង ។ មុនចេញដំណើរ សីហា ក៏បានទៅជួប ឡាយនី ប្រាប់ពីដំណឹងនេះ ។ ឡាយនី បានផ្ញើសំបុត្រមួយច្បាប់ទៅឲ្យ តូច ខាំឿន ដែលជាប្រធានសមាគមនិស្សិតខ្មែរនៅប្រទេសបារាំងហៅកាត់ថា អ៊ុយ.អឺ.កា (UEK) និងសំបុត្រមួយច្បាប់ទៀតផ្ញើឲ្យ គាន់ លៀកម៉េង (វិស្វកររៀនចប់នៅប្រទេសបារាំងហើយមានប្រពន្ធជាជនជាតិបារាំង) ។

ស្នាក់នៅប្រទេសបារាំងបានមួយខែ សីហា ត្រឡប់មកពីរុស្ស៊ីវិញដោយធ្វើដំណើរកាត់តាមប្រទេសឆេកូស្លូវ៉ាគី ។ សីហា និងបានជួបនិស្សិតខ្មែរមួយចំនួននៅទីក្រុងប្រាក ដូចជា ពិន ជុន, ពិន ថា, អាំង ជីប៊ុ, ឡុង ណារិន, ស្រី ម៉ន, និង ទៀវ អ៊ុន ។ សីហា មកដល់ម៉ូស្គូវិញនៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ១៩៦៥ ។

ខែធ្នូ ឆ្នាំ១៩៦៧ សីហា បានប្រលងជាប់វិស្វករសំណង់ស្ពាននិងរូងភ្នំ ហើយត្រៀមខ្លួនវិលត្រឡប់មកប្រទេសកម្ពុជាវិញ ។ មុនចេញដំណើរ សីហា បានទៅជួប ឡាយនី ដើម្បីទទួលផែនការ ក.ហេ្ស.បេមកអនុវត្តក្នុងប្រទេស ។ ឡាយនី ចាត់តាំងឲ្យ សីហា រកកន្លែងប្រជុំការងារសម្ងាត់ និងរកកន្លែងបោះពុម្ពឯកសារបំផុសបំផុលចលនាប្រជាជននិងសិស្សនិស្សិតឲ្យប្រឆាំងនឹងរដ្ឋាភិបាល និងចក្រពត្តិអាមេរិកាំង ។ ឡៅ ជិនហុង បានយល់ព្រមយកផ្ទះរបស់ខ្លួនធ្វើជាទីស្នាក់ការសម្ងាត់របស់ក.ហេ្ស.បេ ។ នៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៦៨ សីហា បានត្រឡប់មកដល់ កម្ពុជាវិញ ។

## មកដល់ភ្នំពេញ

នៅក្នុងរយៈពេលបីខែ សីហា មិនទាន់រកការងារបានធ្វើទេ ដោយហេតុថារាជការខ្មែរមិនទទួលស្គាល់សញ្ញាប័ត្រមកពីសូវៀត ។ ខែមីនា ឆ្នាំ១៩៦៨ សីហា បានសុំការងារធ្វើពី ពិន យ៉ាថៃ ចាងហ្វាងផ្នែកការងារនៃក្រសួងសាធារណការ ។ សីហា បានជាប់ជាបុគ្គលិកអណ្តែតទទួលប្រាក់បៀវត្សរ៍៦ពាន់រៀលក្នុងមួយខែ ។ ក្នុងអំឡុងពេលនោះ អតីតនិស្សិតមកពីសូវៀត បានរួមគ្នាបង្កើតសមាគមមួយដែលមានឈ្មោះថា "សមាគម អតីតនិស្សិតមកពីសូវៀត" ដែលមាន ប៉ែន ថៅងអាន ជាប្រធាន ។ គោលបំណងនៃការបង្កើតសមាគមនេះគឺដោះស្រាយការងារដល់វិស្វករដែលទើបបញ្ចប់ការសិក្សា ។ ប៉ុន្តែផែនការសម្ងាត់គឺដើម្បីប្រមូលកម្លាំង សេ.អ៊ី.អា ប្រឆាំងនឹងបដិវត្តន៍របស់ខ្មែរក្រហម ។

មិនយូរប៉ុន្មាន រដ្ឋាភិបាលបានប្រកាសតាមវិទ្យុថា និស្សិតក្រហមមកពីសូវៀតកំពុងធ្វើសកម្មភាពប្រឆាំងរដ្ឋាភិបាល រួមមាន ៖ ប៉ែន ថៅងអាន, ម៉ែន ម៉ូនីង៉ាម, អ៊ឹង វ៉ាត់ឈីវ និង អ៊ាង សីហា ។ សីហា បានរត់ទៅលាក់ខ្លួនក្នុងបន្ទាយរបស់បងប្រុសឈ្មោះ អ៊ាង ជូ (ទាហានពាក់ស័ក្តិបី) ។ មួយខែក្រោយមក រដ្ឋាភិបាលបានប្រកាសលើកលែងទោសអ្នកទាំងនេះ ។ សីហា បានមកដាក់ពាក្យសុំធ្វើការងារនៅក្រសួងសាធារណការវិញ ។ កិច្ចការរបស់ សីហា គឺគូរប្លង់ផ្លូវរថភ្លើង ផ្លូវថ្នល់ និងស្ពាន ។

ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ សីហា ត្រូវបានបញ្ចូលជាពលទាហានសំណង់និង**ការពារសេដ្ឋកិច្ច**នៃក្រសួងសាធារណការទទួលភារកិច្ចជួសជុលស្ពានដែលត្រូវខ្មែរក្រហមដាក់មីនបំផ្លាញ ។ នៅខែវិច្ឆិកា មានការបង្កើតសមាគមវិស្វករខ្មែរមួយដែលមាន ផ្ទែក ឆាត

ជាប្រធាន, ឈុត ឈឿ ជាអនុប្រធាន, ពិន យ៉ាថៃ លេខា, អ៊ិន ញ៉ិល និង ឃួន ឈៀក ហិរញ្ញិក ។ ប៉ែន ថៅងអាន បានកោះប្រជុំអតីតសមាជិករបស់សមាគមនិស្សិតមកពីសូវៀតដើម្បីបញ្ចូលសមាជិកខ្លះទៅក្នុងសមាគមវិស្វករកម្ពុជា ក្នុងគោលបំណងប្រមូលកម្លាំងធ្វើវិប្លវកម្មនយោបាយប្រឆាំងនឹងខ្មែរក្រហម ។

នៅឆ្នាំ១៩៧១ សីហា បានរៀបការជាមួយបូនជីដូនមួយឈ្មោះ ឃិន ច័ន្ទថៃថៅ ហើយអ្នកទាំងពីរបានកូនស្រីមួយ ។ ជីវភាពគ្រួសាររបស់ សីហា មានសភាពយ៉ាប់យ៉ឺន ដោយសារប្រាក់ខែទាប ហើយទំនិញក៏ឡើងថ្លៃ ។

## ការចូលជាសមាជិក សេ.អ៊ី.អា

សីហា ចូលជាសមាជិកសេ.អ៊ី.អា នៅខែឧសភា ឆ្នាំ១៩៧០ ដោយមាន សេង គិមជុន ជាអ្នកនាំចូល និង អ៊ិន ញ៉ិល ជាអ្នកទទួលស្គាល់ ។ សីហា មានតួនាទីបញ្ចុះបញ្ចូលវិស្វករថ្មី និងនិស្សិតឲ្យចូលជាសមាជិកសមាគមវិស្វករខ្មែរដើម្បីជ្រើសយកចូលក្នុងអង្គការសេ.អ៊ី.អា ។ សីហា អូសទាញបានមនុស្សមួយចំនួនមាន ៖ សៅ ដៃ, យុង សុខុន, ឈៀវ វ៉ាណូ, សារិន ក្រែប៊ិន, ឡុង តាន់ស៊ីថា, និង តៅ គីមហួរ ។ ក្រៅពីនេះ សីហា មានតួនាទីតាមដានក្រុមខ្មែរក្រហមដែលបះបោរប្រឆាំងនឹងរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ ។ ខែមិថុនា ឆ្នាំ១៩៧១ សីហា បានទទួលផែនការថ្មីមួយទៀតពី អ៊ិន ញ៉ិល ចាប់ខ្មែរក្រហមឲ្យអស់ពីភ្នំពេញ ជាពិសេសតាមចាប់ចេញពីចលនាបាតុកម្មរបស់សិស្សនិងចលនាបះបោររបស់កម្មកររទេះភ្លើងដែលទាមទារដំឡើងប្រាក់បៀវត្សរ៍ ។

ក្នុងពេលនេះដែរ សីហា ជាអ្នកទាក់ទងជាមួយកងទ័ពរំដោះ (ខ្មែរក្រហម) ដើម្បីបញ្ចូលបក្ខពួករបស់ខ្លួនទៅបង្កប់ក្នុងជួរបដិវត្តន៍ ។ ខែវិច្ឆិកា ឆ្នាំ១៩៧៣ អ៊ិន ញ៉ិល ដែលជាប្រធានផ្នែករថភ្លើងបានបញ្ជូន សីហា និង ខៀវ វ៉ាណូ ឲ្យទៅរៀនបច្ចេកទេសរថភ្លើងនៅប្រទេសឥណ្ឌា ។ ឆ្លៀតឱកាសនេះ សីហា បានបញ្ចុះបញ្ចូល ខៀវ វ៉ាណូ ឲ្យចូលជាភ្នាក់ងារសេ.អ៊ី.អា ។ ពីខែកញ្ញាដល់ខែធ្នូ ឆ្នាំ១៩៧៤ អ៊ិន ញ៉ិល បានបញ្ជូន សីហា ឲ្យទៅរៀនបច្ចេកទេសរថភ្លើងនៅប្រទេសជប៉ុនបន្ថែមទៀត ។ មកដល់ឆ្នាំ១៩៧៤ សភាពការណ៍មានការតានតឹងយ៉ាងខ្លាំង ហើយក្រុមសេ.អ៊ី.អា ស៊ើបការណ៍របស់ សីហា មិនអាចធ្វើសកម្មភាពបានច្រើនទេ ។ ឃើញសភាពការណ៍មិនស្រួលបែបនេះ សីហា បានបញ្ជូនប្រពន្ធនិងកូនស្រីអាយុបីឆ្នាំឈ្មោះ អ៊ាង ចិន្តា ឲ្យទៅរស់នៅប្រទេសបារាំង ។

ដើមឆ្នាំ១៩៧៥ អ៊ិន ញ៉ិល បានកោះប្រជុំក្រុមសេ.អ៊ី.អា ទាំងអស់ដើម្បីត្រៀមចាញ់សង្គ្រាម អង្គប្រជុំបានដាក់ផែនការដើម្បីអនុវត្តក្រោយពេលសង្គ្រាម ។ កិច្ចការសំខាន់គឺបង្កប់ក្នុងជួរបដិវត្តន៍ដើម្បីបំផ្លាញសេដ្ឋកិច្ច ដោយធ្វើឲ្យរោងចក្រ រថភ្លើង និងមធ្យោបាយដឹកជញ្ជូនទាំងអស់លែងដំណើការ ។

## ១៧មេសា ១៩៧៥

ថ្ងៃ១៧មេសា ១៩៧៥ រថក្រោះនិងកងទ័ពបដិវត្តន៍កម្ពុជាកំពុងធ្វើដំណើរចូលមកទីក្រុងភ្នំពេញ ហើយបានប្រកាសឲ្យប្រជាជនប្រមូលអាវុធនិងសម្ភារយោធាទាំងអស់មកគទុកកណ្តាលថ្នល់ ។ សីហា បានយកកាំភ្លើងនិងគ្រាប់បែកទៅដាក់កណ្តាលថ្នល់ដូចអ្នកឯទៀត ប៉ុន្តែគាត់កប់កាំភ្លើងខ្លីមួយដើមនិងគ្រាប់បែកបួនគ្រាប់នៅមុខផ្ទះ ។ កងទ័ពភូមិភាគបូព៌ាបានឲ្យ សីហា និង ជាវ ភាន (វិស្វករអាកាសចរស៊ីវិល) យកឡាននិងម៉ូតូហុងដាមួយចំនួនទៅឲ្យក្រុមខ្លួននៅមុំជីតដ្ឋផ្លូវជាតិលេខ១ ។ នៅព្រឹកថ្ងៃបន្ទាប់ សីហា មានបំណងទៅជួបជាមួយបក្ខពួក ដើម្បីពិភាក្សាពីបញ្ហាជម្លៀសនេះ ប៉ុន្តែត្រូវបានខ្មែរក្រហមបង្ខំឲ្យចាកចេញពីទីក្រុងតាមផ្លូវជាតិលេខ៥វិញ ។ នៅថ្ងៃទី២៨ មេសា តំណាងអង្គការឈ្មោះ តាសាត បានឲ្យ សីហា ចូលធ្វើការក្នុងអង្គភាពជួសជុលផ្លូវនិងស្ពានមួយចំនួនរួមមានកំណាត់ស្ពានព្រែកគ្រួស ព្រែកក្តាម ព្រែកពាមសត្វា និងព្រែកតាទែន ។

នៅខែមិថុនា សីហា ត្រូវអង្គការបញ្ជូនទៅជួសជុលផ្លូវរថភ្លើងដែលមានសមមិត្ត ប្រាំង ជាប្រធាន និង សាំង ជាអនុប្រធាន ។ នៅទីនេះ សីហា បានជួបមិត្តចាស់មួយចំនួនដូចជា ទួន សុកផល្លា និង ម៉ែល សាវ៉ាន ។ ប្រាំង បានឲ្យ សីហា ទៅធ្វើស្ពានស៊ីងតូចនៅតាមផ្លូវជាតិលេខ៣ ។ ពេលនោះ សីហា បានជួប ឡាយនី កំពុងជិះម៉ូតូតាមផ្លូវ ។ អ្នកទាំងពីរបានណាត់គ្នា ដើម្បីប្រជុំពិភាក្សាពីខ្សែរយៈកា.ហ្សេ.បេ ។ ការជួបប្រជុំគ្នានេះមាន ឡាយនី, ហាក់ ផាដេត និង គ្រិន លាន ។ អ្នកទាំងបួនបានសម្រេចថានឹងទាក់ទងបក្ខពួកខ្លួនដែលកំពុងបង្កប់ក្នុងជួរបដិវត្តន៍ដើម្បីរួមគ្នាកម្ទេចបដិវត្តន៍ ប៉ុន្តែផែនការនេះពិបាកក្នុងការអនុវត្តដោយសារថាបក្ខពួករបស់ខ្លួនត្រូវអង្គការបានបញ្ជូនទៅតំបន់ផ្សេងៗ ។ ប៉ុន្មានថ្ងៃក្រោយមក

ប្រាំង បានចាត់តាំងឲ្យ សីហា ទៅបើកការដ្ឋានសាងសង់ស្ពានពីរទៀត គឺស្ពានដើមឫស និងស្ពានស្វាគូ ។

ខែធ្នូ ១៩៧៥ អង្គការបញ្ជូន សីហា ឲ្យទៅតជួររថភ្លើងពីស្ពានីយ៍កំពតទៅរោងចក្រស៊ីម៉ង់ត៍ចក្រីទីង ។ នៅទីនោះ សីហា និងមិត្តភក្តិម្នាក់បានបំផ្លាញលូ ម៉ាស៊ីន និងធ្វើឲ្យឆេះម៉ូទ័រមួយចំនួន ។ នៅខែមករា ឆ្នាំ១៩៧៦ សីហា បានដឹកនាំគម្រោងសាងសង់ផ្លូវរថភ្លើងថ្មីមួយខ្សែភ្ជាប់ពីភ្នំពេញកំពង់សោម ។ គម្រោងនេះ ត្រូវចំណាយអស់ពេលពីរខែទើបរៀបចំហើយនិងចាប់ផ្តើមគម្រោងនៅខែមីនា ។ ក្នុងរយៈកាលសាងសង់ផ្លូវរថភ្លើងថ្មីនេះ សីហា អូសទាញសមាជិកសេ.អ៊ី.អា បានមួយចំនួនឈ្មោះ ជា, អ៊ួន, ជូ, ដេង, និង ឡុង ។ អ្នកទាំងនេះបានធ្វើសកម្មភាពបំផ្លាញម៉ូទ័រអស់ពីរគ្រឿង ។

អង្គការបានប្រគល់រថយន្តមួយគ្រឿងនិងកម្មករ១២នាក់ឲ្យ សីហា ។ សីហា តែងតែរិះរកគ្រប់មធ្យោបាយដើម្បីកុំដំណើរសាងសង់ប្រព្រឹត្តទៅលឿនពេក ។ ថ្ងៃមួយ សីហា និង ឌឿន អ្នកមើលការខុសត្រូវនៅខេត្តកំពង់ស្ពឺ បានធ្វើដំណើរទៅពិនិត្យមើលការដ្ឋានសាងសង់នៅពេជ្រនិល ។ ឌឿន បើករថយន្តលឿនពេកបណ្តាលឲ្យក្រឡាប់ធ្លាក់ជ្រោះពេជ្រនិល ។ សីហា ត្រូវរបួសបាក់ដៃស្តាំ ហើយបានមកសម្រាកព្យាបាលនៅមន្ទីរពេទ្យព-១៧ (ពេទ្យ១៧មេសា) ។ ក្រោយពីជាសះស្បើយ អង្គការបានបញ្ជូន សីហា ឲ្យមកមើលការខុសត្រូវសំណង់ផ្លូវរថភ្លើងវិញ ។

ខែកញ្ញា ឆ្នាំ១៩៧៦ សីហា ត្រូវត្រឡប់មកភ្នំពេញវិញ និងធ្វើការនៅរោងជាងរថភ្លើងដដែល ។ អង្គការចាត់តាំង សីហា ដើរប្រមូលសម្ភារៈណាដែលអាចកែច្នៃជាម៉ាស៊ីនកិនថ្មបាន ។ នៅទីនោះ សីហា បានជួបបក្ខពួកមួយចំនួនដែលបានបង្កប់ក្នុងជួរបដិវត្តន៍ដូចជា លី គឹមបា៉ក់, ទឹម និង តាន់ ហ៊ី ។ សីហា ក៏បានដាក់ផែនការឲ្យបក្ខពួកបំផុសកម្មករកុំឲ្យធ្វើការច្រើន និងធ្វើឲ្យគ្រាក់ទ័រខូចញឹកញាប់ ។ នៅខែតុលា សីហា បានចូលរួមប្រជុំជាមួយ ឡាយនី (ប្រធានអង្គ ប្រជុំ) គ្រិន លាន, ម៉ែល សុវណ្ណ, និង ហាក់ ផាដេត ដើម្បីរាយការណ៍ ប្រាប់គ្នាទៅវិញទៅមកអំពីសកម្មភាពដែលខ្លួនបានធ្វើកន្លងមក ។ អង្គប្រជុំបានដាក់ផែនការកម្ទេចបដិវត្តន៍តទៅទៀត ។

ខែធ្នូ ឆ្នាំ១៩៧៦ សីហា បានធ្វើឲ្យឆេះម៉ាស៊ីនផ្តិតបួងដែលមានតែមួយគត់បណ្តាលឲ្យដំណើរការសាងសង់ផ្លូវឬស្ពានមិនអាចដំណើរការទៅបាន ។ មូលហេតុនេះហើយទើប សីហា ត្រូវអង្គការចាប់បញ្ជូនមកមន្ទីរស-២១ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៧៦ ។ សីហា ត្រូវបានសួរចម្លើយចំនួនពីរលើក ។ លើកទីមួយធ្វើនៅថ្ងៃទី៣ ខែមករា ឆ្នាំ១៩៧៧ មានចំនួន១៧១ទំព័រសួរដោយឈ្មោះ ម៉េត ។ លើកទីពីរសរសេរចប់នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៧៧ មានចំនួន ១៧២ទំព័រ ។ ចុងបញ្ចប់នៃចម្លើយសារភាពមានរាយនាមបក្ខពួកចំនួន៨០នាក់ ដែលរួមសកម្មភាពក្បត់បដិវត្តន៍ ។ សីហា ត្រូវអង្គការកម្ទេចនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ ។

## បញ្ជីរាយនាមអ្នកជាប់ក្នុងចម្លើយសារភាព

◆ ហាក់ សៀងឡាយនី ◆ ហាក់ ផាដេត ◆ គ្រិន លាន ◆ ប៉ុច មាយបូរី ◆ អ៊ុង ប៉ុច ◆ លី គឹមបា៉ក់ ◆ ហាក់ សៀកគ្រី ◆ តាត វ៉ាន់នី ◆ ប៉ែន ថោងអាន ◆ ម៉ែន ប៊ុនឈួយ ◆ អ៊ំ ស៊ុំនឿន ◆ ម៉ែន មុន្នីង៉ាម ◆ អ៊ុង វ៉ាត់ឈីវ ◆ ឡោ ជិនហុង ◆ អ៊ុន ញ៉ិល ◆ ឃួន ឈៀក ◆ ពិន ថុន ◆ សេង គីមជន់ ◆ ឈៀង សាអ៊ុម ◆ ថៃ សុវណ្ណថា ◆ ពិន យ៉ាថៃ ◆ផ្លេក ឆាត ◆ អ៊ុន ហាំងកាំង ◆ អ៊ឹង ក្រពុំផ្កា ◆ ឈុត ឈឿ ◆ លឹក ហួរ ◆ ឃៀវ វ៉ាណូ ◆ សារិន ក្រែបិន ◆ ឃួន ឃុននាយ ◆ ម៉ៅ កាឡុង ◆ កែ ស៊ុនហួរ ។ល ។

**ឌី ខាំបូលី**

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាននិងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ៖

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខ ៖ (៨៥៥) (២៣) ២១១ ៨៧៥

ទូរសារលេខ ៖ (៨៥៥) (២៣) ២១០ ៣៥៨

Email: dccam@online.com.kh

Home page: www.dccam.org

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ (គុកទួលស្លែង)

## រៀបចំនិងចងក្រងដោយ : យិន នាន

(តពីលេខមុន)

| ល.រ | នាម-គោត្តនាម | មុខងារ | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ២៦៥៩ | អែម អុន ហៅ អេន | យុទ្ធជន | កងពល៤៥០ | ២៤-៤-៧៧ | ១០-៦-៧៧ |
| ២៦៦០ | ពៅ ញ៉ែម ហៅ យុន | យោធាកងធំ | កងពល៤៥០ | ២៩-៥-៧៧ | ១០-៦-៧៧ |
| ២៦៦១ | សយ សំបូរ ហៅ យ៉ន | អនុនយោបាយ | កងពល៤៥០ | ១៦-៥-៧៧ | ១០-៦-៧៧ |
| ២៦៦២ | យី អ៊ីន | លេខាកងធំ | កងពល៤៥០ | ២៤-៤-៧៧ | ១០-៦-៧៧ |
| ២៦៦៣ | កង រិន ហៅ ឆោម | អនុនយោបាយ | កងពល៤៥០ | ១២-៥-៧៧ | ១០-៦-៧៧ |
| ២៦៦៤ | គីម ម៉េង ហៅ វ៉ុន | យោធាកងធំ | កងពល៤៥០ | ១៩-៥-៧៧ | ១០-៦-៧៧ |
| ២៦៦៥ | គួម ញ៉ូង ហៅ វ៉ាត | ភ័ស្តុភារ | កងពល៤៥០ | ?-៤-៧៧ | ១០-៦-៧៧ |
| ២៦៦៦ | ដឹម ដេត ហៅ ឌឿន | លេខាកងធំ | កងពល៤៥០ | ១-៦-៧៧ | ១០-៦-៧៧ |
| ២៦៦៧ | នួន ស្រ៊ុន ហៅ ស៊ា | យោធាកងធំ | កងពល៤៥០ | ១-៦-៧៧ | ១០-៦-៧៧ |
| ២៦៦៨ | ប្រាក់ ហយ ហៅ ឆុន | សមាជិកកងធំ | កងពល៤៥០ | ២២-៥-៧៧ | ១០-៦-៧៧ |
| ២៦៦៩ | មុក ទ្រី ហៅ ខឿន | ប្រធានកងតូច | កងពល៤៥០ | ២៩-៥-៧៧ | ១០-៦-៧៧ |
| ២៦៧០ | សូត្រ ស៊ាន | អនុកងតូច | កងពល៤៥០ | ២៩-៥-៧៧ | ១០-៦-៧៧ |
| ២៦៧១ | ឡុង ឈិន ហៅ ថាន | សមាជិកកងតូច | កងពល៤៥០ | ១២-៥-៧៧ | ១០-៦-៧៧ |
| ២៦៧២ | កើត រឿន | អនុក្រុម | កងពល៤៥០ | ២៩-៥-៧៧ | ១០-៦-៧៧ |
| ២៦៧៣ | ហ៊ុន ជឿន ហៅ ទៀង | អនុក្រុម | កងពល៤៥០ | ២៩-៥-៧៧ | ១០-៦-៧៧ |
| ២៦៧៤ | មួញ លន | អនុក្រុម | កងពល៤៥០ | ២៩-៥-៧៧ | ១០-៦-៧៧ |
| ២៦៧៥ | ប្រាក់ ម៉ៅ ហៅ យ៉ន | អនុក្រុម | កងពល៤៥០ | ២៩-៥-៧៧ | ១០-៦-៧៧ |
| ២៦៧៦ | រឿង ហ៊ត | សមាជិកក្រុម | កងពល៤៥០ | ២៦-៥-៧៧ | ១០-៦-៧៧ |
| ២៦៧៧ | គង់ ដួន | អនុក្រុម | កងពល៤៥០ | ២៦-៥-៧៧ | ១០-៦-៧៧ |
| ២៦៧៨ | ម៉ី ទន ហៅ ត្រា | មេក្រុម | កងពល៤៥០ | ២៦-៥-៧៧ | ១០-៦-៧៧ |
| ២៦៧៩ | សោម គឿន | មេក្រុម | កងពល៤៥០ | ២៦-៥-៧៧ | ១០-៦-៧៧ |
| ២៦៨០ | ហ៊ៅ ឆេន ហៅ ឌិត | មេក្រុម | កងពល៤៥០ | ១៦-៥-៧៧ | ១០-៦-៧៧ |
| ២៦៨១ | ឡុង ឡុប | មេពួក | កងពល៤៥០ | ២២-៥-៧៧ | ១០-៦-៧៧ |
| ២៦៨២ | គាំ វ៉ុន ហៅ សែន | យុទ្ធជន | កងពល៤៥០ | ២២-៥-៧៧ | ១០-៦-៧៧ |
| ២៦៨៣ | ឈាង ឈាត ហៅ លាង | មេពួក | កងពល៤៥០ | ២៩-៥-៧៧ | ១០-៦-៧៧ |
| ២៦៨៤ | ទេព ឈឹន ហៅ ឈុន | យុទ្ធជន | កងពល៤៥០ | ២៩-៥-៧៧ | ១០-៦-៧៧ |
| ២៦៨៥ | ជា ណុល ហៅ មាន | យុទ្ធជន | កងពល៤៥០ | ១៤-៤-៧៧ | ១០-៦-៧៧ |

| | | | | | |
|---|---|---|---|---|---|
| ២៦៨៦ | យិន ផាន់ | យុទ្ធជន | កងពល៤៥០ | ១-៦-៧៧ | ១០-៦-៧៧ |
| ២៦៨៧ | ចាប ហុន | ពេទ្យ | កងពល៤៥០ | ១-៦-៧៧ | ១០-៦-៧៧ |
| ២៦៨៨ | កែវ ដាំ ហៅ រៀម | យុទ្ធជន | កងពល៤៥០ | ៤-៦-៧៧ | ១០-៦-៧៧ |
| ២៦៨៩ | ព្រូ សុផាត ហៅ ធឿន | យុទ្ធជន | កងពល៤៥០ | ៤-៦-៧៧ | ១០-៦-៧៧ |
| ២៦៩០ | អំ អយ ហៅ ហាន | យុទ្ធជន | កងពល៤៥០ | ៤-៦-៧៧ | ១០-៦-៧៧ |
| ២៦៩១ | ប្រាក់ ញឹម ហៅ រឹម | យុទ្ធជន | កងពល៤៥០ | ៨-៦-៧៧ | ១០-៦-៧៧ |
| ២៦៩២ | ភាំ ទូច ហៅ អាន | យុទ្ធជន | កងពល៤៥០ | ៨-៦-៧៧ | ១០-៦-៧៧ |
| ២៦៩៣ | ខុប ខុន ហៅ ខន | អនុក្រុម | មន្ទីរ វ-៦៦ | ២៦-៥-៧៧ | ១០-៦-៧៧ |
| ២៦៩៤ | ប៉ិល សារ៉ែន ហៅ ថេង | អនុក្រុម | មន្ទីរ វ-៦៦ | ២២-៥-៧៧ | ១០-៦-៧៧ |
| ២៦៩៥ | ខាន់ ណាត | មេពួក | មន្ទីរ វ-៦៦ | ២៦-៥-៧៧ | ១០-៦-៧៧ |
| ២៦៩៦ | កែន ឆេង | មេពួក | មន្ទីរ វ-៦៦ | ២២-៥-៧៧ | ១០-៦-៧៧ |
| ២៦៩៧ | ពៅ វឿន ហៅ រិន | មេពួក | មន្ទីរ វ-៦៦ | ២២-៥-៧៧ | ១០-៦-៧៧ |
| ២៦៩៨ | ខែម ហួត | មេពួក | មន្ទីរ វ-៦៦ | ២២-៥-៧៧ | ១០-៦-៧៧ |
| ២៦៩៩ | ស្រិល សំអេង ហៅ អាត | យុទ្ធជន | មន្ទីរ វ-៦៦ | ២៥-៣-៧៧ | ១០-៦-៧៧ |
| ២៧០០ | ឡេង លីម | យុទ្ធជន | មន្ទីរ វ-៦៦ | ២៥-៣-៧៧ | ១០-៦-៧៧ |
| ២៧០១ | ភាំ កេន ហៅ គាម | យុទ្ធជន | មន្ទីរ វ-៦៦ | ?-៥-៧៧ | ១០-៦-៧៧ |
| ២៧០២ | ប្រាក់ ឡេន | យុទ្ធជន | មន្ទីរ វ-៦៦ | ២៤-៣-៧៧ | ១០-៦-៧៧ |
| ២៧០៣ | សួស រុំ | យុទ្ធជន | មន្ទីរ វ-៦៦ | ២២-៣-៧៧ | ១០-៦-៧៧ |
| ២៧០៤ | ជា រ៉ុ ហៅ អេង | យុទ្ធជន | មន្ទីរ វ-៦៦ | ២៤-៣-៧៧ | ១០-៦-៧៧ |
| ២៧០៥ | ទិត រស់ ហៅ រឹម | យុទ្ធជន | មន្ទីរ វ-៦៦ | ២៦-៥-៧៧ | ១០-៦-៧៧ |
| ២៧០៦ | ស៊ិន អៀង | យុទ្ធជន | មន្ទីរ វ-៦៦ | ២៦-៥-៧៧ | ១០-៦-៧៧ |
| ២៧០៧ | អ៊ុយ ថន ហៅ ចិត្ត | យុទ្ធជន | មន្ទីរ វ-៦៦ | ២៦-៥-៧៧ | ១០-៦-៧៧ |
| ២៧០៨ | គង់ គា ហៅ រ៉ែម | យុទ្ធជន | មន្ទីរ វ-៦៦ | ២៦-៥-៧៧ | ១០-៦-៧៧ |
| ២៧០៩ | ទុយ ហន | យុទ្ធជន | មន្ទីរ វ-៦៦ | ២៦-៥-៧៧ | ១០-៦-៧៧ |
| ២៧១០ | សំ កឿន ហៅ អឿន | យុទ្ធជន | មន្ទីរ វ-៦៦ | ២៦-៥-៧៧ | ១០-៦-៧៧ |
| ២៧១១ | គង់ ហាស់ ហៅ ឈាន | យុទ្ធជន | មន្ទីរ វ-៦៦ | ២៦-៥-៧៧ | ១០-៦-៧៧ |
| ២៧១២ | លោន វ៉េង | យុទ្ធជន | មន្ទីរ វ-៦៦ | ២២-៥-៧៦ | ១០-៦-៧៧ |
| ២៧១៣ | ឡុញ ដួន ហៅ ជឿន | យុទ្ធជន | មន្ទីរ វ-៦៦ | ២២-៥-៧៦ | ១០-៦-៧៧ |
| ២៧១៤ | យឿ នឹម ហៅ ភា | យុទ្ធជន | មន្ទីរ វ-៦៦ | ២២-៥-៧៦ | ១០-៦-៧៧ |
| ២៧១៥ | យោគ ផាត ហៅ វ៉ង | យុទ្ធជន | មន្ទីរ វ-៦៦ | ២២-៥-៧៦ | ១០-៦-៧៧ |
| ២៧១៦ | ដុក ជឿន | យុទ្ធជន | មន្ទីរ វ-៦៦ | ៨-៦-៧៧ | ១០-៦-៧៧ |

(នៅមានត)

(ឯកសាររណសិរ្សលេខ D22609)

# រដ្ឋកម្ពុជា
# ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

**ក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីកសាងការពារមាតុភូមិ**

**លេខៈ ០២-៩១ កជរស.ណន**

## ផែនការណែនាំស្តីពីការចាត់តាំងទិវាចងកំហឹងចំពោះរបបប្រល័យពូជសាសន៍ ប៉ុលពត, អៀង សារី, ខៀវ សំផន ២០ ឧសភា ១៩៩១

ក្នុងអំឡុងឆ្នាំ១៩៧៥ដល់ដើមឆ្នាំ១៩៧៩ ប៉ុល ពត, អៀង សារី, ខៀវ សំផន បានធ្វើឲ្យមាតុភូមិនិងប្រជាជនកម្ពុជាធ្លាក់ជ្រៅទៅគ្រោះមហន្តរាយយ៉ាងធ្ងន់ធ្ងរ ។ សង្គមត្រូវប្រឬកប្រឬល់ស្រុកភូមិត្រូវវិនាសខ្ទេចខ្ទាំ គ្រួសារត្រូវវិនាសព្រាត់ប្រាសគ្មានការសប្បាយរីករាយ គ្មានសំណើចមានតែឈាមនិងទឹកភ្នែក ។ រាល់តម្លៃស្មារតីនិងសម្ភាររបស់ប្រជាជាតិត្រូវបំផ្លិចបំផ្លាញ ។

មាតុភូមិនិងប្រជាជនកម្ពុជាត្រូវបានរំដោះ ហើយបានទទួលសិទ្ធិសេរីភាពឡើងវិញនៅថ្ងៃ៧ មករា ១៩៧៩ ដោយសារការប្រយុទ្ធសង្គ្រោះជាតិរបស់បក្ស រណសិរ្ស និងរដ្ឋអំណាចបដិវត្តយើង ។ ចាប់តាំងពីពេលនោះមក ប្រជាជនកម្ពុជាទាំងមូលក្រោមការដឹកនាំរបស់បក្ស រណសិរ្ស និងរដ្ឋអំណាចបដិវត្ត បានធ្វើឲ្យសម្រេចសមិទ្ធផលដ៏ធំធេង កែប្រែជីវភាពរស់នៅរបស់ខ្លួននិងជំរុញការរីកចម្រើនរបស់ប្រទេសគួរជាទីពេញចិត្ត ។

ឯខ្មាំងសត្រូវពិតមែនត្រូវបរាជ័យតែពួកវានៅមានឧបាយកលជាច្រើនសំដៅបំផ្លាញរបបថ្មីយើង ពិសេសចាប់ពីក្រោយកងទ័ពវៀតណាមដកអស់ទាំងស្រុងពីកម្ពុជានាខែកញ្ញា ១៩៧៩ ពពួកមេក្លោងសម្ព័ន្ធភាពប្រល័យពូជសាសន៍ ប៉ុល ពត, សឺន សាន បានប្រព្រឹត្តឧក្រិដ្ឋកម្មថ្មីៗជាបន្តបន្ទាប់មកលើមាតុភូមិនិងប្រជាជនយើង ។ ប៉ុន្តែឧបាយកលទាំងអស់របស់ពួកវាត្រូវកម្លាំងប្រដាប់អាវុធនិងប្រជាជនយើងវាយឲ្យបរាជ័យយ៉ាងដំណំ ។

ឆ្នាំនេះ យើងចាត់តាំងទិវាចងកំហឹងចំពោះរបបប្រល័យពូជសាសន៍ ប៉ុល ពត, អៀង សារី, ខៀវ សំផន ២០ ឧសភា ១៩៩១ ក្នុងសភាពការណ៍បដិវត្តកម្ពុជារ៉ាប់រងដោយខ្លួនឯងទាំងស្រុងនូវរាល់ភារកិច្ច ហើយពុះពារឆ្លងកាត់ការលំបាកស្មុគស្មាញនិងសម្រេចបានស្នាដៃធំៗជាច្រើន ចំណុចខ្លាំងបំផុតដែលលេចឡើងក្នុងរយៈពេលនេះគឺយើងរក្សាបានរឹងមាំសមិទ្ធផលរបស់សង្គមជាតិ ដែលបក្សកងកម្លាំងប្រដាប់អាវុធ និងប្រជាជនយើងទូទាំងប្រទេសតស៊ូសម្រេចបានរយៈពេល១២ឆ្នាំកន្លងមកនេះ ។

ដើម្បីញ៉ាំងឲ្យពិធីចាត់តាំងទិវា ២០ ឧសភា ១៩៩១ ប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពខ្ពស់ ក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីកសាងមាតុភូមិកម្ពុជា សូមធ្វើការណែនាំដូចខាងក្រោមនេះ

**សំណូមពរនិងខ្លឹមសារឃោសនាថ្ងៃចងកំហឹង ២០ ឧសភា ៖**

១) បង្ហាញច្បាស់ថា រាល់ជ័យជម្នះដែលយើងសម្រេចបានក្នុង១២ឆ្នាំកន្លងទៅគឺជាលទ្ធផលនៃការខិតខំប្រឹងប្រែងដ៏ធំធេងរបស់បក្សប្រជាជនបដិវត្តកម្ពុជានិងរដ្ឋាភិបាលនៃរដ្ឋកម្ពុជាក្នុងការពុះពាររាល់ការលំបាកនិងឧបសគ្គគ្រប់បែបយ៉ាងដើម្បីស្ដារសង្គមជាតិឲ្យរស់រានមានជីវិតឡើងវិញ ហើយទទួលបានការចម្រើនលើគ្រប់វិស័យ ទន្ទឹមការឈ្លាសវៃក្នុងការដឹកនាំប្រមូលកម្លាំងមហាសាមគ្គីឯកភាពជាតិរឹងមាំ ទប់ស្កាត់នូវការវិលត្រឡប់មកវិញនៃរបបប្រល័យពូជសាសន៍ប៉ុលពត ។

២) បំពាក់កំហឹងនិងបកអាក្រាតថ្កោលទោសយ៉ាងខ្លាំងក្លា ពួកប៉ុលពត, អៀង សារី, ខៀវ សំផន ក្បត់ប្រជាជន ក្បត់ជាតិបង្កឡើងនូវមហន្តរាយប្រល័យពូជសាសន៍និងនាំមកនូវគ្រោះវិនាសកម្មដ៏ធំធេងដល់មាតុភូមិនិងប្រជាជនយើង ហើយ១២ឆ្នាំកន្លងទៅនេះ មេក្លោងសម្ព័ន្ធភាពប្រល័យពូជសាសន៍នៅតែបន្តបង្កើនការឃុបឃិតធ្វើសកម្មភាពសាបព្រោះវិនាសកម្ម បំផ្លិចបំផ្លាញ

រដ្ឋកម្ពុជា យើងប្រឆាំងនឹងការរស់នៅដ៏សុខសាន្តរបស់ប្រជាជនកម្ពុជា ។

៣) លើកទឹកចិត្តបក្សទាំងមូល កងកម្លាំងប្រដាប់អាវុធទាំងមូល និងប្រជាជនយើងទាំងមូល មើលឃើញចរិតរឹងរូសនិងឧបាយកលឥតប្រែប្រួលរបស់បច្ចាមិត្រនិងរំពុកឡើងវិញជានិច្ចនូវរាល់ឧបាយកលចាស់និងថ្មីៗរបស់ពួកវាមកលើប្រជាជនយើង ។ ផ្ដើមចេញពីកំហឹងឈឺចាប់នោះ ត្រូវលើកកម្ពស់ស្មារតីប្រុងប្រយ័ត្នថែមទៀត បំពាក់ជាប់មនសិការខ្លួនឧបត្ថម្ភខ្លួន ជឿជាក់លើកម្លាំងខ្លួន បន្តជ្រោងខ្ពស់ទង់មហាសាមគ្គីជាតិទាំងមូល បង្កឲ្យបានកម្លាំងសរុប វិធានការសរុប សំដៅការពាររឹងមាំសមិទ្ធផលសង្គមជាតិ ស្តារអភិវឌ្ឍន៍ខឿនសេដ្ឋកិច្ចជាតិ លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន ដោយសកម្មចូលរួមគ្រប់យុទ្ធនាការក្នុងឆ្នាំ១៩៩១ ជាអាទិ៍យុទ្ធនាការវាយបកខ្មាំង យុទ្ធនាការបង្កបង្កើនផលរួមគ្នាកសាងថវិកាជាតិ បង្កើនការសន្សំសំចៃ យុទ្ធនាការប្រឆាំងអំពើអសកម្ម រួមចំណែកលើកកម្ពស់ភាពយុត្តិធម៌ក្នុងសង្គម ប្ដេជ្ញាដណ្ដើមឲ្យបានជ័យជម្នះថ្មីៗថែមទៀត ដើម្បីនាំមកនូវសន្តិភាពពិតប្រាកដជូនមាតុភូមិនិងសុភមង្គលដ៏រុងរឿងជូនប្រជាជន ។

៤) បន្តពង្រីងនិងពង្រីកនូវមនសិការសាមគ្គីជាតិនិងអន្តរជាតិ ពិសេសសាមគ្គីជាមួយវៀតណាម ឡាវ សភាពសូវៀត ព្រមទាំងបង្កើតទំនាក់ទំនងល្អជាមួយប្រទេសទាំងអស់លើសកលលោកបង្កើនអំណោយផលដល់ការកសាងនិងការពារមាតុភូមិកម្ពុជា ។

***រូបភាពចាត់តាំងអនុវត្ត ៖***

១) នៅមជ្ឈិមគណៈកម្មាធិការរៀបចំបុណ្យជាតិ អន្តជាតិនិងគណៈកម្មាធិការប្រជាជនរដ្ឋធានីភ្នំពេញ ចាត់តាំងមិទ្ទីងមហាជននៅថ្ងៃ២០ ឧសភា ក្នុងបរិវេណ "មជ្ឈមណ្ឌលប្រល័យពូជសាសន៍ទួលស្លែង" ។

◆ សុន្ទរកថាសម្រាប់ថ្ងៃចាត់តាំងមិទ្ទីងគឺខុទ្ទកាល័យក្រុមប្រឹក្សាជាតិរណសិរ្សជាអ្នករៀបរៀង ។

◆ វិយោគកថាគឺក្រសួងឃោសនាការវប្បធម៌ជាអ្នករៀបរៀង ។

◆ នៅបណ្តាខេត្ត-ក្រុងគឺអាស្រ័យដោយគណៈកម្មាធិការបក្ស រដ្ឋអំណាច និងរណសិរ្សខេត្ត-ក្រុង រៀបចំអង្គមិទ្ទីង ។

***ខ្លឹមសារអង្គមិទ្ទីង គួរយកចិត្តទុកដាក់បញ្ជាក់ ៖***

◆ សោកនាដកម្ម៣ឆ្នាំ ៨ខែ និង២០ថ្ងៃ ដែលយើងបានឆ្លងកាត់ដោយផ្ទាល់ ។ ត្រូវសញ្ជឹងគិតហើយរំឭកដល់ឪពុកម្តាយ យាយតា ប្រពន្ធប្តី កូនចៅ ក្រុមគ្រួសារញាតិមិត្ត និងប្រជាជនរួមឈាមរបស់យើងជាងបីលាននាក់ដែលបានរងទុក្ខ រងទារុណកម្ម បាត់បង់ជីវិតយ៉ាងខ្លោចផ្សារដោយសារស្នាដៃដ៏ឧក្រិដ្ឋកម្មព្រៃផ្សៃនៃរបបពេជ្ឈឃាតប្រល័យពូជសាសន៍ប៉ុលពត ។

◆ សភាពការណ៍និងភារកិច្ចចំពោះមុខត្រូវប្រមូលផ្តុំនិងប្រើប្រាស់កម្លាំងសរុបដើម្បីសម្រេចខាងតែបាននូវការងារសំខាន់ៗគឺៈ

ក) ទប់ស្កាត់ឧបាយកលខ្មាំងនិងកម្លាំងអមិត្ត សំខាន់គឺទប់ស្កាត់ឧបាយកលដែលគេចង់រំលាយរដ្ឋអំណាច និងកម្លាំងប្រដាប់អាវុធយើង តាមរយៈដំណោះស្រាយនយោបាយដោយតស៊ូដាច់ខាតរក្សាងដែលស្ថានភាពខាងយោធានិងនយោបាយ ទោះក្នុងកាលៈទេសៈណាក៏ដោយ ។

ខ) ប្រមូលផ្តុំការងារសំខាន់ៗដែលកំណត់ចេញដោយសន្និបាតមជ្ឈិមបក្សលើកទី១២ និងខ្លឹមសារសម័យប្រជុំវិសាមញ្ញរបស់រដ្ឋសភា និងគោលការណ៍ថ្មីៗរបស់មជ្ឈិមណែនាំ ដោយពាក់ព័ន្ធនិងសភាពការណ៍ជាក់ស្តែងតាមមូលដ្ឋាននិងលើកឡើងនូវភារកិច្ចចំពោះមុខរបស់មូលដ្ឋាននីមួយៗ ជាអាទិ៍ការងារវាយបកខ្មាំង ការងារពង្រឹងសតិអារម្មណ៍ឲ្យបានរឹងមាំ ការកសាងកម្លាំងគ្រប់ផ្នែក ដើម្បីមានលទ្ធភាពនិងលក្ខណៈសម្បត្តិរ៉ាប់រងភារកិច្ចក្នុងសភាពការណ៍ថ្មី ការស្តារកសាងសេដ្ឋកិច្ចបម្រើការប្រយុទ្ធនិងដោះស្រាយជីវភាពសង្គម ការតស៊ូ ការទូត លើលក្ខការណ៍របស់យើង ដើម្បីរក្សាសមិទ្ធផលសង្គមជាតិអធិបតេយ្យជាតិនិងសិទ្ធិស្វ័យសម្រេចរបស់ប្រជាជន ទប់ស្កាត់ការវិលត្រឡប់មកវិញនៃរបបប្រល័យពូជសាសន៍ប៉ុលពត ។

ក្នុងការចាត់តាំងមិទ្ទីង បណ្តាខេត្ត-ក្រុង គប្បីយកចិត្តទុកដាក់រៀបចំនៅកន្លែងដែលខ្មាំងធ្លាប់បង្កវិនាសកម្មនៅតាមវត្តអារាម

មន្ទីរពេទ្យ សាលារៀន ។ល ។ ក្រោយមិទ្ទីងត្រូវមានកម្មវិធីគោរពវិញ្ញាណក្ខន្ធ បង្សុកូលនៅតាមស្តូបឬវិមានដែលបណ្តាមូលដ្ឋានបានរៀបចំរួចហើយ ។

ក្នុងមិទ្ទីងមហាជន ទាំងនៅមជ្ឈិម តាំងនៅខេត្ត-ក្រុង ត្រូវមានបដាពាក្យស្លោកប៉ង់កាតដែលមានខ្លឹមសារបកអាក្រាតថ្កោលទោសឧក្រិដ្ឋកម្មរបស់បនប៉ុលពត អៀងសារី, ខៀវ សំផន មកលើមាតុភូមិនិងប្រជាជនក្នុងអំឡុង៣ឆ្នាំ ៨ខែ ២០ថ្ងៃ និងឧក្រិដ្ឋកម្មថ្មីៗរបស់មេក្លោងសម្ព័ន្ធភាពប្រល័យពូជសាសន៍ ។

ក្រោយថ្ងៃងចប់សុន្ទកថានិងវិយោគកថា គួររៀបចំឲ្យមានតំណាងគ្រួសាររងគ្រោះឡើងសម្តែងកំហឹងឈឺចាប់ បកអាក្រាតថ្កោលទោសឧក្រិដ្ឋកម្មចាស់-ថ្មីរបស់បនប៉ុលពតនិងពួកខ្មែរប្រតិកិរិយា ។

រាល់សកម្មភាពសប្បាយផ្អុយនិងទិវានេះគួរផ្អាកពេញមួយថ្ងៃ ។

២) ចាប់ពីថ្ងៃទី១៥ដល់២៥ ឧសភា ក្រសួងមន្ទីរជុំវិញមជ្ឈិមរោងចក្រ សហគ្រាសសាលារៀន មន្ទីរពេទ្យ អង្គភាពកងកម្លាំងប្រដាប់អាវុធគ្រប់ភូមិ ឃុំ ស្រុកទូទាំងប្រទេសត្រូវចាត់តាំងការជួបសំណេះសំណាលអំពីឧក្រិដ្ឋកម្មឲ្យបានផុសផុល ខ្លឹមសារសំណេះសំណាលតាមខ្លឹមសារខាងលើ ។

ដោយឡែកក្រសួងឃោសនាការវប្បធម៌ត្រូវយកចិត្តទុកដាក់ៈ

◆ បោះពុម្ពអាហ៊ីសរូបភាពឧក្រិដ្ឋកម្មទាំងនោះដើម្បីចែកផ្សាយគ្រប់ខេត្ត-ក្រុងទូទាំងប្រទេស ។

◆ បំផុសការនិពន្ធបទភ្លេង ចម្រៀង ដែលមានលក្ខណៈលើកទឹកចិត្តក្នុងការតស៊ូជាមួយសម្ព័ន្ធភាពប្រល័យពូជសាសន៍ ។ ត្រូវមានផែនការណែនាំដាក់ស្តែងថែមទៀតដល់មន្ទីរឃោសនាការវប្បធម៌ដែលនៅក្រោមឱវាទដើម្បីដំណើរការចាត់តាំងទិវាចងកំហឹងនេះនៅមូលដ្ឋានឲ្យបានផុសផុល ព្រមទាំងបោសសម្អាតនិងកែលំអជួសជុលស្តូបឡើងវិញឲ្យបានសមរម្យ ។ កន្លែងដែលពុំទាន់មានស្តូបត្រូវប្រញាប់ប្រញាល់សាងសង់ដើម្បីជានិមិត្តរូប ព្រមទាំងរៀបចំឲ្យមានពិព័រណ៍ឧក្រិដ្ឋកម្មទាំងឧក្រិដ្ឋកម្មចាស់និងឧក្រិដ្ឋកម្មនៅកន្លែងប្រារព្ធពិធី ។

៣) រណសិរ្សត្រូវមានកម្មវិធីសំណេះសំណាលជាមួយព្រះសង្ឃ អាចារ្យ គណៈកម្មការវត្ត ចាស់ព្រឹទ្ធាចារ្យ បញ្ញវន្ត ជនជាតិនិងគ្រិស្តសាសនា នៅតាមវត្តអារាម វិហារ សូរ៉ាវ ថ្កោលទោសឧក្រិដ្ឋកម្មប៉ុលពត, អៀង សារី, ខៀវ សំផន និងបកអាក្រាតឧបាយ-កលថ្មីៗរបស់រដ្ឋាភិបាលចម្រុះត្រីភាគីឲ្យបានសមស្របតាមសំណូមពរខ្លឹមសារខាងលើ ព្រមទាំងបង្សុកូលឧទ្ទិសដល់វិញ្ញាណក្ខន្ធបងប្អូនស្លូតត្រង់ ដែលត្រូវពួកប្រល័យពូជសាសន៍ប៉ុលពតសម្លាប់យ៉ាងព្រៃផ្សៃ ។

៤) គ្រប់ថ្នាក់ គ្រប់ផ្នែក គ្រប់មូលដ្ឋាន ត្រូវចាត់តាំងការចុះសួរសុខទុក្ខដល់គ្រួសារយុទ្ធជនពលី ពិការ របួសនៅតាមមន្ទីរពេទ្យ អង្គភាពកម្លាំងប្រដាប់អាវុធ កុមារកំព្រា ។ល ។

៥) ក្រសួងការបរទេសត្រូវមានផែនការណែនាំដាក់ស្តែងដល់បណ្តាស្ថានទូតតំណាងរបស់យើងនៅបរទេស ចាត់តាំងទិវាចងកំហឹងនេះតាមខ្លឹមសារដូចពោលខាងលើ ។

៦) គណៈឃោសនាអប់រំមជ្ឈិមណែនាំឲ្យប្រព័ន្ធឃោសនាមានកម្មវិធីឃោសនាឲ្យបានសមស្របចាប់ពីថ្ងៃទី១៥ ដល់ថ្ងៃទី២៥ ឧសភា ១៩៩១ ដោយផ្អែកតាមសំណូមពរនិងខ្លឹមសារឃោសនាដែលបានលើកឡើងខាងលើ ដោយគួបផ្សំនឹងទិសដៅភារកិច្ចចំពោះមុខរបស់គណៈឃោសនាអប់រំមជ្ឈិម ។

៧) គណៈកម្មាធិការបក្ស គណៈកម្មាធិការប្រជាជន ត្រូវប្រមូលផ្តុំជុំវិញអនុវត្តការងារសំខាន់ៗ ដោយធ្វើសកម្មភាពបំផុសស្របទៅតាមពេលវេលា និងទិដ្ឋភាពជាក់ស្តែងរបស់មូលដ្ឋាននីមួយៗ ។ ត្រូវយកចិត្តដាក់ជាពិសេសណែនាំបំពាក់បំប៉នដល់រណសិរ្សនិងអង្គការមហាជនមូលដ្ឋាន ដើម្បីឲ្យអង្គការទាំងនេះបំពេញភារកិច្ចឃោសនាអប់រំ បំផុសមានប្រសិទ្ធភាពខ្ពស់នៅតាមមូលដ្ឋាន

របស់ខ្លួន ។

ក្រុមប្រឹក្សាជាតិរណសិរ្សសង្ឃឹមនិងជឿជាក់លើស្មារតីរួមសាមគ្គីអនុវត្តរបស់គ្រប់ផ្នែក គ្រប់ថ្នាក់ គ្រប់មូលដ្ឋានឲ្យបានសម្រេចជោគជ័យតាមផែនការណែនាំនេះ ហើយត្រូវផ្ញើរបាយការណ៍បូកសរុបលទ្ធផល ទៅក្រុមប្រឹក្សាជាតិរណសិរ្សឲ្យបានមុនថ្ងៃ៣០ ខែឧសភា ១៩៩១ ដើម្បីបូកសរុបរាយការណ៍ជូនគណៈលេខាមជ្ឈិមបក្ស ។

**ពាក្យស្លោក :**

១) ជានិច្ចកាលចងកំហឹងនិងថ្កោលទោសយ៉ាងខ្លាំងក្លាចំពោះបនប្រល័យពូជសាសន៍ប៉ុលពត, អៀង សារី, ខៀវ សំផន និងជនដែលកំពុងជួយជ្រោមជ្រែងពួកវា ។

២) ដាច់ខាតប្រជាជនកម្ពុជាមិនអនុញ្ញាតឲ្យរបបប្រល័យពូជសាសន៍កើតឡើងជាថ្មីនៅលើទឹកដីកម្ពុជា ទោះបីក្នុងរូបភាពណាក៏ដោយ ។

៣) ប្តេជ្ញាប្រែក្លាយកំហឹងឈឺចាប់ឲ្យទៅជាសកម្មភាពជាក់ស្តែងក្នុងការងារកសាងពង្រឹងភូមិ-ឃុំរឹងមាំ កសាងកម្លាំងប្រដាប់អាវុធបង្កើនការវាយខ្លាំង ការពារអាយុជីវិតរបស់នៅដ៏សុខសាន្តរបស់ប្រជាជន ។

◆ អ្វីៗទាំងអស់ដើម្បីសមរភូមិប្រយុទ្ធ

◆ អ្វីៗទាំងអស់ដើម្បីឯករាជ្យរបស់មាតុភូមិនិងសុភមង្គលប្រជាជន

៤) ជយោ បក្សប្រជាជនបដិវត្តកម្ពុជា

◆ ជយោរដ្ឋកម្ពុជា

◆ ជយោចំណងសាមគ្គីភាព មិត្តភាពកម្ពុជា វៀតណាម ឡាវ សហភាពសូវៀត និងបណ្តាប្រទេសជាមិត្ត ជាបងប្អូនស្ថិតស្ថេរចីរកាល ។

**ចម្លងជូន :** ខុទ្ទកាល័យមជ្ឈិមបក្ស, ខុទ្ទកាល័យរដ្ឋសភា, ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋ, ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី, គណៈចាត់តាំងមជ្ឈិម, គណៈឃោសនាការអប់រំមជ្ឈិម "ដើម្បីជូនជ្រាប", គ្រប់ស្ថាប័នបក្ស រដ្ឋ អង្គការមហាជនជុំវិញមជ្ឈិមខេត្ត-ក្រុង, សមាជិកក្រុមប្រឹក្សាជាតិរណសិរ្ស, នាយកដ្ឋាន ការិយាល័យក្រោមឱវាទ "ដើម្បីសហការអនុវត្ត", ឯកសារ ។

**ជ.ក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីកសាងការពារមាតុភូមិកម្ពុជា**

**ប្រធាន**

**ជា ស៊ីម**


ប៉ុល ពត (ស្លាប់ឆ្នាំ១៩៩៨)


នួន ជា


អៀង សារី


ខៀវ សំផន

# រឿងរ៉ាវដែលមិនចេះសាបសូន្យ

## ស៊ុម ស្រស់



ស៊ុម ស្រស់ មុនឆ្នាំ១៩៧៥

*ស៊ុម ស្រស់ អាយុ ៧៣ឆ្នាំ រស់នៅខ័ណ្ឌដង្កោ រាជធានីភ្នំពេញ ។ បងប្អូនរបស់គាត់៥នាក់បានស្លាប់អស់ទៅហើយ ក្នុងនោះពីរនាក់ស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយបីនាក់ទៀតស្លាប់នៅក្នុងរបបក្រោយនេះ ។ ស្រស់ រំឭកឡើងវិញអំពីរឿងរ៉ាវរបស់គាត់និងអំពីរូបថតដែលគាត់បានរក្សាទុក ៖*

ខ្ញុំបួសរៀននៅវត្តកំពង់គុលតាំងពីខ្ញុំអាយុ១២ឆ្នាំ ។ ខ្ញុំបួសបានតែមួយវស្សាក៏សឹក ។ ពេលនោះខ្ញុំអានសាស្ត្រាដាច់ខ្លះៗដែរ ។ នៅអាយុ២២ឆ្នាំខ្ញុំរៀបការ ប្រពន្ធខ្ញុំឈ្មោះ ដឹម ផុន ។ មុនពេលរៀបការយើងរស់នៅភូមិជិតគ្នា ។ ប្រពន្ធខ្ញុំរស់នៅខាងជើងវត្តកំពង់គុល ខ្ញុំនៅខាងត្បូងវត្ត ។ ឪពុកម្តាយខ្ញុំឃើញប្រពន្ធខ្ញុំហើយក៏ដណ្តឹងឲ្យខ្ញុំ ។ កាលពីដើមការរៀបចំគូស្រករគឺអាស្រ័យលើឪពុកម្តាយទាំងស្រុង ។ យើងជាកូនចាំតែយល់ព្រមតាមគាត់ប៉ុណ្ណោះ ។ ពេលរៀបការរួចថ្មីៗខ្ញុំរស់នៅជាមួយឪពុកម្តាយ ក្រោយមកទើបបែកផ្ទះពីគាត់ ។ ខ្ញុំមានកូន៨នាក់សុទ្ធតែបានរស់ឆ្លងផុតពីជំនាន់ប៉ុលពតទាំងអស់ ។

នៅជំនាន់លន់នល់ ខ្ញុំបានឡើងធ្វើជាប្រធានភូមិ៥០ខ្នង ។ ខ្ញុំមានកូនទាហាន១២នាក់សម្រាប់ដើរល្បាតជុំវិញភូមិ ។

ក្នុងឆ្នាំ១៩៧៣ ដោយខ្មែរក្រហមអុកឡុកក្នុងភូមិខ្លាំងពេក អ្នកភូមិខ្លះរត់ទៅនៅវត្តឫស្សីសាញ់ ខ្លះរត់ទៅស្ទឹងមានជ័យ ខ្លះទៀតរត់ទៅនៅទួលពង្រ ។ ដោយសារខ្ញុំមានកូនច្រើន ខ្ញុំសុខចិត្តយកអង្ករបាយទន់ទៅដូរយកអង្ករបាយរឹងដើម្បីឲ្យបានចំនួនច្រើន ។ ខ្ញុំនាំកូនរត់ទៅស្នាក់នៅវត្តឫស្សីសាញ់ ។ ខ្ញុំសង់រោងមួយនៅមុខវត្តស្នាក់នៅបណ្តោះអាសន្នហើយធ្វើស្រែនៅទីនោះ ។ ខ្ញុំឆ្លៀតពេលស៊ីឈ្នួលធ្វើម្ហូបការ គឺធ្វើជាកូនកាំបិត ។

ឆ្នាំ១៩៧៥ ខ្មែរក្រហមជម្លៀសខ្ញុំទៅឃុំកន្ទោក ស្រុកកណ្តាលស្ទឹង ។ ចំណែកបងប្អូនខ្ញុំត្រូវខ្មែរក្រហមបញ្ជូនទៅខេត្តបាត់ដំបងអស់ នៅសល់តែខ្ញុំពីរគ្រួសារ ។ នៅពេលជម្លៀសចេញ ខ្ញុំគ្មានបានយកខោអាវទាហានចេញទៅជាមួយទេ ។ ខ្ញុំកប់វាចោលជាមួយនឹងកាំភ្លើងនៅក្នុងវត្តឫស្សីសាញ់ ។

នៅឃុំកន្ទោក ខ្មែរក្រហមបានសួរប្រវត្តិរូបខ្ញុំជារៀងរាល់ខែ ។ ខ្ញុំឆ្លើយថាខ្ញុំធ្វើស្រែ លីបាវ និងរែកទឹកលក់ ។ ខ្ញុំលាក់មិនឲ្យខ្មែរក្រហមដឹងថាខ្ញុំធ្លាប់ធ្វើជាមេ៥០ខ្នងឬជាទាហានទេ ។ នៅឆ្នាំ១៩៧៧ ខ្ញុំបាននិយាយត្រង់ថាខ្ញុំធ្លាប់ធ្វើជាទាហាន ។

ខ្ញុំមិនបានរស់នៅជួបជុំប្រពន្ធកូនទេ ។ ខ្មែរក្រហមចាត់តាំងខ្ញុំទៅអារឈើនៅវត្តទឹកថ្លា វត្តព្រៃរោង និងវត្តចំការស្តេចផ្លាស់ប្តូរគ្នារហូត ។ កូនស្រីច្បងធ្វើអង្ករនៅសង្កែ ។ កូនស្រីខ្ញុំម្នាក់ទៀត ត្រូវអង្គការឲ្យចូលក្នុងកងចល័តនារី ។ កូនខ្ញុំដែលវ័យជំទង់ៗត្រូវខ្មែរក្រហមឲ្យឃ្វាលគោនៅក្នុងកងចល័តជំទង់ ។ យើងមានពេលជួបគ្នាតិចបំផុត ។

ចាប់ពីឆ្នាំ១៩៧៧មក ខ្ញុំអារឈើនៅវត្តព្រៃរោង ។ យើងរស់នៅលាយគ្នាជាមួយប្រជាជនមូលដ្ឋាន ។ ប្រជាជនមូលដ្ឋានរាប់អានយើងដែរ ប៉ុន្តែយើងមិនសូវមានសិទ្ធិដូចប្រជាជនមូលដ្ឋានទេ ។ ពេលខ្លះខ្ញុំដឹងថាមានមនុស្សបាត់ពីភូមិ ក៏ប៉ុន្តែខ្ញុំមិនហ៊ានមាត់កឬសួរនាំទេ ។

ពេលមួយ ឈើបាក់ធ្លាក់លើខ្នងខ្ញុំបណ្តាលឲ្យរបួសទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យអស់រយៈពេល២៨ថ្ងៃ ។ ខ្ញុំសម្គាល់ឃើញអ្នកជំងឺដែលសម្រាកនៅគ្រែជិតខ្ញុំចេះតែបាត់ខ្លួនជាបន្ត-បន្ទាប់ ។ ពេលខ្ញុំសួរគ្រូពេទ្យឆ្លើយថាគាត់ចេញទៅធ្វើការអស់ហើយ ។ ក្រោយមក មេក្រុមរបស់ខ្ញុំបានហៅខ្ញុំមកឱ្យប្រញាប់ចេញពីពេទ្យ ព្រោះអ្នកដែលបាត់ខ្លួននោះសុទ្ធតែត្រូវ

ខ្មែរក្រហមយកទៅសម្លាប់ មិនមែនចេញទៅធ្វើការទេ ។

### អំពីរូបថត



សៀង មុនឆ្នាំ១៩៧៥

នេះគឺជារូបថតរបស់ សៀង ធ្លាប់ធ្វើជាងឈើជាមួយខ្ញុំ ។ ខ្ញុំមិនដឹងអំពីប្រវត្តិរបស់គាត់ទេ ព្រោះខ្ញុំនិងគាត់ទើបតែស្គាល់គ្នានៅពេលមកធ្វើផ្ទះជាមួយគ្នា ។ ខ្ញុំមិនដឹងថារូបនេះថតនៅពេលណាទេហើយក៏មិនដឹងថារូបនេះមកនៅនឹងខ្ញុំដោយរបៀបណាដែរ ។ រូបថតនេះនៅនឹងខ្ញុំតាំងជំនាន់ប៉ុលពតម្ល៉េះ ។ កូនស្រីខ្ញុំឈ្មោះ ចំរើន លាក់រូបថតនេះទុក ។

រូបថតមួយសន្លឹកទៀតខ្ញុំថតយូរហើយ តាំងពីអំឡុងឆ្នាំ១៩៥០ ។ ខ្ញុំថតដើម្បីបិទកាត ហើយរូបថតនេះខ្ញុំបកពីកាតមកវិញ ។ កាលនោះខ្ញុំមានកាតទាហាន កាតពេទ្យ និងកាត ៥ផ្នត់ ។ ខ្ញុំមិនចាំថាកាលនោះខ្ញុំអាយុប៉ុន្មានទេ ។ ខ្ញុំថតនៅហាងថតរូបមួយនៅថ្នល់បត់ ខ្ញុំភ្លេចឈ្មោះហាងនោះបាត់ទៅហើយ ។ កាលនោះមិនសម្បូរហាងថតរូបដូចឥឡូវទេ មានតែមួយឬពីរប៉ុណ្ណោះ ។ ខ្ញុំថតរូបបីបួនសន្លឹក ក្នុងមួយសន្លឹកតម្លៃប្រហែល៥ឬ៦រៀល ។



ក្មួយរបស់ ស៊ុម ស្រស់ មុនឆ្នាំ១៩៧៥

នេះជារូបថតក្មួយរបស់ខ្ញុំ ថតនៅជំនាន់លន់នល់ ។ ខ្ញុំមិនដឹងអំពីប្រវត្តិក្មួយម្នាក់នេះច្បាស់លាស់ទេ ខ្ញុំគ្រាន់តែដឹងថាវាធ្លាប់ធ្វើទាហាននៅខាងត្បូងវត្តកំពង់គុល ។ ក្មួយខ្ញុំមានប្រពន្ធហើយស្លាប់នៅជំនាន់ប៉ុលពតទាំងអស់គ្នា ។ គ្រួសារវាត្រូវខ្មែរក្រហមយកទៅសម្លាប់ចោលអស់មួយពូជ ។

រូបថតដែលខ្ញុំដុតចោលគឺជារូបថតបិទកាត ។ ខ្ញុំដុតចោលដោយសារខ្លាចខ្មែរក្រហមឆែកឃើញ ។ ខ្មែរក្រហមឡើងឆែក-ឆេរពេលខ្ញុំទៅធ្វើការឆ្ងាយពីផ្ទះ ។ ពេលខ្ញុំត្រឡប់មកពីធ្វើការវិញឃើញបាត់របស់របរពីក្នុងផ្ទះ យើងគ្មានហ៊ាននិយាយទេនោះជាបាត់របស់អ្វីក៏ដោយ ។

រូបថតទាំងអស់នេះរំឭកខ្ញុំអំពីជីវិតយុវវ័យ និងអំពីសាច់ញាតិនិងមិត្តភក្តិរបស់ខ្ញុំ ។ ◆◆◆

## ឡៅ ឆេងស៊ិន

## អតីតអ្នកបច្ចេកទេសពេទ្យនៅមន្ទីរពិសោធន៍

ក្នុងឱកាសបុណ្យភ្ជុំបិណ្ឌនាឆ្នាំ១៩៥៨ ឪពុកម្តាយ បងប្អូននិងពូមីងរបស់ ឡៅ ស៊ិនថារ៉េត បានជួបជុំគ្នាថតរូបជាគ្រួសារនៅស្រុកកំណើត នៅភូមិព្រែកបាឡាត់ឆីង ឃុំត្រើយស្លា ស្រុកស្អាង ខេត្តកណ្តាល ។ រូបថតពីរសន្លឹកដែលថតនៅពេលនោះបានស្ថិតនៅគង់វង្សរហូតដល់សព្វថ្ងៃ និងបានលាតត្រដាងរឿងរ៉ាវគ្រួសាររបស់ ស៊ិនថារ៉េត ៖

រូបថតទីមួយគឺរូបថតរបស់ឪពុកម្តាយនិងបងប្អូនបង្កើតខ្ញុំ ។ រូបនេះថតពេលដែលខ្ញុំអាយុប្រហែល១០ឆ្នាំ ។ ខ្ញុំមានបងប្អូន៦នាក់ ។ ពេលដែលយើងថតរូបនេះប្អូនពៅរបស់ខ្ញុំពីរនាក់មិនទាន់កើតនៅឡើយ ទើបក្នុងរូបថតមានតែ៤នាក់ ។ បងប្រុសច្បងបង្អស់ឈ្មោះ ឡៅ ស៊ិតថារ៉ា អង្គុយនៅខាងស្តាំបំផុត ។ កាលនោះគាត់មានអាយុ១២ឬ១៣ឆ្នាំ ។ ឈរជាប់នឹងបងប្រុសខ្ញុំគឺឪពុកខ្ញុំឈ្មោះ ឡៅ ឆេងស៊ិន ។ រូបឈរនៅកណ្តាលគឺប្អូនស្រីខ្ញុំឈ្មោះ ឡៅ សារ៉េតធី ។ ប្អូនប្រុសបន្ទាប់ឈ្មោះ ឡៅ ស៊ីសុផល អង្គុយនៅលើម្តាយខ្ញុំ ចំណែកខ្ញុំ ឡៅ ស៊ិនថារ៉េត នៅខាងឆ្វេងបំផុត ។ បងប្រុសច្បង ស៊ិតថារ៉ា បានបាត់ខ្លួននៅក្នុងជំនាន់ ប៉ុល ពត ។ ខ្ញុំមិនប្រាកដថាគាត់ស្លាប់ឬរស់ទេ ប៉ុន្តែតាំងពីគាត់ទៅបាត់មិនឃើញត្រឡប់មកវិញ ខ្ញុំសន្មតថាគាត់ស្លាប់បាត់ទៅហើយ ។

រូបថតមួយសន្លឹកទៀតជារូបថតក្រុមគ្រួសារជីតាខាងឪពុកខ្ញុំ ។ រូបនេះក៏ថតមិនបានជុំគ្នាកូនគាត់ទាំងអស់ដែរ គឺនៅខ្វះកូនប្រុសម្នាក់ឈ្មោះ ឡៅ សុង ។ ជីតាខ្ញុំឈ្មោះ ហេង ឡៅ អង្គុយនៅលើ

កៅអី ។ កូនស្រីច្បងរបស់គាត់ឈ្មោះ ឡៅ យុន ឈរនៅខាងស្តាំជាប់លោកតា (នៅរស់) ។ កូនបន្ទាប់គឺ ឡៅ ឃិន ឈរខាងស្តាំបន្ទាប់ពី ឡៅ យុន ។ បន្ទាប់មកទៀត ឡៅ ហួន ឈរខាងឆ្វេងជាប់លោកតា (ស្លាប់នៅក្នុងរបបប៉ុលពត) ។ ទីបួនគឺឪពុកខ្ញុំ ឡៅ ឆេង ។ កូនទីប្រាំ ឡៅ សុន ឈរនៅខាងស្តាំបំផុត និងកូនពៅ ឡៅ យ៉ុង ឈរនៅខាងឆ្វេងបង្អស់ (នៅរស់) ។

រូបថតទាំងពីរសន្លឹកនេះថតនៅកន្លែងតែមួយ ថ្ងៃតែមួយ គឺនៅឆ្នាំ១៩៥៨ គឺនៅភូមិព្រែកបាឡាត់ឆឹង ឃុំត្រើយស្លា ស្រុកស្អាង ខេត្តកណ្តាល ដែលជាស្រុកកំណើតរបស់ឪពុកខ្ញុំ ។ កាលណោះគឺក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ ឪពុកខ្ញុំបានទៅលេងស្រុកកំណើតជួបជុំបងប្អូន ។ គាត់បានយកម៉ាស៊ីនថតរូបទៅជាមួយ យើងក៏បានថតរូបជុំគ្នានៅមុខផ្ទះរបស់អ៊ំប្រុសខ្ញុំ ឡៅ យុន ។

អ៊ំប្រុសខ្ញុំឈ្មោះ ឡៅ សុងមិនបានទេព្រោះគាត់ ជាទាហានដែលត្រូវផ្លាស់ទៅធ្វើការនៅខេត្តផ្សេងៗ ។ ក្នុងឱកាសបុណ្យទានគាត់មិនដែលបានមកលេងជួបជុំបងប្អូនទេ ។

កាលពីនៅក្មេង ឪពុកខ្ញុំរៀននៅស្រុកស្អាងបានត្រឹមថ្នាក់ទី៧ ក៏ផ្លាស់មករៀននៅភ្នំពេញដោយស្នាក់នៅជាមួយម្តាយមីង ។ គាត់ទទួលវិញ្ញាបនប័ត្របញ្ចប់ការសិក្សា ហើយបានប្រឡងចូលរៀនពេទ្យមធ្យម ។ រៀនពេទ្យបានរយៈពេលបីឆ្នាំ ឪពុកខ្ញុំប្តូរទៅរៀនខាងផ្នែកពិសោធន៍អស់រយៈពេលមួយឆ្នាំទៀត ។ បន្ទាប់ពីរៀនចប់ ឪពុកខ្ញុំបានចូលបម្រើការងារជាអ្នកបច្ចេកទេសមន្ទីរពិសោធន៍នៅមន្ទីរពេទ្យ (បច្ចុប្បន្នជាមជ្ឈមណ្ឌលគាំពារមាតា និងទារក) ។

ឪពុកខ្ញុំរៀបការតាំងពីគាត់ទើបចូលរៀនសាលាពេទ្យឆ្នាំទីមួយ ។ ម្តាយធំខ្ញុំជាអ្នកណែនាំឪពុកខ្ញុំឲ្យស្គាល់ម្តាយខ្ញុំ ។ ម្តាយធំខ្ញុំរកស៊ីលក់សំពត់ព្រែ (ជាសំពត់សាច់សូត្រសុទ្ធនាំចូលពីប្រទេសចិន ស្ត្រីពីដំនាន់មុនចូលចិត្តស្លៀកសំពត់នេះ) ។ គាត់ទៅលក់ដល់ស្រុកកំណើតរបស់ម្តាយខ្ញុំនៅឃុំតាំងដូង ស្រុកបាទី ខេត្តតាកែវ ក៏បានឃើញម្តាយខ្ញុំហើយស្រលាញ់ពេញចិត្ត ។ គាត់ក៏នាំឪពុកខ្ញុំទៅមើលម្តាយខ្ញុំរួចស្តីដណ្តឹងរៀបការ ។



ឡៅ ឆេងស៊ិន ជាមួយប្រពន្ធកូន ក្នុងឆ្នាំ១៩៥៨ នៅភូមិបាឡាត់ឆឹង ឃុំត្រើយស្លា ស្រុកស្អាង ខេត្តកណ្តាល

ក្រោយពេលរៀបការរួច ឪពុកខ្ញុំផ្លាស់ចេញពីផ្ទះម្ដាយមីង របស់គាត់មកសរស់នៅជិតវត្តស្វាយពពែ ។ ក្រោយមក រដ្ឋាភិបាល ដេញប្រជាជនចេញពីកន្លែងនោះសំអាងថាយកទីតាំងនោះធ្វើជា សំណង់សាធារណៈ ឪពុកខ្ញុំផ្លាស់ផ្ទះទៅនៅជិតរោងកុនច្បារអំពៅ ។

ជីវភាពគ្រួសារខ្ញុំកាលនោះល្អបង្គួរដែរ ព្រោះយើងមាន លទ្ធភាពទិញរថយន្តជិះ ។ ប្រាក់ខែរបស់ឪពុកខ្ញុំគឺពី៦ពាន់ទៅ ៧ពាន់រៀល ហើយគាត់ឆ្លៀតធ្វើការឲ្យគ្លីនិកឯកជននៅក្រៅ ម៉ោងធ្វើការទៀត ។ ដោយយើងមានជីវភាពធូរធារ ឪពុកខ្ញុំបាន យកបងប្អូននិងក្មួយពីរនាក់មករស់នៅជាមួយ សូម្បីតែជីតាខ្ញុំក៏ មកនៅភ្នំពេញជាមួយយើងដែរ ។

ឪពុកខ្ញុំមិនមែនជាមនុស្សកាចទេ ប៉ុន្តែក៏មិនស្លូតដែរ ។ គាត់ គឺធ្ងន់ធ្ងរចំពោះកូន ប៉ុន្តែមិនធ្វើឲ្យកូនខ្លាចដល់ថ្នាក់មិនហ៊ាននិយាយ លេងជាមួយគាត់នោះទេ ។

ខ្ញុំនៅរៀននៅសាលាបឋមសិក្សាចៅពញាហុកនិងវិទ្យាល័យ ព្រះយុគន្ធរ ។ នៅឆ្នាំ១៩៧០ខ្ញុំប្រឡងជាប់បាក់ឌុប និងចូលរៀន នៅមហាវិទ្យាល័យពេទ្យ ។ សាលាពេទ្យជំនាន់នោះជាសាលាធំ ដែលមានសិស្សពីបរទេស ដូចជា ឡាវ បារាំង ជាដើម មករៀន ។ បារាំងជាអ្នកគ្រប់គ្រងសាលានេះ ហើយសញ្ញាប័ត្រចេញពី សាលានេះត្រូវបានបារាំងទទួលស្គាល់ ។

នៅជំនាន់ខ្ញុំរៀន ខ្ញុំចូលរៀននៅវិទ្យាល័យដោយពុំចាំបាច់ ត្រូវប្រលងប្រជែងយកវិញ្ញាបនប័ត្រទេ ។ ក្រោយពេលប្រឡង ជាប់បាក់ឌុបហើយ យើងអាចជ្រើសរើសចូលរៀននៅមហា វិទ្យាល័យមួយណាក៏បានដោយមិនចាំបាច់ប្រឡងចូលម្ដងទៀត ព្រោះមិនសូវមានបេក្ខជនប្រឡងជាប់បាក់ឌុបច្រើនប៉ុន្មានទេ ។

បងប្រុសខ្ញុំ ស៊ុតថារ៉ា អាយុច្រើនជាងខ្ញុំពីរឆ្នាំ ។ គាត់ រៀនខាងគ្រូបង្រៀនបន្ទាប់ពីប្រឡងជាប់បាក់អង់នៅវិទ្យាល័យ ព្រះស៊ីសុវត្ថិ ។

ខ្មែរក្រហមចាប់ផ្ដើមអុកឡុកស្រុកភូមិខ្ញុំនៅចុងទសវត្សរ៍ឆ្នាំ ១៩៦០ ។ យើងលែងហ៊ានធ្វើដំណើរតាមផ្លូវជាតិនៅពេលយប់ ទៀតហើយ ព្រោះខ្លាចខ្មែរក្រហមស្ទាក់តាមផ្លូវ ។ តាមខ្ញុំនៅចាំ បាន ស្រុកស្អាងជាស្រុកដំបូងដែលខ្មែរក្រហមចាត់ទុកជាតំបន់ រំដោះ ។ ក្រុមគ្រួសារខ្ញុំក៏ដាច់ទំនាក់ទំនងជាមួយបងប្អូននៅស្រុក ស្អាងដែរ ។ បងប្អូនដែលធ្លាប់ចុះឡើងភ្នំពេញក៏លែងបានមក ។ យូរៗទើបខ្ញុំឃើញបងប្អូនខ្ញុំមកលេងម្ដង ។

ខ្ញុំរៀនពេទ្យមិនទាន់ចប់ផងខ្មែរក្រហមរំដោះបានទីក្រុងភ្នំពេញ ហើយបានជម្លៀសយើងចេញទៅពីទីក្រុង ។ មុននេះមួយថ្ងៃ គឺ ថ្ងៃទី១៦ ខែមេសា ខ្ញុំ បងប្រុស និងប្អូនស្រីបន្ទាប់ខ្ញុំ បានបើក រថយន្តទៅលេងអ៊ំខាងម្ដាយខ្ញុំនៅតាខ្មៅ ។ ពេលនោះដោយមាន ការទម្លាក់គ្រាប់បែកផ្លូវត្រូវបិទ ។ អ៊ំខ្ញុំជាមេបញ្ជាការប៉េអឹមនៅ ខេត្តកណ្ដាល ។ ទាហានដែលស្គាល់អ៊ំខ្ញុំចេះតែបើកផ្លូវឲ្យខ្ញុំធ្វើដំណើរ ត្រឡប់មកវិញ ។ មកដល់ភ្នំពេញ ខ្ញុំមិនបានត្រឡប់ទៅផ្ទះ ខ្ញុំច្បារ អំពៅទេ តែខ្ញុំបែរជាទៅផ្ទះបងជីដូនមួយខ្ញុំនៅជិតពេទ្យចិន ។ យើងស្នាក់នៅផ្ទះគាត់ដោយមានខោអាវតែមួយចង្កេះជាប់ខ្លួន ។ រហូតដល់ខ្មែរក្រហមដេញយើងចេញពីភ្នំពេញ យើងធ្វើដំណើរ ជាមួយរថយន្តរបស់យើងទៅដល់ស្រុកស្អាង ហើយបានជួប ឪពុកម្ដាយខ្ញុំនៅទីនោះ ។ ខ្មែរក្រហមបានឃោសនាឲ្យយើងចាក ចេញពីទីក្រុងក្នុងរយៈពេលបីថ្ងៃ ដើម្បីគេចពីការទម្លាក់គ្រាប់បែក របស់អាមេរិកកាំង ។

យើងចេញពីភ្នំពេញដោយគ្មានបានយកឥវ៉ាន់ទៅជាមួយ ទាល់តែសោះ ។ សំណាងល្អ បងប្អូនខ្ញុំនៅស្រុកស្អាងដែលជា ប្រជាជនមូលដ្ឋាន បានចែកខោអាវនិងរបស់ប្រើប្រាស់មួយចំនួន ឲ្យគ្រួសារខ្ញុំ ។ យើងទៅស្នាក់នៅក្នុងខ្ទមតូចៗដែលសល់ពីប្រជាជន មូលដ្ឋាន ។ ពេលយើងទៅដល់ដំបូង អង្គការមិនឲ្យប្រជាជន មូលដ្ឋាននិយាយរកយើងឬក៏រស់នៅជិតយើងទេ ។ ក្រោយមក អង្គការបន្ធូរបន្តិច ដោយអនុញ្ញាតឲ្យយើងបានជជែកគ្នាជាមួយ ប្រជាជនមូលដ្ឋាន ។ រថយន្តដែលយើងយកទៅជាមួយនោះ ខ្ញុំទុកវាចោលនៅក្រោមដើមស្វាយសល់រហូតមកដល់សព្វថ្ងៃ ។ ឡាននោះនៅសល់តែគ្រោងឆ្អឹងទេព្រោះខ្មែរក្រហមបានដោះ យកសំបកកង់ធ្វើជាស្បែកជើង និងយកគ្រឿងម៉ាស៊ីនវាទៅ ប្រើប្រាស់អស់ហើយ ។

រយៈពេល៨ខែក្រោយមក អង្គការបានបញ្ជូនយើងទៅ បាត់ដំបងដោយប្រាប់យើងថា បាត់ដំបងជាកន្លែងសម្បូរស្រូវ អង្ករ ។ យើងជិះកាណូតពីស្អាងមកឡើងគោកព្រែកតូច បន្ទាប់មក ជិះរថយន្តបន្តទៅដល់ឃុំប្រទះឡាង (ក្នុងវ័ណ្ឌដង្កោ) រួចទើប

យើងបន្តដំណើរតាមរថភ្លើងទៅបាត់ដំបង ។ ទៅដល់បាត់ដំបង អង្គការឲ្យយើងរស់នៅក្នុងភូមិសំរោង ឃុំសំរោង ក្នុងស្រុកសង្កែ ស្ថិតនៅតាមបណ្តោយដងស្ទឹងសង្កែ ។ ប្រជាជននៅក្នុងភូមិនេះ មិនត្រូវបានជម្លៀសទៅទីណាទេ គឺរស់នៅទីនេះតាំងពីយូរមក ហើយភាគច្រើនជាអតីតជនផ្ញើស្រែ ដល់ពេលខ្មែរក្រហមកាន់កាប់ គ្រាន់តែចុះពីផ្ទះធំមកធ្វើខ្ទមនៅតែប៉ុណ្ណោះ ។ ប្រជាជនមួយចំនួន នៅស្លៀកសម្លៀកបំពាក់ចម្រុះពណ៌នៅឡើយ ។

យើងរស់នៅជួបជុំគ្នា ប៉ុន្តែធ្វើការបែកគ្នា ។ កាលណោះខ្ញុំនៅលីវ ប៉ុន្តែខ្ញុំប្រាប់អង្គការថាខ្ញុំមានប្រពន្ធហើយបានបែកគ្នា ម្ល៉ោះហើយអង្គការក៏ដាក់ខ្ញុំចូលក្នុងកងបុរសរៀបការរួច ។ យើងមានបាយហូបតែនៅរដូវច្រូតកាត់ប៉ុណ្ណោះ ក្រៅពីនោះហូបបបរ ។ ពេលនោះហើយដែលយើងឃើញមនុស្សស្លាប់ដោយខ្វះអាហារកាន់តែច្រើនឡើងៗ ។

ឪពុកម្តាយ ខ្ញុំធ្វើការងារនៅក្នុងកងមនុស្សចាស់ ។ ឪពុកខ្ញុំធ្វើត្បាល់ ម្តាយខ្ញុំកិនអង្ករ ។ បងប្រុសខ្ញុំឈ្មោះ ស៊ុតថាវ៉ា ធ្វើការក្នុងកងមនុស្សពេញកម្លាំង បងខ្ញុំបាត់ខ្លួននៅពេលដែលអង្គការផ្លាស់យើងចេញពីភូមិសំរោងទៅភូមិអណ្តូងត្រាច ។ អង្គការបានឲ្យគាត់ទៅធ្វើការនៅព្រៃនាម ។ គាត់លួចសមគំនិតគ្នាជាមួយអតីតទាហានលន់នល់ លាក់ស្បៀងសន្សំដើម្បីរកផ្លូវរត់ទៅប្រទេសថៃ ។ គាត់បាត់ខ្លួនរហូតចាប់តាំងពីពេលនោះមក បន្សល់ទុកប្រពន្ធនិងកូនពីរនាក់រស់នៅរហូតដល់សព្វថ្ងៃ ។

ពេលកងទ័ពវៀតណាមវាយចូលមក កម្មាភិបាលខ្មែរក្រហមបានរត់គេចចេញពីភូមិបាត់អស់ ។ ក្រោយពីកម្មាភិបាលខ្មែរក្រហមទៅបាត់មួយអាទិត្យ យើងក៏ចាកចេញពីភូមិអណ្តូងត្រាចធ្វើដំណើរសំដៅមកភូមិសំរោងវិញ ។ ឪពុកខ្ញុំបានដាក់ពាក្យសុំចូលធ្វើការនៅមន្ទីរពេទ្យខេត្តបាត់ដំបង ។ មិនបានប៉ុន្មានផង យើងបានសម្រេចចិត្តត្រឡប់មកភ្នំពេញវិញ ។ ខ្ញុំនិងប្អូនខ្ញុំដើរមកមុន ឪពុកម្តាយបងប្អូនខ្ញុំដទៃទៀតជិះឡានមកតាមក្រោយ ។

ក្រោយឆ្នាំ១៩៧៩ ខ្ញុំធ្វើការបណ្តើររៀនបណ្តើរ ។ ដំបូងខ្ញុំធ្វើការផ្នែកវះកាត់នៅមន្ទីរពេទ្យព្រះអង្គឌួង ក្រោយមកមន្ទីរពេទ្យបង្កើតផ្នែករោគស្ត្រី ខ្ញុំក៏ផ្លាស់ទៅធ្វើខាងផ្នែកវះកាត់សម្ភព ។

រូបថតដែលសល់មកដល់សព្វថ្ងៃនេះបានមកពីបងប្អូនខ្ញុំជាអ្នករក្សាទុក ។ កាលណោះពេលដែលឪពុកម្តាយខ្ញុំត្រូវខ្មែរក្រហមដេញចេញពីផ្ទះដុត សាច់ញាតិរបស់ខ្ញុំដែលត្រូវជម្លៀសកាត់តាមផ្ទះខ្ញុំ បានចូលទៅក្នុងផ្ទះហើយរើកកាយឥវ៉ាន់ក្នុងផ្ទះ ។ ពេលនោះប្រហែលជាគាត់ឃើញរូបថត ហើយក៏កាន់យកទៅជាមួយ ។

ពេលយើងមកដល់ភ្នំពេញវិញនៅឆ្នាំ១៩៧៩ បងប្អូនខ្ញុំយករូបថតគ្រួសារខ្ញុំនិងសញ្ញាប័ត្រឌីប្លូមរបស់ខ្ញុំមកប្រគល់ឲ្យខ្ញុំវិញ ។



ឡៅ ឆេងស៊ិន និងឪពុកព្រមទាំងបងប្អូនបង្កើត ក្នុងឆ្នាំ១៩៥៨ នៅភូមិបាឡាត់ឆឹង ឃុំត្រើយស្លា ស្រុកស្អាង ខេត្តកណ្តាល

ខ្ញុំសប្បាយចិត្តណាស់ពេលឃើញរូបថតខ្លួនឯងកាលពីនៅតូច ។ រូបថតនេះធ្វើឲ្យខ្ញុំនៅចងចាំអំពីក្រុមគ្រួសាររបស់ខ្ញុំ ។ ◆◆◆

## តាំង ហៃសង

## អតីតអ្នកបើករថយន្ត

តាំង ហៃសង គឺជាអតីតអ្នកបើករថយន្ត នៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០-៧០ ។ គាត់បាត់បង់ជីវិតនៅឆ្នាំ១៩៨៤ ដោយជំងឺចាស់ជរា ។ សោ យ៉ន ប្រពន្ធរបស់ ហៃ សង បច្ចុប្បន្នមាន

*អាយុ៧០ឆ្នាំ រស់នៅក្រុងព្រះសីហនុ បានបង្ហាញរូបថតមួយសន្លឹករបស់ ហៃសង ដែលថតនៅក្នុងសម័យសង្គមរាស្ត្រនិយម ។ នោះគឺជារូបថតតែមួយសន្លឹកគត់ដែល ហៃសង មាន ។*

*ខាងក្រោមនេះគឺជាការរៀបរាប់របស់ សោ យ៉ន ៖*

*ខ្ញុំមានស្រុកកំណើតនៅខេត្តមាត់ជ្រូក កម្ពុជាក្រោម ។ ខ្ញុំបានផ្លាស់មករស់នៅគីឡូម៉ែត្រលេខ៤ ទីក្រុងភ្នំពេញ តាំងពីខ្ញុំអាយុ១០ឆ្នាំ ដោយសារកាលណោះមានចម្បាំងរវាងវៀតណាម និងបារាំង ។ រាជរដ្ឋាភិបាលបានចែកដីធ្លីឲ្យក្រុមគ្រួសារខ្ញុំសង់ផ្ទះនៅ ។ ខ្ញុំមិនបានទៅសាលារៀនទេ ពីព្រោះឪពុកម្តាយខ្ញុំមិនឲ្យខ្ញុំទៅរៀន គាត់ខ្លាចខ្ញុំចេះសរសេរសំបុត្រឲ្យមនុស្សប្រុស ។*

*ប្តីរបស់ខ្ញុំជាកូនទី១ក្នុងចំណោមបងប្អូន៦នាក់ ។ គាត់គឺជាកូនកាត់ចិន រស់នៅខេត្តកំពង់ស្ពឺ ។ គាត់រៀនចេះអក្សរខ្មែរបន្តិចបន្តួច និងជួយលក់ដូរចាប់ហ៊ួយជាមួយឪពុកម្តាយរបស់គាត់ ។ គាត់មានសាច់ញាតិរស់នៅក្បែរផ្ទះរបស់ខ្ញុំ ។ សាច់ញាតិរបស់គាត់ពេញចិត្តខ្ញុំ ហើយទៅប្រាប់ប្តីខ្ញុំនិងឪពុកម្តាយរបស់គាត់ឲ្យមកមើល ។ ប្តីខ្ញុំចេះតែលបមើលខ្ញុំដោយខ្ញុំមិនដឹងខ្លួន ។ ចំណែកឪពុកម្តាយគាត់ចេះតែយករបស់របរមកផ្ទះរបស់ខ្ញុំ ។ ខ្ញុំមិនដែលបានឃើញមុខប្តីខ្ញុំទេ រហូតដល់ថ្ងៃរៀបការទើបខ្ញុំបានជួបមុខគាត់ ។*



តាំង ហៃសង
ក្នុងសម័យសង្គមរាស្ត្រនិយម

*ក្រោយពេលរៀបការហើយ យើងទៅធ្វើពិធីកាត់ចំណងដៃនៅផ្ទះរបស់គាត់ ហើយស្នាក់នៅទីនោះអស់រយៈពេល១ខែ ។ ដោយឪពុកម្តាយខ្ញុំនឹករឭកខ្ញុំពេក ម្យ៉ាងគាត់បារម្ភក្រែងបងប្អូនសាច់ថ្លៃធ្វើបាបខ្ញុំ គាត់ក៏ទៅតាមយកខ្ញុំនិងប្តីខ្ញុំពីខាងណោះមកវិញ ។ តាមពិត យើងអត់មានបញ្ហាអ្វីទេ សាច់ញាតិខាងប្តីខ្ញុំស្រលាញ់ខ្ញុំណាស់ ។*

*ឪពុកខ្ញុំឲ្យប្តីខ្ញុំរៀនបើកឡានដោយចំណាយលុយអស់៥០០រៀល ។ ក្រោយពេលចេះបើកឡានហើយ ប្តីខ្ញុំទៅស៊ីឈ្នួលបើកឡានដឹកជញ្ជូនគ្រឿងសំណង់ដូចជា ឥដ្ឋ ដែក ស៊ីម៉ង់ត៍ និងដីខ្សាច់ ។ ក្នុងមួយខែគាត់អាចរកប្រាក់ចំណូលបានពី១ពាន់ទៅ២ពាន់រៀល ដែលអាចផ្គត់ផ្គង់ជីវភាពគ្រួសារយើងបាន ។ ចំណែកខ្ញុំធ្វើកិច្ចការផ្ទះនិងថែរក្សាកូន ។*

*នៅមុនពេលខ្មែរជម្លៀស មានគ្រាប់ផ្លោងធ្លាក់ក្បែរផ្ទះរបស់ខ្ញុំបណ្តាលឲ្យស្លាប់មនុស្សជាច្រើន ។ ពេលខ្មែរក្រហមប្រកាសឲ្យប្រជាជនចេញពីទីក្រុងភ្នំពេញតែ៣ថ្ងៃ ក្រុមគ្រួសាររបស់ខ្ញុំជឿតាម ហើយរៀបចំម្ហូបអាហារនិងរបស់របរប្រើប្រាស់យកទៅតាមតែបន្តិចបន្តួចប៉ុណ្ណោះ ។ កូនៗរបស់ខ្ញុំចែកគ្នាកាន់របស់របរហូបចុក ខ្លះកាន់ឆ្នាំងបាយ ខ្លះយួរកាដុងទឹក ខ្លះស្ពាយបង្វេចខោអាវ ។ យើងធ្វើដំណើរដោយថ្មើរជើងឆ្ពោះទៅពោធិ៍ចិនតុង ។ រួមដំណើរជាមួយគ្នាពេលនោះមានឪពុកខ្ញុំ ប្តីរបស់ខ្ញុំ ព្រមទាំងខ្ញុំនិងកូន១១នាក់ ។ ម្តាយរបស់ខ្ញុំស្លាប់ដោយជំងឺនៅក្នុងរបបលន់នល់ ។ ខ្ញុំមានការពិបាកក្នុងការធ្វើដំណើរណាស់ ព្រោះខ្ញុំមានផ្ទៃពោះជិតគ្រប់ខែ ។ យើងសម្រាកនៅវត្តជម្ពូវ័ន្តមួយយប់ រួចបន្តដំណើរទៅដល់ផ្សារបាត់ដឹង (ភ្នំប្រសិទ្ធ) ។ អង្គការមានបំណងយកយើងទៅសម្លាប់ចោល ប៉ុន្តែខ្ញុំបានសុំអង្វរកុំឲ្យសម្លាប់ ព្រោះខ្ញុំមានផ្ទៃពោះនិងមានកូនច្រើននៅក្នុងបន្ទុកទៀត ។ បន្ទាប់ពីសម្រាកនៅបាត់ដឹងមួយយប់ទៀត អង្គការបញ្ជូនយើងតាមឡានទៅភូមិក្រាំងស្រម៉ ក្នុងឃុំស្វាយជុក ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ។*

*អង្គការបានសួរអំពីប្រវត្តិរូបក្រុមគ្រួសារខ្ញុំ ។ ខ្ញុំប្រាប់ថាប្តីរបស់ខ្ញុំជាអ្នកបើកឡាន ហើយខ្ញុំជាអ្នកលក់បន្លែនៅផ្សារថ្មី ។ ដូច្នេះ អង្គការក៏ចាត់តាំងឲ្យប្តីខ្ញុំទៅបើកឡានដឹកសម្ភារនៅផ្សារកំពង់ឆ្នាំង ដឹកត្រី និងដឹកយុវនារីទៅធ្វើការនៅការដ្ឋាន ។ រយៈពេលកន្លះខែ ឬ១ខែទើបគាត់បានមកផ្ទះម្តង ។*

*ស្នាក់នៅភូមិក្រាំងស្រម៉មិនបានប៉ុន្មានថ្ងៃផង ខ្ញុំប្រសូត្របានកូនប្រុសមួយ ។ ចាស់ៗនៅទីនោះជាអ្នកជួយបង្កើតកូនឲ្យខ្ញុំ ។ ប្តីខ្ញុំមិនបានមកមើលថែខ្ញុំទេ ព្រោះអង្គការមិនអនុញ្ញាត ។ ក្រោយពេលឆ្លងទន្លេហើយ អង្គការចាត់តាំងឲ្យខ្ញុំរែកទឹកពីស្ទឹងទៅស្រោចបន្លែឲ្យបាន៥០អម្រែកក្នុងមួយថ្ងៃ និងឲ្យខ្ញុំហូបតែទឹកបបរ ។ ដោយ*

ហូបមិនគ្រប់គ្រាន់ ខ្ញុំទៅបេះផ្កាស្នោយកមកលាយជាមួយបបរ ។ ខ្ញុំខំធ្វើការណាស់អត់ហ៊ានត្អូញត្អែរឲ្យប្រធានកងដឹងទេ ។

កាលណោះរបស់របរប្រើប្រាស់និងស្បៀងអាហារត្រូវដាក់រួមទាំងអស់ ។ ក្នុង១ពេលក្រុមគ្រួសារខ្ញុំទទួលបានអង្ករ ២ខាំ ។ យើងហូបមិនគ្រប់គ្រាន់ទេ ។ យើងយកអង្ករទៅដាំបបរហើយហូបសាប ។ សូម្បីតែអំបិលក៏យើងគ្មានដែរ ។ ពេលខ្លះយើងបេះផ្ទីមកលាយជាមួយបបរ មានរសជាតិឆ្ងាញ់ណាស់ ។ ខ្ញុំឃើញអ្នកភូមិលួចយករបស់របរពីរោងសហករណ៍យកមកហូប អង្គការដឹងក៏យកអ្នកទាំងនោះទៅសម្លាប់ចោលនៅក្នុងព្រៃ ។

អង្គការបែងចែកប្រជាជនចាស់និងប្រជាជនថ្មីឲ្យរស់នៅដាច់ដោយឡែកពីគ្នា ប៉ុន្តែឲ្យប្រជាជនចាស់មើលខុសត្រូវត្រួតត្រាប្រជាជនថ្មី ។ កូនៗរបស់ខ្ញុំបែកខ្ញែកទៅតាមកងចល័តផ្សេងៗពីគ្នា ។ កូនខ្លះនៅឆ្ងាយ កូនខ្លះនៅជិត ។ មានតែកូនតូច២នាក់ទេដែលរស់នៅជាមួយខ្ញុំ ។ យូរៗម្តង កូនខ្ញុំមកលេងនឹងខ្ញុំមួយព្រឹក ហើយត្រឡប់ទៅកងវិញ ។ ពេលខ្លះវាលួចរត់មក ខ្ញុំក៏បង្ខំវាឲ្យត្រឡប់ទៅវិញ ព្រោះខ្លាចប្រធានកងធ្វើទារុណកម្ម ។

ពេលខ្លះកូនអ្នកមូលដ្ឋានវាយកូនរបស់ខ្ញុំដោយសារវារត់មកផ្ទះ ។ ខ្ញុំខឹងខ្លាំងណាស់ ក៏ទៅវាយកូនអ្នកមូលដ្ឋានវិញ ។ ប្រធានកងមកស្តីបន្ទោសឲ្យខ្ញុំយ៉ាងខ្លាំង ។ ខ្ញុំអត់ខ្លាចទេ អង្គការបំបែកប្តីខ្ញុំឲ្យធ្វើការនៅកន្លែងឆ្ងាយ ហើយចង់មកធ្វើបាបកូនរបស់ខ្ញុំទៀតមិនបានទេ ។ ប្រជាជនមូលដ្ឋានខ្លះដៀលខ្ញុំថា "ជាអ្នកធ្លាប់រស់នៅស្រណុកសុខស្រួល មានម៉ូតូមានឡានជិះ ពេលឲ្យធ្វើការមិនចេះធ្វើចេះតែស៊ី" ។ មានអ្នកខ្លះច្រណែនខ្ញុំដោយសារខ្ញុំមានកូនច្រើន បើករបបអង្ករមកបានច្រើន ក៏តាមដានខ្ញុំហើយរាយការណ៍ឲ្យអង្គការថាខ្ញុំខ្ជិលធ្វើការ ។ ក្រោយមក អង្គការចាប់អ្នករាយការណ៍នោះទៅសម្លាប់ចោល ។ បន្ទាប់ពីស្រោចបន្លែ អង្គការចាត់តាំងខ្ញុំឲ្យកាប់ដីនិងកាស់គល់ឈើនៅក្នុងព្រៃ ។

រូបថតនេះខ្ញុំទើបតែថតចម្លងវាឡើងវិញក្រោយពេលរបបខ្មែរក្រហមត្រូវបញ្ចប់ ។ នៅពេលខ្ញុំឃើញរូបថតនេះ ខ្ញុំនឹកឃើញដល់ពេលដែលប្តីខ្ញុំនៅរស់ គាត់រ៉ាប់រងផ្គត់ផ្គង់ក្រុមគ្រួសារឲ្យរស់នៅបានសមរម្យ ។ ឥឡូវគាត់ស្លាប់ហើយ គាត់ផុតទុក្ខកង្វល់ហើយ ភារកិច្ចទាំងនេះធ្លាក់មកលើខ្ញុំ ។ ◆◆◆

# ម៉ម ប៊ុនលន អតីតទាហានលន់នល់ និងប្រពន្ធឈ្មោះ ជា នឿន

ជា នឿន រៀបការជាមួយ ម៉ម ប៊ុនលន នៅឆ្នាំ១៩៦៩ ។ ប៊ុនលន គឺជាអតីតទាហានលន់នល់ ។ ប៊ុនលន បានស្លាប់នៅក្នុងរបបខ្មែរក្រហមដោយជំងឺគ្រុនចាញ់ ។ បច្ចុប្បន្ននេះ នឿន មានអាយុ៥៥ឆ្នាំ រស់នៅស្រុកមុខកំពូល ខេត្តកណ្តាល បានរំឭកការចងចាំរបស់គាត់អំពី ប៊ុនលន ÷

ខ្ញុំបានថតរូបមួយសន្លឹកនេះតាំងពីខ្ញុំអាយុ១៩ឆ្នាំម្ល៉េះ ។ ខ្ញុំទៅថតជាមួយបងស្រីខ្ញុំឈ្មោះ ជា សឿន ។ យើងថតនៅហាងថតរូបមួយល្បីជាងគេនៅផ្សាររការកោង គឺហាងចឹកហុក ។ ខ្ញុំមានបងប្អូន៦នាក់ ។ សម័យមុន កូនស្រីមិនសូវមានឱកាសទៅសាលារៀនឬធ្វើដំណើរឆ្ងាយពីផ្ទះទេ ។ ឪពុកម្តាយច្រើនទុកឲ្យកូនស្រីធ្វើកិច្ចការនៅផ្ទះនិងការងារស្រែចម្ការ ។ ខ្ញុំធ្វើកិច្ចការផ្ទះនិងទៅផ្សារទិញម្ហូប ។ កាលនោះ បងលន ធ្វើការនៅជិតផ្សាររការកោង ។ គាត់ឧស្សាហ៍ឃើញខ្ញុំ ប៉ុន្តែខ្ញុំមិនបានឃើញគាត់ទេ ។ ក្រោយមក គាត់ឲ្យឪពុកម្តាយគាត់មកចូលស្តីដណ្តឹងខ្ញុំ ។ ខ្ញុំមិនដែលស្គាល់គាត់ទាល់តែសោះ រហូតទាល់តែរៀបការរួចទើបគាត់ប្រាប់ខ្ញុំថាគាត់បានលួចមើលខ្ញុំអស់រយៈពេលមួយឆ្នាំហើយ ។

ក្រោយពេលយើងរៀបការហើយ ឪពុកម្តាយក្មេកខ្ញុំបានមកយកខ្ញុំទៅរស់នៅជាមួយគាត់នៅបាក់ខែង ។ ខ្ញុំត្បាញក្រមាជាមួយប្អូនថ្លៃស្រីខ្ញុំ ។ ប្តីខ្ញុំមានបងប្អូនទាំងអស់៧នាក់ ស្រី២នាក់ ប្រុស៥នាក់ ។ ឪពុកក្មេកខ្ញុំឈ្មោះ ម៉ម ជាអ្នកម៉ៅការសំណង់ ម្តាយក្មេកខ្ញុំឈ្មោះ រ៉ុង ជាមេផ្ទះ ។ យើងទៅរស់នៅទីនោះបានតែកន្លះឆ្នាំក៏ត្រឡប់ទៅរស់នៅជាមួយឪពុកម្តាយខ្ញុំវិញ ។ ប្តីខ្ញុំត្រូវផ្លាស់ពីរការកោងទៅធ្វើការនៅខដុក្គ ប៉ុន្តែគាត់បានសុំលាឈប់ពីការងារព្រោះចង់នៅផ្ទះជួយត្បាញក្រមា ។

នៅឆ្នាំ១៩៧៣ ដោយមានការបាញ់គ្នានិងគ្រាប់ផ្លោងខ្លាំងពេក ក្រុមគ្រួសារខ្ញុំរួមទាំងក្រុមគ្រួសារឪពុកម្តាយក្មេកខ្ញុំភៀសខ្លួនទៅរស់នៅភ្នំពេញ ។

នៅឆ្នាំ១៩៧៥ ពេលដែលខ្មែរក្រហមវាយចូលមកដល់ទីក្រុងភ្នំពេញ និងជម្លៀសប្រជាជនចេញពីទីក្រុង ក្រុមគ្រួសារខ្ញុំធ្វើដំណើរត្រឡប់មកបាក់ខែងវិញ ប៉ុន្តែផ្ទះនៅបាក់ខែងត្រូវរុះរើ

អស់នៅសល់តែខ្សឿននិងដំបូល ។ យើងក៏កាប់ស្លឹកដូងមកបាំងស្នាក់នៅបណ្ដោះអាសន្ន ។ ឪពុកម្ដាយក្មេកនិងបងប្អូនថ្លៃខ្ញុំបន្តរស់នៅឃុំបាក់ខែង ចំណែកខ្ញុំនិងប្ដីខ្ញុំបន្តដំណើរទៅឃុំរការកោង ។

នៅចុងឆ្នាំ១៩៧៦ អង្គការបានបញ្ជូនប្ដីប្រពន្ធខ្ញុំទៅរស់នៅខេត្តពោធិសាត់ ។ យើងជិះកាណូតទៅដល់ព្រែកក្ដាមរួចឡើងគោកជិះឡានបន្តទៅដល់សាលាដំណាក់ស្នាច់ ។ នៅម៉ោង៣រសៀលយើងបន្តដំណើរតាមរថភ្លើងហើយចំណាយពេលអស់មួយយប់ទៀតទើបទៅដល់ភូមិកោះជុង ស្រុកបាកាន ខេត្តពោធិសាត់ ។ អង្គការបញ្ជាឲ្យយើងសង់កូនខ្ទមនៅដោយខ្លួនឯង ហើយបង្កើតជាសហករណ៍នៅទីនោះ ។

ទីនេះមិនដែលមានប្រជាជនរស់នៅពីមុនមកទេ ពេលនេះមានសុទ្ធតែប្រជាជនដែលអង្គការជម្លៀសពីឃុំរការកោងទៅ លើកលែងតែកម្មាភិបាលដែលគ្រប់គ្រងយើងដែលជាអ្នកមូលដ្ឋាន ។ យើងត្រូវអង្គការចាត់តាំងឲ្យផ្លាស់ប្ដូរទីកន្លែងរស់នៅច្រើនកន្លែង ។ យើងផ្លាស់ទៅនៅភូមិពោធិ ឃុំកោះគ្រាង ស្រុកបាកាន ។ យើងមិនដឹងពីមូលហេតុច្បាស់លាស់នៃការផ្លាស់ទីកន្លែងនេះទេ ។


ម៉ម ប៊ុនលន


ផា នឿន

ភូមិពោធិដែលខ្ញុំរស់នៅជាភូមិដាច់ស្រយាល គ្មានដីចម្ការទេ មានតែដីស្រែ ។ យើងធ្វើស្រែបានផលច្រើនណាស់ ប៉ុន្តែប្រជាជនមិនដែលបានហូបគ្រប់គ្រាន់ទេ ។ ការងាររបស់ខ្ញុំគឺដកនិងស្ទូង ។ ប្ដីរបស់ខ្ញុំធ្វើការនៅកងភ្ជួរដី ។ ក្នុងឆ្នាំដដែលនេះ ខ្ញុំសម្រាលបានកូនប្រុសម្នាក់ ប៉ុន្តែខ្ញុំគ្មានទឹកដោះឲ្យកូនបៅ កូនខ្ញុំកើតបានតែបួនខែក៏ស្លាប់ទៅវិញ ។ ខ្ញុំមានតែថ្នាំខ្មែរដែលរកដោយខ្លួនឯងយកមកដាំផឹក ។ ពេលកូនខ្ញុំអាយុបានពីរខែ ខ្ញុំឈឺទាស់ហើយធ្លាក់ខ្លួនស្គម ។ ខ្ញុំទៅធ្វើការទាំងឈឺ ។ ប្ដីខ្ញុំធ្វើការនៅកងភ្ជួរ មានជំងឺគ្រុនចាញ់ធ្ងន់ធ្ងរត្រឡប់មកផ្ទះវិញ ហើយស្លាប់នៅផ្ទះ ។ អ្នកភូមិមកយកសាកសពរបស់គាត់ទៅកប់ ។ ពេលនោះ ខ្ញុំនៅឈឺស្ទើរតែដើរមិនរួច ម៉្លោះហើយខ្ញុំមិនដឹងថាសពប្ដីខ្ញុំត្រូវកប់នៅទីកន្លែងណាទេ ។

តាំងពីប្ដីខ្ញុំស្លាប់ទៅ ខ្ញុំរស់នៅក្នុងសភាពភ័យខ្លាចជារៀងរាល់ថ្ងៃ ។ មនុស្សនៅក្នុងភូមិចេះតែបាត់ខ្លួនគ្មានថ្ងៃលោះ ។ ពីមុនយើងមាន៣០០គ្រួសារឥឡូវនេះយើងនៅសល់ត្រឹមតែ១៣គ្រួសារប៉ុណ្ណោះ ហើយភាគច្រើនជាស្ត្រីមេម៉ាយ ។ អង្គការប្រាប់ថាដកកម្លាំងទៅជួយដកសំណាបនៅភូមិផ្សេង ។

ពេលវៀតណាមវាយចូលក្នុងឆ្នាំ១៩៧៩ កងទ័ពវៀតណាមបានដេញយើងឲ្យត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួន ។ យើងធ្វើដំណើរកាត់ព្រៃទម្រាំតែទៅដល់ផ្លូវជាតិទើបអាចរកផ្លូវទៅស្រុកកំណើតឃើញ ។ ខ្ញុំចំណាយពេលជិតមួយខែទើបទៅដល់ឃុំរការកោង ។

ទោះបីជាប្ដីខ្ញុំបានស្លាប់ទៅបាត់ហើយក៏ដោយ ពេលដែលខ្ញុំឃើញរូបថតរបស់គាត់ខ្ញុំមានអារម្មណ៍ដូចជាបានឃើញមនុស្សពិតដូច្នោះដែរ ។ ខ្ញុំនឹកឃើញអនុស្សាវរីយ៍ដែលយើងធ្លាប់រស់នៅជាមួយគ្នា ។ ខ្ញុំគិតថា ប្រសិនបើគាត់នៅរស់ជួបជុំក្រុមគ្រួសារយើងអាចជួយដោះស្រាយលំបាកជាមួយគ្នាបាន ។

រូបថតប្ដីខ្ញុំថតតាំងពីពេលដែលគាត់មិនទាន់រៀបការជាមួយខ្ញុំម្ល៉េះ ។ កាលណោះគាត់ទើបត្រឡប់មកពីហ្វឹកហាត់ក្បួនទ័ពនៅប្រទេសវៀតណាម ។ ពេលដែលយើងជម្លៀសចេញទៅ យើងមិនបានយករូបថតនេះទៅជាមួយទេ ប្អូនស្រីពៅខ្ញុំបានយករូបថតនេះជាមួយរូបថតខ្ញុំខ្ចប់ដាក់ក្នុងបង្វេចខោអាវទុកនៅផ្ទះរហូតដល់ចប់សង្គ្រាម ។ ប្អូនស្រីនិងឪពុកម្ដាយរបស់ខ្ញុំមិនត្រូវអង្គការជម្លៀសទៅភូមិផ្សេងទេ គាត់នៅឃុំរការកោងរហូត ហេតុនេះហើយទើបគាត់អាចថែរក្សារូបថតយើងបាន ។ ◆◆◆

**ប៊ុន ពីច័ន និង ស៊ីវ សាវីណា**

# ដំណើរទស្សនកិច្ចលើកទី៤របស់ប្រជាជនទៅកាន់អគារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ំណើរទស្សនកិច្ចលើកទី៤នេះប្រព្រឹត្តទៅនៅថ្ងៃទី២២ និង ២៣ ខែឧសភា ឆ្នាំ២០០៦ ។ ដំណើរទស្សនកិច្ចលើកនេះមានការអញ្ជើញចូលរួមពីប្រជាជន៤៦៤នាក់ មកពីតាមខេត្តចំនួនប្រាំមួយ ដែលរួមមានខេត្តព្រៃវែង ស្វាយរៀង កណ្តាល តាកែវ កំពត និង កំពង់ធំ ក្នុងនោះមានជនជាតិចាម៦១នាក់ និងដូនជី៥០នាក់ ។

### ដំណើរទៅកាន់សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

ព្រឹកថ្ងៃទី២២ ខែឧសភា អ្នកចូលរួមបានទៅទស្សនាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលជាអតីតមន្ទីរសន្តិសុខថ្នាក់មជ្ឈិម(ឬមន្ទីរស-២១) នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ អ្នចូលរួមបានទស្សនាអគារទាំងបួននៅក្នុងបរិវេណសារមន្ទីរ ដែលមានតាំងរូបថតជនរងគ្រោះរាប់ពាន់សន្លឹក រូបគំនូររបស់វិចិត្រករ វ៉ាន់ ណាត (ដែលជាអតីតអ្នកទោសមន្ទីរស-២១) ឧបករណ៍ធ្វើទារុណកម្ម និងរូបថតតាំងពិព័រណ៌របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។

ជាទូទៅ អ្នកចូលរួមមានការចាប់អារម្មណ៍ចំពោះរូបថតជនរងគ្រោះដែលតាំងនៅជាន់ទីមួយនៃអគារ “ខ” ។ អ្នកចូលរួមស្ទើរគ្រប់រូបបានឆ្លៀតឱកាសនេះពិនិត្យមើលរូបថតម្តងមួយសន្លឹកៗ យ៉ាងផ្ចិតផ្ចង់ ក្រែងប្រទះឃើញបងប្អូន កូនចៅ ឬសាច់ញាតិដែលបានបាត់ខ្លួនក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ តេង សួន មកពីខេត្តកណ្តាល បានប្រទះឃើញរូបថតរបស់មិត្តគាត់ម្នាក់ឈ្មោះ ធី ។ ការរកឃើញនេះត្រូវបានបញ្ជាក់អះអាងបន្ថែមដោយ ងួន រី ដែលរស់នៅក្នុងឃុំជាមួយគ្នា ។

ប្រជាជនមួយចំនួនផ្សេងទៀត ដែលបានរកឃើញរូបថតបងប្អូនឬកូនរបស់ខ្លួនមានការរំជួលចិត្តរហូតដល់ស្រែកទ្រហោយំសំពះ និងស្ទាបអង្អែលរូបថត ។ ម៉ែន រី អាយុ៦៨ឆ្នាំ មកពីឃុំព្រៃតាអី ស្រុកស្វាយទាប ខេត្តស្វាយរៀង បានរកឃើញរូបប្អូនប្រុសរបស់គាត់ពីរនាក់ឈ្មោះ ម៉ែន ស្ដើង និង ម៉ែន សារ៉ែន ។ ងួន វ៉ុន អាយុ៦០ ឆ្នាំ មកពី ឃុំព្រៃតាអី ស្រុកស្វាយទាប ខេត្តស្វាយរៀង បានរកឃើញរូបថតឪពុកធម៌របស់គាត់ឈ្មោះ ឡឹក សូ ដែលធ្លាប់ធ្វើជាមេឃុំព្រៃតាអី ហើយក្រោយមកធ្វើជាប្រធានសុខាភិបាលស្រុកប្រសូត្រ ។ អ្នកដែលបានរកឃើញរូបថតបងប្អូន ឬមិត្តភក្តិបានស្នើសុំមកមជ្ឈមណ្ឌលឯកសារកម្ពុជាឲ្យជួយចម្លងរូបថតឲ្យគាត់មួយសន្លឹកដើម្បីគាត់យកទៅធ្វើបុណ្យ ។

ឆាយ ហេល អាយុ៦១ឆ្នាំ មកពីឃុំព្រៃល្វា ស្រុកព្រៃកប្បាស ខេត្តតាកែវ មានការរន្ធត់ចិត្តយ៉ាងខ្លាំងរហូតដល់ទៅវិលមុខដើរលែងកើត បន្ទាប់ពីបានឃើញទិដ្ឋភាពនៅក្នុងសារមន្ទីរឧក្រិដ្ឋប្រល័យពូជសាសន៍ទួលស្លែង ។ គាត់ទៅអង្គុយនៅក្រោមដើមស្វាយមុខអគារ“ខ” ហើយរៀបរាប់អំពីបទពិសោធន៍ដ៏ឈឺចាប់ដែលសមាជិកប្រាំពីរនាក់របស់គ្រួសារបងប្រុសគាត់ត្រូវសម្លាប់ទាំងអស់ ។ នៅចុងបញ្ចប់នៃដំណើរទស្សនកិច្ច ដូនជីទាំងអស់ចំនួន៥១នាក់បានសូត្រធម៌នៅពីមុខផ្នូលលាដ៍ក្បាលដែលត្រូវបានដាក់តាំងនៅក្នុងទូកញ្ចក់នៅជាន់ទីមួយនៃអគារ“ឃ” ដើម្បីឧទ្ទិសកុសលជូនដល់វិញ្ញាណក្ខន្ធជនរងគ្រោះដែលត្រូវបានសម្លាប់នៅទីនោះ ។ ដំណើរទស្សកិច្ចនៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងបានបញ្ចប់ទៅនៅម៉ោងប្រាំបួនកន្លះ ។ ប្រជាជនបានបន្តដំណើរមកកាន់សាលមហាវិទ្យាល័យគរុកោសល្យ ដើម្បីជួបសំណេះសំណាលជាមួយឯកឧត្តម ម៉ោញ សាផាន តំណាងរាស្ត្រមណ្ឌលកំពង់ចាម និងជាអ្នកដែលបានចូលរួមក្នុងការតាក់តែងច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហម ។

ឯកឧត្តម ម៉ោញ សាផាន បានបកស្រាយពន្យល់នូវរាល់ចំណុចទាំងឡាយ ដែលមានចែងនៅក្នុងច្បាប់ស្តីអំពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ឯកឧត្តមក៏បានធ្វើការបកស្រាយអំពីកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ដោយ

សង្កត់ធ្ងន់ទៅលើសិទ្ធិរបស់ជនជាប់ចោទនិងសាក្សីដែលធានាដោយមាត្រា២៤នៃកិច្ចព្រមព្រៀងនេះ ។

បន្ទាប់ពីការបកស្រាយពន្យល់ចប់ អ្នកចូលរួមបានចែករំលែកបទពិសោធន៍របស់គាត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងចែករំលែកការយល់ឃើញរបស់គាត់អំពីការវិវត្តន៍របស់អង្គជំនុំជម្រះវិសាមញ្ញ ហើយមួយចំនួនទៀតបានឡើងសួរសំណួរ ។ សំណួរដែលអ្នកចូលរួមសួរញឹកញាប់បំផុតគឺ *“តើតុលាការនឹងចាប់ផ្តើមកាត់ក្តីនៅពេលណា? អ្នកណាខ្លះជាមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?”*

**ដំណើរទៅកាន់បូជនីយដ្ឋានវាលពិឃាតជើងឯក**

នៅម៉ោងពីររសៀល អ្នកចូលរួមបានអញ្ជើញទៅដល់វាលពិឃាតជើងឯកដើម្បីទស្សនាស្តូបតម្កល់អដ្ឋិធាតុ ដែលគាស់ចេញពីរណ្តៅចំនួន១២៩ក្នុងបរិវេណនោះ ។ អ្នកចូលរួមបានមកប្រមូលផ្តុំគ្នានៅពីមុខស្តូបដើម្បីធ្វើពិធីថ្លែងសុន្ទរកថា ស្មឹង-ស្មាធ និងសូត្រធម៌គោរពវិញ្ញាណក្ខ័ន្ធជនរងគ្រោះដែលត្រូវបានសម្លាប់ ។ សាន្ត សុខ អាយុ៦៨ឆ្នាំ មកពីឃុំចា ស្រុកព្រៃកប្បាស ខេត្តតាកែវ ជាតំណាងរបស់អ្នកចូលរួម បានឡើងថ្លែងសុន្ទរកថាដែលមានសេចក្តីជាអាទិ៍ថា *“ថ្ងៃនេះយើងខ្ញុំបានមកទស្សនានៅមជ្ឈមណ្ឌលតម្កល់អដ្ឋិធាតុនៃវាលពិឃាតបឹងជើងឯក... យើងខ្ញុំទាំងអស់គ្នាដែលមកឈរនៅទីនេះជាតំណាងឲ្យប្រជាជនកម្ពុជាទាំងជាង១៤លាននាក់នៅទូទាំងប្រទេសសូមលំឱនកាយវាចាចិត្តគោរពវិញ្ញាណក្ខ័ន្ធដល់ប្រជាជនកម្ពុជាដែលបានស្លាប់ក្នុងរបបប៉ុលពត... ។ វិញ្ញាណក្ខ័ន្ធជនស្លូតត្រង់ទាំងឡាយ! យោងតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយបានការឯកភាពពីអង្គការសហប្រជាជាតិ និងការតស៊ូមតិដ៏ច្រើនរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅពេលនេះយើងបានបើកឡើងសាលាជំនុំជម្រះកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលជាមេក្លោងប្រល័យជីវិតមនុស្សនេះហើយ ។ សូមដួងព្រលឹងអ្នកទាំងឡាយបានស្ងប់ចុះ....”* ។ បន្ទាប់ពីបញ្ចប់សុន្ទរកថា អ្នកចូលរួមបានស្មឹងស្មាធមួយនាទីគោរពវិញ្ញាណក្ខ័ន្ធអ្នកស្លាប់ ។

បន្ទាប់មក ប្រជាជនបានអញ្ជើញទស្សនារណ្តៅសាកសពរួម និងបានផ្លាស់ប្តូរយោបល់គ្នាអំពីការយល់ឃើញរបស់គាត់បន្ទាប់ពីបានទស្សនាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ស្តាប់ការបកស្រាយរបស់ឯកឧត្តម ម៉ោញ សាផាន និងបានមកឃើញផ្ទាល់នឹងភ្នែកនូវវាលពិឃាតបឹងជើងឯកនេះ ។ ដូចដំណើរទស្សនកិច្ចលើកមុនៗដែរ ក្រុមដូនជីបានសូត្រធម៌នៅពីមុខស្តូបតម្កល់អដ្ឋិធាតុនិងនៅតាមរណ្តៅធំៗ ដើម្បីឧទ្ទិសដល់វិញ្ញាណក្ខ័ន្ធជនរងគ្រោះ ។



ដូនជីកំពុងសាកសួរឯកឧត្តម ស៊ាន វិសុទ្ធ អំពីដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម

**ដំណើរទៅកាន់អគារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

នៅព្រឹកថ្ងៃទី២៣ អ្នកចូលរួមបានមកជួបជុំគ្នានៅមជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីចេញដំណើរទៅកាន់អគារអង្គជំនុំជម្រះវិសាមញ្ញ ។ អ្នកចូលរួមត្រូវបានស្វាគមន៍ដោយឯកឧត្តម ស៊ាន វិសុទ្ធ ប្រធានការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញ, លោកស្រី មីសែល លី អនុប្រធានការិយាល័យរដ្ឋបាល, លោក រាជ សម្បត្តិ និងលោកស្រី ហេឡែន ហ្សាវីស មន្ត្រីផ្នែកព័ត៌មាននៃអង្គជំនុំជម្រះវិសាមញ្ញ ។

បន្ទាប់ពីសុន្ទរកថាស្វាគមន៍ និងការបកស្រាយពន្យល់អំពី

ដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជារួចមក កម្មវិធីសំណួរចម្លើយបានចាប់ផ្តើម ។ អ្នកចូលរួមបានឡើងថ្លែងពីការឈឺចាប់និងការបាត់បង់សមាជិកគ្រួសាររបស់ខ្លួនក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយសំណូមពរឲ្យតុលាការរៀបចំដំណើរការកាត់ក្តីឲ្យបានឆាប់រហ័ស និងបានសួរសំណួរដែលមានសារសំខាន់ជាច្រើនដូចជា "ក្រោយពីការកាត់ទោសហើយ តើមានការលើកលែងទោសដែរឬទេ? តើ អៀង សារី ដែលត្រូវបានព្រះមហាក្សត្រលើកលែងទោស នឹងត្រូវបានយកមកកាត់ទោសម្តងទៀតដែរឬទេ? តើការកាត់ទោសនេះមានពាក់ព័ន្ធដល់ប្រទេសផ្សេងៗដែរឬទេ? ។ល។"

លោកស្រី មីសែល លី អនុប្រធានរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញ និងជាតំណាងរបស់អង្គការសហប្រជាជាតិ បានមានប្រសាសន៍ថា "ខ្ញុំសូមចូលរួមជាមួយលោក ស៊ាន វិសុទ្ធ ដើម្បីស្វាគមន៍អ្នកទាំងអស់គ្នាដែលអញ្ជើញមកដល់ទីនេះ...។ ខ្ញុំសូមបញ្ជាក់ជូនអ្នកទាំងអស់គ្នាឲ្យបានជ្រាបថា ខ្លួនខ្ញុំផ្ទាល់និងបុគ្គលិកតំណាងឲ្យអង្គការសហប្រជាជាតិនៅទីនេះ ដើម្បីជួយលោក ស៊ាន វិសុទ្ធ ធ្វើកិច្ចការដ៏មានសារសំខាន់នេះ ។ យើងខ្ញុំនឹងព្យាយាមផ្តល់ព័ត៌មានអំពីដំណើរការវិវត្តន៍ទាំងអស់ដែលយើងនឹងធ្វើនៅក្នុងខែជាបន្តបន្ទាប់នេះ ។ ពេលអញ្ជើញទៅដល់ផ្ទះវិញសូមអ្នកទាំងអស់គ្នាប្រាប់មិត្តភក្តិនិងបងប្អូនរបស់អ្នកនូវអ្វីដែលអ្នកបានឃើញនៅទីនេះ ដើម្បីឲ្យគាត់ដឹងថាការកាត់សេចក្តីនឹងចាប់ផ្តើមនៅក្នុងពេលដ៏ខ្លីខាងមុខនេះ ។ អង្គការសហប្រជាជាតិនិងចៅក្រមអន្តរជាតិនឹងប្រឹងប្រែងឲ្យអស់ពីលទ្ធភាពដើម្បីធានាឲ្យបានថាដំណើរការកាត់សេចក្តីនេះគោរពតាមបទដ្ឋានអន្តរជាតិ..." ។

បន្ទាប់ពីបញ្ចប់ដំណើរទស្សនកិច្ច អ្នកចូលរួមបានសម្តែងការសប្បាយរីករាយ ដោយគាត់បានឃើញនិងបានដឹងទាំងព្រឹត្តិការណ៍ដែលកើតមានឡើងនៅមន្ទីរស-២១ និងជើងឯក និងដំណើរការវិវត្តន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ជាពិសេសគាត់បានជួបសួរផ្ទាល់ជាមួយអ្នកជំនាញច្បាប់និងមន្ត្រីនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ យើងសង្ឃឹមថាគាត់នឹងនាំនាំទិដ្ឋភាពនិងព័ត៌មានទាំងនេះទៅប្រាប់និងពិភាក្សាជាមួយបងប្អូនមិត្តភក្តិ និងអ្នកជិតខាងរបស់គាត់ ។

**ឌី ខាំបូលី**

# ចំណោទឧក្រិដ្ឋកម្មមន្ទីរសន្តិសុខភូមិភាគនិរតី
# ការកកើត ប្រតិបត្តិការ និង ទំនាក់ទំនង

### អារម្ភកថា

ខ្ញុំមានអាយុ២ឆ្នាំនៅពេលដែលកងទ័ពខ្មែរក្រហមផ្តួលរំលំរបបលន់ នល់ ហើយកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ បន្ទាប់មកកសាងប្រទេសកម្ពុជាតាមបែបកុម្មុយនីស្តជ្រុលនិយមដោយពឹងផ្អែកទាំងស្រុងលើវិស័យកសិកម្ម ។ ជាលទ្ធផលផែនការរបស់ខ្មែរក្រហមបានបង្កឲ្យបាត់បង់ជីវិតប្រជាជនកម្ពុជាប្រមាណ២លាននាក់ដោយការកាប់សម្លាប់ ខ្វះអាហារ និងជំងឺ ។

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក្រុមគ្រួសាររបស់ខ្ញុំត្រូវកងទ័ពខ្មែរក្រហមជម្លៀសចេញពីទីក្រុងភ្នំពេញទៅរស់នៅខេត្តកណ្តាល ។ បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យត្រូវដួលរលំនៅឆ្នាំ១៩៧៩ ក្រុមគ្រួសាររបស់ខ្ញុំបានបន្តរស់នៅក្នុងខេត្តកណ្តាលមួយរយៈទៀតមុនពេលប្តូរមករស់នៅក្នុងទីក្រុងភ្នំពេញ ។ កាលនោះខ្ញុំស្ថិតក្នុងវ័យកុមារនៅឡើយ ប៉ុន្តែខ្ញុំនៅចាំថា ម្តាយរបស់ខ្ញុំបានណែនាំខ្ញុំមិនឲ្យលេងជាមួយកូនរបស់អ្នកជិតខាងទេ ដោយសារឪពុកម្តាយរបស់កុមារទាំងនោះជាអតីតកងឈ្លបខ្មែរក្រហម ។ ម្តាយខ្ញុំប្រាប់ថា គាត់បារម្ភក្រែងឪពុកម្តាយកុមារទាំងនោះវាយធ្វើបាបខ្ញុំនៅពេលដែលខ្ញុំឈ្លោះជាមួយកុមារទាំងនោះ ។ ខ្ញុំស្តាប់តាមសម្តីរបស់ម្តាយខ្ញុំ ប៉ុន្តែខ្ញុំបានសួរសំណួរជាច្រើនទៅគាត់អំពីរបបកម្ពុជាប្រជាធិបតេយ្យ និងអំពីអតីតកងឈ្លបខ្មែរក្រហមដែលបានកាប់សម្លាប់ប្រជាជនកម្ពុជារាប់លាននាក់ រួមទាំងពូបង្កើតរបស់ខ្ញុំផង ។ សំណួររបស់ខ្ញុំមានដូចជា "ហេតុអ្វីបានជាខ្មែរក្រហមសម្លាប់ប្រជាជន? តើការសម្លាប់

ប្រជាជនអស់រាប់លាននាក់នេះកើតឡើងតាមរបៀបណា?” ខ្ញុំចាំបានថាម្តាយរបស់ខ្ញុំមិនបានផ្តល់ចម្លើយច្បាស់លាស់ចំពោះសំណួររបស់ខ្ញុំឡើយ ។

សំណួររបស់ខ្ញុំគឺជាសំណួរដែលប្រជាជនកម្ពុជាភាគច្រើនបានសួរនិងពិភាក្សាគ្នា ។ កុំ គឺជាស្ត្រីមេម៉ាយអាយុ៤៥ឆ្នាំ បាននិយាយថា “បើឈ្មោះ ដុច អតីតមេភូមិដែលជាឃាតករសម្លាប់ប្តីខ្ញុំ នៅមានសេរីភាពជិះកង់កាត់មុខផ្ទះខ្ញុំរាល់ថ្ងៃ ខ្ញុំពិតជាមិនអាចសប្បាយចិត្តបានទេ” ។ សំ អតីតយុទ្ធជនការពារមន្ទីរស-២១ (គុកទួលស្លែង) មានអារម្មណ៍ខ្មាសអៀនចំពោះបងប្អូននិងអ្នកជិតខាងរបស់គាត់ ។ សំ រៀបរាប់ថា “កាលនោះអ្នកណាក៏ដូចអ្នកណាដែរ គឺសុទ្ធតែគ្មានផ្លូវជ្រើសរើស ។ បើយើងមិនធ្វើតាមបញ្ជាទេគឺមានតែស្លាប់” ។ សំ មិនចង់រំឭកអំពីការងាររបស់គាត់ប្រាប់ក្រុមគ្រួសារនិងអ្នកជិតខាងរបស់គាត់ឡើយ ដោយសារគាត់បារម្ភថាគ្មាននរណាជឿគាត់ ។ សំ បញ្ជាក់ថា “ប្រជាជនជាច្រើនត្រូវចាប់ខ្លួន បញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែង” ។ អតីតយុទ្ធជនការពារមន្ទីរស-២១ម្នាក់ទៀតឈ្មោះ ខេង បានរៀបរាប់ថា “យុទ្ធជនការពារគុកទួលស្លែងជាច្រើនក៏ត្រូវបានចាប់ខ្លួននិងឃុំឃាំងនៅទីនោះដែរ ។ ប្រសិនបើពួកនោះនៅរស់វិញច្បាស់ជាចង់សងសឹកមេខ្មែរក្រហម ជាពិសេសពួកនោះនឹងសប្បាយចិត្តបើមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម” ។

កុំ ទាមទារឲ្យតុលាការកាត់ទោសអតីតកងឈ្លបនិងយុទ្ធជនខ្មែរក្រហមដែលជាអ្នកចាប់ខ្លួននិងសម្លាប់ប្រជាជនដូចជាប្តីរបស់គាត់ជាដើម ។ សំ និង ខេង ក៏ចង់ឲ្យមានតុលាការដែរ ប៉ុន្តែចង់ឲ្យតុលាការកាត់ទោសតែមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលជាអ្នកបញ្ជាឲ្យយុទ្ធជននិងកងឈ្លបសម្លាប់ប្រជាជនតែប៉ុណ្ណោះ ។ គាត់ពន្យល់ថា កងឈ្លបនិងយុទ្ធជនគឺជាឧបករណ៍សម្លាប់មនុស្សដែលទទួលបញ្ជាអំពីមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ដូច្នេះកងឈ្លបនិងយុទ្ធជនមិនមែនជាអ្នកទទួលខុសត្រូវចំពោះការស្លាប់បាត់បង់ជីវិតប្រជាជនទេ ។ ការទាមទាររបស់ កុំ ខុសពីការទាមទាររបស់ សំ និង ខេង ប៉ុន្តែអ្នកទាំងបីសុទ្ធចង់ដឹងអំពីមូលហេតុនៃអំពើកាប់សម្លាប់ប្រជាជននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ តើមូលហេតុអ្វីបានជារបបកម្ពុជាប្រជាធិបតេយ្យកាប់សម្លាប់ប្រជាជន? តើការសម្លាប់ប្រជាជនប្រព្រឹត្តឡើងតាមរបៀបណា?

អត្ថបទសិក្សានេះនឹងពិភាក្សាវែកញែកដោះស្រាយចម្ងល់ខាងលើ ។ ជំពូកទីមួយនឹងពិភាក្សាអំពីមនោគមវិជ្ជារបស់មេដឹកនាំខ្មែរក្រហមដែលយល់ថា នៅក្នុងសង្គមនិងជុំវិញខ្លួនពោរពេញទៅដោយខ្មាំង ។

អត្រាខ្មាំងនៅក្នុងសហករណ៍មានរហូតដល់ពាក់កណ្តាលនៃចំនួនប្រជាជនទាំងអស់ ។ បានសេចក្តីថា ក្នុងចំណោមប្រជាជន២នាក់មានម្នាក់ជាខ្មាំង ។ ក្រៅអំពីខ្មាំងក្នុងសហករណ៍ ដែលត្រូវខ្មែរក្រហមចាត់ទុកជាប្រភេទខ្មាំងខាងក្នុងរបបនេះនៅមានខ្មាំងមួយប្រភេទផ្សេងទៀតគឺខ្មាំងខាងក្រៅដែលរួមមាន សេ.អ៊ី.អា កា.ហ្វេ.បេ និងវៀតណាម ។ ចំពោះខ្មែរក្រហម ខ្មាំងទាំង២ប្រភេទនេះប៉ុនប៉ងវាយដណ្តើមអំណាចនិងបំផ្លិចបំផ្លាញបដិវត្តន៍គ្រប់ទីកន្លែងនិងគ្រប់ពេលវេលា ទាំងនៅលើសមរភូមិ និងសូម្បីតែនៅក្នុងវាលស្រែ ។

ដើម្បីការពារនិងកសាងសង្គមនិយមឲ្យរីកចម្រើនក្រហមឆ្អិនឆ្អៅ មេដឹកនាំខ្មែរក្រហមបានចេញគោលនយោបាយនិងវិធានការកម្ទេចខ្មាំងគ្រប់ប្រភេទដែលប៉ុនប៉ងផ្តួលរំលំបដិវត្តន៍របស់ខ្លួន ។ គណៈមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជាបានប្រគល់សិទ្ធិស្វ័យសម្រេចកម្ទេចខ្មាំងដល់គ្រប់ក្រសួង មន្ទីរ តំបន់ និងភូមិភាគក្នុងការដឹកនាំអនុវត្តផែនការកម្ទេចខ្មាំងដើម្បីការពារនិងកសាងបក្សកុម្មុយនិស្តកម្ពុជា ។ បទវិចារណកថានៅក្នុងព្រឹត្តិប័ត្រផ្សព្វផ្សាយទ្រឹស្តីរបស់បក្ស (សៀវភៅទង់បដិវត្តន៍) បញ្ជាក់ថា “អន្តរាយរបស់មជ្ឈិមបក្សជាអន្តរាយធំណាស់... ។ យើងត្រូវតែការពារក្បាលម៉ាស៊ីនដឹកនាំនេះឲ្យបានជាដាច់ខាត ។ ប្រសិនយើងអាចការពារបក្សបាន គឺយើងអាចការពារអ្វីៗបានទាំងអស់” ។

វិធីក្នុងការកម្ទេចខ្មាំងរបស់អង្គការតាមរយៈមន្ទីរសន្តិសុខគឺជាវិធីដ៏មានប្រសិទ្ធភាព ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មន្ទីរសន្តិសុខត្រូវបានបង្កើតឡើងនៅគ្រប់ទីកន្លែង និងដំណើរការយ៉ាងសស្រាក់សស្រាំនិងគ្មានត្រាប្រណីនៅគ្រប់ទីកន្លែងចាប់តាំងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ដើមឆ្នាំ១៩៧៩ ។

មន្ទីរស-២១ ហៅគុកទួលស្លែង គឺជាមន្ទីរសន្តិសុខសំខាន់បំផុតរបស់កម្ពុជាប្រជាធិបតេយ្យ ។ មន្ទីរនេះល្បីល្បាញ

ដោយសារតែភាពកាចសាហាវដែលបានបង្កឲ្យស្លាប់ប្រជាជនប្រមាណ១ម៉ឺន៤ពាន់នាក់ ។ ម្យ៉ាងទៀត ភាពល្បីល្បាញរបស់សារមន្ទីរនេះគឺដោយសារវាបានបន្សល់ទុកឯកសារយ៉ាងច្រើនសម្បើម និងត្រូវបានប្រែក្លាយទៅជាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍សម្រាប់សាធារណជនចូលទស្សនាបន្ទាប់ពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យនៅក្នុងឆ្នាំ១៩៧៩ ។ ប្រវត្តិវិទូដេវីដ ឆេនដល័រ ពន្យល់ថា "ចំនួនអ្នកទោសដ៏ច្រើនដែលត្រូវសម្លាប់នៅមន្ទីរស-២១ គឺជាកត្តាសំខាន់ដែលធ្វើឲ្យមន្ទីរនេះមានភាពល្បីល្បាញ" ។

លក្ខណៈពិសេសរបស់មន្ទីរស-២១ គឺអ្នកទោសដែលជាប់នៅទីនេះភាគច្រើនជាកម្មាភិបាលជាន់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យ ហើយមន្ទីរនេះស្ថិតនៅក្រោមការត្រួតពិនិត្យផ្ទាល់របស់មជ្ឈិមបក្ស ។ ក៏ប៉ុន្តែ ចំនួនប្រជាជនដែលត្រូវកាប់សម្លាប់នៅមន្ទីរស-២១ មិនប្រាកដថាច្រើនបំផុតនៅទូទាំងប្រទេសឡើយ ។ មានន័យថា មន្ទីរអប់រំថ្នាក់ស្រុកនិងមន្ទីរសន្តិសុខថ្នាក់តំបន់មួយចំនួនទំនងបានកាប់សម្លាប់ប្រជាជនច្រើនជាងមន្ទីរស-២១ ឧទាហរណ៍ដូចជាមន្ទីរអប់រំស្រុកត្រាំកក់ ហៅគុកក្រាំងតាចាន់ស្ថិតនៅក្នុងខេត្តតាកែវ មន្ទីរសន្តិសុខតំបន់២៥ និងមន្ទីរអប់រំស្រុកស្អាងស្ថិតក្នុងខេត្តកណ្តាលជាដើម ។

ប្រតិបត្តិការនៃមន្ទីរសន្តិសុខភូមិភាគនិរតីមិនសូវល្បីល្បាញដូចប្រតិបត្តិការនៅក្នុងមន្ទីរស-២១ទេ ប៉ុន្តែឯកសារដែលបន្សល់ទុកពីរបបខ្មែរក្រហមបញ្ជាក់ថា ខ្មាំងនៃរបបកម្ពុជាប្រជាធិបតេយ្យមានចំនួនរាប់លាននាក់នៅតាមជនបទនិងសហករណ៍ ។ មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមបានចេញគោលនយោបាយនិងបញ្ជាឲ្យលេខាភូមិភាគចាប់ខ្លួន សួរចម្លើយ និងសម្លាប់ខ្មាំង នៅក្នុងមន្ទីរអប់រំស្រុកនិងមន្ទីរសន្តិសុខតំបន់ ។

នេះគឺជាអត្ថបទសិក្សាអំពីប្រតិបត្តិការរបស់មន្ទីរសន្តិសុខនៅក្នុងភូមិភាគនិរតី ។

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ស្រុកត្រាំកក់គឺជាស្រុកគំរូមួយ ជាពិសេសមន្ទីរអប់រំស្រុកត្រាំកក់គឺជាមន្ទីរអប់រំឈានមុខក្នុងវិស័យកម្ទេចខ្មាំង ។ ឯកសាររាប់ម៉ឺនទំព័រត្រូវបានប្រមែប្រមូលពីមន្ទីរអប់រំនេះក្រោយថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។

ឯកសារចម្លើយសារភាពរបស់ នី ខាងក្រោមនេះនឹងបញ្ជាក់អំពីប្រតិបត្តិការរបស់មន្ទីរសន្តិសុខភូមិភាគនិរតី ។ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នី ត្រូវខ្មែរក្រហមជម្លៀសចេញពីទីក្រុងភ្នំពេញជាមួយក្រុមគ្រួសារខ្ញុំនិងប្រជាជនរាប់ម៉ឺននាក់ទៀតទៅស្រុកស្អាង ខេត្តកណ្តាល ។ ៦ខែបន្ទាប់មក នី ត្រូវប្រធានឃុំចាប់ឃុំឃាំងក្នុងមន្ទីរសន្តិសុខ ។ នី ត្រូវដាក់ច្រវាក់ជាប់ដៃនិងជើង ។ នី ត្រូវប្រធានមន្ទីរសន្តិសុខធ្វើទារុណកម្មនិងសួរចម្លើយជាច្រើនលើកច្រើនសា ។ ចម្លើយសារភាពរបស់ នី ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៧៥ បញ្ជាក់អំពីដំណើរការចាប់ខ្លួន ឃុំឃាំងសួរចម្លើយ និងទារុណកម្ម ដែលកើតឡើងចំពោះគាត់ ។

“ដំបូង ពេលព្រលប់ៗមានពូ២នាក់ជិះកង់ទៅហៅខ្ញុំពីមូលដ្ឋានដោយប្រាប់ថាម្ចាស់ផ្ទះហៅខ្ញុំទៅជួប ។ ខ្ញុំក៏ជិះកង់តាមគេ ....ខ្ញុំមិននឹកស្មានថាមកកន្លែងនេះសោះ ។ ពេលខ្ញុំសួរថាតើខ្ញុំជាអ្នកទោសមែនទេ? ពូថាពុំមែនទេ ។ ពុំមែនយ៉ាងម៉េច បើជើងជាប់ច្រវាក់ ជាប់សោទាំងទារបន្ទប់ទៀត ។ នៅពេលខ្ញុំសរសេរអំពីជីវប្រវត្តិលម្អិតតាមសំណួរលើក្រដាសដែលពូឲ្យខ្ញុំរួច តើខ្ញុំបានទៅផ្ទះវិញឬទេ? ខ្ញុំគ្មានសង្ឃឹមសោះរឿងនេះ ព្រោះខ្ញុំលែងទុកចិត្តអង្គការហើយ ។ ខ្ញុំសុំឲ្យពូយកខ្ញុំទៅបាញ់ចោល ឬយកដុំថ្មមួយដុំយ៉ាងធំចងផ្អោបនឹងខ្លួនរបស់ខ្ញុំហើយច្រានទម្លាក់ទឹកទន្លេចុះ ព្រោះខ្ញុំពុំចង់បានជីវិតដូចសព្វថ្ងៃនេះទេ ។ វាជាជីវិតលើកទីមួយ ហើយជាជីវិតខ្មាសអស់ធម្មជាតិនិងខ្មាសខ្លួនឯងពេកណាស់ ។ ខ្ញុំសុខចិត្តស្លាប់ដោយឥតស្តាយស្រណោះថ្វីបើខ្ញុំពុំទាន់បានស្គាល់ឆាកជីវិតដែលមានគ្រួសារក៏ដោយ ។ សូមអង្គការយកជីវិតខ្ញុំ ទៅសម្លាប់ភ្លាមចុះ កុំចាំបាច់សម្លាប់ខ្ញុំម្តងបន្តិចៗ ធ្វើឲ្យទឹកភ្នែកហូរពុំឈប់ឈឺគ្រុនរាល់ថ្ងៃបែបនេះ ។ គួរពុំគួរសុំអង្គការធ្វើតាមសំណូមពរខ្ញុំចុះ” ។

ចម្លើយសារភាពរបស់ នី រួមទាំងកសិណសាក្សីដែលខ្ញុំបានជួបសម្ភាសន៍ (អតីតអ្នកទោសចំនួន១២៥នាក់ និងអតីតយុទ្ធជនការពារមន្ទីរសន្តិសុខនៅភូមិភាគនិរតីចំនួន១៨នាក់) និងឯកសារខ្មែរក្រហមដែលបន្សល់ទុករហូតមកទល់សព្វថ្ងៃនេះ ឆ្លុះបញ្ចាំងអំពីដំណើរការសំខាន់បីនៃមន្ទីរសន្តិសុខនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺ ទី១) ការចាប់ខ្លួន ទី២) ការឃុំឃាំងនិងសួរចម្លើយ និងទី៣) ការ

សម្លាប់ ។ ដំណើរការទាំងបីខាងលើបង្កឲ្យបាត់បង់ជីវិតប្រជាជនរាប់សែននាក់ក្នុងភូមិភាគនិរតី និងជិត២លាននាក់នៅទូទាំងប្រទេសកម្ពុជា ។ របកគំហើញនៃការសិក្សាស្រាវជ្រាវគឺ មេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យបានចូលរួមប្រព្រឹត្តដឹកនាំនិងបង្កដោយចេតនាឲ្យមានការសម្លាប់ប្រជាជនជាលក្ខណៈប្រព័ន្ធ (ការចាប់ខ្លួន បង្ខំឲ្យឆ្លើយសារភាព និងប្រហារជីវិត) ។ របកគំហើញនេះគឺជាធាតុផ្សំក្នុងច្បាប់ស្តីអំពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលអ្នកច្បាប់អាចសិក្សាស្រាវជ្រាវបន្តដើម្បីប្រើប្រាស់នៅក្នុងដំណើរការតុលាការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមនាពេលខាងមុខ ។

មន្ទីរសន្តិសុខក្នុងភូមិភាគនិរតីត្រូវបានបង្កើតឡើងតាំងពីថ្នាក់ឃុំ ស្រុក តំបន់ និងភូមិភាគ តាមគោលនយោបាយរបស់គណៈមជ្ឈិមបក្សនៃបក្សកុម្មុយនិស្តកម្ពុជា ។ មន្ទីរសន្តិសុខទាំងនោះបានដំណើរការយ៉ាងស្រោកស្រាំ និងទាក់ទងគ្នាយ៉ាងស្អិតល្មួតតាំងពីថ្នាក់ក្រោមរហូតដល់ថ្នាក់លើ ។

## មន្ទីរសន្តិសុខនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ដំណើរការបោសសម្អាតខ្មាំងរបស់អង្គការតាមរយៈការចាប់ខ្លួន ឃុំឃាំង បង្ខំឲ្យឆ្លើយសារភាព និងសម្លាប់ គឺជាការអនុវត្តរបស់ថ្នាក់ក្រោមតាមគោលនយោបាយរបស់គណៈមជ្ឈិមបក្សនៃបក្សកុម្មុយនិស្តកម្ពុជា ។ មេដឹកនាំក្នុងជួរបក្សកុម្មុយនិស្តកម្ពុជាចេញគោលនយោបាយ សេចក្តីណែនាំ និងផ្សព្វផ្សាយទូទាំងប្រទេស ។ បន្ទាប់ពីបានទទួលគោលនយោបាយ ផែនការនិងសេចក្តីសម្រេចរបស់គណៈមជ្ឈិមបក្ស ថ្នាក់ក្រោមចាប់ផ្តើមអនុវត្ត ។ នៅក្នុងដំណាក់កាលអនុវត្តគោលនយោបាយនិងសេចក្តីណែនាំរបស់គណៈមជ្ឈិមបក្ស ចរន្តទំនាក់ទំនងរវាងអង្គការបក្សពីថ្នាក់ក្រោមទៅថ្នាក់លើជាបន្តបន្ទាប់រហូតដល់គណៈមជ្ឈិមបក្សគឺជាចរន្តដែលវិលមិនឈប់ឈរ ។ ចរន្តទំនាក់ទំនងនោះរួមមានការចាប់ខ្លួនឃុំឃាំង ការសួរចម្លើយ ការសរសេររបាយការណ៍ការផ្ញើចម្លើយសារភាពរបស់អ្នកទោសជូនថ្នាក់លើដើម្បីវិភាគនិងសម្រេច និងការសម្លាប់អ្នកទោស ។

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ កងទ័ពត្រូវបានបែងចែកជា៣ប្រភេទគឺ កងទ័ពភូមិភាគនិងមជ្ឈិម កងទ័ពតំបន់ និងកងឈ្លប ។ ជាទូទៅកងទ័ពមានភារកិច្ចប្រយុទ្ធនៅសមរភូមិ ចំណែកកងឈ្លបមានភារកិច្ចការពារនិងរក្សាសន្តិសុខនៅតាមភូមិស្រុក ។ បានសេចក្តីថា ភារកិច្ចសំខាន់របស់យុទ្ធជនខ្មែរក្រហមគឺ កម្ទេចខ្មាំងគ្រប់ប្រភេទទាំងនៅលើសមរភូមិក៏ដូចជានៅតាមភូមិស្រុកដើម្បីការពារកម្ពុជាប្រជាធិបតេយ្យ ។

ប៉ុល ពត រៀបរាប់ថា “កងទ័ពយើងមានភារកិច្ចទទួលខុសត្រូវផ្នែកការពារប្រទេស ហើយមិនទទួលខុសត្រូវបញ្ហាសន្តិសុខឡើយ ។ ប៉ុន្តែក្នុងករណីចាំបាច់និងមានសំណូមពរជាក់ស្តែងកងទ័ពយើងអាចចូលរួមអនុវត្តការងារសន្តិសុខបាន” ។

## រចនាសម្ព័ន្ធមន្ទីរសន្តិសុខ


ហ៊ឹម ខេង សន្តិសុខមន្ទីរស-២១

មន្ទីរសន្តិសុខនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមាន៥ថ្នាក់ ៖ មន្ទីរឈ្លបឃុំ មន្ទីរអប់រំស្រុក មន្ទីរសន្តិសុខតំបន់ មន្ទីរសន្តិសុខភូមិភាគ និងមន្ទីរសន្តិសុខមជ្ឈិម ហៅ មន្ទីរស-២១ ។

មន្ទីរឈ្លបឃុំគឺជាកន្លែងឃុំឃាំងប្រជាជនដែលបានប្រព្រឹត្តកំហុសបន្តិចបន្តួចដូចជាលួចចំណីអាហារ លួចបេះបន្លែផ្លែឈើ និងជាកន្លែងឃុំឃាំងបណ្តោះអាសន្នមុនពេលបញ្ជូនទៅមន្ទីរអប់រំស្រុក ។

មន្ទីរអប់រំស្រុកនិងមន្ទីរសន្តិសុខតំបន់គឺជាទីតាំងឃុំឃាំងសួរចម្លើយ និងសម្លាប់អ្នកទោស ។ អ្នកទោសនៅក្នុងមន្ទីរអប់រំ

ស្រុករួមមានអតីតទាហានប៉ូលិសនៃរបបលន់នល់ ប្រជាជនដែលត្រូវខ្មែរក្រហមចាត់ទុកថាបានប្រឆាំងនឹងគោលនយោបាយរបស់អង្គការ ដូចជា លួចរត់ចេញពីកងទៅផ្ទះ ធ្វើឲ្យបាក់ដងចប ស្ទាបព្រានិងនិយាយឬមានគំនិតមិនល្អចំពោះអង្គការ ។ អ្នកទោសនៅក្នុងមន្ទីរសន្តិសុខតំបន់ភាគច្រើនគឺជាអតីតកងទ័ពខ្មែរក្រហមដែលត្រូវអង្គការចោទប្រកាន់ថាមានកំហុសដោយសារថ្នាក់លើក្បត់នឹងអង្គការនិងត្រូវអង្គការចាប់ខ្លួននិងប្រហារជីវិត ។

មន្ទីរសន្តិសុខភូមិភាគគឺជាមន្ទីរសន្តិសុខលំដាប់ទីបួន ។ មន្ទីរសន្តិសុខភូមិភាគសម្រាប់ឃុំឃាំងកងទ័ពដែលត្រូវអង្គការចោទ


ហ៊ឹម ខេង ២០០២

ប្រកាន់ថាក្បត់ដោយសារជាប់ពាក់ព័ន្ធនឹងខ្មាំងរបស់អង្គការព្រមទាំងសាច់ញាតិរបស់អ្នកទាំងនោះ ។

មន្ទីរសន្តិសុខធំបំផុតគឺមន្ទីរសន្តិសុខមជ្ឈិម ហៅ មន្ទីរស-២១ ឬគុកទួលស្លែង ។ អត្ថបទសិក្សានេះនឹងមិនរើកញែកក្បោះក្បាយអំពីមន្ទីរស-២១ឡើយ ដោយសារមន្ទីរស-២១ មិនស្ថិតនៅក្នុងភូមិភាគនិរតី ។

មន្ទីរសន្តិសុខនៅក្នុងភូមិភាគនិរតីភាគច្រើនមានទីតាំងនៅក្នុងវត្តអារាមឬសាលារៀនឬអគាររដ្ឋបាលផ្សេងទៀតដែលមានលក្ខណៈអំណោយផល ។ អ្នកទោសភេទប្រុសនិងភេទស្រីជាប់ក្នុងបន្ទប់ដោយឡែកពីគ្នា ។ អ្នកទោសភេទប្រុសត្រូវជាប់ខ្នោះដៃឬជើង ចំណែកអ្នកទោសភេទស្រីនិងកុមារតូចៗមិនត្រូវដាក់ខ្នោះដៃនិងជើងឡើយ ។ អ្នកទោសស្រាលនិងអ្នកទោសធ្ងន់ក៏ត្រូវឃុំឃាំងដាច់ដោយឡែកពីគ្នាដែរ ។

មន្ទីរសន្តិសុខគ្រប់ថ្នាក់មានទំនាក់ទំនងគ្នាយ៉ាងស្អិតល្មួត ។ អ្នកទោសមួយចំនួនត្រូវបញ្ជូនពីមន្ទីរសន្តិសុខថ្នាក់ទាបទៅមន្ទីរសន្តិសុខថ្នាក់ខ្ពស់ ឧទាហរណ៍ពីមន្ទីរឈ្លបឃុំទៅមន្ទីរអប់រំស្រុក ឬពីមន្ទីរអប់រំស្រុកទៅមន្ទីរសន្តិសុខតំបន់ និងរហូតដល់ចុងក្រោយបំផុតគឺមន្ទីរស-២១ ។ ហង់រី ឡូកា ពិពណ៌នាអំពីមន្ទីរសន្តិសុខនៃរបបកម្ពុជាប្រជាធិបតេយ្យថា ៖ "អត្រាអ្នកទោសដែលជាប់ឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខថ្នាក់ទាបត្រូវបានដោះលែងពី២០ ទៅ ៣០ភាគរយ ប៉ុន្តែនៅមន្ទីរស-២១ គ្មានអ្នកទោសណាម្នាក់ត្រូវបានដោះលែងឡើយ ។ នេះបានសេចក្តីថា អ្នកទោសដែលជាប់នៅមន្ទីរសន្តិសុខថ្នាក់កាន់តែខ្ពស់គឺកាន់តែបាត់បង់ឱកាសរស់រានមានជីវិត" ។

## ខ្មាំងរបស់អង្គការ

ខ្មាំងរបស់អង្គការមាន២ប្រភេទ គឺខ្មាំងខាងក្រៅនិងខ្មាំងខាងក្នុង ។ ខ្មាំងខាងក្រៅមាន សេ.អ៊ី.អា កា.ហ្សេ.បេ និងវៀតណាម ។ ខ្មាំងខាងក្នុងមាន៣ប្រភេទ ។ ប្រភេទទី១គឺអតីតទាហានប៉ូលិសនៃរបបលន់នល់និងសក្តិភូមិនាយទុន ។ ប្រភេទទី២គឺកងទ័ពយុទ្ធជនខ្មែរក្រហមដែលត្រូវចោទប្រកាន់ថាក្បត់នឹងអង្គការមិនពេញចិត្តនឹងមាគ៌ាមហាលោតផ្លោះមហាអស្ចារ្យរបស់បដិវត្តន៍ និងប្រភេទទី៣គឺប្រជាជនដែលជាប់និន្នាការនយោបាយវណ្ណៈជាមួយខ្មាំងរបស់អង្គការ ។

ខ្មាំងខាងក្នុងជាប្រភេទខ្មាំងដែលបក្សកុម្មុយនិស្តកម្ពុជាខ្វល់ខ្វាយជាខ្លាំង ហើយខ្មាំងប្រភេទនេះមានចំនួនរហូតដល់រាប់សែននាក់ ។ ខ្មាំងទាំងនោះរស់នៅនិងធ្វើការនៅក្នុងសហករណ៍ស្រុក តំបន់ និងភូមិភាគ ជាមួយនឹងប្រជាជនកម្ពុជា ទាំងប្រជាជនថ្មី (១៧មេសា) និងប្រជាជនមូលដ្ឋាន ។ សៀវភៅទង់ក្រហមកិត្តិយសបានបញ្ជាក់ថា "ខ្មាំងខាងក្នុងភាគច្រើនស្ថិតនៅក្នុងវណ្ណៈអនុធន វណ្ណៈកសិករខ្វះ តែជាកសិករដែលអស់ធាតុ

ជាកសិករ ជាអនុធនក្លាយដែលកើតកើន" ។

បក្សកុម្មុយនិស្តកម្ពុជាយល់ថា ខ្មាំងខាងក្នុងបានបង្កទំនាស់ ស្មុគ្រស្មាញស្ទាប់រស់ពីតូចទៅធំ ដោយ"បង្កវិទ្ធង្សនាផ្សេងៗ ប្រឆាំងនឹងបដិវត្តន៍" ។ អំពើវិទ្ធង្សនាដែលខ្មាំងខាងក្នុងបង្កមាន ដូចជាលួចបេះបោចដំណាំជាដើម ។ អំពើវិទ្ធង្សនារបស់ខ្មាំងខាង ក្នុងកើតឡើងនៅគ្រប់ទីកន្លែង គ្រប់ច្រកល្ហក និងសូម្បីតែនៅ វាលស្រែ ។ "ក្នុងការធ្វើស្រែគឺមានការប្រយុទ្ធ២ ។ ទី១ប្រយុទ្ធ នឹងធម្មជាតិ ទី២ប្រយុទ្ធជាមួយខ្មាំងបំផ្លាញ ។ ខ្មាំងវាបំផ្លាញ តាំងពីសន្ទូងទៅ វាបត់ដើម វាមិនស្ទូងពីឫសពីគល់ឯណា វាស្ទូង បត់បំផ្លាញ ច្រូតវាបំផ្លាញ ដឹកវាបំផ្លាញបញ្ជាន់ វាបំផ្លាញ បង្កបង្កើនផលដោយការតស៊ូខាងបច្ចេកទេសផងតស៊ូវណ្ណៈផង តស៊ូរវាងបដិវត្តន៍និងមិនបដិវត្តន៍ផង" ។ ខ្មាំងខាងក្នុងថែមទាំង បានស៊ីរូងដល់ក្នុងជួរបក្សនិងជួរកម្មាភិបាលដឹកនាំថែមទៀត ។ នៅក្នុងជួរដឹកនាំ ខ្មាំងធ្វើសកម្មភាព ប្រឆាំងនឹងអង្គការ ដោយ "ការបង្វែរ មហាជនទៅតាមផ្លូវខុសពីមាគ៌ារបស់បក្ស" ។

ខ្មាំងជាប់និន្នាការនយោបាយវណ្ណៈជាខ្មាំងមួយប្រភេទទៀត ដែលបក្សកុម្មុយនិស្តកម្ពុជាចាត់ទុកថាមានបំណង គោលជំហរ និងគំនិត ដូចខ្មាំងពិតប្រាកដរបស់អង្គការដែរ ។ ខ្មាំងជាប់និន្នាការ នយោបាយនិងវណ្ណៈមានទំនាក់ទំនងជាមួយខ្មាំងរបស់អង្គការ ។ បក្សកុម្មុយនិស្តកម្ពុជាមានជំនឿថា ការមានគំនិតគោលជំហរ ប្រឆាំងនឹងអង្គការពីមួយថ្ងៃទៅមួយថ្ងៃ ធ្វើឲ្យកម្លាំងប្រឆាំងនឹង បដិវត្តន៍រីកធំឡើងបង្កឲ្យទំនាស់រីកពីតូចទៅធំ ។ ដូចក្នុងទ្រឹស្តីបដិច្ច សមុប្បាទដែលបានបំពាក់បំប៉នកម្មាភិបាលគ្រប់រូបថា "អ្វីៗ ទាំងអស់សុទ្ធតែមានទំនាក់ទំនង អ្វីៗទាំងអស់សុទ្ធតែមានការវិវត្ត ប្រែប្រួលទៅមុខ អ្វីៗទាំងអស់ដែលវិវត្តគឺវិវត្តពីទាបទៅខ្ពស់ពី តូចទៅធំ ពីបរិមាណទៅគុណភាពអ្វីៗទាំងអស់សុទ្ធតែមានទំនាស់" ។

ប្រជាជនគ្រប់រូបដែលត្រូវចាប់ខ្លួនបញ្ជូនមកមន្ទីរសន្តិសុខ ត្រូវបានចាត់ទុកជាខ្មាំងរបស់អង្គការ និងលែងត្រូវបានចាត់ទុក ជាប្រជាជននៃរបបកម្ពុជាប្រជាធិបតេយ្យទៀតហើយ ។ ក្នុង គំនិតរបស់កម្មាភិបាលនៅក្នុងមន្ទីរសន្តិសុខ វត្តមានរបស់ប្រជាជន នៅក្នុងមន្ទីរសន្តិសុខ "ទោះបីជាគ្មានអាវុធឬជាប់ចំណងក៏ដោយ ក៏ធាតុពិតគឺជាខ្មាំង" ។ ភារកិច្ចរបស់កម្មាភិបាលមន្ទីរសន្តិសុខ ជាមួយនឹងខ្មាំងទាំងនោះគឺជាភារកិច្ចដោះស្រាយទំនាស់ ជា ទំនាស់រវាងបដិវត្តន៍នឹងខ្មាំង ហើយជាប្រភេទទំនាស់ស្លាប់រស់ ។ តាមទ្រឹស្តីបដិច្ចសមុប្បាទ វិធីដោះស្រាយទំនាស់ស្លាប់រស់នេះ ដាច់ខាតត្រូវឈរលើគោលជំហរវណ្ណៈ ។ ទ្រឹស្តីនេះពន្យល់ថា "មុននឹងសម្រេចវិភាគទំនាស់មួយកម្មាភិបាលត្រូវតែសង្កេតមើល អំពីវណ្ណៈរបស់អ្នកដែលបានបង្កឲ្យមានទំនាស់នេះជាមុនសិន" ។

សៀវភៅកំណត់ហេតុរបស់សមមិត្ត យិន សូផន កត់ត្រា វគ្គសិក្សាវិភាគទំនាស់ក្នុងសង្គមកម្ពុជា ។ ឧទាហរណ៍នៃវិធីវិភាគ ទំនាស់មួយដែលសៀវភៅនេះបានកត់ត្រាគឺ "យើងឃើញខ្មាំង ធ្វើសកម្មភាពហើយប៉ុន្តែយើងថាវាមិនអី នេះមកពីយើងណែនាំ មិនទាន់ក្តៅ ។ ដូចជាខ្មាំងវាដឹកទឹកគ្នោតហើយជុះអាចម៍ដាក់ក្នុង បំពង់ទៀតយើងថាវាខិលណាស់ គឺមិនថាវាខ្មាំងទេ តាមពិតវា ជាខ្មាំង" ។ វិធីវិភាគទំនាស់តាមទ្រឹស្តីបដិច្ចសមុប្បាទបានធ្វើឲ្យ ប្រជាជនស្លូតត្រង់ដែលមានកំហុសបន្តិចបន្តួចក្លាយទៅជាខ្មាំងរបស់ អង្គការដោយមិនដឹងខ្លួន ដោយសារអ្វីៗសុទ្ធតែទាក់ទងនឹងអំពើ ក្បត់ សុទ្ធតែទាក់ទងជាខ្សែសង្វាក់ ។ សកម្មភាពផ្សេងទៀតដែល ត្រូវរាប់បញ្ចូលរួមមាន ការធ្វើឲ្យបាក់នង្គ័ល ស្ទូងបត់គល់ ធ្វើបាក់ ស្នាបព្រា ជំហរកម្មសិទ្ធិឯកជន ការលួចបេះផ្លែឈើ ដំណាំ និង លួចរបស់របរសមូហភាព ។

## ១) ការកកើត

សមមិត្ត សុន សេន រដ្ឋមន្ត្រីក្រសួងសន្តិសុខជាតិ បាន ប្រកាសក្នុងពិធីប្រជុំលេខា-អនុលេខាកងពលនិងវរសេនាធំ ឯករាជ្យ អំពីភារកិច្ចចំនួនពាររបស់យុទ្ធជនបដិវត្តន៍គឺ ការពារ ប្រទេស បន្តធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយម ។ ភារកិច្ចការពារប្រទេសនិងភារកិច្ចបន្តធ្វើបដិវត្តសង្គមនិយមគឺ បោសសម្អាតមនុស្សមិនសង្គមនិយម និងត្រួសត្រាយឧបសគ្គ ឆ្ពោះទៅរកការកសាងសង្គមនិយម ។ ល្គឹកណាមនុស្សមិនសង្គម និយមត្រូវបានបោសសម្អាតអស់ ការកសាងសង្គមនិយមប្រាកដ ជាអាចធ្វើទៅបានប្រកបដោយជោគជ័យ ។ សមមិត្ត សុន សេន បញ្ជាក់ប្រាប់យុទ្ធជនបដិវត្តន៍ថា "យើងមិនចោលការកសាង សង្គមនិយមទេ តែសំខាន់មនុស្សដែលកសាងនោះជាមនុស្ស បដិវត្តពិតប្រាកដ" ។

ខ្មែរក្រហមចាត់ទុកមនុស្សមិនសង្គមនិយមជាខ្មាំងរបស់អង្គការដែលត្រូវតែបោសសម្អាត ។ សមមិត្ត នួន ជា អនុលេខាបក្សនិយាយបំផុសទឹកចិត្តយុទ្ធជនរបស់គាត់ថា ការចូលរួមរបស់យុទ្ធជនបដិវត្តន៍ក្នុងការបោសសម្អាតខ្មាំងគឺបានសេចក្តីថាបានចូលរួមក្នុងការ "ការពារប្រទេសនិងកសាងសង្គមនិយម" ។

## គោលការណ៍ និងវិធានការ

គោលការណ៍របស់បក្សកុម្មុយនិស្តកម្ពុជាក្នុងការដោះស្រាយទំនាស់ស្លាប់រស់រវាងបដិវត្តន៍និងខ្មាំង គឺស្វែងរកឲ្យឃើញ សួរចម្លើយឲ្យខ្ទេច និងកម្ទេចឲ្យអស់ ។ ភារកិច្ចស្វែងរកដើម្បីចាប់ខ្លួននិងប្រហារជីវិតខ្មាំងគឺជាភារកិច្ចចាំបាច់មិនចេះចប់មិនចេះហើយរបស់យុទ្ធជនបដិវត្ត ជាភារកិច្ចដ៏ឧត្តុង្គឧត្តមនិងមានតម្លៃដូចបានចូលរួមក្នុងបុព្វហេតុ"ការពារនិងកសាងប្រទេស"ដែរ ។ ទោះបីជាជាប់រវល់មមាញឹកយ៉ាងណាក៏ដោយ ក៏ការចូលរួមកម្ទេចខ្មាំងជាភារកិច្ចចាំបាច់ដែលយុទ្ធជនបដិវត្តគ្រប់រូបដាច់ខាតត្រូវតែចូលរួមដូចពាក្យស្លោកខ្មែរក្រហមមួយចែងថា "ដៃម្ខាងបង្កបង្កើនផល ដៃម្ខាងវាយខ្មាំង" ។

រដ្ឋធម្មនុញ្ញនៃរបបកម្ពុជាប្រជាធិបតេយ្យដែលចូលជាធរមាននៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦ និងលក្ខន្តិកៈបក្សកុម្មុយនិស្តកម្ពុជា បានកំណត់ផ្តន្ទាទោសប្រហារជីវិត "ខ្មាំងដែលមានបំណងប្រឆាំងនឹងបដិវត្តន៍និងបំផ្លិចបំផ្លាញកម្ពុជាប្រជាធិបតេយ្យជាខ្សែសង្វាក់" ។ គណៈកម្មាធិការមជ្ឈិមបក្សក៏បានចេញសេចក្តីណែនាំអំពីខ្មាំងគ្រប់ប្រភេទ ហើយបានប្រគល់សិទ្ធិស្វ័យសម្រេចកម្ទេចខ្មាំងដល់គ្រប់អង្គការ ក្រសួង មន្ទីរ និងភូមិភាគ ដោយកំណត់កម្រិតផ្តន្ទាទោសដូចការកំណត់របស់រដ្ឋធម្មនុញ្ញនិងលក្ខន្តិកៈបក្សដែរ ។ សេចក្តីណែនាំរបស់គណៈកម្មាធិការមជ្ឈិមបក្សផ្តន្ទាទោសចំពោះកំហុសតិចតួចដោយ"ការណែនាំអប់រំ" និងផ្តន្ទាទោសកម្រិតខ្ពស់ដោយ"កម្ទេច"ខ្មាំងដែលប្រឆាំងនឹងអង្គការ "ដោយចេតនា ដោយគោលជំហរពេញចិត្តពេញថ្លើម" ។

វិធានការដោះស្រាយទំនាស់ស្លាប់រស់របស់បក្សកើតឡើងជាបន្តបន្ទាប់ គ្មានព្រំដែនកំណត់ និងគ្មានមេត្តា ។ ពាក្យស្លោកខ្មែរក្រហមមួយកំណត់ថា "សម្លាប់ច្រឡំមនុស្សគ្មានកំហុស ១០ នាក់ប្រសើរជាងដោះលែងមនុស្សមានកំហុសម្នាក់" ។

ផែនការរបស់បក្សក្នុងការបោសសម្អាតខ្មាំងបានចាប់ផ្តើមភ្លាមបន្ទាប់ពីទទួលបានជ័យជម្នះទាំងស្រុងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ផែនការបោសសម្អាតនេះកើតឡើងចាប់តាំងពីយុទ្ធនាការជម្លៀសប្រជាជនចេញពីទីក្រុងឲ្យទៅរស់នៅតាមជនបទដូចដែលសមមិត្ត នួន ជា បញ្ជាក់អំពីជោគជ័យនៃផែនការនេះក្នុងឱកាសថ្លែងទៅកាន់ប្រតិភូបក្សពលករដាណឺម៉ាកថា "គ្រាន់តែក្រោយពេលរំដោះភ្លាម យើងជម្លៀសប្រជាជនចេញពីទីក្រុងទាំងអស់ ។ ពេលនោះភ្នាក់ងារ សេ.អ៊ី.អា កា.ហ្សេ.បេ និងភ្នាក់ងារវៀតណាម ត្រូវទៅនៅតាមជនបទ ហើយមិនអាចអនុវត្តផែនការដែលបានគ្រោងទុកឡើយ" ។

យុទ្ធជនខ្មែរក្រហមម្នាក់ឈ្មោះ អែម មីន ហៅ សែន បានទទួលបញ្ជាអំពីអង្គការឲ្យស្វែងរកនិងប្រហារជីវិតខ្មាំង ។ សែន បញ្ជាក់ថា ៖

"តាមផែនការបក្ស ត្រូវរៀបចំទទួលប្រជាជនដែលជម្លៀសចេញពីទីក្រុងភ្នំពេញនិងទីរួមខេត្តនានា ទុកប្រជាជនទាំងនេះមួយកន្លែងដោយឲ្យរស់នៅក្នុងភូមិនិងឃុំរបស់ប្រជាជន ។ ចំពោះអ្នកដែលបានបង្កប់ខ្លួនក្នុងចំណោមប្រជាជនចាំបាច់ត្រូវតែដកចេញយកទៅដាក់មួយកន្លែង បន្ទាប់មកវាយតម្លៃស៊ើបអង្កេតពួកនេះឲ្យច្បាស់លាស់ ។ ប្រសិនរកឃើញថានរណាជាមន្ត្រី ត្រូវកម្ទេចម្តងមួយៗ" ។

## ការស្វែងរកចាប់ខ្លួន

សមមិត្ត អៀង សារី អតីតឧបនាយករដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងការបរទេសនៃកម្ពុជាប្រជាធិបតេយ្យបានឲ្យដឹងថា បន្ទាប់ពីយុទ្ធនាការជម្លៀសប្រជាជនចេញពីទីក្រុង បក្សបានតាមដានរកឃើញគ្រាប់រំសេវនិងអាវុធជាច្រើនដែលអតីតទាហានប៉ូលិសរបបលន់នល់បានលាក់ទុកដើម្បីផ្តួលរំលំដណ្តើមអំណាចពីបក្សវិញ ។ ពេលនោះបក្សបានប្រកាសអំពីវត្តមានខ្មាំង ហើយផែនការរបស់បក្សចំពោះខ្មាំងទាំងនោះគឺបន្តតាមរកនិងកម្ទេចចោល ។ តាមគំនិតរបស់ អៀង សារី "នៅទូទាំងប្រទេសមានខ្មាំងខាងក្នុងពី១ ទៅ៥ ភាគរយ" ហើយខ្មាំងទាំងនោះកំពុងតែធ្វើសកម្មភាពប្រឆាំងនឹងបដិវត្តន៍នៅគ្រប់ទិសទីរួមទាំងនៅក្នុងក្រសួងការបរទេសផង ។ តាមផែនការរបស់ អៀង សារី វិធានការកម្ទេចខ្មាំងខាងក្នុង

ទាំងនោះដាច់ខាតត្រូវតែធ្វើ និងធ្វើជាជំហានៗនិងច្បាស់លាស់បំផុតតាមរយៈការ“តាមដានប្រវត្តិរូបនិងធ្វើជីវទស្សន៍ឲ្យច្បាស់លាស់” ហើយធ្វើដោយហ្មត់ចត់និងតឹងរ៉ឹងឲ្យដូចជា “ព្រួលបិទជិត” ដែលសូម្បីតែ “កំពឹសក៏ចេញមិនរួច” ។

ផែនការរបស់បក្សក្នុងការស្វែងរកនិងប្រហារជីវិតអតីតទាហានប៉ូលិសរបបលន់នល់បានកើតឡើង និងទទួលជោគជ័យនៅគ្រប់ទីកន្លែងទូទាំងប្រទេសចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ចុងឆ្នាំ១៩៧៦ និងបន្តរហូតដល់ចុងឆ្នាំ១៩៧៨ ។ តយ អតីតគណៈឃុំកំពែង ស្រុកព្រៃកប្បាស ខេត្តតាកែវ បានទទួលផែនការរបស់បក្សក្នុងការស្វែងរកនិងប្រហារជីវិតខ្មាំង និងបានអនុវត្តតាមផែនការនេះ ។ នៅពាក់កណ្ដាលឆ្នាំ១៩៧៥ តយ បានចាប់អតីតទាហានលន់នល់ជាច្រើននាក់ដែលរស់នៅក្នុងឃុំកំពែងប្រគល់ទៅឲ្យគណៈស្រុកព្រៃកប្បាស ។

ចាប់ពីឆ្នាំ១៩៧៦ដល់ចុងឆ្នាំ១៩៧៨ មុខសញ្ញាខ្មាំងដែលទទួលរងការបោសសម្អាតបន្ទាប់ពីអតីតទាហានប៉ូលិសរបបលន់នល់គឺយុទ្ធជនខ្មែរក្រហមនិងប្រជាជនដែលត្រូវចោទប្រកាន់ថាក្បត់នឹងអង្គការ មានបំណងផ្តួលរំលំបក្សដោយការធ្វើរដ្ឋប្រហារនិងបង្កវិប្បទកម្ម ។ វិធីសាស្ត្រទីមួយដែលបក្សកុម្មុយនិស្តកម្ពុជាអនុវត្តចំពោះខ្មាំងផ្ទៃក្នុងគឺ “បញ្ចុះបញ្ចូល” ។ វិធីសាស្ត្រនេះបរាជ័យ ។ ខ្មាំងនៅតែបន្តអុកឡុកនិងបំផ្លាញបក្សដដែល ។ វិធីសាស្ត្រទីពីរគឺកម្ទេចចោល ដោយចាប់ផ្តើមត្រួតពិនិត្យយ៉ាងហ្មត់ចត់អំពី “ធាតុដើមរបស់កម្មាភិបាល” បន្ទាប់មកចាប់ខ្លួននិងសម្លាប់ ។ នៅខែកក្កដា ឆ្នាំ១៩៧៧ នួន ជា បានបំពាក់បំប៉នគោលជំហរកងទ័ពនិងកម្មា-ភិបាលក្នុងភូមិភាគឧត្តរ អំពីផែនការរបស់បក្សចំពោះខ្មាំងដែលជ្រៀតចូលក្នុងជួរដឹកនាំ ជាពិសេសក្នុងសហករណ៍និងក្នុងជួរបក្សឲ្យ“តាមដានដោយធ្វើប្រវត្តិរូបនិងបោសសម្អាតឲ្យអស់” ។ វិធានការទីពីរនេះបានទទួលជោគជ័យយ៉ាងធំធេងដូចការបញ្ជាក់របស់ នួន ជា ប្រាប់គណៈប្រតិភូបក្សពលករដាណឺម៉ាកថា “ការធ្វើប្រវត្តិរូបកម្មាភិបាលបានធ្វើឲ្យយើងរកឃើញនិងដឹងថាកម្មាភិបាលរបស់យើងមួយចំនួនគឺជាភ្នាក់ងាររបស់ខ្មាំង” ។

## ការធ្វើផ្តន្ទាទោស

ដើម្បីកំណត់ប្រភេទខ្មាំងបានច្បាស់លាស់ មជ្ឈិមបក្សបានចេញសេចក្តីណែនាំកំណត់និយមន័យ“ខ្មាំងរបស់អង្គការ” និងកម្រិតនៃការផ្តន្ទាទោសខ្មាំងតាមប្រភេទផ្សេងៗគ្នា ។ ត្រូវផ្តន្ទាទោសដោយអប់រំចំពោះខ្មាំងដែលភ័ន្តច្រឡំ និងផ្តន្ទាទោសដោយប្រហារជីវិតចំពោះខ្មាំងដែលប៉ុនប៉ងប្រឆាំងបដិវត្តន៍ដោយចេតនា ។

សេចក្តីណែនាំរបស់អង្គការថ្នាក់លើត្រូវបានសមមិត្ត សុន សេន ផ្សព្វផ្សាយបន្តដល់លេខាកងពល អនុលេខាកងពល និងប្រធានវរសេនាធំឯករាជបន្តទៀត ។ បើតាមកំណត់ហេតុអង្គប្រជុំកម្រិតនៃការផ្តន្ទាទោសត្រូវកំណត់តាមគោលការណ៍៣គឺ “ប្រភេទទី១ : ប្រភេទអន្តរាយត្រូវសម្រិតសម្រាំងដាច់ខាត ។ ប្រភេទទី២ :


អតីតអគារឃុំឃាំងនៅគុកសង់

ប្រភេទសេរីធម្មតាត្រូវអប់រំជាបន្តបន្ទាប់ក្នុងសាលាអប់រំរបស់យើង ។ ប្រភេទទី៣ : អ្នកដែលទើបតែត្រូវខ្មាំងញុះញង់ ទើបតែការញុះញង់ជាជំហានដំបូងត្រូវអប់រំកសាងកុំឲ្យជឿខ្មាំងទៀត” ។

ប៉ុល ពត ក៏បានប្រកាសអំពីការបែងចែកខ្មាំងនិងការដាក់ទោសទៅតាមប្រភេទទោសនីមួយៗ ប្រាប់គណៈប្រតិភូសមាគមបែលស៊ិក-កម្ពុជា ។ ខ្មាំងដែល ប៉ុល ពត បញ្ជាក់នៅពេលនោះមានតែ២ប្រភេទប៉ុណ្ណោះ ហើយការផ្តន្ទាទោសគឺអប់រំកែប្រែមិនមែនដាក់គុកឡើយ ។ ប៉ុល ពត បញ្ជាក់ថា ចំពោះ“អ្នកមាន

កំហុសធម្មតា ត្រូវទៅបង្កបង្កើនផលជាមួយប្រជាជន ។ ចំណែកអ្នកប្រព្រឹត្តកំហុសច្រើនលើកច្រើនគ្រា ហើយជាប្រភេទពិសពុល ត្រូវទៅបង្កបង្កើនផល នៅការដ្ឋានឬកសិដ្ឋានដោយឡែកដើម្បីកសាងខ្លួន" ។

គោលការណ៍និងវិធានការរបស់បក្សចំពោះខ្មាំងបានជ្រួតជ្រាបដល់គ្រប់ថ្នាក់តាំងពីថ្នាក់ភូមិភាគរហូតដល់ឃុំនៅទូទាំងប្រទេស ។ កម្មាភិបាលមន្ទីរសន្តិសុខម្នាក់សរសេរក្នុងសៀវភៅកំណត់ហេតុរៀនសូត្ររបស់ខ្លួនអំពីវិធានការរបស់បក្សក្នុងការប្រហារជីវិតខ្មាំងថា"ក្រោយថ្ងៃ១៧ មេសា ១៩៧៥ ទោះបីអ្នកឯងចូលសេ.អ៊ី.អា



ពីឆ្នាំណាក៏ដោយ ឲ្យតែរួមសកម្មភាពជាខ្សែសង្វាក់ប្រឆាំងនឹងបដិវត្តន៍មិនព្រមឈប់សោះ អ្នកនោះឯងត្រូវមានទោស ។ ចំពោះយួននិង កា.ហ្សេ.បេ ក៏ដូចជា សេ.អ៊ី.អា ដែរ ឲ្យតែក្រោយ១៧ មេសា ១៩៧៥ មិនព្រមឈប់គឺត្រូវមានទោស" ។

## ការបំពាក់បំប៉ន

តាមការបញ្ជាក់របស់ ប៉ុល ពត ប្រាប់គណៈប្រតិភូសមាគមបែលស៊ីក-កម្ពុជា និងតាមសៀវភៅកំណត់ហេតុរបស់កម្មាភិបាលមន្ទីរស-២១ សាលាកែប្រែនិងអប់រំកសាងខ្លួនគឺជាកន្លែងដែលបង្កើតឡើង"ដើម្បីសង្គ្រោះប្រជាជនដែលវង្វេងវង្វាន់ឲ្យដើរផ្លូវត្រូវឡើងវិញ" ។ វិធីសង្គ្រោះគឺ "អប់រំបំពាក់បំប៉នខាងនយោបាយ សតិអារម្មណ៍ ដើម្បីឲ្យបុគ្គលនោះដាច់ចេញពីគ្រួសារផ្ទាល់ ដាច់ចេញពីបនភៀនក៏អាក្រក់លាមករបស់ខ្លួន" ។ គោលជំហរយុទ្ធវិធី និងការបង្ក្រងជាបទពិសោធន៍ គឺជាវិធីក្នុងការសម្រេចភារកិច្ចនេះ ។ នៅពេលឈានដល់ដំណាក់កាលនេះ សាលាអប់រំត្រូវអនុវត្តផែនការថ្មី ដោយ"សួរចម្លើយខ្មាំងជាប្រជាជនកម្ពុជាដោយមិនបាច់ធ្វើទារុណកម្ម ហើយឲ្យសារភាពឲ្យបាន៨០ភាគរយ មិនបាច់ធ្វើទារុណកម្មហើយឲ្យសារភាពអស់ខ្ទេចខ្ទីបាន៧០ភាគរយ ។ ចំណែកជនបរទេសជាយួន ជាសេ.អ៊ី.អារបស់ចក្រពត្តិ យើងអនុវត្តការងារសន្តិបាល ដាច់ខាត និងទាំងស្រុង និងជាស្ថាពរដដែល" ។

## ការឃុំឃាំង

នួន ជា យល់ថា ខ្មាំងខាងក្នុងដែលសំខាន់ហើយត្រូវតែប្រហារជីវិតចោលមុនបំផុតគឺសំណល់របស់របបលន់ នល់ ។ នួន ជា បានណែនាំកម្មាភិបាលថា "ទាហានចាស់កុំទុកធ្វើអ្វី ព្រោះអានេះវាមិនងាយលះបង់គំនិតចាស់ទេ ដូចនេះត្រូវកម្ទេចចោលទាំងអស់" ។

## ការបែងចែកសិទ្ធិអំណាចក្នុងការកម្ទេចខ្មាំង

នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ គណៈមជ្ឈិមបក្សនៃបក្សកុម្មុយនិស្តកម្ពុជាបានសម្រេចបែងចែកសិទ្ធិសម្រេចកម្ទេចខ្មាំងដល់គ្រប់ភូមិភាគ ក្រសួង មន្ទីរទូទាំងប្រទេស ដូចតទៅ ÷

- នៅក្នុងក្របខ័ណ្ឌមូលដ្ឋានត្រូវអចិន្ត្រៃយ៍ភាគសម្រេច
- ជុំវិញមន្ទីរមជ្ឈិមត្រូវគណៈមន្ទីរមជ្ឈិមសម្រេច
- តំបន់ឯករាជ្យត្រូវអចិន្ត្រៃយ៍សម្រេច
- កងទ័ពមជ្ឈិមត្រូវសេនាធិការសម្រេច

ប៉ុល ពត ថ្លែងបញ្ជាក់អំពីជោគជ័យនៃការបែងចែកសិទ្ធិដល់ថ្នាក់ក្រោមក្នុងការចូលរួមធ្វើឲ្យមានស្ថិរភាពទូទាំងប្រទេស ប្រាប់គណៈប្រតិភូសមាគមបែលស៊ីក-កម្ពុជា នៅទីក្រុងភ្នំពេញ នៅថ្ងៃទី៩ ខែសីហា ឆ្នាំ១៩៧៨ ថា ស្ថិរភាពនៃកម្ពុជាប្រជាធិបតេយ្យកើតឡើងដោយសារមានការចូលរួមពីគ្រប់ថ្នាក់ ហើយប្រជាជនដើរតួនាទីសំខាន់បំផុត ។ "សន្តិសុខរបស់យើងគឺ

សន្តិសុខសាធារណៈ រ៉ាប់រងជាមូលដ្ឋានដោយប្រជាជនខ្លួនឯង ពីព្រោះនយោបាយយើងគឺបង្ការមិនឲ្យមានអសន្តិសុខជាមុន ។ បានន័យថា ប្រជាជនដោះស្រាយទំនាស់តូចធំផ្សេងៗជាមុន ស្រេចនៅក្នុងផ្ទៃក្នុងគេ...” ។

បទវិចារណកថារបស់បក្សនៅក្នុងសៀវភៅ “ទង់បដិវត្ត លេខពិសេស” បានប្រៀបធៀបខ្មាំងខាងក្នុងទៅនឹង “ដង្កូវក្នុងសាច់” ហើយវិធានការចំពោះដង្កូវនេះគឺ “ឆ្កឹះចោលឲ្យអស់” ។ ចំពោះសមមិត្ត ឌុច គណៈមន្ទីរស-២១ ខ្មាំងខាងក្នុងគឺជា “សត្រូវ” គឺជា “ដង្កូវ” និងជា “មេរោគ” ដែលកើតចេញក្នុងសាច់ ហើយបំផ្លាញសាច់នោះឲ្យខូចស្អុយរលួយ ។ វិធានការចំពោះដង្កូវក្នុងសាច់នោះគឺដាច់ខាតត្រូវតែ“កម្ចាត់” ហើយការកម្ចាត់ខ្មាំងនេះផ្អែកសំខាន់ត្រូវលើជំហរវណ្ណៈបដិវត្ត ។ កម្មាភិបាលមន្ទីរសន្តិសុខអនុវត្តការងារសន្តិបាលដោយសស្រាក់សស្រាំ ដោយសារការងារនេះជាការងារដោះស្រាយទំនាស់ស្លាប់រស់រវាងបដិវត្តន៍និងខ្មាំង ។ សៀវភៅស្ថិតិសន្តិបាលស-២១កំណត់ថា “ការងារសន្តិបាលជាការងារតស៊ូវណ្ណៈ ជាការងារគាស់រំលើងឫសគល់វណ្ណៈជិះជាន់ ហើយការងារនេះទៀតសោតជាការងារការពារប្រទេសនិងកសាងបដិវត្តន៍សង្គមនិយម” ។

លក្ខន្តិកៈបក្សកុម្មុយនិស្តកម្ពុជាបានកំណត់ឲ្យមន្ទីរសន្តិសុខដំណើរការ ហើយត្រូវតែមានទំនាក់ទំនងគ្នាពីមួយទៅមួយមិនឲ្យដាច់ ។ “អង្គការបក្សគ្រប់ជាន់ថ្នាក់ត្រូវអនុវត្តភារកិច្ចក្នុងចំណោមមហាជន ហើយអង្គការបក្សគ្រប់ជាន់ថ្នាក់ត្រូវតែរាយការណ៍អំពីសភាពការណ៍និងភារកិច្ចដែលខ្លួនបានធ្វើទៅតាមកាលកំណត់នីមួយៗ” ។

ដំណើរការប្រហារជីវិតខ្មាំងនៅក្នុងមន្ទីរសន្តិសុខមានសកម្មភាពយ៉ាងខ្លាំងក្លា ដែលសូម្បីតែសមមិត្ត ខៀវ សំផន គណៈប្រធានរដ្ឋ និងជាប្រធានមន្ទីរ៨៧០ ក៏មានការភ្ញាក់ផ្អើល ។ ខៀវ សំផន បញ្ជាក់ថា គាត់ភ្ញាក់ផ្អើលបន្ទាប់ពីបានដឹងអំពីការប្រហារជីវិតប្រជាជនដ៏ច្រើនសន្ធឹកសន្ធាប់នៅក្នុងខេត្តព្រះវិហារ និងតំបន់១០៣ ។ ខៀវ សំផន បញ្ជាក់ថា ការដឹងឮរបស់គាត់កើតឡើងដោយចៃដន្យនៅឆ្នាំ១៩៧៨ ដែលពេលនោះគាត់អះអាងថាជាសមាជិកមន្ទីរ៨៧០ ។

សមមិត្ត ឈិត ជឿន ហៅ “តាម៉ុក ឬ តា១៥” លេខាភូមិភាគនិរតី និងកម្មាភិបាលដឹកនាំគ្រប់លំដាប់ថ្នាក់ បានអនុវត្តតាមរដ្ឋធម្មនុញ្ញនិងតាមលក្ខន្តិកៈបក្សក្នុងការតាមរកនិងកម្ទេចខ្មាំងយ៉ាងមានប្រសិទ្ធភាពបំផុត ។

តាម៉ុក មានឈ្មោះដើម អ៊ុង ជឿន ហៅ អាចារ្យជឿន កើតនៅឆ្នាំ១៩២៦ ក្នុងភូមិប្រកាប ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ ។ ឪពុកឈ្មោះ អ៊ុង ព្រាក ម្តាយឈ្មោះ ទូច សុច ។ តាម៉ុក មានបងប្អូន៧នាក់ ប្រុស៣ ស្រី៤ ហើយ តាម៉ុកជាកូនច្បងទី១ ។ តាម៉ុក មានប្រពន្ធឈ្មោះ អ៊ុក ខឹម និងមានកូនស្រី៤នាក់ ។ តាម៉ុកធ្លាប់បួសរៀននៅវត្ត ហើយរៀបចប់គម្ពីរព្រះត្រៃបិដក ។ នៅឆ្នាំ១៩៤៩ តាម៉ុក បានក្លាយជាប្រធានឥស្សរៈស្រុកត្រាំកក់ ខេត្តតាកែវ ។ តាម៉ុក ចូលបក្សកុម្មុយនិស្តឥណ្ឌូចិននៅឆ្នាំ១៩៥០ និងចូលបក្សពលករនៅឆ្នាំ១៩៦៣ ។ តាម៉ុក ក្លាយជាលេខាបក្សភូមិភាគនិរតីឆ្នាំ១៩៦៨ និងក្រោយមកបានក្លាយជាសមាជិកគណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនិស្តកម្ពុជា ។ តាម៉ុក ត្រូវចាប់ខ្លួនដោយកងទ័ពរាជរដ្ឋាភិបាលកម្ពុជានៅថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៩៩ និងដាក់គុកនៅតុលាការយោធានៅទីក្រុងភ្នំពេញពីបទបង្កសង្គ្រាមខុទ្ទាម ។ នៅថ្ងៃទី៨ ខែមីនា ឆ្នាំ២០០២ តាម៉ុក ត្រូវតុលាការកម្ពុជាសម្រេចឃុំខ្លួនបន្តចំនួន៣ឆ្នាំទៀត ក្រោមបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។

តាម៉ុក និងកម្មាភិបាលបដិវត្តន៍របស់គាត់ បានបង្កើតឲ្យមានមន្ទីរសន្តិសុខក្នុងភូមិភាគនិរតីតាំងពីថ្នាក់ឃុំ ស្រុក តំបន់ និងភូមិភាគ ។ មន្ទីរសន្តិសុខក្នុងភូមិភាគនិរតីមានចំនួនសរុប ២៥០ ដែលបែងចែកជាមន្ទីរឃុំឃាំងថ្នាក់ឃុំចំនួន២២៥ ថ្នាក់ស្រុកចំនួន២១ ថ្នាក់តំបន់ចំនួន៣ និងថ្នាក់ភូមិភាគចំនួន១ ។

មន្ទីរសន្តិសុខទាំងអស់ត្រូវបានបង្កើតឡើងដើម្បីបម្រើតាមគោលបំណងធំរួមគឺ ឃុំឃាំង សួរចម្លើយ និងប្រហារជីវិតអ្នកទោស ។ ចំនួនអ្នកទោសកើនឡើងពីតិចនៅមន្ទីរសន្តិសុខថ្នាក់ក្រោម ទៅច្រើននៅមន្ទីរសន្តិសុខថ្នាក់លើ ប៉ុន្តែដំណើរការធ្វើទារុណកម្ម សួរចម្លើយ និងប្រហារជីវិត កើនឡើងខ្លាំងបំផុតនៅមន្ទីរសន្តិសុខថ្នាក់កណ្តាល គឺមន្ទីរអប់រំស្រុកនិងមន្ទីរសន្តិសុខតំបន់ ។

មន្ទីរឈ្លបឃុំសម្រាប់ឃុំឃាំងប្រជាជនដែលមានទោសស្រាលដូចជាលួចបេះបោចបន្លែបផ្ការបន្តិចបន្តួចនិងខ្ជិលច្រអូសហើយត្រូវអង្គការហៅថា "ប្រជាជនសេរី" ។ មន្ទីរឈ្លបឃុំមានមុខងារ២ គឺជាមន្ទីរឃុំឃាំងបណ្តោះអាសន្ន និងជាមន្ទីរលត់ដំ ។ មន្ទីរឈ្លបឃុំអាចឃុំឃាំងអ្នកទោសពី៣នាក់ទៅ១០នាក់ ។ អ្នកទោសត្រូវចាក់សោបង្ខាំងក្នុងបន្ទប់ ប៉ុន្តែមិនមែនសុទ្ធតែជាប់ខ្នោះច្រវាក់ឡើយ ។ អ្នកទោសត្រូវធ្វើការងារតាមបញ្ជារបស់ប្រធានឈ្លប និងត្រូវឈ្លបយាមកាមជាប់ជានិច្ច ។ ពេលខ្លះអ្នកទោសត្រូវធ្វើការងាររហូតដល់កណ្តាលអធ្រាត្រទើបបានឈប់សម្រាក ។ អ្នកទោសទទួលអាហារក្នុងមួយថ្ងៃ២ពេល គឺម៉ោង១១កន្លះឬ១២ថ្ងៃត្រង់និងម៉ោង៥ល្ងាច ។ អ្នកទោសត្រូវសួរនាំដើម្បីធ្វើកំណត់ហេតុ ប៉ុន្តែពុំមានការវាយធ្វើបាបឡើយ ។ អ្នកទោសនៅមន្ទីរឈ្លបឃុំត្រូវប្រឈមមុខនឹងវាសនា២គឺ ទី១ត្រូវដោះលែងបន្ទាប់ពីលត់ដំការងារមួយរយៈ និងទី២ត្រូវបញ្ជូនទៅមន្ទីរអប់រំស្រុក ។ មូលហេតុនៃការដោះលែងឲ្យត្រឡប់ទៅតាមកងនិងសហករណ៍វិញដោយសារអ្នកទោសឆ្លងកាត់ការលត់ដំហើយត្រូវមើលឃើញថាបានកែប្រែខ្លួន ។ អ្នកទោសដែលត្រូវបញ្ជូនបន្តទៅមន្ទីរអប់រំស្រុកគឺអ្នកទោសដែលឆ្មាំគុកមើលឃើញថាមិនបានកែខ្លួន ។ មន្ទីរឈ្លបឃុំស្ថិតក្រោមការគ្រប់គ្រងរបស់គណៈឃុំនិងប្រធានឈ្លបឃុំ ។

មន្ទីរអប់រំស្រុកសម្រាប់ឃុំឃាំងអតីតទាហានប៉ូលិសរបបលន់នល់ និងប្រជាជនដែលបានធ្វើឬប៉ុនប៉ងធ្វើសកម្មភាពប្រឆាំងនឹងអង្គការ ។ មន្ទីរអប់រំស្រុកបំពេញមុខងារឃុំឃាំង សួរចម្លើយ និងប្រហារជីវិត ។ មន្ទីរអប់រំស្រុកមានអ្នកទោសបានពី៤០ទៅ៤០០នាក់ ។ បន្ទប់ឃុំឃាំងត្រូវបែងចែកជា២ប្រភេទសម្រាប់អ្នកទោសធ្ងន់និងអ្នកទោសស្រាល ។ អ្នកទោសស្រាលជាប់ខ្នោះជាជួរពី១៥ទៅ២៥នាក់ក្នុងបន្ទប់ធំ និងត្រូវបញ្ចេញឲ្យទៅធ្វើការងារនៅពេលថ្ងៃ ។ អ្នកទោសធ្ងន់ត្រូវដាក់ខ្នោះក្នុងបន្ទប់តូចៗដាច់ដោយឡែក ។ ខ្នោះសម្រាប់ដាក់អ្នកទោសគឺជាដែករនុកទំហំប៉ុនមេដៃមនុស្សចាស់ និងដែកដែលកាច់ជារាងអក្សរយូ "U" គួចក្បាលជាប្រហោងសំរាប់ស៊កដែករនុកចូល ។ កុមារដែលត្រូវចាប់ខ្លួនមកតាមឪពុកម្តាយ ត្រូវឃុំឃាំងក្នុងបន្ទប់ជាមួយម្តាយប៉ុន្តែមិនត្រូវដាក់ខ្នោះឡើយ ។ កុមារទាំងនោះស្ថិតក្នុងស្ថានភាពហេវហត់ ខ្វះអាហារ មានជំងឺ និងយំស្រែកទារចំណីដោយក្តីស្រេកឃ្លាន ។ របបអាហាររបស់អ្នកទោសនៅមន្ទីរអប់រំស្រុកមានបបររាវ២ពេលក្នុងមួយថ្ងៃ គឺពេលថ្ងៃត្រង់និងពេលល្ងាច ។ អ្នកទោសដែលមកដល់មុនត្រូវនាំចេញទៅសួរចម្លើយមុន ហើយភាគច្រើនក៏ត្រូវនាំទៅសម្លាប់មុនដែរ ។ ការសម្លាប់អ្នកទោសប្រែប្រួលតាមចំនួនជាក់ស្តែងនៃអ្នកទោសក្នុងមន្ទីរអប់រំនីមួយៗ ។ ឧបករណ៍សម្រាប់ប្រហារជីវិតរួមមានកាំបិត ដាវ ពូថៅ ត្បូងចបដែកក្អៀរទេះ និងគល់ឫស្សី ។ មូលហេតុនៃការស្លាប់របស់អ្នកទោសមាន៣គឺ ១) ស្លាប់ដោយទារុណកម្មក្នុងពេលសួរចម្លើយ ឬស្លាប់ប៉ុន្មានថ្ងៃបន្ទាប់ពីសួរចម្លើយដោយសារគ្រាំគ្រា ២) ស្លាប់ដោយការស្រេកឃ្លាន និង ៣) ស្លាប់ដោយការសម្លាប់ ។ មន្ទីរអប់រំស្រុកស្ថិតក្រោមការគ្រប់គ្រងរបស់អង្គការតំបន់ អង្គការស្រុក និងប្រធានមន្ទីរអប់រំស្រុក ។

មន្ទីរសន្តិសុខតំបន់សម្រាប់ឃុំឃាំងអតីតទាហានប៉ូលិសរបបលន់នល់និងកម្មាភិបាលខ្មែរក្រហមដែលត្រូវចោទប្រកាន់ថាក្បត់នឹងអង្គការជាខ្សែរសន្ទាក់ និងជាកន្លែងទទួលយកអ្នកទោសដែលបញ្ជូនមកពីមន្ទីរអប់រំស្រុក ។ មន្ទីរសន្តិសុខតំបន់បំពេញមុខងារជាមន្ទីរឃុំឃាំង សួរចម្លើយ និងប្រហារជីវិតខ្លាំងនៅក្នុងតំបន់ ។ មន្ទីរសន្តិសុខតំបន់មានអ្នកទោសពី៥រយទៅ៨រយនាក់ ។ ខ្នោះសម្រាប់ដាក់អ្នកទោសមានទម្រង់ដូចខ្នោះដែលប្រើប្រាស់នៅមន្ទីរអប់រំស្រុក សូម្បីតែស្ថានភាពរបស់អ្នកទោស របបអាហារ ការសួរចម្លើយ ការស្លាប់ ការសម្លាប់អ្នកទោស និងវិធីសម្លាប់អ្នកទោសក៏ដូចនៅមន្ទីរអប់រំស្រុកដែរ ។ មន្ទីរសន្តិសុខតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់គណៈតំបន់និងប្រធានមន្ទីរសន្តិសុខតំបន់ ។

មន្ទីរសន្តិសុខភូមិភាគនិរតីមានទីតាំងនៅភ្នំសន្លុង ក្នុងស្រុកត្រាំងខេត្តតាកែវ ។ មន្ទីរសន្តិសុខនេះត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៧៦សម្រាប់ឃុំឃាំងកងទ័ពយុទ្ធជនខ្មែរក្រហមដែលត្រូវអង្គការចោទថាក្បត់ រួមទាំងប្រពន្ធកូនសាច់ញាតិរបស់អ្នកទាំងនោះផង ។ អ្នកទោសនៅក្នុងមន្ទីរសន្តិសុខភូមិភាគនិរតីអាចមានចំនួនពី៥ពាន់ទៅ១ម៉ឺននាក់ ។ មន្ទីរសន្តិសុខភូមិភាគនិរតីជាកន្លែងលត់ដំធ្ងន់ធ្ងរហើយរបបហូបចុកក៏កាន់តែតិច ។ ប្រភេទទោសដែលជាប់នៅ

មន្ទីរសន្តិសុខភូមិភាគ រួមមាន លួចរបស់របរសមូហភាព លួចរត់គេចពីអង្គភាព ធ្វើការមិនពេញដៃពេញជើង។ល។ អ្នកទោសត្រូវឃុំឃាំងក្នុងអគារដែលសង់នៅក្នុងចម្ការស្វាយ នៅខាងជើងភ្នំវង់ចាំសួរចម្លើយនិងប្រហារជីវិត។ មន្ទីរសន្តិសុខភូមិភាគនិរតីស្ថិតក្រោមការគ្រប់គ្រងរបស់ប្រធានមន្ទីរសន្តិសុខ និងលេខាភូមិភាគនិរតីឈ្មោះ ឈិត ជឿន ហៅ តាម៉ុក។

ការប្រគល់សិទ្ធិស្វ័យសម្រេចរបស់គណៈមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជាដល់ក្រសួង មន្ទីរ និងភូមិភាគ បានបង្កើតឲ្យមានការចាប់ខ្លួននិងសម្លាប់ប្រជាជននៅក្នុងភូមិភាគនិរតីកាន់តែច្រើនឡើង។ គោលនយោបាយនេះត្រូវបានផ្សព្វផ្សាយពីមជ្ឈិមបន្តរហូតដល់ភូមិភាគ តំបន់ ស្រុក ឃុំ សហករណ៍ និងភូមិ ហើយទំនាក់ទំនងការងាររវាងថ្នាក់លើមកថ្នាក់ក្រោមប្រៀបដូចជាចលនាកង់រង្វង់ដែលវិលមិនឈប់ឈរ។ ប្រជាជន ប្រធានកង ប្រធានភូមិ គណៈឃុំ គណៈសហករណ៍ គឺជាអ្នករាយការណ៍ជូនគណៈស្រុកអំពីសមាសភាពមិនល្អនិងអំពីខ្មាំង។ បន្ទាប់ពីពិនិត្យរបាយការណ៍រួចគណៈស្រុកជាអ្នកសម្រេចឲ្យគណៈឃុំចាប់ខ្លួនខ្មាំង។ អ្នកទោសស្រាលគ្មានពាក់ព័ន្ធនិន្នាការនយោបាយវណ្ណៈ ត្រូវជាប់ឃុំឃាំងក្នុងមន្ទីរឈ្លបឃុំ។ អ្នកទោសធ្ងន់ត្រូវបញ្ជូនបន្តទៅមន្ទីរអប់រំស្រុក។ ប្រធានមន្ទីរអប់រំស្រុកបំពេញមុខងារឃុំឃាំង សួរចម្លើយ និងបញ្ជូនរបាយការណ៍និងចម្លើយសារភាពរបស់អ្នកទោសទៅគណៈតំបន់។ បន្ទាប់ពីពិនិត្យរបាយការណ៍និងចម្លើយសារភាពរបស់អ្នកទោសរួច គណៈតំបន់ចេញបញ្ជាឲ្យប្រធានមន្ទីរអប់រំស្រុកសម្លាប់អ្នកទោស។ អ្នកទោសដែលគណៈតំបន់យល់ថាមានពាក់ព័ន្ធខ្មាំងជាខ្សែសង្វាក់ ត្រូវបញ្ជូនបន្តទៅមន្ទីរសន្តិសុខតំបន់។ ប្រធានសន្តិសុខតំបន់បំពេញមុខងារឃុំឃាំង សួរចម្លើយរួចបញ្ជូនរបាយការណ៍និងចម្លើយសារភាពរបស់អ្នកទោសទៅគណៈភូមិភាគ។ បន្ទាប់ពីពិនិត្យរបាយការណ៍និងចម្លើយសារភាពរបស់អ្នកទោសរួច គណៈភូមិភាគជាអ្នកចេញបញ្ជាឲ្យប្រធានមន្ទីរសន្តិសុខតំបន់សម្លាប់អ្នកទោស។ អ្នកទោសដែលគណៈភូមិភាគយល់ថាមានជាប់ពាក់ព័ន្ធនឹងផែនការខ្សែសង្វាក់ប្រឆាំងនឹងអង្គការ ឬមានទំនាក់ទំនងនឹងគណៈមជ្ឈិម គណៈភូមិភាគធ្វើរបាយការណ៍ជូនគណៈមន្ទីរស-២១។ គណៈមន្ទីរស-២១ពិនិត្យរបាយការណ៍និងចម្លើយសារភាពរបស់អ្នកទោសរួចសម្រេចឲ្យកម្មាភិបាលមន្ទីរស-២១ ចាត់ការចុះទៅចាប់និងទទួលយកអ្នកទោសពីភូមិភាគ។

ពេលដែលអ្នកទោសត្រូវចាប់និងបញ្ជូនមកដល់មន្ទីរស-២១ មន្ទីរស-២១បំពេញមុខងារឃុំឃាំង សួរចម្លើយ និងធ្វើរបាយ-ការណ៍និងចម្លើយសារភាពរបស់អ្នកទោសជូនគណៈមជ្ឈិមបក្សពិនិត្យ។ គណៈមជ្ឈិមបក្សពិនិត្យរបាយការណ៍និងចម្លើយសារភាពរបស់អ្នកទោសរួចចេញបញ្ជាឲ្យគណៈមន្ទីរស-២១ប្រហារជីវិតអ្នកទោស។ ឈ្មោះមនុស្សដែលជាប់ពាក់ព័ន្ធក្នុងចម្លើយសារភាពរបស់អ្នកទោសមន្ទីរស-២១ ត្រូវបានផ្ញើបន្តទៅអង្គការភូមិភាគដើម្បីចាប់ខ្លួន។ **(នៅមានត)**

**អៀ ម៉េងទ្រី**

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុមួយចំនួនដូចតទៅ÷

- វិទ្យុ FM១០២MHz របស់មណ្ឌលពត៌មានស្ត្រីកម្ពុជា រៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង៧:៣០-៧:៤៥ល្ងាច។
- វិទ្យុ FM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង៧-៧:៣០ព្រឹក និងម៉ោង៧:០០-៧:៣០ល្ងាច។
- វិទ្យុ FM៩៩MHz ខេត្តព្រះវិហារ រៀងរាល់ថ្ងៃនៅម៉ោង៧:០០-៧:៣០ព្រឹក និងម៉ោង៦:៣០-៧:០០ ល្ងាច។
- វិទ្យុ FM១០៣.២៥MHz ខេត្តបាត់ដំបង រៀងរាល់ថ្ងៃនៅម៉ោង៩:០០-៩:៣០ព្រឹក និងម៉ោង៣:០០-៣:៣០រសៀល។

នៅក្នុងពេលដ៏ខ្លីខាងមុខនេះមជ្ឈមណ្ឌលយើងនឹងពង្រីកការផ្សព្វផ្សាយនៅវិទ្យុខេត្តសៀមរាបទៀត។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើង និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ។ **ឡាត់ សោភ័ណ និង ឡេង រតនៈ**

# ស្វែងរករូបថតជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលបានថតនៅរវាងឆ្នាំ១៩៦០ដល់ឆ្នាំ១៩៧៥

ថ្មីៗនេះមជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពផ្សាយសៀវភៅមួយក្បាលដែលមានចំណងជើងថា "ជីវិតក្នុងភាពនឹងថ្កល់" ដែលបង្ហាញអំពីរូបថតជាច្រើនដែលបន្សល់ទុកពីសម័យខ្មែរក្រហម ។ សៀវភៅនេះរៀបរាប់អំពីដំណើរជីវិតរបស់បុរស៣៥នាក់និងស្ត្រី១៦នាក់មកពីខេត្តកំពង់ចាម កណ្តាល កំពង់ធំ និងតាកែវ ដែលបានចូលបម្រើបដិវត្តន៍ខ្មែរក្រហម ។ មនុស្សចំនួន៣៩នាក់ ក្នុងចំណោម៥១នាក់ដែលបានចុះនៅក្នុងសៀវភៅនេះបានស្លាប់នៅមន្ទីរសន្តិសុខ ស-២១ ហើយមានតែ៩នាក់ប៉ុណ្ណោះដែលមានជីវិតរហូតមកដល់សព្វថ្ងៃនេះ ។

នៅក្នុងពេលឆាប់ៗខាងមុខនេះ យើងនឹងអានអត្ថបទស្តីពីរឿងរ៉ាវរបស់មនុស្សមួយចំនួននៅក្នុងសៀវភៅនេះផ្សាយតាមរលកធាតុអាកាសវិទ្យុ *FM102MHz* ទីក្រុងភ្នំពេញ វិទ្យុ *FM93.25MHz* ខេត្តកំពត វិទ្យុ *FM99MHz* ខេត្តព្រះវិហារ និងវិទ្យុ*FM* ១០៣.២៥*MHz* ខេត្តបាត់ដំបង ។

ក្នុងការសរសេរសៀវភៅនេះ យើងបានធ្វើសម្ភាសន៍អតីតកម្មាភិបាលខ្មែរក្រហម ប្រជាជនមូលដ្ឋាន និងសមាជិកក្រុមគ្រួសាររបស់អ្នកទាំងនោះ ។ សាក្សីរបស់យើងបានឲ្យរូបថតជាច្រើនមកយើង ដែលភាគច្រើននៃរូបថតទាំងនោះបានថតមុនពេលខ្មែរក្រហមកាន់កាប់ប្រទេសកម្ពុជា ប៉ុន្តែក៏មានរូបថតកម្មាភិបាលមួយចំនួនបានថតក្នុងអំឡុងពេលចូលបម្រើបដិវត្តន៍ខ្មែរក្រហមដែរ ។

សៀវភៅដែលរួមមានទាំងរូបថតនិងរឿងរ៉ាវអមជាមួយនេះបានទទួលជំនួយពី "ទាយជ្ជទានជាតិដើម្បីប្រជាធិបតេយ្យ" ។ សៀវភៅនេះបង្ហាញថា អ្នកដែលបានចូលបម្រើបដិវត្តន៍ខ្មែរក្រហមមានក្តីសង្ឃឹមនិងការចង់បានដូចជាប្រជាជនកម្ពុជាដទៃទៀត ហើយអ្នកទាំងនោះក៏បានជួបប្រទះនូវការលំបាកជាច្រើនដែរ រួមទាំងការបាត់បង់មនុស្សជាទីស្រលាញ់របស់ខ្លួនផង ។ យើងសង្ឃឹមថាសៀវភៅនេះនឹងជួយឲ្យប្រជាជនកម្ពុជាយល់ថា ទាំងជនរងគ្រោះនិងជនដៃដល់គឺជាមនុស្សដូចគ្នា ។

ឥឡូវនេះ យើងមានគម្រោងសរសេរសៀវភៅថ្មីមួយក្បាលទៀតដែលរៀបរាប់អំពីដំណើររឿងរបស់ប្រជាជនថ្មីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ប្រសិនបើលោកអ្នកឬសាច់ញាតិណាម្នាក់របស់លោកអ្នកជាប្រជាជនថ្មី ហើយចង់រួមចំណែកចែករំលែករឿងរ៉ាវនៅក្នុងសៀវភៅនេះយើងនឹងទៅសម្ភាសលោកអ្នកដោយផ្ទាល់ ។ យើងសូមស្វាគមន៍ចំពោះការចូលរួមចំណែករបស់ប្រជាពលរដ្ឋខ្មែរទាំងក្នុងនិងក្រៅប្រទេស ហើយដោយសារតែរូបថតទាំងនេះជាផ្នែកមួយដែលមានសារសំខាន់សម្រាប់សៀវភៅ យើងគ្រាន់តែស្នើសុំការជួយជ្រោមជ្រែងពីសំណាក់ប្រជាពលរដ្ឋដែលស្ម័គ្រចិត្តចែករំលែករូបថតរបស់ខ្លួនតែប៉ុណ្ណោះ ។ រូបថតទាំងនោះចាំបាច់ ត្រូវតែជារូបថតដែលបានថតមុនឬក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ យើងនឹងថតចម្លងរូបថតរបស់អស់លោកអ្នកបន្ទាប់មក នឹងប្រគល់រូបថតដើមជូនទៅលោកអ្នកវិញ ។



រូបថតរៀបអាពាហ៍ពិពាហ៍ សំ ស៊ីនថៃ និង ហួត ផាន់ណារី ក្នុងឆ្នាំ១៩៦៨

សូមលោកអ្នកទាក់ទងមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈទូរស័ព្ទលេខ០២៣ ២១១ ៨៧៥ ឬផ្ញើលិខិតមកប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញឬទាក់ទងតាមអ៊ីមែល dccam@online.com.kh ។

សូមអរគុណ ។

# ដំណើរទស្សនកិច្ចលើកទី៨ទៅកាន់អង្គជំនុំជម្រះវិសាមញ្ញ







# នៅក្នុងតុលាការកម្ពុជា ថ្ងៃទី២២-២៣ ខែឧសភា ឆ្នាំ២០០៦









# អ្នកបកប្រែភាសាខ្មែរនៅវិទ្យុជាតិឡាវ

ចាប់ពីឆ្នាំ១៩៧៤ ដល់ថ្ងៃទី១៧ ខែមេសា ដែលជាថ្ងៃកងទ័ពខ្មែរក្រហមបានរំដោះទីក្រុងភ្នំពេញនិងគ្រប់គ្រងទូទាំងប្រទេស ខ្ញុំមានឋានៈជាអនុសេនីយ៍ត្រី អត្តលេខ ២៤៨៩៦ ប្រចាំការនៅតំបន់ប្រតិបត្តិការសឹករងក្រុងប៉ៃលិន ។

នៅថ្ងៃបុណ្យចូលឆ្នាំថ្មីទាំងបីថ្ងៃនាឆ្នាំ១៩៧៥ នៅទីក្រុងប៉ៃលិន ប្រជាពលរដ្ឋ មន្ត្រីរាជការ បានប្រារព្ធពិធីបុណ្យចូលឆ្នាំថ្មីតាមប្រពៃណីជាតិយ៉ាងគគ្រឹកគគ្រេង ដោយមានកម្មវិធីប្រគំតន្ត្រីនៅជាប់សួនកុមារក្បែរផ្ទះវរសេនីយ៍ឯក ហ៊ុន ទន អភិបាលក្រុងប៉ៃលិន ដោយមានអ្នកចម្រៀងមកពីភ្នំពេញដូចជា រស់ សេរីសុទ្ធា, សូ សាវឿន និងអ្នកចម្រៀងផ្សេងៗទៀត មកច្រៀងជូនទស្សនិកជននៅទីក្រុងប៉ៃលិន ។ ចំណែកខ្ញុំដែលមានចំណង់ចំណូលចិត្តខាងវិស័យសិល្បៈ ក៏បានទៅទស្សនាតន្ត្រីរាល់យប់ ។ នៅពេលអ្នកចម្រៀង រស់ សេរីសុទ្ធា ឡើងច្រៀងម្តងៗ មានស្នូរទះដៃយ៉ាងកងរំពងពីទស្សនិកជន ។ កុងសៃត្បូងមួយចំនួនបានផ្តល់រង្វាន់លើកទឹកចិត្តដល់អ្នកចម្រៀងរូបនេះដោយបំពាក់កម្រងផ្កានិងផ្តល់ថវិការាប់លានរៀល ។ បទចម្រៀងដែលអ្នកទីក្រុងប៉ៃលិនចូលចិត្តគឺបទណាដែលមានខ្លឹមសារទាក់ទងនឹងទឹកដីទីក្រុងប៉ៃលិន និងបទ “ស្អែកអូនលាបងហើយ” ។ ក្នុងមួយយប់ៗ រស់ សេរីសុទ្ធា ទទួលបានកូនលិខិតសំណូមពរពីទស្សនិកជនឲ្យច្រៀងបទ “ជ្រោះអូរយ៉ាដាវ” និងបទ “ស្អែកអូនលាបងហើយ” ។ ពេលអ្នកចម្រៀងរូបនេះច្រៀងចប់មួយបទៗ ស្នូរទះដៃគាំទ្រលាន់ឮកាន់តែកងរំពងនៅក្នុងទីលានសម្តែងសិល្បៈ ។

នៅយប់ថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៥ គឺជាយប់ចុងក្រោយបង្អស់នៃការប្រគំតន្ត្រី នាងច្រៀងផ្តាំផ្ញើទស្សនិកជនទីក្រុងប៉ៃលិននូវបទ “ស្អែកអូនលាបងហើយ” ។

ទស្សនិកជនបានអង្វរ រស់ សេរីសុទ្ធា កុំអាលប្រញាប់ត្រឡប់ទៅភ្នំពេញវិញអី ។ ពេលនោះ រស់ សេរីសុទ្ធា ឆ្លើយតបថា “ខ្ញុំទៅតែខ្លួនទេ ប៉ុន្តែចិត្តគំនិតនិងអារម្មណ៍សុំបន្តុបទុកក្នុងអារម្មណ៍ទស្សនិកជនក្នុងទឹកដីត្បូងពេជ្រជាប់ជានិច្ច” ។

ព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ លោកអភិបាលក្រុងប៉ៃលិនបានទទួលសារទូរលេខពីទីក្រុងភ្នំពេញដែលមានខ្លឹមសារថា “ទីក្រុងភ្នំពេញនឹងត្រូវរំដោះនាពេលប៉ុន្មានម៉ោងខាងមុខនេះហើយ អគ្គបញ្ជាការកងទ័ពជាន់ខ្ពស់ចេញបទបញ្ជាឲ្យអភិបាលខេត្ត-ក្រុង ដកទ័ពទៅព្រំដែនកម្ពុជា-ថៃនៅថ្ងៃទី១៧ ខែមេសា ជាបន្ទាន់” ។

នៅពេលនោះ អភិបាលក្រុងប៉ៃលិនបានប្រជុំនាយទាហានទាំងអស់នៅក្នុងតំបន់ប្រតិបត្តិការសឹកក្រុងប៉ៃលិន ក៏ដូចជាអង្គភាពយោធាឈរជើងតាមចំណុចផ្សេងៗបញ្ជាឲ្យដកមកឈរជើងនៅព្រំដែនកម្ពុជា-ថៃ ។ ក្រោយពេលប្រជុំ ខ្ញុំ (ភូ គឹមមឿ) លោកអនុសេនីយ៍ឯក ស៊ឹម ជីម៉េង, លោក ម៉ា ឡៅពី, អ្នកនាង សូ សាវឿន និងគ្រួសារទាហានដទៃទៀត បានរៀបចំអីវ៉ាន់ដែលអាចយកទៅបានដូចជា ម៉ូតូ ឡាន អង្ករ សម្លៀកបំពាក់មួយចំនួនរួចមកជួបជុំគ្នានៅមុខផ្ទះលោកអភិបាលក្រុងប៉ៃលិន រង់ចាំកងរថក្រោះ M១១៣ ដកថយពីត្រែងមកប៉ៃលិនឲ្យបានមុនម៉ោង ១២ថ្ងៃត្រង់ ។

ពេលនោះភាពជ្រួលច្របល់ចាប់ផ្តើមកើតឡើង ។ មានដំណឹងថាខ្មែរក្រហមបម្រុងស្ទាក់បង្កប់មិនកាត់ផ្លូវវាយស្ទាក់កុំឲ្យដំណើរដកទ័ពពីក្រុងប៉ៃលិនទៅព្រំដែនកម្ពុជា-ថៃប្រព្រឹត្តទៅបាន ។ មួយសន្ទុះក្រោយមក លោកអភិបាលក្រុងប៉ៃលិនបញ្ជាតាមវិទ្យុទាក់ទង C២៥ ថា “ខ្ញុំជាអភិបាលខេត្តក្រុងប៉ៃលិន បញ្ជាមកគ្រប់មេបញ្ជាការ មេបញ្ជាការរងដែលឈរជើងតាមចំណុចគោលដៅផ្សេងៗ កុំដាក់អាវុធចុះចាញ់ខ្មែរក្រហមឲ្យសោះ ។ ត្រូវដកទ័ពទាំងអស់ចេញដំណើរទៅព្រំដែនកម្ពុជា-ថៃ” ។ ពេលនោះអភិបាលក្រុងប៉ៃលិន បញ្ជាកងរថក្រោះ M១១៣ បើកផ្លូវទៅមុនឆ្ពោះទៅកាន់ព្រំដែន ចំណែករថយន្តគ្រួសារយោធានិងប្រជាពលរដ្ឋនៅកណ្តាល និងមានរថក្រោះមួយចំនួនទៀតបើកពីក្រោយការពារក្បួនដកថយអមដំណើរទាហានថ្មើរជើងដើរជាជួរសងខាងផ្លូវ ។

ក្បួនដកថយធ្វើដំណើរចេញពីទីក្រុងប៉ៃលិនទៅព្រំដែន

អូរឡាក់ចម្ងាយតែជាង១០គីឡូម៉ែត្រ ប៉ុន្តែយើងត្រូវចំណាយពេលវេលាអស់ជិត៦ម៉ោងទើបទៅដល់ ។ រថយន្តខ្លះខូចត្រូវទុកចោល ខ្លះត្រូវរុញចេញពីផ្លូវដើម្បីកុំឲ្យស្ទះ ។ ប្រជាជនទួលអីវ៉ាន់ ដឹកដៃកូនទាំងប្រញាប់ប្រញាល់ ។ គ្រាប់ផ្លោងនិងគ្រាប់កាំភ្លើងផ្ទុះនៅខាងមុខនិងខាងក្រោយលាន់ឮកងរំពង លាយឡំសម្រែកទ្រហោយំនឹកគុណម៉ែគុណឪបន់ស្រន់សុំឲ្យរួចផុតពីគ្រោះថ្នាក់ ។

តាមបទបញ្ជារបស់លោកអភិបាលក្រុង ខ្ញុំបើករថយន្តទៅប៉ុស្តិ៍ព្រំដែនអូរឡាក់ (កម្ពុជា-ថៃ) មុន ដើម្បីទាក់ទងជាមួយអាជ្ញាធរថៃសុំសិទ្ធិជ្រកកោនជាជនភៀសសឹក ។ រហូតដល់ម៉ោង៧យប់ទើបថៃអនុញ្ញាតឲ្យក្បួនរថយន្តចូលទៅក្នុងទឹកដីថៃជម្រៅ១០គីឡូម៉ែត្រ ។ ព្រឹកថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៥ ទាហានថៃបានដកអាវុធពីយុទ្ធជនកងរថក្រោះM១១៣ទាំងអស់ ហើយប្រមូលផ្តុំទាហាននៅមួយជំរំផ្សេងប្រជាជនស៊ីវិលនៅមួយជំរំផ្សេងទៀត ។ ជំរំទាហានភៀសសឹកស្ថិតនៅក្នុងវត្តមួយក្បែរផ្លូវទៅខេត្តចាន់បុរី ។ ខ្ញុំគឺជាអ្នកបកប្រែភាសាខ្មែរ-ថៃប្រចាំជំរំនេះ ។ ទាហានថៃចាត់តាំងអ្នកគ្រប់គ្រងជំរំ និងចាប់ផ្តើមធ្វើបញ្ជីឈ្មោះដើម្បីចែកស្បៀងអាហារដូចជាអង្ករនិងត្រីខកំប៉ុងដែលជាអំណោយពីឧត្តមអគ្គការស្នងការជនភៀសខ្លួន ។

## ជីវិតរបស់ខ្ញុំនៅក្នុងជំរំទាហានភៀសខ្លួន

ក្រៅពីការងារបកប្រែ ខ្ញុំប្រជុំជាមួយអភិបាលក្រុងប៉ៃលិន ហ៊ុន ទន លោក ម៉ា ឡៅពី លោក ស៊ឹម ជីម៉េង និងនាយទាហាន នាយទាហានរង ពលទាហាន គ្រួសារយុទ្ធជន ដើម្បីសរសេរសំណើសុំឲ្យឧត្តមស្នងការជនភៀសខ្លួនមេត្តាជួយសុំសិទ្ធិជ្រកកោននៅប្រទេសទីបី ។ ៦ខែក្រោយមក អ្នកនៅក្នុងជំរំទាហានរបស់យើងត្រូវបានអនុញ្ញាតឲ្យចេញទៅប្រទេសទី៣មុន ឯជំរំជនភៀសខ្លួនស៊ីវិលចេញទៅក្រោយជាដំណាក់កាលៗ ។ មុនថ្ងៃចេញដំណើរទៅប្រទេសទី៣ ខ្ញុំដេកមិនលក់អន្ទះអន្ទែងវិលវល់ក្នុងចិត្ត ណាមួយព្រាត់ឪពុកម្តាយបងប្អូនញាតិសន្តានពុំបានទៅជាមួយ ។ ទីបំផុត ខ្ញុំជម្រាបលោកអភិបាលក្រុងប៉ៃលិនថា "ខ្ញុំបាទសម្រេចមិនទៅប្រទេសទី៣ទេ មូលហេតុនឹកឪពុកម្តាយបងប្អូន ប្រសិនបើខ្ញុំនៅប្រទេសថៃឬឡាវ ថ្ងៃណាមួយប្រទេសជាតិមានសន្តិភាពពេញបរិបូរណ៍នឹងអាចវិលចូលក្នុងស្រុកខ្មែរវិញ" ។

ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ខ្ញុំចាកចេញពីជំរំថៃធ្វើ



គណៈប្រតិភូឡាវ សមមិត្ត ខៀវ សំផន

ដំណើរទៅប្រទេស ឡាវ ។ ទើបតែទៅដល់ប្រទេសឡាវខ្ញុំមិនបានប៉ុន្មានថ្ងៃផង ឡាវ ប្រកាសថ្ងៃជ័យជម្នះរំដោះទូទាំងប្រទេស គឺថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៥ ។ ខ្ញុំរស់នៅក្នុងនាមជាជនភៀសខ្លួនខ្មែរនៅប្រទេសឡាវ ។ ខ្ញុំបានដាក់ពាក្យសុំចូលធ្វើការនៅវិទ្យុផ្សាយសំឡេងប្រជាជនឡាវ ជាអ្នកបកប្រែ និងអានព័ត៌មានជាភាសាខ្មែរ ។ នៅស្ថានីយ៍វិទ្យុនោះមានជនភៀសខ្លួនខ្មែរ៥នាក់ធ្វើការខាងបកប្រែ ។

ខែមីនា ឆ្នាំ១៩៧៦ កម្ពុជាប្រជាធិបតេយ្យនិងប្រទេសឡាវបានភ្ជាប់ទំនាក់ទំនងការទូតជាមួយគ្នា ហើយកម្ពុជាប្រជាធិបតេយ្យបានដាក់ស្ថានទូតខ្មែរប្រចាំនៅប្រទេសឡាវ ដោយមានសមមិត្ត មាឃ ទូច ជាឯកអគ្គរដ្ឋទូតកម្ពុជាប្រជាធិបតេយ្យប្រចាំប្រទេសឡាវ ចំណែកអគ្គរដ្ឋទូតឡាវប្រចាំនៅកម្ពុជាគឺសមមិត្ត ខាំ ម៉ាផុមកង ។

នៅខែធ្នូ ឆ្នាំ១៩៧៦ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យបានស្នើសុំឲ្យរដ្ឋាភិបាលឡាវផ្តល់ជំនួយដល់កម្ពុជានូវថ្នាំពេទ្យមួយចំនួន ។ ពេលនោះខ្ញុំបានរួមដំណើរជាមួយថ្នាក់ដឹកនាំមជ្ឈិមបក្សឡាវនិងរដ្ឋមន្ត្រីក្រសួង ការបរទេសអាជ្ញាធរខេត្តចាំបាសាក់ និងអង្គភាពការពារខ្សែ ក្រវ៉ាត់ព្រំដែនដុងក្រឡ (ឡាវ-កម្ពុជា) ។

ក្បួនរថយន្តគណៈប្រតិភូឡាវអមដំណើរដោយទូតកម្ពុជាប្រជាធិបតេយ្យប្រចាំប្រទេសឡាវ បានទៅដល់ចំណុចព្រំដែនដុងក្រឡនៅវេលាម៉ោង១១ព្រឹក ។ ប៉ុស្តិ៍ព្រំដែនកម្ពុជានិងឡាវស្ថិតនៅឃ្លាតពីគ្នាប្រហែលជាង៨គីឡូម៉ែត្រ ។ បន្ទាប់ពីរថយន្តចតរួចរាល់ គណៈប្រតិភូភាគីកម្ពុជាក្នុងសម្លៀកបំពាក់ ពណ៌ខ្មៅបង់កក្រមា ពាក់ស្បែកជើងកង់ឡាន មានអង្គរក្សស្ពាយកាំភ្លើងអាកាតាមការពារ បានមកចាប់ដៃភាគីឡាវ រួចក៏បានសំណេះសំណាលអំពីគោលបំណងនៃការជួបគ្នានៅថ្ងៃនេះ គឺអនុវត្តតាមកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងប្រទេសទាំងពីរដែលធ្លាប់រួមសហការគ្នាវាយសត្រូវតែមួយគឺចក្រពត្តិលុះត្រាតែប្រទេសនីមួយៗបានទទួលជ័យជម្នះជាស្ថាពរនៅក្នុងឆ្នាំ១៩៧៥ ។

មុនការប្រគល់អំណោយ ភាគីទាំងពីរបានថ្លែងសុន្ទរកថាដោយសង្ខេបក្នុងនាមរដ្ឋាភិបាលប្រទេសទាំងពីរ ។ ខ្ញុំបានបកប្រែដោយខ្លឹមសារច្បាស់លាស់គ្មានខ្វះចន្លោះចំណុចណាមួយ ។ ភាគីទាំងពីរបានជូនពរជាចុងក្រោយដែលមានខ្លឹមសារថា "សូមឲ្យចំណងទាក់ទងកម្ពុជា-ឡាវឋិតថេរគង់វង្សជាអមតៈ" ។ បន្ទាប់មកភាគីកម្ពុជាប្រគល់ឲ្យឡាវនូវអំបិល១០តោននិងត្រីងៀត២តោន ចំណែកភាគីឡាវប្រគល់ឲ្យកម្ពុជានូវថ្នាំពេទ្យ២០កេសនិងប៊ីចេង២០កេស ។ ពិធីប្រគល់អំណោយបានបញ្ចប់នៅម៉ោង១២ថ្ងៃត្រង់ ។ គណៈប្រតិភូទាំងពីរបានចាប់ដៃលាគ្នា ។

ក្រោយការប្រគល់អំណោយនៅចំណុចព្រំដែនដុងក្រឡ ឯកអគ្គរដ្ឋទូតកម្ពុជាប្រជាធិបតេយ្យប្រចាំនៅប្រទេសឡាវបានទូរស័ព្ទមកប្រាប់ការិយាល័យបកប្រែភាសាខ្មែរប្រចាំវិទ្យុជាតិឡាវថា "អ៊ីសុំលាក្មួយៗទាំងអស់ត្រឡប់ទៅភ្នំពេញវិញ ។ យោងសារទូរលេខរបស់ក្រសួងការបរទេសកម្ពុជា ការវិលត្រឡប់ទៅកម្ពុជាលើកនេះគឺមានតែរូបខ្ញុំនិងភរិយាខ្ញុំទេ" ។

នៅឆ្នាំ១៩៧៦នោះដែរ បន្ទាប់ពីសមមិត្ត មាឃ ទូច និងភរិយា ត្រឡប់ទៅភ្នំពេញ ឯកអគ្គរដ្ឋទូតថ្មីបានត្រូវតែងតាំង ដោយមានការជូនសាតាំងលោកប្រធានរដ្ឋឡាវ សុផានុវង្ស ។ ទូតថ្មីនេះឈ្មោះ សម សាន ជាសាស្ត្រាចារ្យភាសាបារាំង ប្រពន្ធរបស់គាត់ក៏ជាសាស្ត្រាចារ្យដូចគ្នា ។ ឯកអគ្គរដ្ឋទូតថ្មីមិនសូវរួសរាយដូចទូតចាស់ទេ គឺមានភាពម៉ឺងម៉ាត់ជាចំហធាតុពិតខ្មែរក្រហមពេញទីតែម្តង ។ ពីឆ្នាំ១៩៧៧ដល់ឆ្នាំ១៩៧៨ រាល់ទំនាក់ទំនងជាមួយការិយាល័យបកប្រែភាសាខ្មែរប្រចាំវិទ្យុជាតិឡាវ គឺខាងទូតច្រើនតែផ្តល់ជាទស្សនាវដ្តីកម្ពុជាប្រជាធិបតេយ្យនិងសេចក្តីប្រកាសព័ត៌មានរបស់ក្រសួងការបរទេសកម្ពុជាស្តីអំពីការចោទប្រកាន់ប្រទេសវៀតណាមឈ្លានពានចូលទឹកដីកម្ពុជា បាញ់សម្លាប់ប្រជាពលរដ្ឋខ្មែរនៅតាមខេត្តដែលជាប់ព្រំប្រទល់ ។

តាមពិត សង្គ្រាមឆ្នាំ១៩៧៧-៧៨ គឺមេដឹកនាំខ្មែរក្រហមនេះឯងជាអ្នកបង្កទំនាស់បញ្ឆោតកងទ័ពខ្មែរក្រហមឲ្យវាយលុកចូលទឹកដីវៀតណាមនៅតាមព្រំប្រទល់ (ផ្តល់ព័ត៌មានដោយកងទ័ពខ្មែរក្រហមមួយចំនួនតូចដែលមិនព្រមធ្វើសង្គ្រាមជាមួយវៀតណាម ហើយបានរត់ភៀសខ្លួនចូលក្នុងខេត្តអាត់តាពើទឹកដីឡាវក្នុងឆ្នាំ១៩៧៨) ។

នៅដើមឆ្នាំ១៩៧៦ ខ្ញុំនិងមិត្តភក្តិទាំង៥នាក់ ជាអ្នកបកប្រែភាសាខ្មែរនៅវិទ្យុជាតិឡាវ ត្រូវបានលេខាទូតកម្ពុជាប្រចាំនៅ

ប្រទេសឡាវអញ្ជើញទៅលេងផ្ទះនៅឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ។

នៅពេលដែលខ្ញុំនិងមិត្តទាំង៥ នាក់ទៅដល់ស្ថានទូតកម្ពុជា នៅម៉ោង៨ព្រឹក សមមិត្ត មាយ ទូច និងលេខាទូត ចេញមកទទួលយើងខ្ញុំ ឲ្យអង្គុយនៅសាឡុង ដាក់ទឹកឲ្យយើងហូប និងអង្គុយសំណេះសំណាលគ្នា ។ នៅពេលនោះ សមមិត្ត មាយ ទូច សួរយើងថា “មិត្តទាំងអស់តើមាននឹកស្រុកទេសដែរឬទេ?” ។ ខ្ញុំនិងមិត្តភក្តិឆ្លើយថា “នឹកណាស់សមមិត្ត គង់ថ្ងៃណាពួកយើងទាំងអស់គ្នានឹងសុំច្បាប់ពីរដ្ឋាភិបាលឡាវទៅលេងឪពុកម្តាយបងប្អូននៅកម្ពុជាមិនខាន” ។

ខណៈពេលជួបសំណេះសំណាលនោះ ខ្ញុំនិងមិត្តភក្តិចេះតែសង្កេតមើលកាយវិការនិងការនិយាយស្តីរបស់សមមិត្ត មាយ ទូច និងលេខាទូត ហាក់ដូចជាលាក់អាថ៌កំបាំង ។ អ្នកទាំងពីរហាក់ដូចជាមិនទុកចិត្តគ្នា ។ ពេលចេញមកអង្គុយជាមួយភ្ញៀវចេញមកទាំងពីរនាក់ ពេលចូលយករបស់ដូចជាកាសែតកម្ពុជាប្រជាធិបតេយ្យឲ្យខ្ញុំនិងមិត្តភក្តិមើលចូលទៅក្នុងទាំងពីរនាក់ ដល់ពេលចេញមកវិញក៏ចេញមកទាំងពីរនាក់ ហាក់ដូចជាមានរឿងអ្វីដែលខ្លាចបែកការណ៍មិនឲ្យលេខាទូតនិយាយនិងអង្គុយលេងជាមួយភ្ញៀវទេ។ សមមិត្ត មាយ ទូច ថែមទាំងបាននិយាយបញ្ចុះបញ្ចូលខ្ញុំនិងមិត្តភក្តិថា “គួរសមមិត្តទាំងអស់ធ្វើមាតុភូមិនិវត្តន៍ទៅកសាងទឹកដីដើមកំណើតយើងវិញល្អជាងរស់នៅបម្រើប្រទេសក្រៅ ។ តើមិត្តដឹងទេ ប្រទេសយើងវាយឈ្នះចក្រពត្តិអាមេរិក ប្រជាជនរស់នៅជួបជុំគ្រួសារ យើងមិនត្រូវការចាយវាយលុយកាក់ ប្រជាជនយើងទំដីកទំនប់លើកប្រឡាយ ធ្វើស្រែមួយឆ្នាំឲ្យបានទិន្នផល៣តោន ប្រជាជនហូបចុកគ្រប់គ្រាន់ កុមារមានសិទ្ធិចូលសាលារៀនគ្រប់ៗគ្នា” ។

ពេលនោះទូតនឹងលេខាទូតបានប្រគល់ទស្សនាវដ្តីឲ្យយើងម្នាក់មួយក្បាល ថែមទាំងបង្ហាញរូបនៅក្នុងទស្សនាវដ្តីថា “នេះនែ៎សមមិត្ត! នេះហើយជាទិដ្ឋភាពរួមក្នុងការកសាងប្រទេសកម្ពុជាឡើងវិញក្រោយពេលបញ្ចប់សង្គ្រាម” ។ ពាក្យសម្តីបញ្ចុះបញ្ចូលមកដល់ត្រឹមនេះ ខ្ញុំនិងមិត្តភក្តិបានជម្រាបលាទូត និងលេខាទូតត្រឡប់មកផ្ទះរៀងៗខ្លួន ។ នៅការិយាល័យបកប្រែភាសា ខ្ញុំនិងមិត្តភក្តិបានប្រជុំវាយតម្លៃសភាពការណ៍ជួបទូតនិងលេខាទូតពីម្សិលមិញថា “តាមពិតនេះជាចិត្តសាស្ត្រខ្មែរក្រហមដែលអួសទាញនិស្សិតបញ្ជូនត្តពីបរទេសតែប៉ុណ្ណោះ” ។

នៅដើមឆ្នាំ១៩៧៧ រដ្ឋាភិបាលឡាវបានទទួលគណៈប្រតិភូសមាគមនារីកម្ពុជាប្រជាធិបតេយ្យដឹកនាំដោយសមមិត្តនារី ទាត់ សី ។ អគ្គនាយកដ្ឋានវិទ្យុជាតិឡាវឈ្មោះ ចាឡឹន វង់សំអាន បាន ចាត់តាំងមិត្តខ្ញុំម្នាក់ឈ្មោះ នូ សៃ ទៅបកប្រែភាសាខ្មែរ-ឡាវ ជូនគណៈប្រតិភូរហូតចប់ដំណើរទស្សនកិច្ច ។

រំលងប៉ុន្មានថ្ងៃក្រោយពីគណៈប្រតិភូសមាគមនារីកម្ពុជាប្រជាធិបតេយ្យត្រឡប់ទៅភ្នំពេញវិញ មិត្តរបស់ខ្ញុំឈ្មោះ នូ សៃ និយាយជាមួយមិត្តភក្តិក្នុងការិយាល័យបកប្រែភាសាថា “យើងទាំងអស់គ្នាគួរសុំការអនុញ្ញាតពីរដ្ឋាភិបាលឡាវ ធ្វើមាតុភូមិនិវត្តន៍វិញទាំងអស់គ្នា ពេលនោះយើងនឹងមានការងារល្អៗ កាន់តួនាទីល្អ ដូចជាធ្វើរដ្ឋមន្ត្រីអភិបាលខេត្តជាដើម” ។ ខ្ញុំលើកឡើងថា “មិត្ត នូ សៃ ដឹងអំពីជីវភាពការរស់នៅរបបកម្ពុជាប្រជាធិបតេយ្យកំពុងអនុវត្តនាពេលសព្វថ្ងៃនេះទេ?” ។ មិត្តខ្ញុំទាំងប្រាំនាក់បានលើកយកហេតុផលជនភៀសខ្លួនដែលចូលមកប្រទេសឡាវ ហើយរដ្ឋាភិបាលឡាវប្រគល់ឲ្យភាគីកម្ពុជាវិញ ត្រូវកម្ពុជាប្រជាធិបតេយ្យទៅសម្លាប់ចោលទាំងអស់ ។ ដូច្នេះក្រោយមកទៀត ពេលណាមានប្រជាជនកម្ពុជាភៀសខ្លួនចូលមក រដ្ឋាភិបាលឡាវសុខចិត្តទទួលយកកហើយមិនព្រមបញ្ជូនទៅវិញទេ ។

យើងលើកពីបញ្ហាទំនាស់រវាងឡាវ-កម្ពុជាតាមខ្សែបន្ទាត់ព្រំដែនទឹកដូចជានៅទន្លេល្ពៅ កំពង់ស្រឡៅ កំពង់ឥន្ទ្រ និងខ្សែបន្ទាត់ព្រំដែនគោកដទៃទៀត ដែលកងទ័ពខ្មែរក្រហមបាញ់ប្រជាជនឡាវដែលរកស៊ីតាមដងទន្លេមេគង្គជារៀងរាល់ថ្ងៃ ។

ពេលខ្ញុំនិយាយអំពីភាពកាចសាហាវយង់ឃ្នង់របស់កងទ័ពខ្មែរក្រហម មិត្ត នូ សៃ ចង្អុលមុខខ្ញុំនិងមិត្តទាំងអស់ដោយប្រើពាក្យសម្តីតិះដៀលថា “ពួកឯងអាពួកវង្វេងជាតិ ឯងចាំមើលចុះ អញនឹងសុំរដ្ឋាភិបាលឡាវត្រឡប់ទៅធ្វើការនៅភ្នំពេញវិញ ពួកឯងនៅចុះ” ។

មិនបានប៉ុន្មានថ្ងៃ នៅបន្ទប់ការិយាល័យបកប្រែភាសាខ្មែរប្រចាំវិទ្យុជាតិឡាវ សមមិត្ត នូ សៃ ចាប់ផ្តើមស្ទៀកពាក់ខោអាវ

ពណ៌ខ្មៅ បង់កក្រមា ពាក់មួកកាតឹប ពាក់ស្បែកជើងកង់ឡាន មកធ្វើការ ។ នៅពេលនោះខ្ញុំនិងមិត្តភក្តិដទៃទៀតលែងហ៊ានអប់រំកែលម្អទៀតហើយ ។ ក្រោយពីបានបកប្រែភាសាជូនគណៈប្រតិភូសហគមនារីកម្ពុជាប្រជាធិបតេយ្យរួចមក មិត្តរបស់ខ្ញុំដែលធ្លាប់តែមានគំនិតល្អបែរទៅជាលង់ក្នុងមនោគមវិជ្ជាខ្មែរក្រហមកែពុំបាន ។

ថ្ងៃមួយ ខ្ញុំនិងមិត្តភក្តិកំពុងបកប្រែអត្ថបទពីកាសែតឡាវ ដើម្បីត្រៀមអានផ្សាយបន្តផ្ទាល់ ស្រាប់តែឃើញមិត្ត នូ សៃ ដើរចូលមកដោយទឹកមុខរីករាយប្លែកពីធម្មតា ព្រមទាំងពោលថា "ខ្ញុំលាមិត្តទាំងអស់គ្នាសិនហើយ" ។ នូ សៃ លូកយកលិខិតមួយសន្លឹកចេញពីហោប៉ៅអាវបង្ហាញយើង ហើយបន្ថែមថា "នេះសំណើរបស់ខ្ញុំដែលសរសេរជូនក្រសួងការបរទេសសុំធ្វើមាតុភូមិនិវត្តន៍ ។ មជ្ឈិមបក្សឡាវបានឯកភាពរួចហើយ ខ្ញុំរង់ចាំតែកាត់ខោអាវក្រ័រហ្សេមួយកំប្លេ ខោអាវស៊ីមប៉ាលីមួយកំប្លេ ស្បែកជើងវ៉ាលិស និងវិទ្យុ ហើយក្រសួងការបរទេសឡាវនឹងធ្វើពិធីជប់លៀងប្រគល់ខ្ញុំឲ្យស្ថានទូតកម្ពុជានិងជូនដំណើរផង" ។

ចាប់តាំងពីបានលិខិតយល់ព្រមរបស់មជ្ឈិមបក្សឡាវរួចមកមិត្ត នូ សៃ ពុំដែលមកធ្វើការទៀតឡើយ ។ ខ្ញុំនិងមិត្តភក្តិទាំងអស់មានទឹកមុខក្រៀមក្រំស្តាយមិត្តភក្តិធ្លាប់រួមការងារពុំគួរអីចាញ់បោកខ្មែរក្រហមត្រឡប់ទៅប្រទេសខ្មែរសោះ ។

ចុងឆ្នាំ១៩៧៦ ក្រសួងការបរទេសឡាវបានរៀបចំពិធីជប់លៀងមួយដើម្បីអបអរសាទរក្នុងនាមរដ្ឋាភិបាលឡាវប្រគល់សមមិត្ត នូ សៃ ឲ្យស្ថានទូតកម្ពុជាប្រជាធិបតេយ្យប្រចាំនៅប្រទេសឡាវ យោងលិខិតសំណើរបស់សមមិត្ត នូ សៃ ដែលសុំធ្វើមាតុភូមិនិវត្តន៍មកកម្ពុជាវិញ ។ ពិធីជប់លៀងនោះមានការចូលរួមពីរដ្ឋមន្ត្រីក្រសួងការបរទេសឡាវ វិទ្យុជាតិឡាវ រដ្ឋមន្ត្រីក្រសួងឃោសនាការវប្បធម៌និងព័ត៌មាន សមមិត្ត មាឃ ទូច ឯកអគ្គរដ្ឋទូតកម្ពុជាប្រជាធិបតេយ្យប្រចាំប្រទេសឡាវ និងមន្ត្រីនៅស្ថានទូត ។

"លាហើយទីក្រុងវៀងច័ន្ទ" ព្រឹកព្រលឹមថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៦ វេលាម៉ោង៧ ខ្ញុំ និងមិត្តភក្តិរួមការងារឱបថើបលាមិត្ត នូ សៃ ទាំងអាក់អួលលាយឡំនឹងទឹកភ្នែករលីងរលោងគ្រប់គ្នា ។

ឆ្នាំ១៩៧៧ រដ្ឋាភិបាលឡាវត្រូវបានរដ្ឋាភិបាលកម្ពុជាអញ្ជើញទៅបំពេញទស្សនកិច្ចនៅកម្ពុជាប្រជាធិបតេយ្យ ។ គណៈប្រតិភូជាន់ខ្ពស់ឡាវដឹកនាំដោយលោកប្រធាន សុផានុវង្ស លោក ភូនស៊ី ប៉ាស៊ើត រដ្ឋមន្ត្រីក្រសួងការបរទេស លោក ស៊ីសាណៈ ស៊ីសាន រដ្ឋមន្ត្រីក្រសួងឃោសនាការវប្បធម៌និងព័ត៌មាន លោក មហាគុ សុវណ្ណមេធី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីផ្សេងៗទៀតខ្ញុំពុំបានចាំឈ្មោះ ។ គោលបំណងនៃដំណើរទស្សនកិច្ចរបស់គណៈប្រតិភូជាន់ខ្ពស់ឡាវលើកនេះគឺដើម្បីជួបចរចាដោះស្រាយបញ្ហាព្រំដែនទឹកព្រំដែនគោកដែលភាគីកម្ពុជាបានរំលោភបាញ់សម្លាប់ប្រជាជនឡាវនៅតាមបណ្តោយទន្លេមេគង្គ (ទន្លេល្ពៅ កំពង់ស្រឡៅ និងកន្លែងដទៃទៀត) ។ រួមដំណើរជាមួយគណៈប្រតិភូជាន់ខ្ពស់ឡាវមានសមមិត្ត នូ ចាន់ អ្នកបកប្រែភាសាខ្មែរប្រចាំវិទ្យុជាតិឡាវ ។

ពេលវិលត្រឡប់មកពីភ្នំពេញ មិត្ត នូ ចាន់ និយាយប្រាប់ខ្ញុំនិងមិត្តរួមការងារថា "គណៈប្រតិភូជាន់ខ្ពស់ឡាវទៅចរចារកដំណោះស្រាយអំពីបញ្ហាព្រំដែននេះពុំបានទទួលលទ្ធផលជាផ្លែផ្កាទេ ព្រោះភាគីកម្ពុជានៅតែប្រកែកថា កងទ័ពខ្មែរក្រហមពុំបានបាញ់សម្លាប់ប្រជាជនឡាវដែលរកស៊ីតាមដងទន្លេមេគង្គឡើយ" ។ មិត្ត នូ ចាន់ បានបន្តទៀតថា "ពេលយន្តហោះចូលដល់ទឹកដីកម្ពុជា ភ្លាមកងបញ្ជាការប្រចាំនៅព្រលានយន្តហោះពោធិ៍ចិនតុងបាននិយាយវិទ្យុទាក់ទងមកក្រុមអាកាសយានិកឡាវថា "សូមឲ្យអ្នកហោះហើរលើទឹកដីខ្ញុំកម្ពស់ពីរគីឡូម៉ែត្រកន្លះបានហើយ រួចហើយហោះតាមបញ្ជាពី Tour Control ពោធិចិនតុង ហាមហោះហើរក្រោមកម្ពស់ពីរគីឡូម៉ែត្រកន្លះ ។ បើមិនស្តាប់បញ្ជាទេ មានគ្រោះថ្នាក់ផ្សេងៗភាគីកម្ពុជាពុំទទួលខុសត្រូវឡើយ" ។

ទៅទទួលគណៈប្រតិភូឡាវនៅពេលនោះមានសមមិត្ត អៀង សារី និងថ្នាក់ដឹកនាំជាច្រើនទៀត និងមានអគ្គរដ្ឋទូតឡាវគឺលោក ខាំម៉ា ផុមកង ។

ក្បួនដង្ហែគណៈប្រតិភូជាន់ខ្ពស់ឡាវចូលមកកាន់ទីក្រុងភ្នំពេញពុំមានសភាពអធិកអធមទេ មានតែរថយន្តមែរសឺដេសបួនគ្រឿង និងមានរថយន្តហ្សីប A-2 មួយគ្រឿង រត់នាំមុខក្បួនរថយន្តគណៈប្រតិភូ ។ នៅសងខាងផ្លូវមានកងទ័ពស្លៀកពាក់ខោខ្មៅអាវ

ខ្មៅបង់កក្រមាពណ៌ក្រហម ស្ពាយកាំភ្លើងអាកា ពាក់ស្បែកជើងកង់ឡាន ឈរផ្តុំគ្នាពី៥ទៅ១០នាក់ ។ រថយន្តខូចៗត្រូវបានដាក់រាំងផ្លូវមួយចំនួន ។ តាមផ្លូវពីពោធិចិនតុងទៅទីក្រុងភ្នំពេញមានសភាពស្ងាត់ជ្រងំគ្មានប្រជាជនរស់នៅអគារធំៗនិងផ្ទះល្វែងត្រូវបិទទ្វារ គ្មានផ្សារ គ្មានការលក់ដូរ ។

គណៈប្រតិភូជាន់ខ្ពស់ឡាវត្រូវរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យឲ្យសម្រាកនៅដំណាក់ចំការមន ។ វេលាម៉ោង២រសៀល កិច្ចប្រជុំរវាងគណៈប្រតិភូជាន់ខ្ពស់ឡាវនិងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ដែលមានសមមិត្ត អៀង សារី, ប៉ុល ពត, សុន សេន, នួន ជា និងសមមិត្តដទៃទៀត ចំណាយពេលអស់២ម៉ោង ។ បន្ទាប់មក សមមិត្ត អៀង សារី ជូនដំណើរគណៈប្រតិភូជាន់ខ្ពស់ឡាវទស្សនារោងចក្រក្រឡឹងដែកនិងការដ្ឋាននានានៅជុំវិញទីក្រុងភ្នំពេញ ។

ថ្ងៃបន្ទាប់ ក្រោយពេលស្រស់ស្រូបអាហារពេលព្រឹក សមមិត្ត អៀង សារី ជូនដំណើរគណៈប្រតិភូឡាវទៅទស្សនាខេត្តសៀមរាបទស្សនាការដ្ឋានជួសជុលទំនប់បារាយណ៍ទឹកថ្លា ។ រាល់ទីកន្លែងដែលទៅទស្សនា កម្ពុជាប្រជាធិបតេយ្យពុំអនុញ្ញាតឲ្យគណៈប្រតិភូថតរូបឡើយ គឺឲ្យឈរមើលឆ្ងាយពីប្រជាជនប្រហែល ៥០០ម៉ែត្រ មើលទៅឃើញតែខោខ្មៅអាវខ្មៅទង់ជ័យក្រហមដោតពាសពេញការដ្ឋាន កាប់ដីនិងរែកដីរត់ផងដើរផងមានសន្ទាក់ដូចគ្រឿងចក្រ ។

បន្ទាប់មក សមមិត្ត អៀង សារី ជូនដំណើរគណៈប្រតិភូឡាវវិលត្រឡប់ទៅមាតុប្រទេសវិញតាមយន្តហោះឡាវដែលហោះត្រង់ពីខេត្តសៀមរាបមកទីក្រុងវៀងច័ន្ទ ។

ពេលដែលយន្តហោះ A-24 ឆ្លងចូលក្នុងទឹកដីឡាវវិញ មេបញ្ជាការអាកាសយានិកចេញមករាយការណ៍ជូនគណៈប្រតិភូឡាវថា : ខណៈពេលដែលយន្តហោះចុះចតទៅពោធិ៍ចិនតុង អាកាសយានិកទាំង៥រូបត្រូវកងទ័ពខ្មែរក្រហមហៅចូលក្នុងបន្ទប់រួចគំរាមកំហែងសួរចម្លើយថា "ហេតុដូចម្ដេចបានជាអ្នកឯងហោះហើរចូលទឹកដីកម្ពុជាហើយមិនស្ដាប់តាមបញ្ជារបស់យើងធ្វើឲ្យការចុះចតខុសពេលវេលាជិត២០នាទី?" មេបញ្ជាការអាកាសយានិកឆ្លើយថា "ខ្ញុំហោះតាមកម្ពស់របស់លោកបញ្ជាហើយ ក៏ប៉ុន្តែខ្ញុំចៀសពីដុំពពកខ្មៅនិងភ្លៀងព្យុះទើបបានជាចុះចតពុំត្រឹមត្រូវតាមកាលកំណត់ដែលបានគ្រោងទុក ។

ក្រោយថ្ងៃរំដោះ ៧មករា ឆ្នាំ១៩៧៩ ខ្ញុំបានមកដល់ភ្នំពេញនៅថ្ងៃទី៨ ខែមករា តាមជើងយន្តហោះវៀងច័ន្ទ-ហាណូយ-ហូជីមិញ-ភ្នំពេញ ក្នុងនាមជាអ្នកបកប្រែភាសាឲ្យអ្នកយកព័ត៌មានឡាវដែលមកយកព័ត៌មាននៅទីក្រុងភ្នំពេញ ។ រាល់ការចុះយកព័ត៌មានគឺមានកងទ័ពកម្ពុជាសហការជាមួយកងទ័ពវៀតណាមជូនដំណើរ ។ នៅគុកទួលស្លែងខ្ញុំឃើញសាកសពជាង១០ដែលខ្មែរក្រហមសម្លាប់ចោលមុនពេលចុះចាញ់សង្គ្រាម ។ យើងបានទៅមើលរណ្ដៅសាកសពរួមនៅភ្នំប្រុសភ្នំស្រី (ខេត្តកំពង់ចាម) ភ្នំសំពៅ (ខេត្តបាត់ដំបង) ។ នៅភ្នំសំពៅ ខ្មែរក្រហមចាប់ប្រជាជនសម្លាប់ទម្លាក់ចូលក្នុងល្អាងប្អូងភ្នំ ជះក្លិនអសោច ។ ខ្ញុំរន្ធត់ចិត្ត និងស្អប់ខ្ពើមបំផុតចំពោះរបបប្រល័យពូជសាសន៍ខ្មែរក្រហមដែលបានកាប់សម្លាប់ប្រជាជនស្លូតត្រង់ដែលគ្មានទោសពៃរ៍រាប់លាននាក់ ។

ឪពុកខ្ញុំនិងសាច់ញាតិជាងដប់គ្រួសារនៅភ្នំពេញត្រូវខ្មែរក្រហមយកទៅសម្លាប់ទាំងអស់ព្រោះជាមន្ត្រីរាជការនៅក្នុងរបបចាស់ ។

សព្វថ្ងៃនេះអ្វីៗដែលខ្ញុំរង់ចាំអស់រយៈពេលដ៏យូរបានមកដល់ហើយ ។ រាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងអស់ពីលទ្ធភាពបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ ការកាត់ក្ដីដែលនឹងខិតជិតមកដល់នាពេលឆាប់ៗខាងមុខនេះគឺជាការផ្ដល់យុត្តិធម៌ដល់ជនរងគ្រោះដែលស្លាប់ទៅហើយនិងអ្នកដែលនៅរស់រានមានជីវិត ជាការទប់ស្កាត់អំពើយង់ឃ្នង់បែបនេះកុំឲ្យកើតមានក្នុងអនាគត និងជាការអប់រំយុវជនជំនាន់ក្រោយអំពីអ្វីដែលកើតឡើងរួចមកហើយ ។

**ភូ គីមមឿ**

## ពាក្យស្លោកខ្មែរក្រហម

- **ផ្អែកឱ្យរឹងមាំលើវណ្ណៈអធន សាមគ្គីយ៉ាងជិតស្និទ្ធជាមួយកម្លាំងប្រជាជាតិទាំងមូល មកខាងបដិវត្តន៍ឯកោ ខ្មាំងសត្រូវមួយក្ដាប់តូចជាអតិបរមា!**

*(សៀវភៅកំណត់ហេតុលេខ១០៧៦)*

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៦/២១៤

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

◆ បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

◆ បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

◆ បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

◆ បានទ្រង់យល់ព្រះរាជក្រមលេខ ០៩ នស.៩៤ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

◆ បានទ្រង់យល់ក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជម្រះក្តីនៃកម្ពុជា

◆ បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០១/១២ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

◆ បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០០៥/០០៤ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

◆ បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០០៤/០០៦ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតឲ្យមានសាលាក្តីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្ត ឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

◆ បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដែលបានការឯកភាពពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនាសម័យប្រជុំថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៦

## ត្រាស់បង្គាប់

**មាត្រា១** ៖ ត្រូវបានតែងតាំងសមាសភាពចៅក្រមសាលាដំបូង តុលាការកំពូល សហចៅក្រមស៊ើបអង្កេត សហព្រះអាជ្ញា និងអង្គបុរេជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យដូចខាងក្រោម ៖

**១- *ចៅក្រមសាលាដំបូង***

◆ លោក និល ណុន ជាចៅក្រម ◆ លោក ធូ មណី ជាចៅក្រម

◆ លោក យ៉ា សុខន ជាចៅក្រម ◆ M[me] Silva CARTWRIGHT (ស៊ីលវ៉ា ខាតរ៉ៃ) (New-Zealand) ជាចៅក្រម

◆ M[R] Jean-Marc LAVERGNE (ហ្សង់ ម៉ាក ឡាវ៉ឺញ) (France) ជាចៅក្រម ◆ លោក យូរ ឧត្តរា ជាចៅក្រមបំរុង

◆ M[me] Claudia FENZ (ក្លោឌីយ៉ា ហ្វេនហ្ស៍) (Autriche) ជាចៅក្រមបំរុង

## ២- តុលាការកំពូល

◆ ឯកឧត្តម គង់ ស្រ៊ឹម ជាចៅក្រម ◆ លោក សោម សិរីវឌ្ឍ ជាចៅក្រម

◆ លោក ស៊ិន រិទ្ធ ជាចៅក្រម ◆ លោក យ៉ា ណារិន ជាចៅក្រម

◆ M[R] MOTOO NOGUCHI (ម៉ូតូ ណូហ្គូឈី) (Japan) ជាចៅក្រម

◆ M[me] Agnieska KLONOWIECKA-MILART (អាន់ទីស្កា ក្លូណូវីកា មីឡាត) (Pologne) ជាចៅក្រម

◆ M[R] Chandra ihal Jahasignhe (ចាន់ដ្រា អ៊ីហាល ចាហាស៊ីង៉ហេ) (Sri-Lanka) ជាចៅក្រម

◆ លោក ម៉ុង មុន្នីចរិយា ជាចៅក្រមបំរុង ◆ M[R] Martin Karopkin (ម៉ាទីន ការ៉ុបឃីន) (USA) ជាចៅក្រមបំរុង

## ៣- សហចៅក្រមស៊ើបអង្កេត

◆ លោក យូ ប៊ុនឡេង ជាសហចៅក្រមស៊ើបអង្កេត

◆ M[R] Marcel LEMONDE (ម៉ាកសែល ឡឺម៉ុង) (France) ជាសហព្រះចៅក្រមស៊ើបអង្កេត

◆ លោក ថោង អុល ជាសហចៅក្រមស៊ើបអង្កេតបំរុង

## ៤- សហព្រះរាជអាជ្ញា

◆ លោកស្រី ជា លាង ជាសហព្រះរាជអាជ្ញា ◆ M[R] Robert PETIT (រ៉ូប៊ែរ ប៉ឺទីត) (Canada) ជាសហព្រះរាជអជ្ញា

◆ ឯកឧត្តម ជួន ស៊ុនឡេង ជាសហព្រះរាជអាជ្ញា ◆ M[R] Paul COFFEY (ប៉ូល កុហ្វី) (USA) ជាសហព្រះរាជអាជ្ញា

## ៥- អង្គបុរេជំនុំជម្រះ

◆ ឯកឧត្តម ប្រាក់ គីមសាន ជាចៅក្រម ◆ ឯកឧត្តម ន័យ ថុល ជាចៅក្រម

◆ លោក ហួត វុទ្ធី ជាចៅក្រម ◆ M[R] Rowan DOWNING (រ៉ូវ៉ាន់ ដោននីង) (Australia) ជាចៅក្រម

◆ M[me] Katinka LAHUIS (កាទីនកា ឡាហ៊ុស) (Netherlands) ជាចៅក្រម ◆ លោក ប៉ែន ពេជ្រសាលី ជាចៅក្រមបំរុង

មាត្រា ២ ៖ បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារ ផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ ៖ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងនាយក រដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ ៖ ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃ ឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

ពរល.០៦០៥.២២៤ **នរោត្តម សីហមុនី**

រាជធានីភ្នំពេញ, ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០០៦

លេខ ៖ ២០៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០០៦

អគ្គលេខាធិការរាជរដ្ឋាភិបាល, **ណាឌី តាន់**

# ខ្សែភាពយន្តរឿង "ល្បែងខ្មោច" គឺជាការនិយាយលេងសើចពីអំពើប្រល័យពូជសាសន៍

ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០០៦ គឺជាទិវារំឭកដល់ការសម្លាប់រង្គាលជនជាតិជ្វីហ្វ ។ ទិវានេះប្រារព្ធឡើងដើម្បីរំឭកដល់វិញ្ញាណក្ខន្ធជនជាតិជ្វីហ្វជាង៦លាននាក់ដែលបានស្លាប់ក្នុងកណ្តាប់ដៃណាហ្ស៊ីកាលពី៦០ឆ្នាំមុន ។ នៅក្នុងទិវានេះមានការរៀបពិធីបុណ្យផ្សេងៗដូចជា ការអានឈ្មោះអ្នកស្លាប់ ការអុជទៀនបំភ្លឺ ការបួងសួង ការសូត្រធម៌ និងការថ្លែងអំពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នកដែលរស់រានមានជីវិតពីរបបហ៊ីត្លែរ ។ នេះគឺជាថ្ងៃដែលប្រជាជនជ្វីហ្វបញ្ឈប់ភាពល្ងង់ខ្លៅរបស់ខ្លួនដោយការបង្រៀនអ្នកដទៃឲ្យយល់អំពីភាពគួរឲ្យរន្ធត់នៃរបបប្រល័យពូជសាសន៍ ។

ខ្ញុំមិនសប្បាយចិត្តទាល់តែសោះដែលក្រុមអ្នកផលិតខ្សែភាពយន្តរឿង "ល្បែងខ្មោច" ត្រូវបានបង្រៀនខុស ។ ខ្សែភាពយន្តរឿង "ល្បែងខ្មោច" ចាប់ផ្តើមបញ្ចាំងពីរថ្ងៃបន្ទាប់ពីទិវារំឭកការសម្លាប់រង្គាលលើជនជាតិជ្វីហ្វ ហើយខ្សែភាពយន្តនេះផ្តើមឡើងដោយក្លែង ឈ្មោះមន្ទីរឃុំឃាំងស-២១របស់ខ្មែរក្រហម (ដែលនៅក្នុងខ្សែភាពយន្តហៅថា "ស-១១") ។ ចំពោះអ្នកដែលស្លាប់ដោយសារខ្វះអាហារ ទារុណកម្ម និងការសម្លាប់នៅក្នុងមន្ទីរឃុំឃាំងស-២១ នេះមិនមែនជាល្បែងឡើយ ។ ក្នុងចំណោមជនរងគ្រោះជាង១ម៉ឺន៤ពាន់នាក់ក្នុងមន្ទីរឃុំឃាំងស-២១ មានតែ១២នាក់ប៉ុណ្ណោះដែលរួចផុតពីសេចក្តីស្លាប់ ។

ក្រុមអ្នកផលិតខ្សែភាពយន្តនេះបានទាញយកផលប្រយោជន៍អំពីរឿងរ៉ាវទុក្ខវេទនាមួយនេះ និងកំពុងតែប្រមាថចំពោះអ្នកស្លាប់និងសមាជិកគ្រួសារដែលកំពុងតែរស់រានមានជីវិត ។ ការប៉ះទង្គិចផ្លូវចិត្តអាចនឹងផុសឡើងវិញពេលដែលសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហមចាប់ផ្តើមនៅឆ្នាំក្រោយ ។ ខ្សែភាពយន្តនេះជាការចំអកដល់អារម្មណ៍ភ័យខ្លាចរបស់ប្រជាជនកម្ពុជាស្លូតត្រង់ ។

ខ្ញុំឆ្ងល់ថា ប្រសិនបើប្រទេសថៃជាអ្នកឆ្លងកាត់អំពើប្រល័យពូជសាសន៍វិញ តើប្រទេសថៃនឹងផលិតខ្សែភាពយន្ត "ល្បែងខ្មោច" នៅក្នុងគុកនៅទីក្រុងបាងកកដែរឬទេ? តើប្រទេសថៃនឹងយករូបថតជនរងគ្រោះ ឆ្អឹងលលាដ៍ក្បាល និងវិញ្ញាណក្ខន្ធឪពុកម្តាយរបស់ខ្លួន ធ្វើជាការកម្សាន្តដែរឬទេ?

**ឆាំង យុ**

# តើកម្ពុជាបានផ្សះផ្សាហើយឬនៅ?

បន្ទាប់ពី លន់ នល់ ទម្លាក់សម្តេច សីហនុ នៅខែមីនា ឆ្នាំ១៩៧០ ប្រជាជនដែលស្មោះស្ម័គ្រដើរតាមការអំពាវនាវរបស់សម្តេច សីហនុ បានចូលបម្រើបដិវត្តន៍ ដោយសង្ឃឹមថាចលនានេះនឹងនាំព្រះអង្គមកកាន់អំណាចវិញ និងដឹកនាំសង្គមជាតិឲ្យបានរុងរឿង ។ ប្រជាជនមួយចំនួនទៀតមានជាអាទិ៍ មន្ត្រីរាជការ គ្រូបង្រៀន បណ្ឌិត បញ្ញវន្ត អ្នកមានចំណេះដឹងដែលរស់នៅតាមស្រុកស្រែចម្ការនាំគ្នាផ្លាស់មកនៅទីក្រុងឬទីរួមខេត្តដើម្បីគេចពីសង្គ្រាម និងគេចពីការបង្ខំឲ្យទៅបម្រើបដិវត្តន៍ខ្មែរក្រហម ឬគេចពីការចាប់ខ្លួនដោយខ្មែរក្រហម ។

ប្រជាជនមួយភាគធំឃ្លាតឆ្ងាយពីភូមិកំណើតដែលធ្លាប់រស់នៅបែកបាក់សាច់ញាតិនិងក្រុមគ្រួសារ ។ ប្រជាជនដែលបន្តរស់នៅក្នុងតំបន់រំដោះក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមត្រូវបានបញ្ចុះបញ្ចូលឬចាប់បង្ខំឲ្យស្អប់ខ្ពើមអ្នកដែលបម្រើរដ្ឋាភិបាលលន់នល់ ។ រដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ គឺជាចំណុចចាប់ផ្តើមនៃការបែកបាក់នៅក្នុងសង្គមកម្ពុជានៅសតវត្សរ៍ទី២០ ។

ពេលដែលកងទ័ពខ្មែរក្រហមចូលកាន់កាប់រដ្ឋធានីភ្នំពេញនៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបង្ខិតបង្ខំប្រជាជនឲ្យចាកចេញពីទីក្រុងដោយមិនបានឲ្យដំណឹងជាមុន ។ ប្រជាជនអាចយកត្រឹមតែរបស់របរបន្តិចបន្តួចប៉ុណ្ណោះ ។ មនុស្សចាស់និងអ្នកជំងឺដែលដើរមិនរួច រួមទាំងអ្នកដែលមិនព្រមចេញពីផ្ទះតាមបញ្ជាត្រូវកងទ័ពខ្មែរក្រហមបាញ់សម្លាប់នៅនឹងកន្លែង ។ ប្រជាជនបោះបង់ចោលផ្ទះសម្បែងនិងទ្រព្យសម្បត្តិហើយធ្វើដំណើររាប់រយ

គីឡូម៉ែត្រឆ្ពោះទៅជនបទ ។

ប្រជាជនដទៃទៀតពីទីក្រុង (ដែលខ្មែរក្រហមហៅថា ប្រជាជនថ្មី) ភាគច្រើនធ្វើដំណើរទៅស្រុកកំណើតរបស់ខ្លួន ដោយសង្ឃឹមថានឹងបានជួបសាច់ញាតិនិងមិត្តភក្តិចាស់ៗដែលបែកគ្នាយូរមកហើយ ។ គាត់សង្ឃឹមថាភូមិកំណើតគឺជាកន្លែងដ៏សុខសាន្តសម្រាប់រស់នៅ ប៉ុន្តែការពិតខុសស្រឡះទាំងស្រុងពីអ្វីដែលគាត់គិតទុក ។ បងប្អូនមិត្តភក្តិរបស់គាត់ដែលពេលនោះជាប្រជាជនមូលដ្ឋានចាត់ទុកគាត់ជាចក្រពត្តិ ជាមូលធននាយទុន និយាយឲ្យចំគឺជាសត្រូវ ។ ប្រជាជនថ្មីក្លាយជាមុខសញ្ញាទីមួយដែលខ្មែរក្រហមយកទៅសម្លាប់ ។

បក្សកុម្មុយនិស្តកម្ពុជាបានផ្លាស់ឈ្មោះប្រទេសកម្ពុជាទៅជា “កម្ពុជាប្រជាធិបតេយ្យ” ។ ក្រោមការដឹកនាំរបស់ ប៉ុល ពត បក្សកុម្មុយនិស្តកម្ពុជាបានបង្កើតនូវសង្គមស្មើភាពដោយលុបបំបាត់សាលារៀន សាសនា ក្រដាសប្រាក់ និងទ្រព្យសម្បត្តិឯកជន ។ សមាជិកគ្រួសារនីមួយៗត្រូវបានបង្ខំឲ្យធ្វើការនៅតាមកងជាច្រើនម៉ោងក្នុងមួយថ្ងៃ ហើយទទួលបានរបបអាហារតែបន្តិចបន្តួច ។ រៀងរាល់ពីរឬបីសប្តាហ៍ អង្គការអនុញ្ញាតឲ្យប្រជាជនជនសម្រាកមួយថ្ងៃ ។ អង្គការហាមឃាត់ដាច់ខាតមិនឲ្យប្រជាជនជជែកវែកញែកអំពីការលំបាក ស្រេកឃ្លាន ឬនឿយហត់ ។ ប្រសិនបើអ្នកណាម្នាក់លួចនិយាយអំពីបញ្ហានេះ អ្នកនោះនឹងត្រូវអង្គការចាប់យកទៅធ្វើទារុណកម្មឬសម្លាប់ចោល ។

ក្រោយរបបកម្ពុជាប្រជាធិបតេយ្យដួលរលំនៅដើមឆ្នាំ ១៩៧៩ ខ្មែរក្រហមភៀសខ្លួនទៅក្នុងព្រៃនៅតាមព្រំដែនកម្ពុជា-ថៃ និងបន្តគំរាមកំហែងបំភិតបំភ័យប្រជាជន ។ ក្រោមកិច្ចព្រមព្រៀងសន្តិភាព អតីតកងទ័ពខ្មែរក្រហមបានធ្វើសមាហរណកម្ម និងបានវិលត្រឡប់មកស្រុកកំណើតវិញនៅឆ្នាំ១៩៩៦ ។

បើទោះបីជាប្រទេសកម្ពុជាបានបង្រួបបង្រួមខាងវិស័យនយោបាយក៏ដោយ ក៏ប្រជាជនទាំងអស់មិនទាន់បានផ្សះផ្សាខាងផ្លូវចិត្តនៅឡើយទេ ។ អ្វីដែលប្រជាជនកម្ពុជាបានឆ្លងកាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺពិបាកនឹងបំភ្លេច ។ ចំពោះជនរងគ្រោះការធ្វើទុកបុកម្នេញឥតត្រាប្រណី ការស្លាប់និងបាត់ខ្លួនរបស់ក្រុមគ្រួសារនិងមិត្តភក្តិមិនមែនជាអ្វីដែលងាយស្រួលនឹងបំភ្លេចទេ ។

អ៊ុយ អ៊ីម អាយុ៧៩ឆ្នាំ បានបាត់បង់កូនពីរនាក់ ។ អ៊ីមមានប្រសាសន៍ថា គាត់ស្អប់ខ្មែរក្រហមសូម្បីតែឈ្មោះក៏មិនចង់ឮផង ។ តាំង គីម ត្រូវកងទ័ពខ្មែរក្រហមវាយលោកលើហើយបម្រុងនឹងសម្លាប់គាត់ ប៉ុន្តែគាត់បានរត់រួចពីសេចក្តីស្លាប់ ។ នៅពេលនិយាយដល់ការបង្រួបបង្រួម តាំង គីម និយាយថា “ខ្ញុំឆ្ងល់ថាតើភាគីទាំងពីររួបរួមគ្នាយ៉ាងម៉េចកើត បើម្ខាងជាជនរងគ្រោះហើយម្ខាងទៀតជាជនដៃដល់? ម្យ៉ាងទៀត ជនដៃដល់មិនដែលទទួលកំហុសដែលខ្លួនបានធ្វើផង” ។

ចំណែកជនដៃដល់រស់នៅក្នុងសភាពភ័យខ្លាចថាថ្ងៃណាមួយខ្លួននឹងត្រូវយកទៅកាត់ទោសនៅចំពោះមុខច្បាប់ ។ ជនដៃដល់មិនដែលចាត់ទុកខ្លួនឯងជាឧក្រិដ្ឋជន និងមិនចង់ប្រាប់អំពីមុខងាររបស់ខ្លួនកាលពីរបបកម្ពុជាប្រជាធិបតេយ្យឡើយ ។ ជនដៃដល់មិនចង់ប្រឈមមុខនឹងមនុស្សដែលខ្លួនធ្លាប់ធ្វើបាបទេ ។ សឿន ធ្លាប់ជាសន្តិសុខយាមគុកខ្មែរក្រហម ។ ពេលគាត់ទៅទស្សនាមន្ទីរ ស-២១ និងឃើញរូបថតអំពីសកម្មភាពដែលខ្មែរក្រហមប្រព្រឹត្តមកលើជនរងគ្រោះ គាត់មិនជឿថានោះជាការពិតឡើយ ។ គាត់បែរជាយល់ថាអ្វីដែលគាត់ឃើញគឺជាទង្វើរបស់មនុស្សមួយក្រុមដែលប្រឆាំងនឹងខ្មែរក្រហម ។ ជនដៃដល់ភាគច្រើនចាត់ទុកខ្លួនឯងថាជាជនរងគ្រោះពីរបបនេះដែរ ។

ជនដៃដល់បន្ទោសមេដឹកនាំរបស់ខ្លួនថាបានបង្ខំខ្លួនឲ្យប្រព្រឹត្តបទល្មើស រីឯមេដឹកនាំបែរជាទម្លាក់កំហុសលើកម្មាភិបាលថ្នាក់ក្រោម ។ ជនរងគ្រោះដាក់ទោសទាំងស្រុងលើជនដៃដល់ថ្នាក់ក្រោមដូចជា ប្រធានភូមិ ឬប្រធានសហករណ៍ ឬឈ្លបជាដើម ។ នរវិទូសញ្ជាតិអាមេរិក អាឡិច ហ៊ីនតុន អះអាងថាការសម្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យធ្វើឡើងដោយកម្មាភិបាលខ្មែរ-ក្រហមថ្នាក់ក្រោម ។ អៀប ឌុច ប្រធានយុវជនស្រុកត្រាំកក់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនិយាយថា ការសម្លាប់មួយចំនួនជាលទ្ធផលនៃជម្លោះនៅក្នុងសហគមន៍ ។

ជនរងគ្រោះដូចជា តាំង គីម និង អ៊ុយ អ៊ីម ទាមទារពេលវេលាច្រើនឆ្នាំដើម្បីអត់អោនទោសឲ្យអ្នកដែលធ្វើបាបគាត់ ។ ហេតុនេះហើយ គ្មានការបង្រួបបង្រួមនៅកម្ពុជាទេដរាបណាប្រជាជនគ្រប់រូបគ្មានការរួបរួមផ្នែកផ្លូវចិត្តរៀងៗខ្លួន ។ ប្រជាជនកម្ពុជាមិនអាចអត់ឱនដល់អ្នកណាម្នាក់ឡើយ លុះត្រាតែបានដឹងថាអ្នកណាមួយដែលខ្លួនត្រូវអត់ទោសឲ្យ ហើយអត់ទោសរឿងអ្វី ។ តាំង គីម និង សឿន មានគំនិតខុសគ្នាស្រឡះ ។ **ញាណ សុជាតិ**

# លិខិតពីមិត្តអ្នកអាន

*ខ្ញុំបាទឈ្មោះ នន់ អ៊ិត ភេទប្រុស កើតនៅឆ្នាំ១៩៤៦ នៅភូមិចារ ឃុំរំលេច ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង ជាអតីតគ្រូបឋមសិក្សា និងជាបុគ្គលិកសុខាភិបាលស្រុកស៊ីធរកណ្តាលពីឆ្នាំ១៩៨០ដល់ឆ្នាំ១៩៩៥ ជាជនពិការសុខភាពរលាកក្រពះពោះវៀនរ៉ាំរ៉ៃតាំងពីរបប ប៉ុល ពត, អៀង សារី, ខៀវ សំផន បច្ចុប្បន្នរស់នៅជាមួយកូនក្នុងក្រុម៦២ ភូមិ១០ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ។*

**សូមគោរពមក**

*លោកប្រធានមជ្ឈមណ្ឌលស្រាវជ្រាវឯកសារប្រល័យពូជសាសន៍កម្ពុជា*

*លោកប្រធានជាទីគោរព! ដោយតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមពីឆ្នាំ១៩៧៥ទល់១៩៧៩ចាប់ផ្តើមដំណើរការបណ្តើរៗហើយនោះ ខ្ញុំបាទជាជនរងគ្រោះមួយរូបដែលបានរស់នៅស្ពាយតែជំងឺជាប្រចាំរហូតដល់សព្វថ្ងៃ សូមធ្វើរបាយការណ៍ជូនលោកប្រធានមជ្ឈមណ្ឌលនូវទីកន្លែងឃុំឃាំងរួម ទីកន្លែងកាប់សម្លាប់រួម និងរណ្តៅកប់រួម នៅក្នុងស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង ៖*

*១) ចាប់តាំងពីមុនឆ្នាំ១៩៧៥មក មណ្ឌលសុខភាពដ៏ធំស្កឹមស្កៃមួយនិងអនុវិទ្យាល័យព្រែកសណ្តែកក្នុងឃុំព្រែកចង្ក្រាន ក្លាយជាមន្ទីរឃុំឃាំងដ៏ធំរបស់ស្រុក និងជាមណ្ឌលពិឃាតមនុស្សរាប់សែននាក់រហូតដល់ចុងឆ្នាំ១៩៧៨ ។ សូម្បីតែរាល់អណ្តូងក្នុងផ្សារក៏ជារណ្តៅផ្ទុកសាកសពដែរ ។*

*២) ព្រៃចេកជិតភូមិកំភារក្នុងឃុំរំលេចជាកន្លែងសម្លាប់មនុស្សតាំងពីឆ្នាំ១៩៧០-១៩៧៨ ដែលគេនាំយកអ្នកជាប់ឃុំនៅមណ្ឌលសុខភាពនិងអនុវិទ្យាល័យព្រែកសណ្តែកទៅវាយសម្លាប់ ។*

*៣) អនុវិទ្យាល័យព្រៃដើមថ្នឹងនិងវត្តព្រៃដើមថ្នឹងខាងជើង ក្នុងឃុំព្រៃដើមថ្នឹង ជាគុក និងជាទីពិឃាតមនុស្សដ៏គួរឲ្យរន្ធត់នាឆ្នាំ១៩៧៨ ។*

*៤) វត្តព្រៃឈៀងក្នុងឃុំឫស្សីសាញ់ ជាកន្លែងសម្លាប់ កងចល័ត (យុវជនចល័តការងារ) ក្នុងស្រុកនៅឆ្នាំ១៩៧៨ ដែលពួកវានិយាយបោកបញ្ឆោតយុវជនទាំងអស់នោះថាទៅធ្វើទ័ពដើម្បីកម្ចាត់ខ្មាំងយួន ។*

*៥) វត្តព្រៃស្វា ឃុំជ្រៃឃ្មុំ ជាកន្លែងពិឃាតនាឆ្នាំ១៩៧៨ ។*

*៦) ព្រៃអន្លង់សរ ក្នុងឃុំរំលេច ជាកន្លែងសម្លាប់មនុស្ស ចាប់ពីថ្នាក់ប្រធានក្រុមឡើងទៅរបស់ឃុំរំលេចនាឆ្នាំ១៩៧៨ ។ ដោយពួកវាកោះហៅប្រជាជនក្នុងឃុំទាំងមូលឲ្យទៅប្រជុំនៅទីរួមស្រុកស្ថិតនៅចុងភូមិអន្លង់សរ រួចឲ្យអ្នកមានតួនាទីចាប់ពីប្រធានក្រុមឡើងឡានទៅរៀនសូត្រច្បាប់ថ្មីមួយរយៈខ្លី ប៉ុន្តែអ្នកទាំងនោះត្រូវសម្លាប់ក្បែរទីនោះឯង ។ ខ្ញុំបាទសូមបញ្ជាក់ថា ស្រុកស៊ីធរកណ្តាលសម័យនោះមានមន្ទីរស្រុកពីរកន្លែង មួយនៅព្រៃដើមថ្នឹង មួយទៀតនៅអន្លង់សរ ។*

*អស់លោកនិងប្រិយមិត្តទាំងអស់! ក្រោយថ្ងៃ៧ មករា ១៩៧៩ភ្លាម បើគេបានចូលទៅឃើញទីណាមួយក្នុងចំណោមទីទាំងនេះគេនឹងបានឃើញគំនរសម្លៀកបំពាក់ ឆ្អឹងមនុស្សគ្រប់ជំពូក គ្រប់ប្រភេទ រដូករណែលពាសពេញវាលពេញអណ្តូង ក្លិនឆ្អាបស្អុយ ឈាមក្រហមក្រម៉ៅដេរដាស រីឯដើមឈើតូចដំទើរបកសំបកមានឈាមប្រឡាក់ប្រឡូសដោយពួកវាចាប់កូនក្មេងបោក ។*

*តើទិដ្ឋភាពព្រឹត្តិការណ៍ពិតដែលកើតមានកន្លងមកលើទឹកដីកម្ពុជាពីឆ្នាំ១៩៧៥ដល់១៩៧៨ ឲ្យយើងជាខ្មែរដែលបានទទួលរងយ៉ាងទារុណបំភ្លេចចោលទេបានដែរឬទេ? ហើយតើគួរយើងលើកលែងទោសឲ្យក្រុមជនមហាឧក្រិដ្ឋមហាហ្វាស៊ីស មហាព្រៃផ្សៃឲ្យរស់នៅយ៉ាងរំភើយដោយមិននាំទៅតុលាការដែរឬទេ?*

ចំពោះខ្ញុំបាទ តាមរយៈលោកប្រធានមជ្ឈមណ្ឌលស្រាវជ្រាវឯកសារ សូមប្តឹងជាដាច់ខាតទៅតុលាការដែលនឹងប្រព្រឹត្តទៅនៅពេលខាងមុខ ដើម្បីកុំឲ្យអំពើបែបនេះកើតមានជាថ្មីម្តងទៀតលើមនុស្សជាតិ និងឲ្យអ្នកដែលស្លាប់ទៅក៏ដូចជាអ្នកនៅរស់រងកម្មពីរបបនេះបានស្ងប់អារម្មណ៍ខ្លះ ។

ខ្ញុំបាទសូមលោកប្រធានមេត្តាបញ្ជូនលិខិតខ្ញុំបាទមួយច្បាប់ទៅតុលាការដោយអនុគ្រោះផង ។

សូមលោកប្រធានមជ្ឈមណ្ឌលស្រាវជ្រាវឯកសារមេត្តាទទួលនូវការគោរពដ៏ស្មោះអំពីខ្ញុំបាទ ។

**ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៦**

**ឆន់ អ៊ិត**

# ការិយាល័យព័ត៌មានសាធារណៈ

“ការិយាល័យព័ត៌មានសាធារណៈ” នៃមជ្ឈមណ្ឌលឯកសារកម្ពុជាឥឡូវនេះបានចាប់ផ្តើមបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករដ្ឋាភិបាលនិងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបស់របបកម្ពុជាប្រជាធិបតេយ្យនិងព្រឹត្តិការណ៍វិវត្តន៍នៃអង្គជំនុំជម្រះវិសាមញ្ញដែលនឹងត្រូវបង្កើតឡើងនៅពេលខាងមុខឆាប់ៗនេះ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាមជ្ឈមណ្ឌលដែលប្រមូលផ្តុំនិងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននិងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារទាំងនេះរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

“ការិយាល័យព័ត៌មានសាធារណៈ” មានផ្តល់ជូននូវសេវា៤យ៉ាង ÷

**១) បណ្ណាល័យ** ៖ នៅក្នុងបណ្ណាល័យរបស់យើង សាធារណជនអាចអានឯកសារ សៀវភៅ និងទស្សនាវដ្តី ស្តាប់កាសែតសំឡេង ទស្សនាខ្សែភាពយន្តឯកសារ និងមើលរូបថតដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង បណ្ណសារដ្ឋានជាតិកម្ពុជា និងពីប្រភពផ្សេងៗទៀត ។

**២) មជ្ឈមណ្ឌលអប់រំ** ៖ មជ្ឈមណ្ឌលនេះមានបញ្ចាំងជូននូវខ្សែភាពយន្តឯកសារ និងបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជា-ធិបតេយ្យ ប្រធានបទទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញ និងប្រធានបទដទៃៗទៀត ។ ភាពយន្តឯកសារអំពីខ្មែរក្រហមមានបញ្ចាំងជូនទស្សនានៅរៀងរាល់ថ្ងៃអង្គារនិងថ្ងៃព្រហស្បតិ៍ នៅវេលាម៉ោង៩ព្រឹកនិង៣រសៀល ។

**៣) ក្រុមការងារផ្នែកតុលាការ** ៖ ទីប្រឹក្សាផ្នែកឯកសារនិងផ្នែកច្បាប់របស់យើងនឹងផ្តល់ជំនួយផ្នែកស្រាវជ្រាវដល់អ្នកជំនាញផ្នែកច្បាប់កម្ពុជានិងអង្គការសហប្រជាជាតិដែលធ្វើការងារផ្នែកតុលាការ ក៏ដូចជាដល់សាធារណជនទូទៅដែរ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង អែម សុខឃីម តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។

សូមអរគុណ ។

# យុត្តិធម៌សម្រាប់ខាលពិឃាត

នៅថ្ងៃទី២០ ខែឧសភា រៀងរាល់ឆ្នាំ ប្រជាជនកម្ពុជាជាច្រើននាក់មកជួបជុំគ្នានៅបូជនីយដ្ឋានមួយនៅទីក្រុងញូវរីករដ្ឋញូវជើស៊ី ដើម្បីរំឭកការចងចាំអំពីរបបប្រល័យពូជសាសន៍ក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ ។ នៅក្នុង"ទិវាចងកំហឹង" មនុស្សម្នាមកកកុញដើម្បីស្តាប់ប្រសាសន៍របស់មន្ត្រីប្រចាំតំបន់ និងអ្នកដែលរស់រានមានជីវិតពីរបបខ្មែរក្រហមថ្លែងពីអំពើឃោរឃៅនិងទុក្ខវេទនាដែលអ្នកទាំងនោះបានឆ្លងកាត់ពី"គុកឥតជញ្ជាំង" ។

អ្នកចូលរួមមួយចំនួនយំខ្សឹកខ្សួលនៅពេលព្រះសង្ឃធ្វើពិធីសូត្រមន្តឧទ្ទិសដល់ព្រលឹងអ្នកស្លាប់ និងនៅពេលស្តាប់ព្រឿងរ៉ាវដែលស្រដៀងគ្នានឹងខ្សែជីវិតរបស់ខ្លួនហើយធ្វើឲ្យខ្លួននឹកដល់ការឈឺចាប់កាលពីពេលកន្លងមក ។ អ្នកចូលរួមមួយចំនួនទៀត ពុះកញ្ជ្រោលដោយកំហឹង ។ កាលពីមុន អ្នកចូលរួមបានគសាងជារូបសំណាករបស់ ប៉ុល ពត និងអ្នកគ្រាំទ្រ រួចហើយទាត់ធាក់ និងដុតភ្លើងបំផ្លាញនៅចំពីមុខបដាដែលសរសេរថា ៖ "ត្រូវចងចាំជីវិតក្រោមអំណាច ប៉ុល ពត ដែលជាអ្នកសម្លាប់ប្រជាជនកម្ពុជា" ។

ដោយទិវានេះបានផ្លាស់ប្តូរទៅតាមចរន្តនយោបាយនៅកម្ពុជាការប្រារព្ធពិធីបុណ្យរំឭកនៅឆ្នាំនេះគឺគួរឲ្យកត់សម្គាល់ជាងឆ្នាំមុនៗ ដោយសារមានការសង្កត់ធ្ងន់លើបញ្ហាយុត្តិធម៌ ។ នៅក្នុងពេលដំណាលគ្នានេះដែរ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា សម្តេចព្រះបរមនាថ នរោត្តម សីហមុនី បានប្រកាសជាផ្លូវការនូវឈ្មោះចៅក្រមនិងព្រះរាជអាជ្ញាជាតិនិងអន្តរជាតិដែលនឹងបម្រើការនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម ។

តុលាការនេះបានផ្តើមដំណើរការនៅដើមរដូវស្លឹកឈើជ្រុះ (នៅរវាងខែកញ្ញានិងខែធ្នូ) ពេលដែលសហព្រះរាជអាជ្ញាជនជាតិកម្ពុជានិងកាជាណាចាប់ផ្តើមស៊ើបអង្កេតរឿងក្តី ។ យ៉ាងណាមិញ តុលាការប្រឈមមុខនឹងឧបសគ្គចម្បងមួយចំនួនដូចខាងក្រោម ៖

**ចុងចោទមានវ័យជរា** ៖ អតីតមេដឹកនាំខ្មែរក្រហមជាច្រើនរូបដូចជា "បងធំទីពីរ" នួន ជា អាយុ៧៨ឆ្នាំ, អតីតប្រធានគណៈប្រធានរដ្ឋ ខៀវ សំផន អាយុ៧៤ឆ្នាំ, និងអតីតឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស អៀង សារី អាយុ៧៦ សុទ្ធតែស្ថិតនៅក្នុងវ័យជរា និងមានសុខភាពទ្រុឌទ្រោម ។ អតីតមេដឹកនាំខ្មែរក្រហមទាំងអស់នេះអាចស្លាប់ដោយមិនបានទទួលការកាត់ទោសដូចករណីការស្លាប់របស់ ប៉ុល ពត កាលពីឆ្នាំ១៩៩៨ ។ ការស្លាប់របស់ ស្លូបូដាន មីឡូសើវីក ក្នុងអំឡុងពេលសវនាការនៅទីក្រុងហេក កាន់តែបង្ហាញឲ្យឃើញនូវភាពបន្ទាន់ក្នុងការនាំឧក្រិដ្ឋជនទៅកាត់ទោសឲ្យកាន់តែឆាប់តាមដែលអាចធ្វើទៅបាន ។

**កង្វះខាតថវិកា** ៖ ខណៈដែលមានថវិកាគ្រប់គ្រាន់សម្រាប់ដំណើរការតុលាការ ខាងភាគីកម្ពុជានៅខ្វះថវិកា៩,៦លានដុល្លារទៀត ដើម្បីបង្គ្រប់ចំនួនថវិកាសរុប៥៦,៣លានដុល្លារ សម្រាប់ដំណើរការតុលាការក្នុងរយៈពេលបីឆ្នាំ ។ នេះជាចំនួនថវិកាដែលប្រទេសក្រីក្រមួយនេះមិនអាចចំណាយបានឡើយ ។ សហរដ្ឋអាមេរិកដែលមិនទាន់បានរួមវិភាគទានថវិកាមួយសេនណានៅឡើយនោះ អាចសម្រួលស្ថានភាពនេះបានដោយចេញបង្គ្រប់ទឹកប្រាក់ដែលនៅខ្វះខាត ។

**ការផ្សព្វផ្សាយពត៌មានទៅក្នុងស្រទាប់ប្រជាជន** ៖ ប្រជាជនកម្ពុជាភាគច្រើន ជាពិសេសអ្នករស់នៅតំបន់ដាច់ស្រយាល មិនបានដឹងថាសវនាការបម្រុងនឹងកើតមានឡើងឡើយ ឬបើទោះបីជាគាត់បានដឹងព្រអំពីតុលាការនេះក៏ដោយ ក៏គាត់នៅមានការយល់ដឹងតិចតួចអំពីដំណើរការនេះ ។ អង្គការមិនមែនរដ្ឋាភិបាលដូចជាមជ្ឈមណ្ឌលឯកសារកម្ពុជា កំពុងធ្វើការយ៉ាងសកម្មក្នុងការផ្សព្វផ្សាយព័ត៌មានស្តីអំពីតុលាការ ប៉ុន្តែការខំប្រឹងប្រែងនេះទាមទារការឧបត្ថម្ភពេញទំហឹងពីម្ចាស់ជំនួយអន្តរជាតិ ។

**ប្រព័ន្ធតុលាការកម្ពុជា** ៖ មានការព្រួយបារម្ភខ្លាំងអំពីបញ្ហាថា បុគ្គលិកច្បាប់មិនទាន់មានការហ្វឹកហ្វឺន និងមិនទាន់មានឯករាជ្យភាពគ្រប់គ្រាន់នៅឡើយ ។ បញ្ហានេះអាចបណ្តាលឲ្យតុលាការស្ថិតនៅក្រោមឥទ្ធិពលរបស់ថ្នាក់ដឹកនាំកម្ពុជា ហើយជាលទ្ធផលតុលាការនឹងមិនអាចឆ្លើយតបទៅនឹងបទដ្ឋានច្បាប់អន្តរជាតិ ។ ការព្រួយបារម្ភមានកាន់តែខ្លាំងនៅពេលដែលបញ្ជីរាយនាមមន្ត្រីចៅក្រម មានឈ្មោះចៅក្រមមួយចំនួនដែលមានទំនាក់ទំនងជិតស្និទ្ធនឹងគណបក្សប្រជាជនកម្ពុជា ក្នុងនោះក៏មានឈ្មោះឧត្តមសេនីយ៍មួយរូបដែលជាសមាជិកគណៈកម្មាធិការ

មជ្ឈិមនៃគណបក្សប្រជាជនកម្ពុជា និងធ្លាប់ជាចៅក្រមនៅក្នុងសវនាការពីរដែលមានភាពមន្ទិលរហូតដល់មានការវាយប្រហារពីគណបក្សប្រឆាំង ។

ទោះបីជាបញ្ហាទាំងនេះចាំបាច់ទាមទារការយកចិត្តទុកដាក់ជាបន្ទាន់ក៏ដោយ ក៏គ្មានបញ្ហាណាមួយអាចបញ្ឈប់ដំណើរការតុលាការនេះបានឡើយ ។ ប្រជាជនកម្ពុជាដែលខ្ញុំទើបតែបានជួបជជែកថ្មីៗនេះ បាននិយាយថាខ្លួនចង់បានតុលាការដើម្បីស្វែងយល់ថាតើមានអ្វីកើតឡើង ហើយហេតុអ្វីបានជារឿងនេះកើតឡើង ។ ប្រជាជនកម្ពុជាចង់ឃើញអតីតមេដឹកនាំខ្មែរក្រហមដែលកំពុងរស់នៅដោយសេរី ទទួលខុសត្រូវចំពោះអ្វីដែលខ្លួនបានប្រព្រឹត្តកន្លងមក ។

សហគមន៍អន្តរជាតិ ជាពិសេសសហរដ្ឋអាមេរិក គួរតែប្រឹងប្រែងឲ្យអស់ពីសមត្ថភាពដើម្បីឲ្យតុលាការនេះទទួលជោគជ័យ ។ ប្រហែលជានៅពេលណាមួយ ប្រជាជនកម្ពុជានឹងប្រារព្ធពិធីបុណ្យថ្មីមួយគឺ "ទិវាយុត្តិធម៌" ។

**អាឡិច ហ៊ិនតុន**

# ស្ត្រីមេម៉ាយក្រោមរបបតាលីបង់

ខាងក្រោមនេះជាការរៀបរាប់របស់ស្ត្រីមេម៉ាយម្នាក់ឈ្មោះ សែស្តា អាយុ៣៨ឆ្នាំ រស់នៅទីក្រុងកាប៊ុល ប្រទេសអាហ្វហ្កានីស្ថាន ។ សែស្តា មានកូន១០នាក់ (ស្រី៩នាក់ប្រុសម្នាក់) ។ ប្តីរបស់ សែស្តា ត្រូវរបបតាលីបង់សម្លាប់កាលពីជាងពីរឆ្នាំមុន ។

ខ្ញុំនឹងរៀបរាប់ប្រាប់អ្នកអំពីជីវិតប្រចាំថ្ងៃរបស់ខ្ញុំ ។

នៅពេលព្រឹក ខ្ញុំក្រោកពីព្រលឹម លុបមុខ ដួតទឹក និងថ្វាយបង្គំព្រះ ។ បន្ទាប់មកខ្ញុំរៀបចំអាហារពេលព្រឹកឲ្យកូនៗ ។ ដោយសារតែខ្ញុំមានកូនស្រីច្រើនពេក ខ្ញុំមិនអាចទុកកូនៗចោលនៅផ្ទះបានទេ ជាពិសេសក្នុងសង្កាត់នេះតែម្តង ។ ដូចនេះ ខ្ញុំមានពេលតែពីរម៉ោងប៉ុណ្ណោះទៅសម្អាតផ្ទះលោកវេជ្ជបណ្ឌិតដែលជាអ្នកជិតខាងខ្ញុំ បន្ទាប់មកខ្ញុំប្រញាប់ត្រឡប់មកផ្ទះវិញ ។ ក្រោយពីចប់ការងារប្រចាំថ្ងៃ ខ្ញុំសម្រាកនៅផ្ទះ ។ ជាធម្មតា ខ្ញុំបរិភោគអាហារថ្ងៃត្រង់នៅចន្លោះម៉ោង១និងម៉ោង២ និងអាហារពេលល្ងាចនៅម៉ោង៧ ។

ខ្ញុំរៀបការនៅអាយុ១៦ឆ្នាំ ប្តីខ្ញុំអាយុ៣៥ឆ្នាំ ជាកម្មករគ្មានជំនាញម្នាក់ដែលគ្មានការងារធ្វើ ។ ឪពុកម្តាយជាអ្នករៀបចំអាពាហ៍ពិពាហ៍យើងទាំងពីរ ។ ប្តីរបស់ខ្ញុំត្រូវទាហានតាលីបង់សម្លាប់កាលពីពីរឆ្នាំកន្លះមុន ។ មុនពេលប្តីខ្ញុំស្លាប់ យើងមានជីវភាពមធ្យម ។ សព្វថ្ងៃ ជីវភាពរបស់ខ្ញុំលំបាកជាងមុន ។ ខ្ញុំគ្មានទីជម្រកនិងអាហារគ្រប់គ្រាន់សម្រាប់ក្រុមគ្រួសាររបស់ខ្ញុំឡើយ ។

ខ្ញុំត្រូវយកកូនស្រីបួននាក់ទៅដាក់នៅមណ្ឌលកុមារកំព្រា ពីព្រោះខ្ញុំគ្មានលទ្ធភាពចិញ្ចឹមកូនទាំងអស់ទេ ។

យើងបានចាកចេញពីប្រទេសអ៊ីរ៉ង់មករស់នៅទីនេះកាលពីឆ្នាំ១០មុន ។ ក្នុងឆ្នាំចុងក្រោយនេះ យើងផ្លាស់ទីកន្លែងរស់នៅបួនលើកហើយក្នុងទីក្រុងកាប៊ុល ។ សព្វថ្ងៃខ្ញុំស្នាក់នៅផ្ទះបងប្អូនរបស់ខ្ញុំ ពីព្រោះគាត់ទៅរស់នៅប្រទេសអ៊ីរ៉ង់ ។ ខ្ញុំស្នាក់នៅក្នុងផ្ទះនេះមួយរយៈ ប៉ុន្តែខ្ញុំពុំអាចរកអាហារគ្រប់គ្រាន់សម្រាប់បរិភោគបានឡើយ ។

យើងមករស់នៅក្នុងទីក្រុងកាប៊ុលចំពេលដែលរដ្ឋាភិបាលណាជីប ដួលរលំ ហើយយើងរស់នៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលតាលីបង់ ។ រស់នៅក្រោមរបបតាលីបង់វេទនាណាស់ វេទនាជាងនៅក្រោមរដ្ឋាភិបាល ណាជីប ទៅទៀត ។ ប្តីខ្ញុំត្រូវទាហានតាលីបង់យកទៅសម្លាប់ចោល ។ បើទោះបីជាឥឡូវនេះ របបតាលីបង់បានរលាយផុតទៅហើយក៏ដោយ ក៏ជីវិតនៅទីនេះនៅតែមានសភាពអាក្រក់ ខ្ញុំនៅតែមិនអាចរកការងារធ្វើបានដដែល ។ សម្រាប់ខ្ញុំ ជីវិតនៅទីនេះគ្មានអ្វីផ្លាស់ប្តូរសោះ ក៏ប៉ុន្តែខ្ញុំសប្បាយចិត្តដែលខ្ញុំបានចូលរួមសិក្សាក្នុងគម្រោងបណ្តុះបណ្តាលនេះ ។

ខ្ញុំសង្ឃឹមថា ការចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ ខ្ញុំនិងកូនៗនឹងអាចក្លាយជាជាងកាត់ដេរ និងអាចរកថវិកាជួយទ្រទ្រង់ជីវភាពគ្រួសារបាន ។ ខ្ញុំឈឺជាញឹកញាប់ មិនបានមករៀនទៀងទាត់ទេ ក៏ប៉ុន្តែខ្ញុំសង្ឃឹមថាកូនៗរបស់ខ្ញុំនឹងបន្តសិក្សាវគ្គនេះ និងចេះដឹងច្រើនជាងខ្ញុំថែមទៀត ។

ខ្ញុំគ្មានសង្ឃឹមទាល់តែសោះអំពីអនាគតរបស់ខ្ញុំ ពីព្រោះខ្ញុំមានកូនស្រីច្រើនណាស់ ។ តើខ្ញុំអាចធ្វើបានទៅ?

ទៅថ្ងៃមុខ ខ្ញុំចង់បានតែរបស់ពីរយ៉ាងគត់ គឺអាហារនិងជម្រកស្នាក់នៅ ។

**រេហ្វ ស្ត្រាកា**

# ស្វែងរកប្តីនិងកូនប្រុសដែលបាត់ខ្លួន

បន្ទាប់ពីស្តាប់អត្ថបទដែលមានចំណងជើងថា "តែងតែរស់នៅក្នុងបេះដូងនិងអារម្មណ៍" និពន្ធដោយ ចូអាណា រ៉េបេកា ម៉ាន់សុន ដកស្រង់ពីទស្សនាវដ្តីស្វែងរកការពិតលេខ៤៥ ចេញផ្សាយនៅខែកញ្ញា ឆ្នាំ២០០៣ ដែលដែលចាក់ផ្សាយតាមស្ថានីយ៍វិទ្យុខេត្តកំពត FM ១០៣.២៥ MHz ស្ត្រីម្នាក់ឈ្មោះ នាក់ ផេន មានការសង្ស័យទៅលើឈ្មោះបុរសម្នាក់នៅក្នុងអត្ថបទឈ្មោះ ជឿត សារ៉ាត់ ដែលមានដំណើររឿងដូចគ្នាទៅនឹងដំណើររឿងរបស់ប្តីគាត់ឈ្មោះ ចុង សារ៉ាត់។ នាក់ ផេន បានទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីសុំបញ្ជាក់ការពិតអំពីដំណើររឿងនេះ ដើម្បីស្វែងរកឈ្មោះ ចុង សារ៉ាត់ និងកូនប្រុសច្បងរបស់គាត់ឈ្មោះ ចុង ស៊ីយ៉ាណា ដែលបានបែកគ្នានៅខេត្តកំពង់ធំនៅឆ្នាំ១៩៧៥ ។



ចុង សារ៉ាត់ មុនឆ្នាំ១៩៧៥



នាក់ ផេន បច្ចុប្បន្ន

នាក់ ផេន អាយុ ៦៣ឆ្នាំ រៀបរាប់ដំណើររឿងរបស់គាត់បណ្តើរភ្នែករបស់គាត់សម្លឹងមើលរូបថតប្តីរបស់គាត់បណ្តើរ ÷

ខ្ញុំកើតនៅភូមិតាងីត ឃុំត្រពាំងសាលាខាងកើត ស្រុកទូកមាស ខេត្តកំពត។ ឪពុកខ្ញុំឈ្មោះ នាក់ សេន ម្តាយឈ្មោះ សុខ មាន។ គាត់ទាំងពីរនាក់ស្លាប់ដោយសារជំងឺតាំងពីមុនរបបខ្មែរក្រហម ។

ខ្ញុំរៀបការជាមួយប្តីរបស់ខ្ញុំឈ្មោះ ចុង សារ៉ាត់ នៅឆ្នាំ១៩៦៣ នៅឃុំលង្វែក ស្រុកពញាឮ ខេត្តកណ្តាល។ សារ៉ាត់មានស្រុកកំណើតនៅភូមិរំដួល ឃុំប្រសូត្រ ស្រុកប្រសូត្រ ខេត្តស្វាយរៀង។ ខ្ញុំបានស្គាល់គាត់នៅពេលខ្ញុំទៅស្នាក់នៅផ្ទះបងប្រុសរបស់ខ្ញុំឈ្មោះ ស្វាយ ពៅ ដែលជាទាហានឆ័ត្រយោងរបស់លន់នល់ ហើយគាត់ជាកូនទាហានរបស់បងប្រុសខ្ញុំ។ ផ្ទះបងប្រុសរបស់ខ្ញុំនៅពោធិចិនតុង។ កាលណោះខ្ញុំបានជួយដេរសម្លៀកបំពាក់ឲ្យបងប្រុសខ្ញុំ។ ខ្ញុំស្នាក់នៅពោធិ៍ចិនតុងបានបន្តិចក៏ផ្លាស់ទៅនៅលង្វែកជាមួយបងប្រុស ។

សារ៉ាត់ ក៏ចាប់ចិត្តស្រលាញ់ខ្ញុំហើយចូលស្តីដណ្តឹងខ្ញុំរៀបការតាមប្រពៃណី។ យើងទាំងពីរនាក់រៀបការនៅលង្វែក ។

នៅពេលខ្ញុំមានកូនប្រុសពីរនាក់គឺ ចុង ស៊ីយ៉ាណា និង ចុង ស៊ីយ៉ាណូ ប្តីខ្ញុំក៏ផ្លាស់មកធ្វើការនៅទីក្រុងភ្នំពេញ ហើយខ្ញុំនិងកូនក៏មកតាមគាត់ដែរ ។ ការងាររបស់គាត់ផ្លាស់ប្តូរចុះឡើងមិននៅមួយកន្លែងទេ។ សារ៉ាត់ ចូលធ្វើជាអង្គរក្សរបស់ លន់នល់ ហើយក្រោយមកគាត់ទៅធ្វើការជាមួយ ទាបែន (នៅក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ ទាបែន សុំចេញពីរដ្ឋាភិបាលលន់នល់) ដែលជាចៅហ្វាយខេត្តសៀមរាបពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥។ នៅពេល ទាបែន ផ្លាស់ទៅធ្វើចៅហ្វាយខេត្តកំពង់ធំ ប្តីខ្ញុំក៏ទៅតាមគាត់ដែរ ។

ឆ្នាំបន្តបន្ទាប់មកខ្ញុំកើតបានកូនស្រី២នាក់ទៀតគឺ ចុង សុខជា និង ចុង សុគន្ធា។ ជាអកុសល កូនស្រីពៅរបស់ខ្ញុំបានស្លាប់ដោយសារជំងឺគ្រុនឈាមនៅពេលអាយុបាន៣ឆ្នាំ។ នៅខែមីនា ឆ្នាំ១៩៧៥ កូនស្រីទី៣របស់ខ្ញុំមានជំងឺគ្រុនសន្និរហូតដល់ស្វិតជើងដើរលែងរួច។ ខ្ញុំនាំកូនមកស្តុំជើងនិងសម្រាកព្យាបាលនៅមន្ទីរពេទ្យអាមេរិកាំងនៅទីក្រុងភ្នំពេញ។ ពេលខ្ញុំចាកចេញមក

កូនប្រុសទីពីររបស់ខ្ញុំឈ្មោះ ចុង ស៊ីយ៉ាណូ បានយំរត់តាមខ្ញុំ ដូច្នេះខ្ញុំក៏យកវាមកជាមួយ ។ យើងទាំងបីនាក់បានធ្វើដំណើរតាមយន្តហោះពីខេត្តកំពង់ធំមកទីក្រុងភ្នំពេញ ។

ខ្ញុំយកកូនមកព្យាបាលបានជាង១ខែប្ដីរបស់ខ្ញុំទូរស័ព្ទហៅខ្ញុំត្រឡប់ទៅខេត្តកំពង់ធំវិញជាប្រញាប់ដោយសារសភាពការណ៍ស្រុកទេសមិនស្រួល ។ ខ្ញុំក៏នាំកូនត្រឡប់ទៅវិញទាំងជើងរបស់កូនខ្ញុំមិនទាន់ជាសះស្បើយ ។ នៅពេលខ្ញុំមកដល់ព្រលានយន្តហោះពោធិ៍ចិនតុងស៊ីវ៉ែនរោទិ៍ឡើង ហើយរំពេចនោះគ្រាប់ផ្លោងមិនដឹងមកពីទិសណាធ្លាក់ផ្ទុះនៅព្រលានយន្តហោះបណ្ដាលមនុស្សនៅក្បែរនោះស្លាប់អស់មួយចំនួន ហើយខ្ញុំត្រូវរបួសសន្លប់មិនដឹងខ្លួន ។ (បើតាមមិត្តភក្ដិរបស់ខ្ញុំប្រាប់ខ្ញុំក្រោយឆ្នាំ១៩៧៩ថា សារ៉ាត់ បានដឹងអំពីរឿងនោះ ប៉ុន្តែគាត់រកយន្តហោះជិះមកមើលខ្ញុំនៅភ្នំពេញមិនបាន) ។ ខ្ញុំ និង សារ៉ាត់ ក៏បែកគ្នាពីចាប់ពីពេលនោះមក ។

ខ្ញុំត្រូវបានបងប្រុស ស្វាយ ពៅ ជួយសង្គ្រោះនាំទៅមន្ទីរពេទ្យវះកាត់ភ្លាមៗ ។ ខ្ញុំសម្រាកព្យាបាលនៅមន្ទីរពេទ្យសេ.សេ.អេង ។ ២-៣ថ្ងៃក្រោយមក គឺថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានចូលកាន់កាប់ទីក្រុងភ្នំពេញ ។ របួសខ្ញុំមិនទាន់ជាសះស្បើយផង ខ្មែរក្រហមបណ្ដេញខ្ញុំនិងអ្នកជំងឺទាំងអស់ចេញពីមន្ទីរពេទ្យដោយប្រាប់ថាមិនឲ្យមានមនុស្សនៅក្នុងទីក្រុងភ្នំពេញទេ ។ យើងចាកចេញដោយមិនហ៊ានគវ៉ាអ្វីទាំងអស់ ។ ខ្ញុំមិនអាចដើរបានបងខ្ញុំបានដាក់ខ្ញុំក្នុងឡានរបស់គាត់រួចរុញឡានទៅមុខ ។ នៅពេលបរកាត់ផ្ទះរបស់ខ្ញុំនៅបន្ទាយស្លឹកជិតពេទ្យរុស្ស៊ី ខ្ញុំចង់ឆៀងចូលយកអីវ៉ាន់នៅក្នុងផ្ទះ ប៉ុន្តែខ្មែរក្រហមមិនអនុញ្ញាតឲ្យចូលទេ ដោយប្រាប់ថាផ្លូវនោះមិនមែនជាមុខសញ្ញាដែលខ្ញុំត្រូវទៅទេ ។ ដូច្នេះ ខ្ញុំមិនបានយកអ្វីទៅតាមខ្លួនក្រៅពីសម្លៀកបំពាក់មួយសម្រាប់ដែលស្លៀកជាប់ខ្លួនតែប៉ុណ្ណោះ ។ ក្រោយមក ខ្មែរក្រហមឲ្យយើងចុះចេញពីឡាននិងទៅជិះរទេះគោវិញ ។

ខ្ញុំបានធ្វើដំណើរទៅដល់ភូមិតាងឹតដែលជាភូមិកំណើតរបស់ខ្ញុំ ហើយរស់នៅទីនោះ ។ អង្គការមិនទាន់ចាត់តាំងខ្ញុំឲ្យធ្វើការភ្លាមទេ ព្រោះជើងរបស់ខ្ញុំនៅហើមដើរមិនរួច ហើយដៃខ្ញុំក៏កម្រើកមិនបាន ។

នៅពេលខ្ញុំបានធូរស្រាលបន្តិច ខ្មែរក្រហមឲ្យខ្ញុំធ្វើការស្រាលៗ លុះដល់ខ្ញុំជាសះស្បើយ ខ្មែរក្រហមចាត់ឲ្យខ្ញុំចូលកងចល័តមេម៉ាយ ។ កងរបស់ខ្ញុំជាកងគំរូតែងតែធ្វើការបានគ្រប់និងលើសផែនការជានិច្ច ។ កូនប្រុសរបស់ខ្ញុំត្រូវចាត់តាំងឲ្យមើលគោ ហើយកូនស្រីស្ថិតក្រោមការមើលថែទាំរបស់យាយចាស់ៗ ។ ខ្ញុំខំធ្វើការដើម្បីកុំឲ្យខ្មែរក្រហមចាប់ថ្នាក់ថាខ្ញុំជាប្រពន្ធរបស់ទាហានលន់នល់ ។ ខ្ញុំដឹងខ្លួនថា បើខ្ញុំមិនខំប្រឹងធ្វើការទេ ខ្ញុំប្រាកដជាស្លាប់មិនខាន ។ ម្យ៉ាងទៀត ខ្ញុំជាប្រជាជន១៧មេសា ។ បើប្រៀបធៀបអាហារដែលខ្ញុំបានទទួលទៅនឹងកម្លាំងពលកម្មដែលខ្ញុំបានលះបង់គឺមិនអាចថ្លឹងថ្លែងគ្នាបានទេ ។ ខ្ញុំទទួលបានបបរ១វែកនិងដំឡូងមីមួយដុំប៉ុណ្ណោះសម្រាប់មួយពេល ។ ទោះបីហូបឆ្អែតឬមិនឆ្អែតក៏ខ្ញុំនៅតែទ្រាំដើម្បីរស់ ។ ខ្ញុំតែងតែបន់ស្រន់សុំឲ្យបានរួចពីរបបខ្មែរក្រហមដើម្បីបានជួបជុំជាមួយប្ដីនិងកូនរបស់ខ្ញុំវិញ ។

នៅឆ្នាំ១៩៧៩ ពេលដែលកងទ័ពវៀតណាមបានវាយសម្រុកចូលប្រទេសកម្ពុជា ខ្ញុំបាននាំកូនរត់ទៅទំបប់កោះស្វាក្នុងបំណងគេចពីខ្មែរក្រហម ។ កងទ័ពវៀតណាមបានប្រាប់ខ្ញុំឲ្យត្រឡប់មកស្រុកកំណើតវិញ ។ ខ្ញុំបានមករស់នៅភូមិតាងឹតមួយរយៈ ប៉ុន្តែដោយសារខ្មែរក្រហមចេះតែចូលបង្កភាពចលាចលក្នុងភូមិញឹកញាប់ពេក ខ្ញុំសម្រេចចិត្តត្រឡប់មករស់នៅបន្ទាយស្លឹកវិញ ដើម្បីរង់ចាំប្ដីនិងកូនក្រែងគាត់មករកខ្ញុំនៅផ្ទះ ប៉ុន្តែនៅពេលមកដល់ផ្ទះខ្ញុំមិនបានជួបប្ដីខ្ញុំទេ ។ ខ្ញុំក៏បានសរសេរសេចក្ដីប្រកាសរកប្ដីនិងកូនប្រុសច្បង ហើយបិទនៅនឹងទ្វារផ្ទះ ។

ខ្ញុំមិនដែលបានទទួលដំណឹងអ្វីសោះពីប្ដីរបស់ខ្ញុំ ទើបតែពេលខ្ញុំបានជួបមិត្តភក្ដិម្នាក់ដែលមានប្ដីជាអតីតទាហានលន់នល់ដែរ ទើបមិត្តរបស់ខ្ញុំរៀបរាប់ប្រាប់ខ្ញុំថា ប្ដីរបស់ខ្ញុំមិនបានឆ្លើយសារភាពប្រាប់ខ្មែរក្រហមអំពីជីវប្រវត្តិរបស់គាត់ទេ ប៉ុន្តែប្ដីរបស់មិត្តខ្ញុំនិងទាហាន១០នាក់ដែលធ្លាប់ធ្វើការងារជាមួយគាត់បានឆ្លើយសារភាពប្រាប់ខ្មែរក្រហម ព្រោះសង្ឃឹមថានឹងបានធ្វើការដូចខ្មែរក្រហមបានសន្យា ។ ខ្មែរក្រហមបញ្ជូនប្ដីខ្ញុំនិងទាហានឆ័ត្រយោងទាំង១១នាក់ទៅស្រុកត្រឡែងកូនក្អែក ខេត្តព្រះវិហារ ។ កូនប្រុសច្បងរបស់ខ្ញុំទៅជាមួយប្ដីខ្ញុំដែរ ។ ខ្មែរ-

ក្រហមមិនឲ្យទាហានលន់នល់ទាំង១២នាក់នោះធ្វើការងារអ្វីទាំងអស់នៅក្នុងរយៈកាលកន្លះខែ ក្រៅពីប្រាប់ឲ្យកាត់សក់ឲ្យស្អាតនិងស្ងោរដំឡូងឲ្យហូប ។ ថ្ងៃមួយប្តីខ្ញុំឃ្លានសាច់មាន់ ក៏ប្រាប់មិត្តភក្តិខ្ញុំថានឹងយកសំពត់របស់ខ្ញុំទៅដូរយកមាន់មកហូបជាមួយកូន ។

ក្រោយមក ខ្មែរក្រហមបញ្ជូនប្តីខ្ញុំនិងទាហានទាំង១១នាក់ទៅឆ្ងាយដោយមិនអនុញ្ញាតឲ្យកូនប្រុសខ្ញុំទៅជាមួយឡើយ ។ ប្តីខ្ញុំបានផ្ញើកូនជាមួយអ្នកស្រុកនៅទីនោះ និងបានទទួលការបង្ហាត់បង្រៀនផ្នែកទ័ពអស់រយៈពេលជាច្រើនខែ ។ មិនយូរប៉ុន្មាន បុរសម្នាក់បានអះអាងថាខ្លួនជាពូរបស់វា ហើយក៏យកវាទៅដោយសន្យាថានឹងជួយវាឲ្យជួបឪពុកវិញ ។ ប្រហែលឆ្នាំ១៩៧៦ កូនប្រុសរបស់ខ្ញុំស្លៀកសម្លៀកបំពាក់ទ័ពដឹកស្បៀងនិងបន្លែបង្ការកាត់តាមភូមិត្រឡែងកូនក្អែក បានជួបជាមួយមិត្តរបស់ខ្ញុំ ។ មិត្តខ្ញុំសួរកូនខ្ញុំថាបានជួបជាមួយឪពុកទេ វាឆ្លើយថាពូដែលនាំវាទៅបានប្រាប់ថា ឪពុកវាបានមករកខ្ញុំដែរ ។ ខ្ញុំបានដំណឹងតែប៉ុណ្ណឹង ។

នៅពេលខ្ញុំស្តាប់វិទ្យុខេត្តកំពត បានឮអត្ថបទដែលមានចំណងជើងថា "តែងតែរស់នៅក្នុងបេះដូងនិងអារម្មណ៍" រៀបរាប់អំពីដំណើររឿងស្ត្រីម្នាក់ដែលមានប្តីឈ្មោះ "ជឿត សារ៉ាត់" ដែលមានរឿងរ៉ាវស្រដៀងគ្នានឹងដំណើររឿងរបស់ប្តីខ្ញុំ ខ្ញុំក៏សង្ស័យភ្លាមថាគាត់អាចជាប្តីរបស់ខ្ញុំពីមុន ។ ខ្ញុំចង់តាមរកគាត់ដើម្បីសួរអំពីកូនរបស់ខ្ញុំ ។

ប្តីរបស់ខ្ញុំមានរាងសង្ហា ខ្ពស់ស្រឡះ ។ បើនិយាយពីអត្តចរិតវិញ គាត់ជាមនុស្សឆ្លាតនិងចិត្តល្អ ។ ឥឡូវនេះ ខ្ញុំគ្មានអ្វីសេសសល់អំពីប្តីខ្ញុំក្រៅពីរូបថតមួយសន្លឹកដែលគាត់ថតសម្រាប់បិទកាតទាហាននៅឆ្នាំ១៩៧០ ។ កាលណោះខ្ញុំក៏បានថតរូបមួយសន្លឹកដែរ ប៉ុន្តែមិនបានថតរួមគ្នាជាមួយគាត់ទេ ។ ខ្ញុំគ្រាន់តែដឹងថា យើងថតនៅទីក្រុងភ្នំពេញប៉ុន្តែមិនចាំហាងថតរូបនោះទេ ។ ខ្ញុំបានផ្តិតរូបថតនេះច្រើនសន្លឹកហើយទុកនៅក្នុងកាបូបរបស់ខ្ញុំជាមួយអត្តសញ្ញាណប័ណ្ណរបស់យើងទាំងពីរ ។ នៅពេលដែលខ្ញុំបែកពីគាត់ ពេលខ្ញុំត្រូវរបួសដោយសារគ្រាប់ផ្លោង រូបថតរបស់គាត់នៅជាមួយខ្ញុំជានិច្ច ។ ដោយខ្លាចឈ្លបខ្មែរក្រហមឆែកឃើញអត្តសញ្ញាណប័ណ្ណរបស់ប្តីខ្ញុំហើយដឹងថាគាត់ជាទាហានលន់នល់ ខ្ញុំបានបករូបថតចេញពីអត្តសញ្ញាណប័ណ្ណយកទៅលាក់ទុកក្នុងស្នុកស្លឹកត្នោត ហើយរុំជាមួយក្រណាត់ដាក់ម្ជុលនិងអំបោះ ។ ប្រសិនបើខ្ញុំមិនបានលាក់រូបថតនោះនៅក្នុងស្នុកទេ ខ្ញុំមិនអាចរក្សាវាបានគង់វង្សដល់សព្វថ្ងៃឡើយ ។

បានជាខ្ញុំថែរក្សារូបថតនោះទុកព្រោះខ្ញុំគិតឃើញថាខ្ញុំបែកគ្នាជាមួយប្តីខ្ញុំហើយ ខ្ញុំមិនចង់ឲ្យរូបថតឃ្លាតទៀតទេ ខ្ញុំទុកវាជាអនុស្សាវរីយ ម្យ៉ាងទៀតរូបថតនេះអាចឲ្យកូនៗរបស់ខ្ញុំស្គាល់មុខឪពុកវាផង ។ ប្រសិនបើគ្មានរូបថតនេះទេ កូនស្រីរបស់ខ្ញុំប្រហែលជាមិនស្គាល់មុខឪពុកវាទេ ព្រោះវាបែកពីឪពុកតាំងពីអាយុជាងមួយឆ្នាំ ។

កូនប្រុសច្បងរបស់ខ្ញុំមានមុខមាត់ស្រដៀងនឹងប្តីរបស់ខ្ញុំ ។ ប្រសិនបើវានៅរស់មកដល់ឥឡូវវាមានអាយុប្រហែល៤០ឆ្នាំ ។ ខ្ញុំអត់មានសល់រូបថតវាសោះ ។ ខ្ញុំនឹកកូនណាស់ ។

ខ្ញុំបានព្យាយាមស្វែងរកប្តីនិងកូនប្រុសខ្ញុំ ប៉ុន្តែមិនបានទទួលដំណឹងអ្វីសោះ ។ ទោះជាយ៉ាងណា ខ្ញុំនៅតែសង្ឃឹមថាគាត់នៅរស់ហើយនឹងវិលត្រឡប់មករកខ្ញុំវិញ ។ ខ្ញុំតែងតែយករូបថតប្តីខ្ញុំមកមើលនៅពេលខ្ញុំនឹកគាត់និងកូនម្តងៗ ។ សព្វថ្ងៃនេះ ខ្ញុំទៅវត្តធ្វើបុណ្យបន់ស្រន់ឲ្យព្រះជួយសម្រេចបំណងខ្ញុំនិងធ្វើឲ្យអារម្មណ៍ ខ្ញុំបានធូរស្បើយ ។

សព្វថ្ងៃនេះខ្ញុំរស់នៅជាមួយកូនស្រីដែលពិការជើងឈ្មោះ ចុង សុខជា ដែលប្រកបរបរកាត់ដេរសម្លៀកបំពាក់ ចំណែកខ្ញុំលក់ដូរអីវ៉ាន់បន្តិចបន្តួច ។ កូនប្រុសទី២ឈ្មោះ ចុង ស៊ីយ៉ាណូ ធ្វើការខាងពន្ធដារ និងបានរៀបការរួចហើយ ។ ឥឡូវនេះវាទៅបំពេញបេសកកម្មនៅក្រុងព្រះសីហនុ ។

អ្នកស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានព្យាយាម ទាក់ទងជាមួយអ្នកនិពន្ធអត្ថបទ "តែងតែរស់នៅក្នុងបេះដូងនិងអារម្មណ៍" ដើម្បីស្វែងរកពត៌មានអំពី ជឿត សារ៉ាត់ ប៉ុន្តែរហូតមកដល់ពេលនេះយើងនៅតែមិនទាន់បានទទួលការឆ្លើយតប ។ យើងកំពុងតែស្វែងរកវិធីថ្មីទៀតដើម្បីជួយ នាក់ផេន ក្នុងការតាមរកប្តីនិងកូនរបស់គាត់ ។

**សូ ហ្វារីណា**

# ចង់ដឹងចង់ឃើញការកាត់ទោសខ្មែរក្រហម

តាំងពីក្រោយទសវត្សរ៍ឆ្នាំ១៩៧០មក ពាក្យ "ខ្មែរក្រហម" គឺសាហាវគួរឲ្យខ្លាចខ្លាំងណាស់ ។ ខ្មែរក្រហមសម្លាប់ប្រជាជនមិនរើសមុខ ដុតផ្ទះ ផ្តាច់ស្ពាន ស្នាក់បាញ់រថយន្ត ប្រើល្បិចបោកបញ្ឆោតភូតភរគ្រប់ឧបាយកល ។ ខ្មែរក្រហមឃោសនាថា "សូមបងប្អូនពុកម៉ែជនរួមជាតិចេញពីតំបន់ខ្មាំងទៅរស់នៅតំបន់រំដោះដែលមានអង្គការយើងទំនុកបម្រុងដោយមិនបាច់ភ័យព្រួយអ្វីទាំងអស់ យើងមិនឲ្យពុកម៉ែខ្វះហូបឡើយ" ។

ខ្មែរក្រហមបំបិទសិទ្ធិប្រជាជនមិនឲ្យយករបស់របរដូចជា ស្រូវ អង្ករ មាន់ទា ត្រីសាច់ ស្ករ ទៅលក់នៅផ្សារដើម្បីដោះស្រាយជីវភាពឡើយ ។ ខ្មែរក្រហមចូលចិត្តនិយាយថា មានរបស់ត្រូវដាក់ជាសមូហភាពទើបស្នេហាជាតិ ។ ពេលចាប់បានប្រជាកសិករដែលទៅនេសាទត្រីឬប្រកបរបររផ្សេងៗឆ្ងាយពីតំបន់ដែលខ្លួនរស់នៅ ខ្មែរក្រហមចោទថាជាគិញសម្ងាត់ ជាខ្មាំងបង្កប់ ឬ សេ.អ៊ី.អា ហើយសម្លាប់ចោលមិនថាចាស់ឬក្មេង បុរសឬស្ត្រី ។

លុះដល់ឆ្នាំ១៩៧៥ ពេលដែលខ្មែរក្រហមកាន់អំណាចពេញទំហឹង អង្គការចាប់ផ្តើមប្រមូលប្រជាជនដាក់ជាសហករណ៍ និងបែងចែកជាពីរប្រភេទ ។ ប្រជាជនដែលរស់នៅក្នុងតំបន់រំដោះតាំងពីមុនឆ្នាំ១៩៧៥ ត្រូវបានហៅថាអ្នកមូលដ្ឋានឬពេញសិទ្ធិ រីឯប្រជាជនដែលទើបជម្លៀសមកហៅថាប្រជាជនថ្មី ឬអ្នក១៧មេសា ។ អ្នកមូលដ្ឋានហូបបាយផ្សេងនិងធ្វើការងារផ្សេងពីអ្នក១៧មេសា ។ អ្នកមូលដ្ឋានធ្វើការងារស្រាលៗ និងចាំយកការណ៍ពីប្រជាជនថ្មី ។ អតីតប្រពន្ធទាហាន អ្នកមានឋានន្តរស័ក្តិ សិស្ស និស្សិត បញ្ញវន្ត សាស្ត្រាចារ្យ អ្នកសិល្បៈ តួកុន អ្នកជំនួញ ។ល ។ ត្រូវអង្គការយកទៅសម្លាប់ចោល ។ អ្នកដែលនៅសេសសល់ត្រូវអង្គការបង្ខំឲ្យធ្វើការហួសកម្លាំង ឲ្យហូបមិនឆ្អែត បើឈឺទៅធ្វើការមិនរួចអង្គការចោទថាធ្វើពុតឬខ្ជិលច្រអូស ហើយត្រូវយកទៅរៀនសូត្រ (ពាក្យថា"រៀនសូត្រ"នេះគ្មានថ្ងៃវិលវិញទេ) ។ អ្នកដែលមានកម្លាំងអាចធ្វើការបានត្រូវអង្គការប្រើគ្រប់ឧបាយកលយកទៅសម្លាប់ជាបន្តបន្ទាប់ ។

ខាងក្រោមនេះជាឈ្មោះសាច់ញាតិរបស់ខ្ញុំដែលស្លាប់នៅក្នុងរបបខ្មែរក្រហម ។

**ជីតារបស់ខ្ញុំឈ្មោះ អ៊ុំ ម៉េង**

ជីតារបស់ខ្ញុំមានអាយុ៨៦ឆ្នាំ ជាអតីតអាចារ្យវត្តជុំគ្រៀល ។ អង្គការប្រាប់ម៉ែថា លោកតាជរាធ្វើការមិនកើត អង្គការគ្មានរបបចែកទេ ។ ក្នុងមួយថ្ងៃ អង្គការចែកអង្ករឲ្យគាត់កន្លះកំប៉ុងដួនកាលបានដំឡូងមួយដុំឬពោតមួយផ្លែ ។ ដោយអត់ទ្រាំនឹងភាពស្រេកឃ្លានមិនបានតាក៏ធ្លាក់ខ្លួនឈឺ គួបផ្សំនឹងតំបន់នោះជាតំបន់ចាញ់ផង លោកតារវើរវាយស្រែកថា "អញស្អប់អង្គការបដិវត្តន៍ណាស់" ។ ម៉ែយកលោកតាមកព្យាបាលនៅមន្ទីរពេទ្យ អង្គការមិនឲ្យម៉ែមកកំដរលោកតាទេ ។ ពីរថ្ងៃក្រោយពីលោកតាទៅដល់មន្ទីរពេទ្យ មានមនុស្សមកប្រាប់ម៉ែថាលោកតាស្លាប់ហើយ ។ លោកតាស្លាប់ក្នុងឆ្នាំ១៩៧៦ ។

**ឪពុករបស់ខ្ញុំឈ្មោះ ព្រុំ សៅ**

ពុកមានក្របីមួយនឹមដែលយកមកពីស្រុកកំណើត ។ អង្គការឲ្យពុកភ្ជួរដីមួយថ្ងៃពីរពេល គឺព្រឹកពីម៉ោង៦រហូតដល់ម៉ោង១១ថ្ងៃត្រង់ សម្រាកហូបបបររាវៗមួយវែករួចឲ្យក្របីស៊ីស្មៅដល់ម៉ោង១រសៀលពុកភ្ជួរបន្តរហូតម៉ោង៦ល្ងាច ។ ពុកខំធ្វើការណាស់ព្រោះខ្លាចអង្គការសម្លាប់ចោល ប៉ុន្តែដោយហូបមិនគ្រប់គ្រាន់ ពុកធ្លាក់ខ្លួនឈឺ ។ ជើងរបស់ពុកហើមប្រេះស្ទើរតែចេញទឹក ពុកថ្ងូរថាចុកជើងខ្លាំងណាស់ដើរមិនរួចទេ ។

អង្គការឲ្យពុកទៅដេកពេទ្យ ។ ពុករៀបចំកំសៀវទឹកមួយ ចានមួយ ក្រណាត់កៅស៊ូមួយដុំ រួចកាន់ឈើច្រត់ដើរចេញទៅ ។ ពេលនោះខ្ញុំមានអាយុ៧ឆ្នាំ ។ ពេលពុកទៅដល់មន្ទីរពេទ្យកូនសាត់ ពេទ្យនិយាយថាគ្មានថ្នាំព្យាបាលជំងឺរបស់ពុកទេ មានតែនៅពេទ្យតំបន់ ។ កម្មាភិបាលខ្មែរក្រហមឲ្យពុកបរទេះដឹកអ្នកឈឺជើងដូចគ្នាពីរនាក់ទៀតទៅតាមផ្លូវទិសខាងត្បូងវត្តកូនសាត់ ។ ពុកទៅដេកពេទ្យតំបន់រហូតដល់សព្វថ្ងៃនេះខ្ញុំមិនឃើញពុកត្រឡប់មកវិញសោះ ។

**បងប្រុសទី១ឈ្មោះ ព្រុំ សារអាត**

នៅឆ្នាំ១៩៧៥ បងសាអាត រស់នៅមួយអភិបាលខេត្តកំពត ឈ្មោះ រស់ សាវង្ស ។ ពេលនោះខ្មែរក្រហមបញ្ចុះបញ្ចូលឲ្យគាត់ចុះចូល ហើយឲ្យទៅជួបគ្នានៅស្រុកជុំគិរី ។ តាមពិត មានប្រជាជនបានឃើញអង្គការនាំលោកអភិបាលខេត្តជាមួយប្រពន្ធនិងកូន ព្រមទាំងបងប្រុសរបស់ខ្ញុំផង យកទៅសម្លាប់ចោលនៅក្នុងស្រុកជុំគិរី ។

**បងប្រុសទី២ឈ្មោះ ព្រំ សំអុន**

បងសំអុន ធ្វើការក្នុងកងចល័តកោះស្លា ជាយុវជនឆ្នើមខំធ្វើការជាជនគំរូ រែកដីម្នាក់ពីរបង្គី ។ ទីបំផុត ក្នុងឆ្នាំ១៩៧៧ បងសំអុន ត្រូវខ្មែរក្រហមយកបងទៅបង្ខាំងទុកបង្អត់បាយពីរថ្ងៃនៅក្នុងវិហារវត្តកំពង់ត្រឡាច រួចសម្លាប់ចោលជាមួយយុវជនដាច់ពីររយនាក់ទៀត ។

**បងប្រុសទី៣ឈ្មោះ ព្រំ សំអិន**

បងសំអិន មានចរិតគួរឲ្យស្រលាញ់ណាស់ អ្នកភូមិសរសើរគាត់គ្រប់ៗគ្នាថាគាត់ជាមនុស្សសុភាពរាបសាកម្រនឹងជួបប្រទះ ។ នៅឆ្នាំ១៩៧៦ អង្គការឲ្យ បងសំអិន និងកូនកសិករ១០នាក់ទៀតមើលគោជាងមួយរយក្បាល ។

ថ្ងៃមួយ អង្គការជម្លៀសប្រជាជនចេញពីភូមិត្រពាំងកក់ក្នុងឲ្យទៅរស់នៅភូមិតស៊ូក្នុងឃុំកូនសាត់ដោយយកលេសថាតំបន់នេះមានខ្មាំងលាក់ខ្លួន ។ តាមពិតនរណាក៏ដឹងថាអង្គការទុកតំបន់នោះសម្រាប់សម្លាប់មនុស្សដែរ ។ ពេលនោះ កម្មាភិបាលខ្មែរក្រហមប្រាប់ម៉ែថា មិនទាន់ឲ្យកូនអឺទៅទេ ព្រោះគ្មានអ្នកណាមើលគោ ។ ពេលម៉ែចុះមកភូមិតស៊ូបានបីថ្ងៃ ម៉ែជួបកម្មាភិបាលនោះម្តងទៀត ហើយបានសួរថា "ពូ! ចុះកូនប្រុសខ្ញុំដែលនៅមើលគោជាមួយពូនោះនៅឯណា?" កម្មាភិបាលនោះឆ្លើយយ៉ាងព្រងើយថា "ឲ្យមកយូរហើយ" ។ ពេលនោះទើបម៉ែដឹងថាបងប្រុសត្រូវអង្គការសម្លាប់ចោលហើយ ។

**បងស្រីទី៦ឈ្មោះ ងោល**

ថ្ងៃមួយម្តាយរបស់ខ្ញុំគ្រុនក្តៅ អង្គការបញ្ជូនគាត់មកដេកពេទ្យវត្តអង្គគ្រីស្នា ។ ដោយគ្មានអ្នកមើលថែ ម៉ែក៏យកបងស្រីមកឲ្យជួយថែគាត់ ។ ដោយសារក្នុងពេទ្យអាប់អួរ គ្មានអនាម័យនិងខ្វះអាហារ បងស្រីវិលមុខក្អួត ។ ម៉ែភ័យខ្លាំងណាស់ ហៅពេទ្យមកមើល ។ នារីពេទ្យម្នាក់យកថ្នាំមកចាក់ឲ្យបងស្រី ។ គ្រាន់តែចាក់ថ្នាំរួចភ្លាម បងស្រីជាច់ខ្យល់ស្លាប់ភ្លាមមួយរំពេច ។ ខ្ញុំឈឺចិត្តយ៉ាងខ្លាំងពេលឮដំណឹងនេះ ព្រោះទើបតែពីព្រឹកមិញសោះ យើងពីរនាក់បងប្អូននាំគ្នាដើររើសផ្លែអំពិលបារាំងយកមកលីងហូប ។

ក្នុងគ្រួសារខ្ញុំនៅសល់តែខ្ញុំនិងម៉ែប៉ុណ្ណោះដែលរស់រានមានជីវិត ។

**ហ៊ាត សាច់ញាតិរបស់ខ្ញុំ**

ហ៊ាត មានអាយុ១៧ឆ្នាំ ធ្វើការក្នុងកងចល័តនារីកោះស្លា ។ ទំនប់កោះស្លាជាជំរំប្រមូលផ្តុំយុវជនយុវនារីទូទាំងខេត្តកំពត ។ ក្រុមនេះរែកដីតាំងពីព្រលឹមទល់ព្រលប់ ប៉ុន្តែហូបតែបបររាវៗមួយវែក ។ ជួនកាលមានសម្លស្លឹកល្ងៀងស្ងោរជាមួយខ្យងប្រុក្តាម ឬស្ងោរតែស្លឹកល្ងៀងសុទ្ធក៏មាន ។ យុវជនយុវនារីឈឺស្លាប់ខ្មោចរាយពេញព្រៃ ។

ថ្ងៃមួយ ហ៊ាត ឃើញពោតមួយគំនរធំដែលជារបស់កងសេដ្ឋកិច្ច ។ ហ៊ាត ឃ្លានខ្លាំងណាស់ក៏យកពោតមួយមកដុតហូប ។ ពោតមិនទាន់ទាំងឆ្អិនផង ស្រាប់តែប្រធានកងរបស់នាងមកទាន់ចាប់នាងចងហើយកោះហៅយុវជនយុវនារីទាំងអស់មកប្រជុំដើម្បីកាត់ទោស ។ មេកងចងដៃ ហ៊ាត ទៅក្រោយ យកពោតពីក្នុងភ្នក់ភ្លើងមកញាត់ចូលមាត់នាងបណ្តាលឲ្យរលាកពេញមាត់ ហើយប្រកាសថា មិត្តម្នាក់នេះក្បត់អង្គការ ក្បត់សមូហភាពវាជាខ្មាំង អ្នកទាំងអស់គ្នាកុំយកតម្រាប់តាម ។ ហ៊ាត មិនត្រូវអង្គការសម្លាប់ទេ ប៉ុន្តែធ្លាក់ខ្លួនឈឺហូបអ្វីមិនកើត រាងកាយរបស់នាងស្គេកស្គាំង ។ ម្តាយរបស់ ហ៊ាត ពេលឃើញកូនមានសភាពដូច្នេះ ក៏កើតទុក្ខរហូតដល់ឈឺធ្វើការងាររលែងកើត ហើយត្រូវអង្គការផ្តាច់របបអាហារ ។ មិនបានប៉ុន្មានថ្ងៃផង ហ៊ាត និងម្តាយបានស្លាប់ក្នុងខ្ទមតូចរបស់ខ្លួន ។

**ឪពុកមាខ្ញុំឈ្មោះ អ៊ុំ ឈឹន**

ពូខ្ញុំជាមន្ត្រីរាជការនៅក្នុងរបបមុន ។ ដោយធុញថប់នឹងបរិយាកាសសង្គម គួបផ្សំនឹងខ្វះខាតអាហារផង ពូខ្ញុំធ្លាក់ខ្លួនឈឺធ្វើការមិនកើត ក៏សុំប្រធានកងមកសម្រាកនៅពេទ្យវត្តអង្គគ្រីស្នា ។ នៅក្នុងពេទ្យគាត់ទទួលបានត្រឹមបបររាវៗមួយពេលមួយវែក ជួនកាលបបរលាយស្លឹកដំឡូងឬពោត ជួនកាលបបរនោះដូមទៀត ។ បានប្រហែលប្អូនប្រាំថ្ងៃពូខ្ញុំលាចាកលោកទៅ ។

បន្ទាប់ពី ពូឈឺន ស្លាប់ ប្រពន្ធរបស់គាត់ឈ្មោះ អឹម គាធ្លាក់ខ្លួនឈឺបានតែមួយសប្តាហ៍ក៏ស្លាប់ដែរ បន្សល់ទុកកូនតូចអាយុបីឆ្នាំឲ្យយំរត់ឆ្វេឆ្វាពេញមន្ទីរពេទ្យ ។ គាត់មានកូនស្រីម្នាក់ទៀតអាយុ១៨ឆ្នាំកំពុងធ្វើការកងចល័តកោះស្លាមិនបានដឹងថាឪពុកម្តាយរបស់នាងស្លាប់ឡើយ ។

## ក្រុមគ្រួសាររបស់ អ៊ឹឈុំ

អ៊ឹឈុំ ជាបងស្រីជីដូនមួយរបស់ម្តាយខ្ញុំ ។ គាត់មានកូន ១១នាក់ ប្រុស៧នាក់ ស្រីបួននាក់ ។

កូនប្រុសច្បងឈ្មោះ ឃី ជាទាហានកុម្មុំងដូ ។ បងឃី ខំធ្វើការទាំងយប់ទាំងថ្ងៃដើម្បីបម្រើអង្គការ ។ មិនយូរប៉ុន្មាន បងកើតជំងឺអុតស្វាយ ពេលនោះអង្គការស៊ើបដឹងប្រវត្តិពិត ។ ទីបំផុត បងឃីត្រូវអង្គការយកទៅសម្លាប់ទាំងឈឺ នៅឆ្នាំ១៩៧៦ ។

បងអ៊ួន ជាកូនទី២របស់អ៊ឹ ។ គាត់រៀបការនិងមានកូនពីរនាក់ក្នុងបន្ទុក ។ បងខំធ្វើការមិនឲ្យខុសបញ្ជាអង្គការឡើយ ប៉ុន្តែអង្គការនៅតែមិនអនុគ្រោះឲ្យបងដដែល ។ បងអ៊ួន និងបុរសជាង ៦០នាក់ទៀត ត្រូវអង្គការហៅទៅប្រជុំក្នុងផ្ទះមួយហើយពុំចែករបបអាហារថ្ងៃត្រង់ឲ្យឡើយ ។ ម៉ោងបីរសៀល អង្គការកោះហៅស្ត្រីមកប្រជុំម្តង ដោយប្រាប់ថាអ្នកដែលប្រជុំពីថ្ងៃត្រង់ក្បត់ហ៊ានតវ៉ានឹងអង្គការ អង្គការកម្ទេចចោលហើយ សូមប្រពន្ធកូនកុំចាំមើលផ្លូវទៀត ។ បងអ៊ួន ស្លាប់ទៅទាំងមិនបានដឹងថាប្រពន្ធរបស់គាត់កំពុងតែមានផ្ទៃពោះកូនទីបី ។

បងអូរ និង បងណោន ជាកូនទីបីនិងទីបួនរបស់ អ៊ឹឈុំ ។ ថ្ងៃមួយអង្គការប្រកាសថា អ្នកដែលមានប្តីប្រពន្ធត្រូវជម្លៀសទៅនៅឃុំកែប ។ ប្រាំពីរថ្ងៃក្រោយ ខ្ញុំឃើញប្រពន្ធកូនរបស់បងប្រុសទាំងពីរព្រមទាំងស្ត្រីនិងកុមារជាច្រើនទៀតវែកអីវ៉ាន់ត្រឡប់មកវិញ ហើយពុំឃើញមានបុរសម្នាក់ឡើយ ។ ពេលនោះទើប អ៊ឹឈុំ ដឹងថាកូនរបស់គាត់ស្លាប់ពីរនាក់ទៀតហើយ ។

*បងតុន និង បងតង ជាកូនក្មោះ, បងទូច និង ចេសៀត*

អ្នកទាំងបួនជាកូនរបស់ អ៊ឹឈុំ គឺជានិស្សិត ។ បងទាំងបួនធ្វើការនៅក្នុងកងចល័តស្រួច ។ ទីបំផុតអង្គការខ្មែរក្រហមយកបងទាំងបួនទៅសម្លាប់ចោលក្នុងវិហារវត្តកំពង់ត្រឡាចទាំងអស់ ។ ចេសៀត មានអាយុ២០ឆ្នាំមានរូបឆោមស្អាតលើសនារីក្នុងក្រុម ។ ថ្ងៃមួយបងស្រីកំពុងវែកកណ្តាប់នៅកណ្តាលវាលស្រែស្រាប់តែមានកងឈ្លបពីរបីនាក់យកខ្សែមកចងដៃនិងនារីៗស្អាតៗជាង១០នាក់ទៀតហើយបណ្តើរយកទៅ ។ ក្រោយមកមានព័ត៌មានខ្សឹបខ្សៀវថា នារីទាំងអស់ត្រូវឈ្លបចាប់រំលោភមុននឹងសម្លាប់ចោល ។

អ៊ឹនុប ជាប្តីរបស់ អ៊ឹឈុំ មានអាយុ៦២ឆ្នាំ ។ ថ្ងៃមួយពេលសម្រាកថ្ងៃត្រង់ អ៊ឹឆៀតដើររើសក្តាមខ្យងយកមកស្ងោជាមួយស្លឹកដំឡូងជ្វា ។ មិនទាន់បានហូបសម្លផង ស្រាប់តែឈ្លបហៅគាត់ទៅប្រជុំជាបន្ទាន់ ។ ពេលដើរចេញទៅជាមួយឈ្លប អ៊ឹបានស្រែកប្រាប់ប្រពន្ធគាត់ថាទុកសម្លឲ្យគាត់ហូបផង ។ អ៊ឹស្រីអង្គុយចាំផ្លូវប្តីដើម្បីហូបសម្លជុំគ្នា ប៉ុន្តែចាំរហូតដល់ម៉ោងពីររសៀលនៅតែមិនឃើញប្តីគាត់មកវិញ ។ អ៊ឹស្រីដើរមកជួបម៉ែទាំងទឹកភ្នែក ។ គាត់គ្រវីក្បាលតិចៗ ហើយនិយាយថា "កូនៗនិងប្តីខ្ញុំត្រូវអង្គការសម្លាប់ចោលអស់ហើយ ។ កូនបង្កើតប្រាំបីនាក់ កូនប្រសាប្រុសបីនាក់ សព្វថ្ងៃនៅសល់តែកូនស្រីម៉េមាយបីនាក់ទេ" ។

## ពូគ្រេន និងមីង អ៊ុន ជាប្អូនជីដូនមួយរបស់ម្តាយខ្ញុំ

មីងអ៊ុន មានកូនខ្ចីហើយធ្វើការហួសកម្លាំងបណ្តាលឲ្យទាស់រហូតដល់ស្លាប់ បន្សល់ទុកកូនតូចឲ្យរស់នៅជាមួយឪពុក ។ រាល់ថ្ងៃមុនពេលចេញទៅធ្វើការ ពូគ្រេន យកកូនមកទុកនៅក្នុងមណ្ឌលកុមារឲ្យយាយៗមើល ។ រសៀលថ្ងៃមួយ អង្គការយក ពូគ្រេន និងបុរសជាច្រើននាក់ទៀតទៅសម្លាប់ចោល ។ កូនតូចរបស់គាត់ខ្លាំងណាស់ព្រោះបាត់ឪពុក ។ យាយអ្នកមើលកុមារបានប្រាប់ប្រធានកងឈ្មោះ វន ថា ក្មេងនេះយំមិនព្រមឈប់សោះ ។ ប្រធានកងនោះឆ្លើយថា "កុំភ័យទុកឲ្យខ្ញុំ" ។ វន ទាញកុមារតូចពីដៃរបស់យាយ ដើរចេញទៅក្រៅចម្ងាយប្រហែលប្រាំម៉ែត្រ ក៏ដាក់កូននោះលើដីហើយទាត់ពីរបីជើង បន្ទាប់មកចាប់ជើងទាំងពីរបោកទៅនឹងគល់ស្វាយក្បែរនោះស្លាប់ទៅ ។

## ពូរី ជាសាច់ញាតិរបស់ម្តាយខ្ញុំ

ពូរី ប្រកបរបរឡើងត្នោត ។ ក្នុងឆ្នាំ១៩៧៤ ពូរី ធ្លាក់ពីលើចុងត្នោតបណ្តាលឲ្យខ្វិនជើងទាំងសងខាង ។ អង្គការឲ្យគាត់វេញខ្សែគោ ខ្សែបង្គី និងកន្ទុះគោ ។ មីងមាន ជាប្រពន្ធរបស់គាត់ចេញទៅធ្វើការតាំងពីព្រលឹម ។ ពេលហូបបបរថ្ងៃត្រង់ មីងត្រូវ

បើបបរទៅឲ្យប្តី ហើយប្រញាប់ប្រញាប់ត្រឡប់ទៅធ្វើការវិញ ។ ម៉ោង៦ល្ងាចពេលត្រឡប់មកពីធ្វើការវិញ មីងបើកបបរយកមកឲ្យប្តីម្តងទៀត ។ មីងធ្វើបែបនេះរាល់ថ្ងៃ ។

ព្រលប់មួយ ពូវី និងកូនស្រីតូចអាយុ៦ឆ្នាំ កំពុងហូបបបរ ពីរនាក់ឪពុកនិងកូន ឈ្លបពីរបីនាក់ឡើងមកគំរាមគាត់ថា ហូបស៊ីថ្មើណេះ ហូបគ្មានរបប ហួសម៉ោងហួសពេល អង្គការមិនអនុញ្ញាតឲ្យហូបបែបនេះទេ ។ ម្តាយរបស់ មីងមាន ឆ្លើយថា "ប្រពន្ធវាទើបបើកបបរមកអម្បាញ់មិញនេះឯង ពូក៏ដឹងស្រាប់ហើយថាវាដើរមិនរួច" ។ ឈ្លបនោះគំហកវិញថា "កុំចេះ ចង់ងាប់ឬ?" ។ ឈ្លបយកខ្សែដែលយួរនៅដៃមកចងដៃចងជើងទាំងពីររបស់ ពូវី ជាប់គ្នា រួចស៊កឈើចំកណ្តាលសែងចេញទៅដូចជ្រូក ។ កូនស្រីរបស់គាត់ស្រែកយំ ឈ្លបងាកមកគំរាមថា "កុំយំ កុំនិយាយអ្វីទាំងអស់បើមិនចង់ងាប់" ។ ស្ត្រីទាំងពីរនិងកុមារីនៅស្ងៀមមិនហ៊ានយំទេ សំងំចាំស្តាប់ ។ ប្រមាណ១០នាទីក្រោយមកឮសំឡេងសត្វយំឆ្អើលពេញព្រៃរួចក៏ស្ងាត់ឈឹងទៅវិញ ។ ព្រឹកឡើង យាយឃើញរណ្តៅមួយចម្ងាយប្រហែល៦០ម៉ែត្រពីខ្ទម គឺស្ថិតនៅជើងភ្នំកំបោរ ក្នុងភូមិកូនសាត់ ឃុំកូនសាត់ ស្រុកកំពត ខេត្តកំពត ។

## ប៉ះ ជាកូនស្រីរបស់ មីងឈិន បួនជីដូនមួយរបស់ឪពុកខ្ញុំ

មីងឈិន ជាកសិករនៅភូមិម៉មពេជ្រ ឃុំកូនសាត់ ។ ថ្ងៃមួយអង្គការបានផ្លាស់មីងឲ្យទៅស្ទូងនៅឃុំកែប ។ បងប៉ះ និងកុមារ៨នាក់ទៀត ក៏ទៅជាមួយដែរ ។ ពេលមីងទៅដល់ឃុំកែបអង្គការប្រាប់ថាគ្មានរបបក្មេងៗទេ ។ មីងនិងកសិករដែលទៅជាមួយគ្នាក៏យកកូនមកផ្ញើនឹងសហករណ៍ទេះគោកងសេដ្ឋកិច្ចខ្មែរក្រហមឲ្យមកភូមិវិញ ។ ប្រាំពីរថ្ងៃក្រោយមីងត្រឡប់មកភូមិវិញ តាមផ្លូវមីងប្រទះឃើញក្បាលសាកសពកុមារ ខ្លះត្រូវជ្រូកព្រៃពាំ ខ្លះត្រូវឆ្កែពាំ មីងឆ្ងល់ក្នុងចិត្តណាស់ ប៉ុន្តែមិនហ៊ាននិយាយ ។ ពេលដល់ផ្ទះមីងសួររកកូន ប៉ុន្តែគ្មានអ្នកណាបានឃើញទេ ។ ពេលនោះទើបមីងដឹងថា ក្បាលរបស់កូនគាត់នៅក្នុងចំណោមក្បាលសាកសពកុមារទាំងនោះ ។ មីងគ្មានអ្វីក្រៅពីសម្រក់ទឹកភ្នែកអាណិតកូនតែប៉ុណ្ណោះ ។

## ម្តាយរបស់ធី អ្នកជិតខាងរបស់ខ្ញុំ

ម្តាយរបស់ ធី រស់នៅខាងត្បូងខ្ទមរបស់ខ្ញុំប្រហែលសាមសិបម៉ែត្រ ។ ក្រៅពី ធី ជាកូនច្បង គាត់មានកូនភ្លោះពីរនាក់ទៀត ។ ឪពុករបស់ ធី ត្រូវអង្គការសម្លាប់ចោលនៅឆ្នាំ១៩៧៧ ។ ព្រលឹមស្រាងៗថ្ងៃមួយ កសិករមួយក្រុមបានប្រទះឃើញកូនភ្លោះអាយុដប់ខែម្នាក់របស់មីងអណ្តែតទឹកនៅក្នុងត្រពាំងមុខផ្ទះ ។ កសិករទាំងនោះក៏ស្ទុះទៅសួរ ធី ។ ពេលនោះ ធី ដេកឱបប្អូនម្នាក់ទៀតក្នុងអង្រឹង មិនដឹងរឿងអ្វីទាំងអស់ ។ កសិករទាំងនោះចុះរាវក្នុងត្រពាំង ក៏ប្រទះឃើញសាកសពម្តាយរបស់ ធី ត្រូវចងភ្ជាប់នឹងជើងតាងលិចនៅបាតត្រពាំង ។ កសិករខ្សឹបខ្សៀវគ្នាថា មីងត្រូវខ្មែរក្រហមចាប់រំលោភរួចចងសណ្តូទម្លាក់ទឹកដើម្បីបំបិទភ័ស្តុតាង ។ ចាប់ពីពេលនោះមក ធី ត្រូវទៅសុំទឹកបាយយកមកបញ្ចុកប្អូនតូច ។ មិនយូរប៉ុន្មានប្អូនរបស់ ធី ក៏ស្លាប់ទៀត ។ ធី ទៅរស់នៅមណ្ឌលកុមារ ក្រោយមកខ្ញុំមិនដឹងថា ធី ទៅទីណាទៀតទេ ។

អតីតកាលកន្លងហួស២៧ឆ្នាំហើយ ប៉ុន្តែអនុស្សាវរីយ៍ ការឈឺចុកចាប់សោកសង្រេងឥតស្រាកស្រាន្តចំពោះអ្នកស្លាប់ នៅតែមកតាមលងខ្ញុំជានិច្ច ។ ខ្ញុំនៅតែឃើញខោអាវបងប្រុសដែលរហែករយ៉ៃ ដេរដោយស្មោកគ្រោក រូបរាងបងស្គមកំព្រឹង ពេលជួបប្អូនបងនៅតែលើកប្អូនពរ ដេញគោជុំពរប្អូនជុំដោយក្តីស្រលាញ់និងប្រោសប្រណីជានិច្ច ។ ខ្ញុំនៅតែឮសម្តីពុកផ្តែផ្តាំឲ្យកូនរក្សាខ្លួន ។ កូននឹកឃើញដៃរញីរញ័រនិងស្គមកំព្រឹងរបស់ពុកស្ទាបអង្អែលក្បាលកូន ។ កូននឹកឃើញពេលពុកកាន់ឈើច្រត់ដើរបាំងខ្ទើចៗដៃម្ខាងកាន់បង្ហេចដើរទៅមន្ទីរពេទ្យ ។

ក្រោយឆ្នាំ១៩៧៩ ពេលជួបគ្នាម្តងៗ យើងរំឭករឿងរ៉ាវឈឺចាប់ទាំងទឹកភ្នែក ។ អ៊ីឈុំ និយាយប្រាប់ម៉ែថា "មិនដឹងកាលណាទើបរដ្ឋាភិបាលយើងចាប់ខ្មែរក្រហមមកកាត់ទោសទេ ខ្ញុំចង់ឃើញមុខរបស់វាខ្លាំងណាស់" ។ ជាអកុសល អ៊ីឈុំ បានលាចាកលោកនេះក្នុងឆ្នាំ១៩៩៧ក្នុងជន្មាយុ៨០ឆ្នាំ ។ យាយម្តាយរបស់ មីងមាន ទទួលអនិច្ចកម្មនៅឆ្នាំ២០០២ ក្នុងជន្មាយុ៩០ឆ្នាំ ។ មីងមាន ស្លាប់នៅឆ្នាំ២០០៤ ក្នុងអាយុ៥៦ឆ្នាំ ។ គាត់ទាំងអស់គ្នាមិនទាន់បានឃើញយុត្តិធម៌នៅឡើយទេ ។

ប្រជាជននៅក្នុងភូមិរបស់នាងខ្ញុំចង់ដឹងចង់ឃើញអំពីដំណើរការកាត់ទោសខ្មែរក្រហមណាស់ ។ គាត់សំណូមពរឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាអញ្ជើញគាត់ទៅចូលរួមស្វែងយល់ពីដំណើរការនេះផង ។ **ព្រុំ សាម៉ុន**

## សេចក្តីប្រកាសរកប្រពន្ធនិងកូន

ខ្ញុំបាទឈ្មោះ លឹម ឈីសុង ស្រុកកំណើតនៅទីក្រុងភ្នំពេញ សូមប្រកាសសួររកប្រពន្ធនិងកូនបួននាក់ ដែលមានឈ្មោះដូចខាងក្រោម ÷



◆ប្រពន្ធឈ្មោះ លឹម លីជួ សព្វថ្ងៃអាយុប្រហែល៦២ឆ្នាំ ស្រុកកំណើតនៅខេត្តក្រចេះ

◆កូនស្រីទី១ឈ្មោះ លឹម ភិចសួង សព្វថ្ងៃអាយុប្រហែល៤២ឆ្នាំ (មានប្រជ្រុយក្រហមលើថ្ពាល់ខាងឆ្វេង)

◆កូនស្រីទី២ឈ្មោះ លឹម ភិចអេង សព្វថ្ងៃអាយុប្រហែល៤០ឆ្នាំ

◆កូនស្រីទី៣ឈ្មោះ លឹម ភិចហុង សព្វថ្ងៃអាយុប្រហែល៣៨ឆ្នាំ

◆កូនស្រីទី៤ឈ្មោះ លឹម ភិចស្រួយ សព្វថ្ងៃអាយុប្រហែល៣៦ឆ្នាំ

កាលពីមុនឆ្នាំ១៩៧៥អ្នកទាំងអស់គ្នារស់នៅទីក្រុងភ្នំពេញ ។ បន្ទាប់ពីត្រូវខ្មែរក្រហមជម្លៀសចេញពីក្រុងភ្នំពេញ ក្នុងអំឡុងខែ៨ ឬខែ៩ ឆ្នាំ១៩៧៥ បានទទួលដំណឹងថា ម្តាយនិងកូនស្រីទាំងបួននាក់ត្រូវជម្លៀសទៅខេត្តកំពង់ឆ្នាំងនិងជិះរថភ្លើងបន្តទៅកាន់ខេត្តពោធិសាត់ ហើយក៏បានបាត់ដំណឹងតាំងពីពេលនោះមក ។

ដូចនេះបើមានបងប្អូនណាបានស្គាល់ ឬបានជួប ឬមានដំណឹង ឬបានជួយយកទៅចិញ្ចឹម សូមមេត្តាអាណិតជួយផ្តល់ដំណឹងដល់ខ្ញុំបាទផង ខ្ញុំបាទនឹងជូនសគុណជាទីគាប់ចិត្ត ។ សូមមេត្តាទាក់ទងតាមទូរស័ព្ទលេខ ០១២ ៨៤១ ៨០៣ (នៅភ្នំពេញ), ០១១ ៩៣៨ ៣២២ (សមាគមខ្មែរ-ចិននៅខេត្ត ពោធិសាត់), ០១១ ៨៣៨ ៤១២ (សមាគមខ្មែរ-ចិននៅខេត្តប៉ោយប៉ែត), ០១២ ៨៤៨ ៦៥៦ (សមាគមខ្មែរ-ចិននៅស្រុកសិរីសោភ័ណ) ។ បើមានបងប្អូនណាបានជួយយកទៅចិញ្ចឹម ខ្ញុំបាទនឹងចាត់ទុកគ្រួសារនោះជាគ្រួសារតែមួយ ។ សូមអរគុណ ។

## សេចក្តីប្រកាសរកបងប្រុស ពិន ចាន់ថុល

ខ្ញុំបាទឈ្មោះ ពិន ថែត អាយុ៤៣ឆ្នាំ ស្រុកកំណើតនៅភូមិមហាលាភ ឃុំពាមប្រធ្នោះ ស្រុកកោះសូទិន ខេត្តកំពង់ចាម សព្វថ្ងៃជាអគ្គលេខាធិការរងទី១ សាលាខេត្តមណ្ឌលគិរី ។ ឪពុកឈ្មោះ ពិន ប៊ិន (ស្លាប់) ម្តាយឈ្មោះ ចឹក អួន សព្វថ្ងៃរស់នៅភូមិមហាលាភ ឃុំពាមប្រធ្នោះ ស្រុកកោះសុទិន ខេត្តកំពង់ចាម ។

សូមសួររកបងប្រុសឈ្មោះ ពិន ចាន់ថុល បាត់ដំណឹងនៅឆ្នាំ១៩៧៧ កាលនោះឮថាអង្គការយកទៅធ្វើការរោងចក្រ ប៉ុន្តែរហូតមកដល់សព្វថ្ងៃនេះគ្មានដំណឹងសោះ ។

បើបងប្រុសទទួលបានដំណឹង ឬញាតិមិត្តណាបានស្គាល់ឈ្មោះនេះ សូមទាក់ទងមកខ្ញុំបាទតាមទូរស័ព្ទលេខ ០៩២ ៩២៨ ៥៧៩ ។ សូមអរគុណ ។

## សេចក្តីប្រកាសរកបងស្រីឈ្មោះ អយ សាន្ត

ខ្ញុំបាទឈ្មោះ ខៀក សារឿន អាយុ៤៦ឆ្នាំ រស់នៅភូមិកណ្តាល ឃុំស្ពានមានជ័យ ស្រុកសែន មនោរម្យ ខេត្តមណ្ឌលគិរី សូមសួររកបងស្រីបង្កើតឈ្មោះ អយ សាន្ត ធ្វើពេទ្យសម័យខ្មែរក្រហម ប្តីឈ្មោះ ញឹម សុផល ។

បើបងស្រីបានទទួលដំណឹង ឬញាតិមិត្តបានស្គាល់ឈ្មោះនេះ សូមទាក់ទងតាមទូរស័ព្ទលេខ ០១២ ៧៦៦ ០៨២ ឬតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។



ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវ៉េ ស៊ុីតដែន និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 77, May 2006 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.